រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# របាយការណ៍

## ស្តីពី

## លទ្ធផលនៃការអង្កេតអភិបាលកិច្ច ក្នុងក្របខ័ណ្ឌនៃកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២

ខែមិថុនា ឆ្នាំ២០២៥

# មាតិកា


មាតិកា ........ i
លិខិតថ្លែងអំណរគុណ ........ v
សេចក្តីសង្ខេប ........ vi
១. សេចក្តីផ្តើម ........ 1
៣. វិធីសាស្ត្រនៃការអង្កេត ........ 2
៣.១. គោលបំណងនៃការអង្កេត ........ 2
៣.២. សមាសភាពសំខាន់នៃសន្ទស្សន៍ ........ 3
៣.៣. គោលការណ៍ទូទៅសម្រាប់ការបង្កើតសន្ទស្សន៍ ........ 3
៣.៤. និយមន័យនៃសន្ទស្សន៍អភិបាលកិច្ច និងសន្ទស្សន៍ការផ្តល់សេវា ........ 5
៣.៥. សន្ទស្សន៍រង និងសូចនាករ ........ 5
  ៣.៥.១. ការពន្យល់ ........ 5
  ៣.៥.២. សន្ទស្សន៍រងពាក់ព័ន្ធនឹងការបំពេញការងារ ........ 6
  ៣.៥.៣. សន្ទស្សន៍រងពាក់ព័ន្ធនឹងការឆ្លើយតប ........ 8
  ៣.៥.៤. សន្ទស្សន៍រងពាក់ព័ន្ធនឹងតម្លាភាព ........ 9
  ៣.៥.៥. សន្ទស្សន៍រងពាក់ព័ន្ធនឹងគណនេយ្យភាព ........ 10
  ៣.៥.៦. សន្ទស្សន៍រងពាក់ព័ន្ធនឹងការចូលរួមរបស់ប្រជាពលរដ្ឋ ........ 11
  ៣.៥.៧. អភិបាលកិច្ចផ្ទៃក្នុង ........ 12
៣.៦. សមាគមក្រុមប្រឹក្សាមូលដ្ឋាន ........ 13
៣.៧. ការបំលែង ........ 13
៣.៨. ទម្ងន់នៃសូចនាករ ........ 13
៣.៩. ការបកស្រាយពិន្ទុ ........ 15
៣.១០. ការបំបែកលទ្ធផលទៅតាមកម្រិតថ្នាក់នីមួយៗ ........ 16
៣.១១. សំណាក ........ 17
៣.១២. ការរៀបចំបញ្ជីសំណួរ ........ 21
៣.១៣. ការប្រមូលទិន្នន័យ ........ 22
៣.១៤. ការសម្អាត និងការវិភាគទិន្នន័យ ........ 24

៣.១៥. ការគណនាគំហុសស្តង់ដា និងចន្លោះទំនុកចិត្ត .......... 25
៤. លក្ខណៈនៃសំណាក .......... 26
៤.១. សំណាកប្រជាពលរដ្ឋ .......... 26
៤.២. ថ្នាក់ដឹកនាំភូមិ .......... 27
៤.៣. សមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ .......... 28
៤.៤. សំណាកស្រុក ក្រុង ខណ្ឌ .......... 29
៤.៥. សំណាករាជធានី ខេត្ត .......... 31
៥. របកគំហើញនៃការអង្កេត .......... 32
៥.១. តម្លៃនៃសន្ទស្សន៍ .......... 32
៥.២. សន្ទស្សន៍ទាក់ព័ន្ធនឹងការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ .......... 36
៥.២.១. តម្លៃសូចនាករ .......... 36
៥.២.២. ចម្លើយរបស់ប្រជាពលរដ្ឋ .......... 38
៥.២.៣. ចម្លើយរបស់ក្រុមប្រឹក្សា និងមន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិ .......... 38
៥.៣. សន្ទស្សន៍ទាក់ព័ន្ធនឹងការឆ្លើយតប .......... 40
៥.៣.១. តម្លៃសូចនាករ .......... 40
៥.៣.២. តម្លៃសន្ទស្សការឆ្លើយតប ដែលបានពីចម្លើយរបស់សំណាកប្រជាពលរដ្ឋ .......... 42
៥.៣.៣. តម្លៃសន្ទស្សន៍នៃការឆ្លើយតបដែលបានមកពីសំណាករដ្ឋបាលថ្នាក់ក្រោមជាតិ .......... 45
៥.៤. សន្ទស្សន៍ទាក់ព័ន្ធនឹងតម្លាភាព .......... 48
៥.៤.១. តម្លៃសូចនាករ .......... 48
៥.៤.២. តម្លៃតម្លាភាពដែលបានពីចម្លើយសំណាកប្រជាពលរដ្ឋ .......... 50
៥.៤.៣. តម្លៃតម្លាភាពដែលបានពីចម្លើយសំណាកមន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិ .......... 52
៥.៥. សន្ទស្សន៍ទាក់ព័ន្ធនឹងគណនេយ្យភាព .......... 54
៥.៥.១. តម្លៃសូចនាករ .......... 54
៥.៥.២. តម្លៃគណនេយ្យភាពដែលបានពីសំណាករបស់ប្រជាពលរដ្ឋ .......... 57
៥.៥.៣. តម្លៃគណនេយ្យភាពដែលបានពីចម្លើយរបស់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ .......... 58
៥.៦. សន្ទស្សន៍ទាក់ព័ន្ធនឹងការចូលរួមរបស់ប្រជាពលរដ្ឋ .......... 62
៥.៦.១. តម្លៃសូចនាករ .......... 62
៥.៦.២. តម្លៃនៃការចូលរួមរបស់ប្រជាពលរដ្ឋដែលវាយតម្លៃដោយប្រជាពលរដ្ឋ .......... 64

៥.៦.៣. តម្លៃនៃការចូលរួមរបស់ប្រជាពលរដ្ឋដែលបានវាយតម្លៃដោយរដ្ឋបាលថ្នាក់ក្រោមជាតិ 66
៥.៧. ទំនាក់ទំនងផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ 71
៥.៨. សមាគមក្រុមប្រឹក្សាមូលដ្ឋាន 75
៦. របាយការណ៍នៃសិក្ខាសាលាពិគ្រោះយោបល់ 77
៧. ដែនកំណត់នៃការអង្កេត 78
៨. ការរក្សាទុកដាក់ទិន្នន័យ និងសំណាក 79
៩. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ 80
៩.១. ការរៀបចំបង្កើត និងការគណនាតម្លៃសន្ទស្សន៍ដោយជោគជ័យ 80
៩.២. គុណភាពនៃអភិបាលកិច្ច និងផ្តោតលើផ្នែកដែលត្រូវការកែលម្អ 80
៩.២.១. សន្ទស្សន៍ជាយុទ្ធសាស្រ្ត 80
៩.២.២. ការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ 81
៩.២.៣. ការឆ្លើយតប 82
៩.២.៤. តម្លាភាព 83
៩.២.៥. គណនេយ្យភាព 84
៩.២.៦. ការចូលរួមរបស់ប្រជាពលរដ្ឋ 85
៩.២.៧. អភិបាលកិច្ចផ្ទៃក្នុង និងសមាគមក្រុមប្រឹក្សាមូលដ្ឋាន 86
៩.៣. អនុសាសន៍សម្រាប់ការអង្កេតនាពេលបន្ទាប់ 86
៩.៣.១. ពេលវេលានៃការអង្កេតបន្ទាប់ 86
៩.៣.២. ការប្រើវិធីសាស្រ្តដដែលដោយប្រុងប្រយ័ត្ន 87
៩.៣.៣. គួរប្រើសំណួរ និងពាក្យពេជដូចគ្នា ឬត្រូវរក្សាការប្រៀបធៀបបាន ប្រសិនបើមានការផ្លាស់ប្តូរសំណួរ និងពាក្យពេចន៍ 87
៩.៣.៤. គួរប្រើវិធីសាស្រ្តវិភាគដដែល ឬការគណនាឡើងវិញនៃការអង្កេតដើមគ្រាបើសិនមានការផ្លាស់ប្តូរណាមួយ 87
៩.៣.៥. គួរប្រើវិធីសាស្រ្តជ្រើសរើសសំណាកដូចគ្នា ក្នុងការជ្រើសរើសសំណាកថ្មី 87
៩.៣.៦. គួរពិចារណាកាត់បន្ថយចំនួនអ្នកឆ្លើយតបជាក្រុមប្រឹក្សាឬមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ 88

## អក្សរកាត់ដែលប្រើក្នុងរបាយការណ៍នេះ

| *វាក្យសព្ទ* | *និយមន័យ* |
|---|---|
| ACC | គណនេយ្យភាព (ប្រើដើម្បីកំណត់សំណួរពាក់ព័ន្ធសូចនាករ និងសន្ទស្សន៍រង) |
| CBO | អង្គការសហគមន៍មូលដ្ឋាន |
| CIT (បជ) | ប្រជាពលរដ្ឋ (ប្រើដើម្បីកំណត់អត្តសញ្ញាណអ្នកឆ្លើយ និងលទ្ធផលពាក់ព័ន្ធនានា) |
| CIV | ការចូលរួមរបស់ប្រជាពលរដ្ឋ (ប្រើដើម្បីកំណត់សំណួរពាក់ព័ន្ធសូចនាករ និងសន្ទស្សន៍រង) |
| CP (រខ) | រាជធានី ខេត្ត (ប្រើដើម្បីកំណត់អត្តសញ្ញាណអ្នកឆ្លើយនៅកម្រិតរាជធានី ខេត្ត) |
| CSC (ឃស) | ក្រុមប្រឹក្សាឃុំ សង្កាត់ (ប្រើដើម្បីកំណត់អត្តសញ្ញាណអ្នកឆ្លើយនៅកម្រិតឃុំ សង្កាត់) |
| DMK (កសខ) | ក្រុង ស្រុក ខណ្ឌ (ប្រើដើម្បីកំណត់អត្តសញ្ញាណអ្នកឆ្លើយតបនៅកម្រិតក្រុង ស្រុក ខណ្ឌ) |
| GOV | អភិបាលកិច្ច (បុព្វបទប្រើដើម្បីកំណត់សំណួរពាក់ព័ន្ធនឹងសូចនាករ និងសន្ទស្សន៍) |
| ID-Poor | ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ |
| INT | ការទំនាក់ទំនងផ្ទៃក្នុង (ប្រើដើម្បីកំណត់សំណួរពាក់ព័ន្ធសូចនាករ និងសន្ទស្សន៍រង) |
| LCA | សមាគមក្រុមប្រឹក្សាមូលដ្ឋាន ពោលគឺសមាគមក្រុង ស្រុក សង្កាត់ និងសមាគមរាជធានី ខេត្ត |
| NCDD-S | លេខាធិការដ្ឋាន គ.ជ.អ.ប. |
| NP-2 | កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ (កជទី២) |
| PER | ការអនុវត្ត (ប្រើដើម្បីកំណត់សំណួរពាក់ព័ន្ធសូចនាករ និងសន្ទស្សន៍រងពាក់ព័ន្ធ) |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SNA | រដ្ឋបាលថ្នាក់ក្រោមជាតិ |
| TRA | តម្លាភាពបុព្វបទប្រើដើម្បីកំណត់សំណួរពាក់ព័ន្ធ សូចនាករ និងសន្ទស្សន៍រងពាក់ព័ន្ធនានា |
| UN-DESA | នាយកដ្ឋានកិច្ចការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ |
| UNDP | កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ |
| VIL (ភ) | ភូមិ (ប្រើដើម្បីកំណត់អ្នកឆ្លើយសំណួរមេភូមិ) |

## លិខិតថ្លែងអំណរគុណ

ក្នុងនាម គ.ជ.អ.ប. ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ប្រចាំកម្ពុជា និងរាជរដ្ឋាភិបាលជប៉ុនដែលបានគាំទ្រ គ.ជ.អ.ប. ក្នុងការធ្វើអង្កេតអភិបាលកិច្ចក្នុងក្របខ័ណ្ឌនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ (កជទី២) តាមរយៈគម្រោង "**ការពង្រឹងតម្លាភាព និងគណនេយ្យភាពក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ**" ដែលគាំទ្រហិរញ្ញប្បទានពីរដ្ឋាភិបាលជប៉ុនតាមរយៈស្ថានទូតជប៉ុនប្រចាំកម្ពុជា និងហិរញ្ញប្បទានរបស់ UNDP។

ខ្ញុំសូមថ្លែងអំណរគុណចំពោះក្រុមហ៊ុន ASKL Service and Consulting Inc. ដែលបានរៀបចំ និងអនុវត្តការអង្កេតអភិបាលកិច្ចនេះប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈទាំងក្នុងការរៀបចំបញ្ជីសំណួរ ប្រព័ន្ធបញ្ចូលទិន្នន័យ ការបណ្តុះបណ្តាលអ្នកធ្វើអង្កេត ការសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មាន ការត្រួតពិនិត្យគុណភាពទិន្នន័យ ការវិភាគទិន្នន័យ និងការគណនាសន្ទស្សន៍អភិបាលកិច្ចតាមរូបមន្តដែលបានកំណត់ ដោយមានការពិគ្រោះយោបល់យ៉ាងល្អិតល្អន់មុននឹងឈានទៅរៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការអង្កេតអភិបាលកិច្ចនេះ។

ខ្ញុំសូមថ្លែងអំណរគុណចំពោះក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រីនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ថ្នាក់ដឹកនាំភូមិ និងប្រជាពលរដ្ឋនៅតាមសហគមន៍ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមសម្ភាសន៍ ញ៉ាំងឱ្យការអង្កេតអភិបាលកិច្ចនេះទទួលបានទិន្នន័យគ្រប់គ្រាន់សម្រាប់ការវិភាគ និងការគណនាសន្ទស្សន៍អភិបាលកិច្ច ដែលជាសន្ទស្សន៍ដើមគ្រាដ៏មានសារៈសំខាន់ធ្វើជាមូលដ្ឋានក្នុងការវាយតម្លៃវាស់វែងនិន្នាការប្រែប្រួលគុណភាពអភិបាលកិច្ចក្នុងក្របខ័ណ្ឌនៃកជទី២។

ក្នុងនាម គ.ជ.អ.ប. ខ្ញុំសូមលើកទឹកចិត្តឱ្យក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ស្ថាប័នសិក្សាស្រាវជ្រាវ អ្នករៀបចំគោលនយោបាយ សិស្ស និស្សិត ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិលពាក់ព័ន្ធប្រើប្រាស់លទ្ធផលនៃការអង្កេតអភិបាលកិច្ចនេះ ធ្វើជាមូលដ្ឋានស្វែងយល់អំពីស្ថានភាពអភិបាលកិច្ចសិក្សាស្រាវជ្រាវឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀតតាមការចាំបាច់ និងស្វែងរកវិធានសមស្របនានាសម្រាប់ការពង្រឹង និងជំរុញឱ្យមានការប្រែប្រួលជាវិជ្ជមាននូវសន្ទស្សន៍អភិបាលកិច្ចនេះ ដើម្បីធានាលើកកម្ពស់អភិបាលកិច្ចក្នុងក្របខ័ណ្ឌនៃកជទី២ ក៏ដូចជាក្នុងក្របខ័ណ្ឌនៃកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឱ្យកាន់តែមានគុណភាពល្អប្រសើរឡើង។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធាន គ.ជ.អ.ប.**

**អគ្គបណ្ឌិតសភាចារ្យ ស សុខា**

## សេចក្តីសង្ខេប

ការអង្កេតអភិបាលកិច្ចក្នុងក្របខ័ណ្ឌនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ (កជទី២) បានអនុវត្តដោយក្រុមហ៊ុន ASKL Service and Consulting Inc. ដែលបានចុះកិច្ចសន្យាជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. ក្រោមការគាំទ្រពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) តាមរយៈគម្រោង "**ការពង្រឹងតម្លាភាព និងគណនេយ្យភាពក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ**" ដែលទទួលហិរញ្ញប្បទានជំនួយឥតសំណងពីរាជរដ្ឋាភិបាលជប៉ុន តាមរយៈស្ថានទូតជប៉ុនប្រចាំនៅកម្ពុជា និងហិរញ្ញប្បទានរបស់UNDP។ ការធ្វើអង្កេតអភិបាលកិច្ចនេះបានចាប់ផ្តើមពីខែធ្នូ ឆ្នាំ២០២៤ និងបានបញ្ចប់នៅខែមីនា ឆ្នាំ២០២៥។

ការអង្កេតអភិបាលកិច្ចនេះ មានបំណងបង្កើតសន្ទស្សន៍ជាយុទ្ធសាស្ត្រចំនួនពីរគឺ (១). **សន្ទស្សន៍ផ្នែកអភិបាលកិច្ច** និង(២). **សន្ទស្សន៍ផ្នែកសេវា** ដើម្បីធ្វើជាទិន្នន័យដើមគ្រាសម្រាប់វាស់វែងកម្រិតនៃការសម្រេចបានគោលដៅ និងគោលបំណងនៃកជទី២។

និយមន័យស្តីពីសន្ទស្សន៍ជាយុទ្ធសាស្ត្រទាំងពីរក្នុងក្របខ័ណ្ឌនៃការអង្កេតនេះ បានកំណត់ដោយផ្អែកតាមគោលបំណង និងគោលដៅនៃកជទី២ ដូចខាងក្រោម៖

- សន្ទស្សន៍ផ្នែកអភិបាលកិច្ច សំដៅដល់សន្ទស្សន៍សម្រាប់វាស់វែងការលើកកម្ពស់ស្វ័យភាព ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងការធ្វើទំនើបកម្មនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលទទួលបានសិទ្ធិ អំណាច ការទទួលខុសត្រូវ និងសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តតួនាទី ភារកិច្ច និងមុខងារដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្រោមការត្រួតពិនិត្យរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិសាមីនីមួយៗ។
- សន្ទស្សន៍ផ្នែកសេវា សំដៅដល់សន្ទស្សន៍សម្រាប់វាស់វែងកម្រិតនៃការធ្វើឱ្យប្រសើរឡើងនូវគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាជូនប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋាន និងការវាស់វែងកម្រិតនៃការឆ្លើយតបរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទៅនឹងតម្រូវការអាទិភាពនានារបស់ប្រជាពលរដ្ឋប្រកបដោយបរិយាបន្ន និងសមធម៌សង្គម។

សន្ទស្សន៍ជាយុទ្ធសាស្ត្រទាំងពីរនេះ បានបង្កើតឡើងពី**សន្ទស្សន៍រង**ចំនួនប្រាំដូចខាងក្រោម៖

១. សន្ទស្សន៍រង៖ ការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

២. សន្ទស្សន៍រង៖ ការឆ្លើយតប

៣. សន្ទស្សន៍រង៖ តម្លាភាព

៤. សន្ទស្សន៍រង៖ គណនេយ្យភាព និង

៥. សន្ទស្សន៍រង៖ ការចូលរួមរបស់ប្រជាពលរដ្ឋ។

ក្នុងការគណនាសន្ទស្សន៍ និងសន្ទស្សន៍រងនីមួយៗបានផ្ដល់នូវមេគុណ ដូចបានកំណត់ក្នុងរូបភាពខាងក្រោម៖




*រូបភាពនៃរចនាសម្ព័ន្ធ និងមេគុណនៃសន្ទស្សន៍*

ចំណុចសំខាន់ៗដែលត្រូវវាស់វែងដោយ**សន្ទស្សន៍រង**នីមួយៗត្រូវបានកំណត់ដូចខាងក្រោម ៖

– **សន្ទស្សន៍រងពាក់ព័ន្ធនឹងការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ៖** ប្រជាពលរដ្ឋនិងសហគមន៍មូលដ្ឋានអាចទទួលបានសេវាសាធារណៈ និងសេវារដ្ឋបាលប្រកបដោយគុណភាពខ្ពស់ ដោយសាររដ្ឋបាលថ្នាក់ក្រោមជាតិបានពង្រឹងសមត្ថភាព និងធនធានរបស់ខ្លួន។

– **សន្ទស្សន៍រងពាក់ព័ន្ធនឹងការឆ្លើយតប៖** រដ្ឋបាលថ្នាក់ក្រោមជាតិមានការយល់ដឹង និងខិតខំប្រឹងប្រែង ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពនានារបស់ប្រជាពលរដ្ឋ។ ក្នុងន័យនេះ អាទិភាពនានារបស់ប្រជាពលរដ្ឋត្រូវបានផ្ដោតការយកចិត្តទុកដាក់នៅក្នុងដំណើរការនៃការរៀបចំផែនការ ថវិកា និងការផ្ដល់សេវាសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

– **សន្ទស្សន៍រងពាក់ព័ន្ធនឹងតម្លាភាព៖** រដ្ឋបាលថ្នាក់ក្រោមជាតិទទួលស្គាល់សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មាន ហើយរដ្ឋបាលថ្នាក់ក្រោមជាតិមានភាពសកម្មក្នុងការចែករំលែកព័ត៌មានដោយចំហជូនប្រជាពលរដ្ឋ រួមទាំងព័ត៌មានអំពីរចនាសម្ព័ន្ធ និងដំណើរការអភិបាលកិច្ចមូលដ្ឋាន ផែនការអភិវឌ្ឍន៍ ថវិកា ការប្រើប្រាស់ថវិកា លទ្ធផលដែលសម្រេចបាន និងសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានសេវា និងព័ត៌មានអំពីតម្លៃសេវា។

– **សន្ទស្សន៍រងពាក់ព័ន្ធនឹងគណនេយ្យភាព៖** រដ្ឋបាលថ្នាក់ក្រោមជាតិមានការទទួលខុសត្រូវចំពោះសកម្មភាព និងលទ្ធផលដែលខ្លួនបានធ្វើ រួមទាំងការទទួលខុសត្រូវតាមបែបប្រជាធិបតេយ្យចំពោះអ្នកបោះឆ្នោត ការទទួលខុសត្រូវផ្នែកច្បាប់និងផ្នែករដ្ឋបាលចំពោះសកម្មភាពរបស់សមាជិកក្រុមប្រឹក្សា និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងទទួលខុសត្រូវចំពោះយន្តការនានាសម្រាប់ទទួល និងដោះស្រាយបណ្ដឹងតវ៉ារបស់ប្រជាពលរដ្ឋ។

- **សន្ទស្សន៍រងពាក់ព័ន្ធនឹងការចូលរួមរបស់ប្រជាពលរដ្ឋ៖** រដ្ឋបាលថ្នាក់ក្រោមជាតិបង្កលក្ខណៈងាយស្រួល សម្របសម្រួល និងលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមយ៉ាងសកម្មក្នុងដំណើរការអភិបាលកិច្ចមូលដ្ឋាន និងការអភិវឌ្ឍមូលដ្ឋាន តាមរយៈការផ្តល់ឱកាសឱ្យចូលរួមដោយផ្ទាល់ក្នុងការកំណត់តម្រូវការអាទិភាពសម្រាប់ការអភិវឌ្ឍ និងការត្រួតពិនិត្យលើលទ្ធផលនានា និងតាមរយៈការចូលរួមជាសមាជិកភាពនៃអង្គការសហគមន៍មូលដ្ឋាន ជាពិសេសអង្គការសហគមន៍មូលដ្ឋានដែលផ្តោតលើការអភិវឌ្ឍមូលដ្ឋាន។

ក្រៅពីការបង្កើតសន្ទស្សន៍ជាយុទ្ធសាស្ត្រដូចបានកំណត់ខាងលើ ការអង្កេតនេះក៏បានផ្តោតលើការបង្កើតសន្ទស្សន៍ទំនាក់ទំនងផ្ទៃក្នុងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងអំពីសារៈសំខាន់នៃសមាគមក្រុមប្រឹក្សាមូលដ្ឋាន។ ការបង្កើតសន្ទស្សន៍បន្ថែមទាំងនេះមិនត្រូវបានយកមកប្រើក្នុងការគណនាសន្ទស្សន៍ផ្នែកអភិបាលកិច្ចនោះឡើយ។

សំណុំសូចនាករដែលបានកំណត់សម្រាប់បង្កើតសន្ទស្សន៍រងនីមួយៗត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការរៀបចំបង្កើតបញ្ជីសំណួរសម្រាប់សម្ភាសន៍ជាមួយក្រុមអ្នកផ្តល់ព័ត៌មានចំនួន៥ប្រភេទផ្សេងៗគ្នា រួមមាន (១). ប្រជាពលរដ្ឋ (២). ថ្នាក់ដឹកនាំភូមិ (៣). ក្រុមប្រឹក្សាឃុំ សង្កាត់ (៤). ក្រុមប្រឹក្សាគណៈអភិបាល និងមន្ត្រីក្រុង ស្រុក ខណ្ឌ និង(៥). ក្រុមប្រឹក្សានិងគណៈអភិបាលរាជធានី ខេត្ត។

ការអង្កេតអភិបាលកិច្ចនេះ បានធ្វើឡើងនៅ២៥រាជធានី ខេត្ត តំណាងឱ្យតំបន់ទីប្រជុំជន តំបន់ជនបទ និងតំបន់ភូមិសាស្ត្រផ្សេងគ្នាក្នុងប្រទេសកម្ពុជា ដែលបានបែងចែកជាតំបន់ទំនាប តំបន់ទន្លេសាប តំបន់ខ្ពង់រាប និងតំបន់ឆ្នេរ និងរាជធានីភ្នំពេញ ជាដើម។ នៅក្នុងរាជធានី ខេត្តនីមួយៗបានជ្រើសរើសយកក្រុង ស្រុក ខណ្ឌសម្រាប់ការអង្កេតអភិបាលកិច្ច ដោយប្រើវិធីសាស្ត្រជ្រើសរើសដោយចៃដន្យ ក្នុងនោះ ក្រុង**ចំនួន២៤** ស្រុក**ចំនួន៧២** ខណ្ឌ**ចំនួន៦**ត្រូវបានជ្រើសរើសជាសំណាកសម្រាប់ការធ្វើអង្កេតអភិបាលកិច្ចនេះ។ ក្នុងក្រុង ស្រុក ខណ្ឌនីមួយៗក៏បានជ្រើសរើសដោយចៃដន្យយកឃុំ សង្កាត់ **ចំនួន២** និងក្នុងឃុំ សង្កាត់នីមួយៗបានជ្រើសរើសដោយចៃដន្យយក**ភូមិចំនួន២**សម្រាប់ការធ្វើអង្កេតអភិបាលកិច្ចនេះដែរ។ ប្រជាពលរដ្ឋ**ចំនួន៥គ្រួសារ**ក្នុងភូមិនីមួយៗត្រូវបានជ្រើសរើសដោយចៃដន្យសម្រាប់ការជួបសម្ភាសជាមួយតំណាងគ្រួសារនីមួយៗជាបុរស ឬស្ត្រី ដើម្បីធានាតុល្យភាពយេនឌ័រ។

សំណាកសរុបដែលបានសម្ភាសន៍ក្នុងដំណើរការអង្កេតអភិបាលកិច្ចនេះមាន**ចំនួន៣.៩០៨នាក់** ក្នុងនោះសំណាកដែលជាប្រជាពលរដ្ឋមាន**ចំនួន១.៩១៨នាក់** និងសំណាកដែលសមាជិកក្រុមប្រឹក្សាគណៈអភិបាល និងមន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិមាន**ចំនួន១.៩៩០នាក់**។

ចម្លើយដែលបានឆ្លើយទៅនឹងសំណួរនានាត្រូវបានបំលែងទៅជាពិន្ទុមានតម្លៃពី 0 (សូន្យ) ទៅ ១ (មួយ) សម្រាប់ការគណនាសន្ទស្សន៍នីមួយៗ។ ទន្ទឹមគ្នានេះ ក្នុងការគណនាតម្លៃសូចនាករ តម្លៃសន្ទស្សន៍នីមួយៗ ក៏បានផ្តល់មេគុណ ឬទម្ងន់ ដែលមេគុណ ឬទម្ងន់ទាំងនេះបានផ្តល់លើចម្លើយរបស់ប្រជាពលរដ្ឋ

ស្មើនឹង២ភាគ៣ និងផ្តល់លើចម្លើយរបស់ក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិស្មើនឹង១ភាគ៣។

ជាមួយគ្នានេះ ដើម្បីផ្តល់ភាពងាយស្រួលក្នុងការបកស្រាយតម្លៃសន្ទស្សន៍ និងសន្ទស្សន៍រងនីមួយៗ ការផ្តល់ចំណាត់ថ្នាក់ ឬការផ្តល់មូលវាចារលើតម្លៃសន្ទស្សន៍ និងសន្ទស្សន៍រងនីមួយៗក៏បានកំណត់ជា៥ចំណាត់ថ្នាក់គឺ "ខ្សោយ" "មធ្យម" "បង្គួរ" "ខ្លាំង ឬល្អ" និង "ខ្លាំងណាស់ ឬល្អណាស់" ។

ជារួម ផ្អែកតាមលក្ខខណ្ឌ និងរូបមន្តដែលបានកំណត់ ការគណនាតម្លៃសន្ទស្សន៍ និងសន្ទស្សន៍រងដែលបង្កើតបានពីការអង្កេតអភិបាលកិច្ចនេះ គឺទទួលបានលទ្ធផលដូចខាងក្រោម៖

តម្លៃសន្ទស្សន៍ជាយុទ្ធសាស្ត្រ៖

- **សន្ទស្សន៍ផ្នែកអភិបាលកិច្ច** = 0,៦៤ គឺមានចំណាត់ថ្នាក់**បង្គួរ**
- **សន្ទស្សន៍ផ្នែកសេវា** = **0,៦៩** គឺមានចំណាក់ថ្នាក់**បង្គួរ**។

តម្លៃសន្ទស្សន៍រង៖

- ការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ = **0,៦៧** មានចំណាត់ថ្នាក់**បង្គួរ**
- ការឆ្លើយតបរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ= **0,៧៤** មានចំណាត់ថ្នាក់**ល្អ**
- តម្លាភាពមានតម្លៃ = **0,៦២** មានចំណាត់**បង្គួរ**
- គណនេយ្យភាព = **0,៥៤** មានចំណាត់ថ្នាក់**មធ្យម**
- ការចូលរួមរបស់ប្រជាពលរដ្ឋ= **0,៥៨** មានចំណាត់ថ្នាក់**មធ្យម។**

**ជាការកត់សម្គាល់៖** តម្លៃនៃសន្ទស្សន៍នីមួយៗមានភាពខុសគ្នាតិចតួចរវាងតម្លៃសន្ទស្សន៍នៅតាមតំបន់ទីប្រជុំជន និងតំបន់ជនបទ និងរវាងតម្លៃសន្ទស្សន៍ក្រុមអ្នកផ្តល់ព័ត៌មានជាបុរស និងស្ត្រី។

ជារួម តម្លៃសន្ទស្សន៍ដែលបានបង្កើតឡើងនេះ គឺជាតម្លៃសន្ទស្សន៍ដើមគ្រា ដូច្នេះតម្លៃសន្ទស្សន៍ទាំងនេះមិនមានសារៈសំខាន់ក្នុងការឆ្លុះបញ្ចាំងអំពីកម្រិតនៃការសម្រេចបានតាមគោលបំណង និងគោលដៅនៃកជទី២នាពេលនេះឡើយ ក៏ប៉ុន្តែសន្ទស្សន៍នេះមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ធ្វើជាមូលដ្ឋានក្នុងវាស់វែងការផ្លាស់ប្តូរ ឬការប្រែប្រួលតម្លៃសន្ទស្សន៍ទាំងនេះ នៅពេល**ការធ្វើអង្កេតអភិបាលកិច្ចតាមបែបនេះនាពេល៣ឆ្នាំបន្ទាប់ ឬនៅពេលបញ្ចប់ការអនុវត្តកជទី២** ។

ផ្នែកខាងក្រោមពណ៌នាអំពីចំណុចខ្លាំងសំខាន់ៗទាក់ទងនឹងសន្ទស្សន៍រងនីមួយៗ ដែលជាការសន្និដ្ឋានចេញពីតម្លៃសន្ទស្សន៍ដើមគ្រាទាំងនេះ និងចង្អុលបង្ហាញពីចំណុចសំខាន់ៗដែលគួរផ្តោតការយកចិត្តទុកដាក់សម្រាប់ការកែលម្អ។

- **សន្ទស្សន៍រងពាក់ព័ន្ធនឹងការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** (Performance)៖

  **ចំណុចខ្លាំង៖** ប្រជាពលរដ្ឋមានបទពិសោធន៍មកទទួលសេវានៅតាមយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយក្រុមប្រឹក្សា និងមន្ត្រីក៏អាចវាយតម្លៃបានអំពីសមត្ថភាព

និងធនធានដែលខ្លួនមានសម្រាប់ការផ្តល់សេវាទាំងនេះ។

**ចំណុចគួរកែលម្អ៖** បន្តការវិនិយោគលើការកែលម្អការអភិវឌ្ឍមូលដ្ឋាន ជាពិសេសលើហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ដែលបានផ្តល់អាទិភាពខ្ពស់ដោយប្រជាពលរដ្ឋ និងអាទិភាពបន្ទាប់ គឺសកម្មភាពផ្តល់ការគាំទ្រដល់ក្រុមជនងាយរងគ្រោះ។ កម្រិតនៃការពេញចិត្តទាបបំផុត គឺការគ្រប់គ្រងសំរាមសំណល់រឹងនៅតាមតំបន់ជនបទ ដូច្នេះគួរមានការពង្រឹងបន្ថែមចំពោះកិច្ចការនេះ។ សេវាចុះបញ្ជីអាជីវកម្មទទួលបានការវាយតម្លៃទាបជាងសេវារដ្ឋបាលដទៃទៀត ដូច្នេះចាំបាច់ត្រូវមានការកែលម្អ។ ចាំបាច់ត្រូវមានការកំណត់ការទទួលខុសត្រូវឱ្យកាន់តែច្បាស់លាស់ និងការពង្រឹងសមត្ថភាពបន្ថែមដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការផ្តល់សេវាពាក់ព័ន្ធនានា។

- **សន្ទស្សន៍រងពាក់ព័ន្ធនឹងការឆ្លើយតប** (Responsiveness)

  **ចំណុចខ្លាំង៖** មានភាពស្របគ្នាឬត្រូវគ្នាក្នុងកម្រិតខ្ពស់ចំពោះចំណាត់ថ្នាក់អាទិភាពដែលបានលើកឡើងដោយប្រជាពលរដ្ឋ និងចំណាត់ថ្នាក់អាទិភាពដែលត្រូវឆ្លើយតបរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ប្រជាពលរដ្ឋមានទំនុកចិត្តខ្លាំងលើរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការយល់ដឹងអំពីតម្រូវការចាំបាច់របស់ខ្លួន។

  **ចំណុចគួរកែលម្អ៖** បន្តជំរុញឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ផ្តល់អាទិភាពដល់ទស្សនៈរបស់ប្រជាពលរដ្ឋក្នុងការរៀបចំផែនការអភិវឌ្ឍន៍ ជាពិសេសត្រូវធានាថាសំឡេង និងតម្រូវការជាទិភាពរបស់ជនជាតិដើមភាគតិចត្រូវបានស្តាប់ និងត្រូវបានយកមកពិចារណាក្នុងដំណើរការរៀបចំផែនការ។

- **សន្ទស្សន៍រងពាក់ព័ន្ធនឹងតម្លាភាព** (Transparency)

  **ចំណុចខ្លាំង៖** ប្រជាពលរដ្ឋជឿជាក់យ៉ាងខ្លាំងថា ពួកគេមានសិទ្ធិដឹងអំពីការងារទូទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយក្រុមប្រឹក្សា និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិបង្ហាញអាកប្បកិរិយាវិជ្ជមានយ៉ាងខ្លាំងចំពោះតម្លាភាព។

  **ចំណុចគួរកែលម្អ៖** គួរបង្កើនយុទ្ធនាការកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីតួនាទី ភារកិច្ច និងការផ្តល់សេវាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ បន្តជំរុញ និងលើកកម្ពស់តម្លាភាពអំពីកម្រៃសេវា និងបង្កើនការប្រើប្រាស់ប្រព័ន្ធឌីជីថលសម្រាប់ការផ្សព្វផ្សាយព័ត៌មានជូនសាធារណជន។

- **សន្ទស្សន៍រងពាក់ព័ន្ធនឹងគណនេយ្យភាព** (Accountability)

  **ចំណុចខ្លាំង៖** អ្នកផ្តល់ព័ត៌មានគ្រប់ក្រុមមានទំនុកចិត្តថា ក្រុមប្រឹក្សា និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិអាចត្រូវបានដាក់ពិន័យចំពោះការបំពេញការងារមិនល្អ ឬការបំពានច្បាប់។

  **ចំណុចគួរកែលម្អ៖** បន្តលើកកម្ពស់ និងកែលម្អយន្តការទទួល និងដោះស្រាយបណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសផ្តោតលើថ្នាក់ដឹកនាំភូមិ និងក្រុមប្រឹក្សា

ឃុំ សង្កាត់ ពីព្រោះប្រជាពលរដ្ឋភាគច្រើននាំយកទុក្ខព្រួយរបស់ខ្លួនទៅកាន់ភូមិ និងឃុំ សង្កាត់មុនគេ។ បង្កើតយន្តការដោះស្រាយពាក្យបណ្តឹងតវ៉ាជាប្រព័ន្ធមួយ ដែលអាចឱ្យដឹងបានថាពាក្យបណ្តឹងតវ៉ាណាមួយ គួរតែត្រូវបានបញ្ជូនទៅការិយាល័យប្រជាពលរដ្ឋ។ បន្តជំរុញ និងបង្កើនការយល់ដឹងអំពីយន្តការការិយាល័យប្រជាពលរដ្ឋ និងពង្រឹងទំនុកចិត្តលើគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ តាមរយៈការលើកទឹកចិត្តប្រជាពលរដ្ឋ និងថ្នាក់ដឹកនាំរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យមើលឃើញថា ការបោះឆ្នោតក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ គឺសំដៅលើការដោះស្រាយបញ្ហានៅមូលដ្ឋាន។

- **សន្ទស្សន៍រងពាក់ព័ន្ធនឹងការចូលរួមរបស់ប្រជាពលរដ្ឋ**

  **ចំណុចខ្លាំង៖** ប្រជាពលរដ្ឋចូលរួមជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈកិច្ចប្រជុំ ហើយបទពិសោធន៍របស់ប្រជាពលរដ្ឋក្នុងការចូលរួមកិច្ចប្រជុំទាំងនេះគឺមានភាពវិជ្ជមាន។ ប្រជាពលរដ្ឋជឿជាក់ថា រដ្ឋបាលថ្នាក់ក្រោមជាតិបានសហការយ៉ាងល្អជាមួយអង្គការសហគមន៍មូលដ្ឋាន និងថ្នាក់ដឹកនាំរដ្ឋបាលថ្នាក់ក្រោមជាតិបានបង្ហាញការគាំទ្រយ៉ាងខ្លាំងចំពោះសកម្មភាពរបស់អង្គការសហគមន៍មូលដ្ឋាន។

  **ចំណុចគួរកែលម្អ៖** បន្តលើកទឹកចិត្ត និងកសាងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការប្រើប្រាស់វិធីសាស្ត្រនានាឱ្យបានទូលំទូលាយ និងទំនើបជាងមុនសម្រាប់ជំរុញការចូលរួមរបស់ប្រជាពលរដ្ឋ ជាពិសេសតាមរយៈការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយឌីជីថល។ លើកទឹកចិត្តថ្នាក់ដឹកនាំរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យយល់ថា សារៈសំខាន់នៃការចូលរួមរបស់ប្រជាពលរដ្ឋ គឺដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចដឹងអំពីទស្សនៈរបស់ប្រជាពលរដ្ឋ។ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបង្កើតភាពជាដៃគូប្រកបដោយប្រសិទ្ធភាពជាមួយអង្គការសហគមន៍មូលដ្ឋាន និងត្រូវលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមតាមរយៈអង្គការសហគមន៍មូលដ្ឋាន។

ចំពោះលទ្ធផលនៃការអង្កេតពាក់ព័ន្ធនឹងទំនាក់ទំនងផ្ទៃក្នុងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងសារៈសំខាន់នៃសមាគមក្រុមប្រឹក្សាមូលដ្ឋាន ក៏បានបង្ហាញឱ្យឃើញនូវតម្លៃសន្ទស្សន៍ល្អផងដែរ គឺ០,៧៨ ចំពោះសន្ទស្សន៍ទំនាក់ទំនងផ្ទៃក្នុង និង ០,៧៧ ចំពោះសារៈសំខាន់នៃសមាគមក្រុមប្រឹក្សាមូលដ្ឋាន។

ទិន្នន័យនៃការអង្កេត វិធីសាស្ត្រ ការវិភាគ រូបមន្តសម្រាប់ការគណនាតម្លៃសន្ទស្សន៍ពាក់ព័ន្ធផ្សេងទៀតត្រូវបានផ្តល់ជូនដល់លេខាធិការដ្ឋាន គ.ជ.អ.ប សម្រាប់ការរក្សាទុកជាឯកសារអេឡិចត្រូនិច ដើម្បីជួយសម្រួលដល់ការធ្វើអង្កេតនៅពេលក្រោយ។ ការធ្វើអង្កេតពេលក្រោយគួរតែធ្វើឡើងនៅឆ្នាំ២០២៧ និងឆ្នាំ២០៣០។ ជាមួយគ្នានេះ ដើម្បីធានាបាននូវការប្រៀបធៀបរវាងតម្លៃសន្ទស្សន៍ដើមគ្រានេះជាមួយនឹងតម្លៃសន្ទស្សន៍នៃការអង្កេតពេលបន្តបន្ទាប់ គួរមានការប្រុងប្រយ័ត្នក្នុងករណីដែលការអង្កេតនាពេលបន្តបន្ទាប់បានផ្លាស់ប្តូរវិធីសាស្ត្រ និងរូបមន្តគណនាសន្ទស្សន៍ខុសពីវិធីសាស្ត្រ និងរូបមន្តដែលបានប្រើប្រាស់សម្រាប់ការអង្កេតដើមគ្រានេះ។

## *តារាងសង្ខេបនៃតម្លៃសន្ទស្សន៍ និងសន្ទស្សន៍រង*

| **សំណាក** | **សន្ទស្សន៍អភិបាលកិច្ច** | **សន្ទស្សន៍សេវា** | **ការបំពេញការងារ** | **ការឆ្លើយតប** | **តម្លាភាព** | **គណនេយ្យភាព** | **ការចូលរួមប្រជាពលរដ្ឋ** |
|---|---|---|---|---|---|---|---|
| **តម្លៃសន្ទស្សន៍រួម** | **០,៦៣៧** | **០,៦៨៥** | **០,៦៦៦** | **០,៧៤៣** | **០,៦២២** | **០,៥៤០** | **០,៥៧៥** |
| *(ចន្លោះទំនុកចិត្ត ៩៥%)* | (០,៦៣០ - ០,៦៤៤) | (០,៦៧៥ - ០,៦៩៥) | (០,៦៥៤ - ០,៦៧៨) | (០,៧៣២- ០,៧៥៥) | (០,៦០៧- ០,៦៣៧) | (០,៥២០ - ០,៥៦០) | (០,៥៦១-០,៥៨៨) |
| *អ្នកឆ្លើយតបជាស្ត្រី* | ០,៦២១ | ០,៦៦៥ | ០,៦៣០ | ០,៧៦៨ | ០,៦០៧ | ០,៥២០ | ០,៥៧៥ |
| *អ្នកឆ្លើយតបជាបុរស* | ០,៦២១ | ០,៦៤៩ | ០,៦១៨ | ០,៧៤៤ | ០,៦៣៤ | ០,៥៥៥ | ០,៥៧២ |
| តំបន់ទីក្រុង/ទីប្រជុំជន | ០,៥៩៣ | ០,៦៤១ | ០,៦១៨ | ០,៧០៩ | ០,៥៧៧ | ០,៤៩៨ | ០,៥៣០ |
| តំបន់ជនបទ | ០,៥៧០ | ០,៦០៧ | ០,៥៧៥ | ០,៧០០ | ០,៥៣៧ | ០,៤៨៦ | ០,៥៥០ |
| ភ្នំពេញ | ០,៦១៨ | ០,៦៣៧ | ០,៦៨៦ | ០,៤៩៣ | ០,៦៨១ | ០,៥៥៦ | ០,៥៤៧ |
| តំបន់ទំនាប | ០,៦១០ | ០,៦៣៩ | ០,៦១១ | ០,៧២៤ | ០,៦២៣ | ០,៥២២ | ០,៥៨១ |
| តំបន់បឹងទន្លេសាប | ០,៦១៨ | ០,៦៥៣ | ០,៦១៩ | ០,៧៥៧ | ០,៥៨៨ | ០,៥៥៧ | ០,៥៧៨ |
| តំបន់ខ្ពង់រាប | ០,៦១៥ | ០,៦៥០ | ០,៦២១ | ០,៧៣៤ | ០,៦២៤ | ០,៥២៦ | ០,៥៧១ |
| តំបន់ឆ្នេរ | ០,៦១៨ | ០,៦៣៣ | ០,៦០៧ | ០,៧១១ | ០,៦៧៤ | ០,៥៣៣ | ០,៥៩០ |

## ១. សេចក្ដីផ្ដើម

កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ (កជទី២) ដែលត្រូវអនុវត្តរយៈពេល១០ឆ្នាំ ចាប់ពីឆ្នាំ២០២១ដល់ឆ្នាំ២០៣០ មានគោលបំណង **"លើកកម្ពស់ការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យប្រកបដោយបរិយាបន្ន សមធម៌សង្គម និងយុត្តិធម៌ តាមរយៈការធ្វើទំនើបកម្មប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ និងការកែលម្អដំណើរការផ្ដល់សេវា និងគុណភាពសេវា ដើម្បីចូលរួមចំណែកលុបបំបាត់ភាពក្រីក្រ និងលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជនឱ្យកាន់តែល្អប្រសើរឡើង"**។

ដើម្បីធានាសម្រេចបានគោលបំណងនេះ កជទី២បានកំណត់គោលដៅជាក់លាក់មួយ គឺ **"រចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានលក្ខណៈទំនើប មានស្វ័យភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពក្នុងការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមានសិទ្ធិអំណាចសមស្រប និងសមត្ថភាពគ្រប់គ្រាន់សម្រាប់អនុវត្តមុខងារទាំងឡាយក្រោមការត្រួតពិនិត្យពីក្រុមប្រឹក្សា ដើម្បីធានាដល់ការពង្រឹងគណនេយ្យភាពចំពោះប្រជាពលរដ្ឋ"**។

កជទី២ (ផ្នែកទី៤.២.២.២) បានចែងថា គោលបំណងកជទី២ត្រូវវាស់វែងដោយសន្ទស្សន៍ជាយុទ្ធសាស្ត្រចំនួនបីគឺ (១). សន្ទស្សន៍ផ្នែកអភិបាលកិច្ច (២). សន្ទស្សន៍ផ្នែកសេវា និង (៣). សន្ទស្សន៍ផ្នែកសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ។ សន្ទស្សន៍ផ្នែកអភិបាលកិច្ច និងសន្ទស្សន៍សេវាត្រូវវាស់វែងដោយការអង្កេតអភិបាលកិច្ច ដើម្បីបង្កើតជាសន្ទស្សន៍ដើមគ្រា។ ក្របខ័ណ្ឌលទ្ធផលនៃកជទី២បានកំណត់ថា សន្ទស្សន៍ទាំងបីនេះជាសូចនាករសម្រាប់វាស់វែងកម្រិតសម្រេចបាននូវគោលបំណង និងគោលដៅ ក្នុងនោះសន្ទស្សន៍ផ្នែកអភិបាលកិច្ច គឺជាសូចនាករសម្រាប់វាស់វែងកម្រិតសម្រេចបានគោលបំណង និងសន្ទស្សន៍ផ្នែកសេវា គឺជាសូចនាករសម្រាប់វាស់វែងកម្រិតសម្រេចគោលដៅនៃកជទី២។

ការអង្កេតអភិបាលកិច្ចត្រូវបានពិពណ៌នានៅក្នុងកជទី២ ផ្នែក៤.២.៦.៥ ដែលត្រូវបានរំលេចឡើងវិញនៅក្នុងប្រអប់ខាងក្រោម។

> ការអង្កេតដែលត្រូវអនុវត្តក្នុងអំឡុងពេលនៃកជទី២ គឺជាការអង្កេតអភិបាលកិច្ច។ ក្នុងការអង្កេតអភិបាលកិច្ច សំណាកនានាដែលតំណាងឱ្យប្រជាពលរដ្ឋ និងតំណាងឱ្យសមាជិកក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវបានសួរសំណួរអំពីបទពិសោធន៍របស់ខ្លួនជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។ សំណួរដែលត្រូវសួរ គឺអំពីការយល់ដឹងអំពីសិទ្ធិអំណាច និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការយល់ដឹងអំពីដំណើរការអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអំពីការប្រើប្រាស់សេវា និងការពេញចិត្តទៅលើគុណភាពនៃសេវាដែលប្រជាពលរដ្ឋបានទទួល។ ការអង្កេតអភិបាលកិច្ចត្រូវបានរៀបចំអនុវត្តក្នុងគោលបំណងតាមដានការផ្លាស់ប្ដូរនៃសន្ទស្សន៍គន្លឹះៗមួយចំនួនពាក់ព័ន្ធនឹងអភិបាលកិច្ច ដូចជា ការផ្ដល់សេវា ការឆ្លើយតប ការចូលរួមរបស់ប្រជាពលរដ្ឋ តម្លាភាព និងគណនេយ្យភាព។ ការអង្កេតអភិបាលកិច្ចត្រូវអនុវត្តចំនួន៣ដងក្នុងអំឡុងពេលនៃកជទី២រួមមាន ការអង្កេតទិន្នន័យដើមគ្រា ការអង្កេតក្នុងឆ្នាំទី៥ និងការអង្កេតទិន្នន័យចុងគ្រាក្នុងឆ្នាំទី៩នៃកម្មវិធីជាតិ។

កជទី២មិនផ្តល់និយមន័យលម្អិតនៃសន្ទស្សន៍ផ្នែកអភិបាលកិច្ច ឬវិធីសាស្ត្រសម្រាប់ការអង្កេតអភិបាលកិច្ចនេះឡើយ។ ទោះយ៉ាងនេះក្តី មូលដ្ឋានសម្រាប់ការរៀបចំអង្កេតដើមគ្រានេះ គឺផ្អែក (១). ឯកសារកជទី២ (២). លក្ខខណ្ឌការងារ (៣). និយមន័យនៃអភិបាលកិច្ចល្អ និងមេរៀនបទពិសោធន៍ល្អៗនៃការអនុវត្តវិធីសាស្ត្រការវាស់វែងអភិបាលកិច្ចផ្អែកលើការអង្កេតទស្សនៈរបស់ប្រជាពលរដ្ឋដែលបានសរសេរក្នុងឯកសារពាក់ព័ន្ធនានា។

កជទី២ បានកំណត់ថា សន្ទស្សន៍ផ្នែកអភិបាលកិច្ច និងសន្ទស្សន៍ផ្នែកសេវាត្រូវផ្អែកលើទស្សនៈយល់ឃើញរបស់ប្រជាពលរដ្ឋ។ ផ្អែកតាមលក្ខខណ្ឌការងារ និងការពិភាក្សានៅដំណាក់កាលចាប់ផ្តើមការអង្កេតដើមគ្រានេះ បានឯកភាពគ្នាឱ្យការធ្វើអង្កេតនេះត្រូវរួមបញ្ចូលទាំងចម្លើយរបស់ប្រជាពលរដ្ឋ ចម្លើយរបស់ថ្នាក់ដឹកនាំភូមិ ក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រីរដ្ឋបាលក្រុង ស្រុក ខណ្ឌ រួមទាំងក្រុមប្រឹក្សា គណៈអភិបាលនៃរដ្ឋបាលរាជធានី ខេត្តផងដែរ។ ទោះយ៉ាងនេះក្តី ចម្លើយរបស់ប្រជាពលរដ្ឋ និងរបស់ក្រុមផ្តល់ព័ត៌មានផ្សេងទៀតត្រូវបានវិភាគដោយឡែកពីគ្នា ហើយតម្លៃសន្ទស្សន៍នីមួយៗត្រូវបង្កើតឡើងដោយរូបមន្តដែលផ្តល់មេគុណច្រើនទៅលើចម្លើយ ឬទស្សនៈយល់ឃើញរបស់ប្រជាពលរដ្ឋ។

## ៣. វិធីសាស្ត្រនៃការអង្កេត

### ៣.១. គោលបំណងនៃការអង្កេត

គោលបំណងនៃការអង្កេតអភិបាលកិច្ច គឺបង្កើតសន្ទស្សន៍យុទ្ធសាស្ត្រចំនួនពីរ៖ សន្ទស្សន៍ផ្នែកអភិបាលកិច្ច និងសន្ទស្សន៍ផ្នែកសេវាដែលពាក់ព័ន្ធនឹងទិដ្ឋភាពសំខាន់ៗចំនួន៥ គឺ (១). ការផ្តល់សេវា (២). ការឆ្លើយតប (៣). តម្លាភាព (៤). គណនេយ្យភាព និង(៥). ការចូលរួមរបស់ប្រជាពលរដ្ឋ។

កិច្ចការដែលត្រូវបានអនុវត្តដើម្បីសម្រេចគោលបំណងនេះ មានពន្យល់លម្អិតដូចតទៅ៖

១. ការកំណត់និយមន័យសម្រាប់សន្ទស្សន៍ផ្នែកអភិបាលកិច្ច និងសន្ទស្សន៍ផ្នែកសេវា ក៏ដូចជាសន្ទស្សន៍រងដែលពាក់ព័ន្ធនឹងទិដ្ឋភាពសំខាន់ៗទាំង៥ ដោយធានាឱ្យបានថា និយមន័យទាំងនេះមានលក្ខណៈសមស្របទៅនឹងបរិបទ និងគោលបំណងផ្នែកគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាដែលបានកំណត់ក្នុង កជទី២។

២. ការកំណត់វិធីសាស្ត្រ និងរូបមន្តសម្រាប់ការគណនាសន្ទស្សន៍ផ្នែកអភិបាលកិច្ច សន្ទស្សន៍ផ្នែកសេវា និងសន្ទស្សន៍រងនីមួយៗដែលពាក់ព័ន្ធនឹងទិដ្ឋភាពសំខាន់ៗទាំង៥។

៣. បង្កើត និងឯកភាពគ្នាលើឧបករណ៍ស្ទង់មតិ និងវិធីសាស្ត្រជ្រើសរើសសំណាក។

៤. ធ្វើការអង្កេត និងធ្វើរបាយការណ៍អំពីលទ្ធផលនៃការអង្កេតដើមគ្រា ដើម្បីបង្កើតតម្លៃនៃសន្ទស្សន៍អភិបាលកិច្ច សន្ទស្សន៍សេវា និងសន្ទស្សន៍រងទាំង៥។

៥. ចងក្រងឯកសារយ៉ាងហ្មត់ចត់ និងត្រឹមត្រូវអំពីឧបករណ៍ វិធីសាស្ត្រ ការវិភាគ និងការគណនាតម្លៃនៃសន្ទស្សន៍ ដើម្បីជួយសម្រួលដល់ការអង្កេតពាក់កណ្តាលគ្រា និងការអង្កេតចុងគ្រា

នាពេលបន្តបន្ទាប់។

៦. ផ្តល់អនុសាសន៍លើចំណុចសំខាន់ៗ ភាពមានកម្រិតមួយចំនួន (limitation) និងការណែនាំសម្រាប់ការអង្កេតនាពេលបន្តបន្ទាប់។

## ៣.២. សមាសភាពសំខាន់នៃសន្ទស្សន៍

សន្ទស្សន៍អភិបាលកិច្ច គឺជាសន្ទស្សន៍រួមដែលគ្រប់ដណ្តប់លើទិដ្ឋភាពសំខាន់ៗនៃអភិបាលកិច្ច ហើយដែលអាចវាស់វែងតាមការអង្កេត។

សន្ទស្សន៍ផ្នែកសេវា គឺជាសន្ទស្សន៍ដែលកើតចេញពីសន្ទស្សន៍រងពាក់ព័ន្ធនឹងការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងសន្ទស្សន៍ពាក់ព័ន្ធការឆ្លើយតបរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ ក្នុងន័យនេះ សមាសភាពសំខាន់ៗនៃសន្ទស្សន៍ផ្នែកអភិបាលកិច្ច និងសន្ទស្សន៍សេវាដែលពាក់ព័ន្ធនឹងទិដ្ឋភាព ឬសន្ទស្សន៍រងសំខាន់ៗទាំង៥ ដូចមានបង្ហាញក្នុងរូបភាពខាងស្តាំ។ តួលេខភាគរយនៅក្នុងតារាងពងក្រពើគឺជាមេគុណនៃសន្ទស្សន៍។ ឧទាហរណ៍ ៧៥%នៃតម្លៃសន្ទស្សន៍ផ្នែកសេវា គឺផ្អែកលើសន្ទស្សន៍រងពាក់ព័ន្ធនឹងការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និង២៥%គឺផ្អែកលើសន្ទស្សន៍រងពាក់ព័ន្ធនឹងការឆ្លើយតប។

## ៣.៣. គោលការណ៍ទូទៅសម្រាប់ការបង្កើតសន្ទស្សន៍

គោលការណ៍ខាងក្រោមសម្រាប់បង្កើតសន្ទស្សន៍ សន្ទស្សន៍រង សូចនាករ និងសំណួរសម្រាប់ការអង្កេត ត្រូវបានបង្កើតឡើង និងយល់ព្រមនៅដំណាក់កាលចាប់ផ្តើមនៃការអង្កេត។

**គោលការណ៍ទី១៖ ការវាស់វែងភាពជោគជ័យនូវគោលបំណងនៃគោលនយោបាយដែលបានកំណត់៖**

តាមរយៈកជទី២ រាជរដ្ឋាភិបាលមានបំណងលើកកម្ពស់អភិបាលកិច្ចមូលដ្ឋាន ដើម្បីបម្រើផលប្រយោជន៍ជូនប្រជាពលរដ្ឋឱ្យកាន់តែមានភាពល្អប្រសើរឡើង។ ទោះជាយ៉ាងនេះក្តី ទស្សនៈរបស់រាជរដ្ឋាភិបាលចំពោះគោលការណ៍នៃអភិបាលកិច្ចល្អ និងទិដ្ឋភាពដែលអាចអនុវត្តបានហើយមានលក្ខណៈសមស្របទៅនឹងបរិបទជាក់ស្តែងរបស់កម្ពុជា អាចមិនស្របគ្នាទាំងស្រុងជាមួយនឹងគោលការណ៍ ឬទិដ្ឋភាពសំខាន់ៗដែលបង្ហាញក្នុងទ្រឹស្តីនៃការអភិវឌ្ឍនោះឡើយ។ ការអង្កេតអភិបាលកិច្ចនេះ បង្កើតជាផែនការសំខាន់មួយសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកជទី២ ដែលជាឧបករណ៍សម្រាប់វាស់វែងភាពជោគជ័យនៃកជទី២ ក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល។



### គោលការណ៍ទី២៖ ផ្ដល់អាទិភាពដល់ការយល់ឃើញរបស់ប្រជាពលរដ្ឋ

សន្ទស្សន៍ផ្នែកអភិបាលកិច្ច និងសន្ទស្សន៍ផ្នែកសេវា គឺជាសន្ទស្សន៍ចម្បងដែលបង្ហាញអំពីទស្សនៈយល់ឃើញរបស់ប្រជាពលរដ្ឋចំពោះអភិបាលកិច្ចមូលដ្ឋាន។ ដូច្នេះ ចម្លើយដែលទទួលបានពីប្រជាពលរដ្ឋត្រូវតែមានទម្ងន់ខ្លាំងបំផុត។ ការរៀបចំឱ្យមានបញ្ជីសំណួរសម្រាប់ទទួលបានព័ត៌មានពីក្រុមប្រឹក្សា និងមន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិមិនមានបំណងដើម្បីបង្រួញទស្សនៈយល់ឃើញរបស់ប្រជាពលរដ្ឋឡើយ។ ផ្ទុយទៅវិញ គឺដើម្បីបំពេញនូវទស្សនៈយល់ឃើញរបស់ប្រជាពលរដ្ឋជាមួយនឹង **ព័ត៌មានបន្ថែម**ដែលប្រជាពលរដ្ឋមិនបានដឹង ឬមិនបានទទួល។

### គោលការណ៍ទី៣៖ មិនត្រូវសន្មត់ដោយគ្មានសមហេតុផលអំពីកម្រិតចំណេះដឹងរបស់ប្រជាពលរដ្ឋ

ប្រជាពលរដ្ឋភាគច្រើននៅក្នុងប្រទេសកម្ពុជា ដូចជាកន្លែងផ្សេងទៀតមានចំណេះដឹងតិចតួចអំពីរដ្ឋបាលមូលដ្ឋាន ហើយចាប់អារម្មណ៍តែលើបញ្ហាដែលប៉ះពាល់ដល់ខ្លួនដោយផ្ទាល់ប៉ុណ្ណោះ។ ក្នុងន័យនេះ វាមិនសមហេតុផលទេក្នុងការរំពឹងថា ប្រជាពលរដ្ឋនឹងដឹងលម្អិតទាំងអស់អំពីអាទិភាពនានានៅក្នុងផែនការអភិវឌ្ឍន៍មូលដ្ឋាន ឬការយល់ដឹងលម្អិតអំពីការសម្រេចនានានៃកិច្ចប្រជុំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលខ្លួនចូលរួម។ ផ្ទុយទៅវិញ ការវាស់ស្ទង់កម្រិតយល់ដឹងរបស់ប្រជាពលរដ្ឋ គឺជាសូចនាករសំខាន់នៃតម្លាភាពក្នុងក្របខ័ណ្ឌនៃអភិបាលកិច្ចមូលដ្ឋាន (ព័ត៌មានត្រូវបានចែករំលែកប្រកបដោយប្រសិទ្ធភាព) និងការចូលរួមរបស់ប្រជាពលរដ្ឋ (ប្រជាពលរដ្ឋចាប់អារម្មណ៍លើបញ្ហារបស់រដ្ឋបាលមូលដ្ឋាន)។

### គោលការណ៍ទី៤៖ ប្រើប្រាស់ពេលវេលាឱ្យមានប្រសិទ្ធភាព

ពេលវេលារបស់ក្រុមអ្នកផ្ដល់ព័ត៌មានគឺមានតម្លៃ និងធនធានដែលមានសម្រាប់ការអង្កេតមានកំណត់។ អ្នកឆ្លើយសំណួរទំនងជាបាត់បង់ការផ្ដោតអារម្មណ៍ ប្រសិនបើត្រូវឆ្លើយទៅនឹងបញ្ជីសំណួរវែង និងស្មុគស្មាញពេក ដែលនាំឱ្យបាត់បង់ភាពត្រឹមត្រូវក្នុងការឆ្លើយតប។ ដូច្នេះ សំណួរដែលមិនចាំបាច់តែត្រូវជៀសវាង ហើយសំណួរដែលចាំបាច់មិនត្រូវប្រើប្រាស់ពេលវេលាយូរជាងការចាំបាច់ ដើម្បីទទួលបានព័ត៌មានសំខាន់ៗនោះឡើយ។

### គោលការណ៍ទី៥៖ កុំបង្ខំអ្នកផ្ដល់ព័ត៌មានឱ្យឆ្លើយទៅនឹងសំណួរដែលមានលក្ខណៈរសើប

បទពិសោធន៍បង្ហាញថា នៅពេលធ្វើអង្កេតប្រភេទនេះនៅក្នុងប្រទេសកម្ពុជា ជាពិសេសនៅតំបន់ជនបទ ការរក្សាការសម្ងាត់មិនអាចធានាបានពេញលេញនោះទេ។ ដូច្នេះ វាមិនល្អទេដែលសួរសំណួររសើបទៅកាន់អ្នកឆ្លើយ ហើយវាមិនសមហេតុផលទេក្នុងការរំពឹងថានឹងមានចម្លើយពេញលេញ និងស្មោះត្រង់ចំពោះសំណួរបែបនេះផងដែរ។

### គោលការណ៍ទី៦៖ ទទួលស្គាល់សារៈសំខាន់នៃការផ្លាស់ប្ដូរសង្គម រួមទាំងឌីជីថលនីយកម្ម

វិធីសាស្ត្រសម្រាប់លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋនៅកម្ពុជាកាលពីពេលមុន គឺមិនមាន

លក្ខណៈសមស្របទៀតទេសម្រាប់ពេលនេះ និងទៅអនាគត។ ឧទាហរណ៍ ប្រជាពលរដ្ឋដែលនៅទីក្រុងកម្រមានពេលវេលា ដើម្បីចូលរួមកិច្ចប្រជុំរៀបចំផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ម្យ៉ាងវិញទៀតបច្ចេកវិទ្យាឌីជីថលបាន និងកំពុងបង្កើតឱកាសថ្មីសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការធ្វើទំនាក់ទំនងជាមួយប្រជាពលរដ្ឋ។ ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងការងាររដ្ឋបាលមានការកើនឡើងយ៉ាងឆាប់រហ័សក្នុងអំឡុងពេលនៃការអនុវត្តកជទី២។ ដូច្នេះ ការអង្កេតនេះ គួរតែរួមបញ្ចូលសំណួរសម្រាប់ពេលអនាគតដែលផ្តោតលើទិដ្ឋភាពឌីជីថល ទោះបីជាការវិវឌ្ឍអាចមានកម្រិតបន្តិចនៅពេលរៀបចំការអង្កេតដើមគ្រានេះក៏ដោយ។

### ៣.៤. និយមន័យនៃសន្ទស្សន៍អភិបាលកិច្ច និងសន្ទស្សន៍ការផ្តល់សេវា

និយមន័យនៃសន្ទស្សន៍ផ្នែកអភិបាលកិច្ច និងសន្ទស្សន៍ផ្នែកសេវាដែលត្រូវបានកំណត់សម្រាប់គោលបំណងនៃការអង្កេតនេះ គឺផ្អែកលើគោលបំណង និងគោលដៅនៃកជទី២។

### ៣.៥. សន្ទស្សន៍រង និងសូចនាករ

#### ៣.៥.១. ការពន្យល់

តម្លៃ ឬរង្វាស់នៃសន្ទស្សន៍រងនីមួយៗដែលឆ្លើយតបទៅនឹងទិដ្ឋភាពទាំង៥នៃសន្ទស្សន៍ផ្នែកអភិបាលកិច្ច (ការផ្តល់សេវា ការឆ្លើយតប តម្លាភាព គណនេយ្យភាព និងការចូលរួមរបស់ប្រជាពលរដ្ឋ) គឺផ្អែកលើសំណុំនៃសូចនាករ។ សូចនាករទាំងនេះបានកំណត់ជាទម្រង់រៀបរាប់។ មានន័យថា ជាការរៀបរាប់ជាពាក្យនូវអ្វីដែលសូចនាករត្រូវវាស់វែង មិនមែនជាការពិពណ៌នាពេញលេញនៃសូចនាករដែលមានឯកតារង្វាស់ដូចដែលមានកំណត់ក្នុងក្របខ័ណ្ឌតក្កភាពឡើយ។

បន្ទាប់មក "សូចនាករ" ទាំងនេះ ត្រូវបានវាស់វែងដោយផ្អែកលើការឆ្លើយតបទៅនឹងសំណួរនៅក្នុងបញ្ជីសំណួរសម្រាប់ក្រុមផ្តល់ព័ត៌មានជាប្រជាពលរដ្ឋ និងក្រុមផ្តល់ព័ត៌មានដែលជាក្រុមប្រឹក្សា និងមន្រ្តីនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការពិពណ៌នាពេញលេញនៃសូចនាករ រួមទាំងការគណនាពីការឆ្លើយតបទៅនឹងបញ្ជីសំណួរ និងមេគុណដែលបានកំណត់។

លើកលែងករណីមួយ (ដែលពន្យល់ក្នុងផ្នែក ៣.៥.៣. លើសន្ទស្សន៍រងនៃការឆ្លើយតប) សូចនាករទាំងអស់ដែលបានប្រើសម្រាប់គណនាសន្ទស្សន៍រងសំខាន់ៗទាំងប្រាំ គឺផ្អែកលើការឆ្លើយតបដែលទទួលបានពីក្រុមសំណាកប្រជាពលរដ្ឋ ឬពីក្រុមសំណាកជាថ្នាក់ដឹកនាំភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត (ដោយទម្ងន់ស្មើគ្នាយោងទៅតាមក្រុមនីមួយៗនៃសូចនាករទាំងបួននេះ)។

រូបភាពខាងក្រោម បង្ហាញពីទិដ្ឋភាពរួមនៃសមាសភាពនៃសន្ទស្សន៍ពីក្រុមអ្នកឆ្លើយតបផ្សេងៗគ្នា។ តួលេខភាគរយនៅក្នុងរង្វង់រាងពងក្រពើគឺជាមេគុណ។ ឧទាហរណ៍ ៦៧% នៃតម្លៃសន្ទស្សន៍រងពាក់ព័ន្ធនឹងការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺផ្អែកលើសូចនាករដែលបានវាស់វែងពីការឆ្លើយតបរបស់ប្រជាពលរដ្ឋ និង៣៣%គឺផ្អែកលើសូចនាករដែលបានវាស់វែងពីការឆ្លើយតបរបស់សមាជិកក្រុមប្រឹក្សា និងមន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ។




សំណុំសូចនាករដែលប្រើដើម្បីវាស់វែងសន្ទស្សន៍រងនីមួយៗមានបង្ហាញនៅក្នុងផ្នែកខាងក្រោម។

### ៣.៥.២. សន្ទស្សន៍រងពាក់ព័ន្ធនឹងការបំពេញការងារ

**និយមន័យ៖** សម្រាប់គោលបំណងនៃការអង្កេតនេះ **ការបំពេញការងារ**របស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកំណត់ថា ជាវិសាលភាពដែលប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋានអាចទទួលបានសេវាសាធារណៈ និងសេវារដ្ឋបាលប្រកបដោយគុណភាពខ្ពស់ ដោយសារការពង្រឹងសមត្ថភាព និងធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

សន្ទស្សន៍រងនេះត្រូវបានវាស់វែង ដោយផ្អែកលើការយល់ឃើញរបស់ប្រជាពលរដ្ឋជាចម្បងចំពោះសេវាសាធារណៈដែលប្រជាពលរដ្ឋទទួលបាននៅក្នុងមូលដ្ឋានរបស់ខ្លួន។

ប្រជាពលរដ្ឋមិនត្រូវបានស្នើឱ្យបែងចែកសេវាដែលផ្តល់នៅកម្រិតផ្សេងៗគ្នាឡើយ (ថ្នាក់ជាតិ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់) ដោយសារតែ៖

១. ប្រជាពលរដ្ឋធម្មតាទំនងជាមិនដឹងច្បាស់លាស់អំពីរដ្ឋបាលថ្នាក់ក្រោមជាតិកម្រិតណាដែលទទួលខុសត្រូវចំពោះសេវាណាមួយឡើយ

២. គោលបំណងនៃកជទី២ គឺដើម្បីកែលម្អសេវាដោយផ្ទេរការទទួលខុសត្រូវលើការផ្តល់សេវាទៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ឧទាហរណ៍ សេវាមួយចំនួនដែលត្រូវបានផ្តល់ដោយថ្នាក់ជាតិ

ក្នុងឆ្នាំ២០២៤ ប៉ុន្តែនឹងត្រូវបានផ្តល់ដោយថ្នាក់ក្រុង ស្រុកនៅឆ្នាំ២០៣០ ដូច្នេះមូលដ្ឋានសមស្របសម្រាប់វាស់វែងគុណភាពនៃសេវាគឺការផ្តល់សេវាពីថ្នាក់ជាតិ (មុនពេលវិមជ្ឈការ) មិនមែនជាការផ្តល់សេវាដោយរដ្ឋបាលថ្នាក់ក្រោមជាតិដែលមិនទាន់បានចាប់ផ្តើមនៅឡើយនាពេលធ្វើការអង្កេតនេះឡើយ។ .

ប្រជាពលរដ្ឋមិនត្រូវបានសួរអំពីបញ្ជីសេវាលម្អិតនោះឡើយ គឺសួរតែសេវាដែលសំខាន់ៗ ហើយប្រជាពលរដ្ឋភាគច្រើនមានបទពិសោធន៍ទទួលបានសេវាសំខាន់ៗទាំងនោះ ព្រមទាំងអាចបញ្ចេញមតិទស្សនៈយល់ឃើញអំពីសេវាទាំងនោះផងដែរ។ ការធ្វើបែបនេះគឺមានលក្ខណៈសមស្រប ដោយសារគោលបំណងសំខាន់ គឺដើម្បីបង្កើតសន្ទស្សន៍សម្រាប់វាស់វែងនូវភាពប្រសើរឡើងនៃការផ្តល់សេវាសម្រាប់រយៈពេលបន្តបន្ទាប់នាពេលអនាគត មិនមែនជាការវាយតម្លៃលើសេវានីមួយៗដាច់ដោយឡែកៗពីគ្នានោះឡើយ។ សេវាដែលដាក់បញ្ចូល គឺជាសេវាដែលមាននៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ប្រភេទ (ឧទាហរណ៍ សំណួរស្តីពីសេវាកសិកម្ម និងប្រព័ន្ធធារាសាស្ត្រមិនត្រូវបានរាប់បញ្ចូលទេ ព្រោះសេវាទាំងនេះនឹងមិនពាក់ព័ន្ធនៅក្នុងតំបន់ទីក្រុង) និងសេវាដែលប្រើប្រាស់ផ្ទាល់ដោយប្រជាពលរដ្ឋ (ដូច្នេះសេវាបរិស្ថានមិនត្រូវបានរាប់បញ្ចូលទេ លើកលែងតែសេវាការគ្រប់គ្រងសំរាម)។ បញ្ជីសេវាពីរប្រភេទត្រូវបានរៀបចំសម្រាប់ការអង្កេតនេះ គឺ "សេវាសាធារណៈទូទៅ" ដែលប្រជាពលរដ្ឋទទួលបាននៅតាមមូលដ្ឋាន និង "សេវារដ្ឋបាល" ដែលជាធម្មតាប្រជាពលរដ្ឋទទួលបានតាមរយៈការទៅកាន់ការិយាល័យរដ្ឋបាលថ្នាក់ក្រោមជាតិ។ បញ្ជីសេវាដែលបានកំណត់ មានការឯកភាពពីលេខាធិការដ្ឋាន គ.ជ.អ.ប. មានបង្ហាញនៅក្នុងប្រអប់ទី២។

*បញ្ជីគម្រោងការអភិវឌ្ឍ និងសេវាកម្មដែលរួមបញ្ចូលក្នុងបញ្ជីសំណួរសម្រាប់ការវាយតម្លៃ*

| **សេវាសាធារណៈ** | **សេវារដ្ឋបាល** |
|---|---|
| – ផ្លូវ និងស្ពាន<br>– ការអប់រំ (សាលា)<br>– សេវាសុខភាព<br>– រក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ<br>– ការប្រមូលសំរាម<br>– ការផ្គត់ផ្គង់ទឹកស្អាត<br>– ការផ្គត់ផ្គង់អគ្គិសនី<br>– សេវាសម្រាប់ស្ត្រី និងកុមារ<br>– ការគាំទ្រដល់ជនក្រីក្រ ឬដែលត្រូវការជំនួយ (ឧទាហរណ៍ ជនមានពិការភាព) | – ការចុះបញ្ជីអត្រានុកូលដ្ឋាន (សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ សំបុត្រមរណភាព)<br>– ការផ្តល់ ការផ្លាស់ប្តូរ ឬការផ្ទេរកម្មសិទ្ធិដីធ្លី<br>– ដោះស្រាយជម្លោះជាមួយអ្នកជិតខាង<br>– ការចុះបញ្ជីអាជីវកម្ម<br>– ការអនុញ្ញាតសាងសង់ផ្ទះ និងជួសជុលផ្ទះ<br>– ការបញ្ជាក់ឯកសារផ្ទាល់ខ្លួន |

សូចនាករចំនួនបីបានប្រើសម្រាប់វាយតម្លៃគុណភាពនៃការផ្តល់សេវា៖

- PER-I៖ **ប្រជាពលរដ្ឋ**ពេញចិត្តចំពោះគុណភាពសេវាសាធារណៈសំខាន់ៗដែលមានសម្រាប់សហគមន៍

- PER-II៖ **ប្រជាពលរដ្ឋ** ពេញចិត្តចំពោះការទទួលបានសេវារដ្ឋបាលពីការិយាល័យច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និង
- PER-III៖ **ក្រុមប្រឹក្សា និងមន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិ**ពេញចិត្តចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិរបស់ខ្លួនមានសមត្ថភាព និងធនធានគ្រប់គ្រាន់ក្នុងការផ្តល់សេវាសាធារណៈ និងរដ្ឋបាលប្រកបដោយគុណភាពខ្ពស់។

### ៣.៥.៣. សន្ទស្សន៍រងពាក់ព័ន្ធនឹងការឆ្លើយតប

**និយមន័យ៖** ក្នុងគោលបំណងនៃការអង្កេតនេះ **ការឆ្លើយតប**ត្រូវបានកំណត់ន័យថា រដ្ឋបាលថ្នាក់ក្រោមជាតិមានការយល់ដឹង និងខិតខំប្រឹងប្រែងដើម្បីឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពនានារបស់ប្រជាពលរដ្ឋ។ អាទិភាពនានារបស់ប្រជាពលរដ្ឋត្រូវបានផ្តោតការយកចិត្តទុកដាក់នៅក្នុងដំណើរការនៃការរៀបចំផែនការ ថវិកា និងការផ្តល់សេវាសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

អង្គការ UN-DESA[1] បានកំណត់ថា "ការគ្រប់គ្រងសាធារណៈដែលមានការឆ្លើយតបគឺចាំបាច់ត្រូវធ្វើការឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពចំពោះតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ។ ប្រការនេះ រួមបញ្ចូលទាំងការតាំងចិត្តផ្នែកគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី សកម្មភាព និងធនធានដោយគិតគូរអំពីការរំពឹងទុករបស់ប្រជាពលរដ្ឋដោយយកចិត្តទុកដាក់ខ្ពស់ ជាពិសេសចំពោះតម្រូវការជាក់ស្តែង ឬការរំពឹងទុកដែលមានលក្ខណៈផ្សេងៗគ្នានៅតាមមូលដ្ឋាននីមួយៗ"។ ទស្សនៈនេះ ការឆ្លើយតប គឺទាមទារឱ្យមានការយល់ដឹងពីតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ និងត្រូវព្យាយាមបំពេញឱ្យបានតាមតម្រូវការទាំងនោះ។ ការផ្តល់សេវានានាដែលបានរៀបចំក្នុងផែនការ និងផ្តល់ជូនតាមបែបមជ្ឈការ (ពីលើចុះក្រោម) ដោយមិនបានគិតគូរពីតម្រូវការរបស់ប្រជាពលរដ្ឋ សេវាទាំងនោះអាចមានគុណភាពខ្ពស់ តែអាចមិនឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ ការព្យាយាមពិតប្រាកដក្នុងការផ្តល់សេវាដែលជាតម្រូវការខ្លាំងរបស់ប្រជាពលរដ្ឋអាចមានភាពឆ្លើយតប បើទោះជាការផ្តល់សេវាទាំងនោះមិនមានគុណភាពខ្ពស់ក៏ដោយ (សម្រាប់ហេតុផលផ្សេងទៀត)។

សម្រាប់ការអង្កេតអភិបាលកិច្ចនេះ សូចនាករចំនួនបីត្រូវបានប្រើសម្រាប់វាយតម្លៃការឆ្លើយតបរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ៖

- RES-I៖ តម្រូវការជាអាទិភាពរបស់**ប្រជាពលរដ្ឋ** គឺស្រដៀងគ្នានឹងសេវាជាអាទិភាពដែលត្រូវផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ
- RES-II៖ **ប្រជាពលរដ្ឋ** យល់ថារដ្ឋបាលថ្នាក់ក្រោមជាតិមានការយល់ដឹងពីតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ ហើយព្យាយាមបំពេញតាមតម្រូវការជាអាទិភាពទាំងនោះ

[1]UN-Department of Economic and Social Affairs (២០១៥)។ អភិបាលកិច្ចសាធារណៈប្រកបដោយការទទួលខុសត្រូវ និងគណនេយ្យភាព (របាយការណ៍វិស័យសាធារណៈពិភពលោកឆ្នាំ ២០១៥) ។

- RES-III៖ **ក្រុមប្រឹក្សា និងមន្ត្រី**យល់ថា តម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋមានសារៈសំខាន់បំផុតក្នុងការសម្រេចចិត្តក្នុងការរៀបចំផែនការ និងគម្រោងថវិកា។

នីតិវិធីដែលប្រើសម្រាប់គណនាសូចនាករ RES-I គឺការផ្តល់ចំណាត់ថ្នាក់បញ្ជីសេវាសាធារណៈទូទៅ (ប្រអប់ទី២) ធៀបទៅតាមអាទិភាពដែលលើកឡើងដោយប្រជាពលរដ្ឋ។ ចំណាត់ថ្នាក់នៃតម្រូវការជាអាទិភាពនានាមានលក្ខណៈស្រដៀងគ្នាទៅនឹងអាទិភាពដែលលើកឡើងដោយដោយសមាជិកក្រុមប្រឹក្សា និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ។ ភាពប្រទាក់ក្រឡាគ្នាគ្នារវាងចំណាត់ថ្នាក់ទាំងពីរនេះបង្ហាញថា ជាមេគុណនៃការជាប់ទាក់ទងគ្នា ដែលត្រូវប្រើជារង្វាស់នៃភាពស្រដៀងគ្នារវាងអាទិភាពរបស់ប្រជាពលរដ្ឋ និងអាទិភាពដែលលើកឡើងដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដូច្នេះ នេះគឺជាសូចនាករតែមួយគត់ ដែលត្រូវបានវាស់វែងដោយការរួមបញ្ចូលគ្នានូវចម្លើយរបស់ប្រជាពលរដ្ឋជាមួយនឹងចម្លើយរបស់សមាជិកក្រុមប្រឹក្សា និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ។

### ៣.៥.៤. សន្ទស្សន៍រងពាក់ព័ន្ធនឹងតម្លាភាព

**និយមន័យ៖** សន្ទស្សន៍រង**ផ្នែកតម្លាភាព**ត្រូវបានរៀបចំឡើងសម្រាប់វាស់វែងពីវិសាលភាពដែលរដ្ឋបាលថ្នាក់ក្រោមជាតិទទួលស្គាល់សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មាន ហើយរដ្ឋបាលថ្នាក់ក្រោមជាតិមានភាពសកម្មក្នុងការចែករំលែកព័ត៌មានដោយចំហជាមួយប្រជាពលរដ្ឋ រួមបញ្ចូលទាំងព័ត៌មានអំពីរចនាសម្ព័ន្ធ និងដំណើរការអភិបាលកិច្ចមូលដ្ឋាន ផែនការអភិវឌ្ឍន៍ ថវិកា ការប្រើប្រាស់ថវិកា លទ្ធផលដែលសម្រេចបាន និងសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានសេវា និងព័ត៌មានអំពីតម្លៃសេវា។

Armstrong (២០០៥)[2] បានកំណត់ថា តម្លាភាពក្នុងសេវាសាធារណៈគឺជា "សាធារណជនអាចទទួលបានព័ត៌មានទាន់ពេល និងអាចទុកចិត្តបានអំពីការសម្រេចចិត្ត និងការផ្តល់សេវាក្នុងវិស័យសាធារណៈដោយមិនមានការរំខាន"។

ការវាស់វែងតម្លាភាពក្នុងការអង្កេតនេះ គឺគិតគូរពីកម្រិតជាក់ស្តែងនៃចំណេះដឹង ជំនឿរបស់ប្រជាពលរដ្ឋអំពីសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មាន និងឥរិយាបថក្នុងការបំពេញការងាររបស់សមាជិកក្រុមប្រឹក្សា និងមន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិលើបញ្ហាជាច្រើនដែលត្រូវចែករំលែកព័ត៌មានជាមួយប្រជាពលរដ្ឋ។

សូចនាករចំនួនប្រាំបានបង្កើតឡើងសម្រាប់វាស់វែងតម្លៃនៃសន្ទស្សន៍រងផ្នែកតម្លាភាព រួមមានដូចខាងក្រោម៖

---

[2] Armstrong, Elia (២០០៥)៖ សុចរិតភាព តម្លាភាព និងគណនេយ្យភាពក្នុងរដ្ឋបាលសាធារណៈ៖ និន្នាការថ្មីៗ ការអភិវឌ្ឍន៍ក្នុងតំបន់ និងអន្តរជាតិ និងបញ្ហាដែលកំពុងកើតមាន (អង្គការសហប្រជាជាតិ)។

- TRA-I៖ **ប្រជាពលរដ្ឋ** មានការយល់ដឹងល្អអំពីរចនាសម្ព័ន្ធ និងតួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- TRA-II៖ **ប្រជាពលរដ្ឋ** ជឿថាពួកគេមានសិទ្ធិទទួលបានព័ត៌មានអំពីការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- TRA-III៖ **ប្រជាពលរដ្ឋ** ជឿថាសេវារដ្ឋបាលថ្នាក់ក្រោមជាតិមានតម្លៃប្រកបដោយតម្លាភាព ហើយប្រជាពលរដ្ឋបង់ថ្លៃត្រឹមត្រូវតាមតម្លៃសេវាទាំងនោះ
- TRA-IV៖ **ក្រុមប្រឹក្សា និងមន្ត្រី** មានទស្សនៈវិជ្ជមានចំពោះតម្លាភាព និង
- TRA-V៖ **ក្រុមប្រឹក្សា និងមន្ត្រី** រាយការណ៍អំពីភាពសកម្មក្នុងការផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋ។

### ៣.៥.៥. សន្ទស្សន៍រងពាក់ព័ន្ធនឹងគណនេយ្យភាព

**និយមន័យ៖** សន្ទស្សន៍រង**ផ្នែកគណនេយ្យភាព**បានកំណត់ឡើងដើម្បីវាស់ស្ទង់អំពីវិសាលភាពដែលរដ្ឋបាលថ្នាក់ក្រោមជាតិមានការទទួលខុសត្រូវចំពោះសកម្មភាព និងលទ្ធផលដែលខ្លួនបានធ្វើ រួមទាំងការទទួលខុសត្រូវតាមបែបប្រជាធិបតេយ្យចំពោះអ្នកបោះឆ្នោតទាំងអស់ ការទទួលខុសត្រូវផ្នែកច្បាប់និងផ្នែករដ្ឋបាលចំពោះសកម្មភាពរបស់សមាជិកក្រុមប្រឹក្សា និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការទទួលខុសត្រូវចំពោះយន្តការទទួល និងដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋ។

ការវាស់ស្ទង់គណនេយ្យភាពផ្សេងទៀតដែលបានប្រើប្រាស់នៅប្រទេសកម្ពុជា គឺខុសគ្នាក្នុងវិសាលភាពនិងគោលបំណងនៃការអង្កេតអភិបាលកិច្ចនេះ។ ជាពិសេស ការវាស់ស្ទង់គណនេយ្យភាពក្នុងកម្មវិធីគណនេយ្យភាពសង្គមបានផ្តោតលើតម្លាភាព និងការផ្តល់សេវា។ ដូច្នេះ ការវាស់ស្ទង់តម្លៃនៃគណនេយ្យភាពក្នុងការអង្កេតអភិបាលកិច្ចនេះ គឺមិនដូចគ្នានឹងគណនេយ្យភាពដែលត្រូវបានវាស់វែងនៅក្នុងកម្មវិធីគណនេយ្យភាពសង្គមឡើយ។ ការវាស់ស្ទង់ទាំងពីរនេះ ត្រូវបានកំណត់និយមន័យខុសគ្នា និងបម្រើឱ្យគោលបំណងផ្សេងគ្នា។

គណនេយ្យភាពក្នុងក្របខ័ណ្ឌនៃការអង្កេតអភិបាលកិច្ចនេះ សំដៅលើកាតព្វកិច្ចរបស់មន្ត្រីសាធារណៈក្នុងការរាយការណ៍អំពីការប្រើប្រាស់ធនធានសាធារណៈ និងការទទួលខុសត្រូវចំពោះការខកខានមិនបានបំពេញតាមគោលបំណងដែលបានកំណត់ ដូចបានកំណត់ដោយ Armstrong (២០០៥)[3]។ ក្នុងន័យនេះ គណនេយ្យភាពនេះ ផ្តោតលើលទ្ធភាពរបស់ប្រជាពលរដ្ឋក្នុងការដាក់បណ្តឹងតវ៉ា និងទទួលបានដំណោះស្រាយសមស្រប ព្រមទាំងមានលទ្ធភាពក្នុងការដាក់ពិន័យលើការអនុវត្តមិនល្អរបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការបោះឆ្នោត និងលទ្ធភាពដែលសមាជិកក្រុមប្រឹក្សា និងមន្ត្រីក្នុងការទទួលបានពិន័យផ្នែករដ្ឋបាល ឬផ្លូវច្បាប់ចំពោះការប្រព្រឹត្តខុស។

---

[3]Armstrong, Elia (2005)៖ សុចរិតភាព តម្លាភាព និងគណនេយ្យភាពក្នុងរដ្ឋបាលសាធារណៈ៖ និន្នាការថ្មីៗ ការអភិវឌ្ឍក្នុងតំបន់ និងអន្តរជាតិ និងបញ្ហាដែលកំពុងកើតមាន (អង្គការសហប្រជាជាតិ)។

ដោយផ្អែកលើការយល់ដឹងអំពីគណនេយ្យភាពនេះ សូចនាករបែបពិពណ៌នាចំនួនប្រាំមួយត្រូវបានបង្កើតសម្រាប់កំណត់តម្លៃសន្ទស្សន៍រងផ្នែកគណនេយ្យភាពដូចខាងក្រោម៖

- ACC-I៖ **ប្រជាពលរដ្ឋ** ជឿជាក់ថាពួកគេមានលទ្ធភាពប្ដឹងតវ៉ា ប្រសិនបើពួកគេមិនពេញចិត្តចំពោះការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយពាក្យបណ្ដឹងរបស់ប្រជាពលរដ្ឋនឹងត្រូវបានទទួល និងសម្រុះសម្រួលដោះស្រាយបានយ៉ាងត្រឹមត្រូវ
- ACC-II៖ **ប្រជាពលរដ្ឋ** ជឿថាសម្លេងឆ្នោតរបស់ពួកគេនៅក្នុងការបោះឆ្នោតអាចដាក់ពិន័យប្រកបដោយប្រសិទ្ធភាពនូវការអនុវត្តមិនល្អរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ACC-III៖ **ប្រជាពលរដ្ឋ** ជឿថាមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សានឹងត្រូវទទួលពិន័យ ប្រសិនបើពួកគេបំពេញការងារមិនល្អ ឬប្រព្រឹត្តល្មើសច្បាប់
- ACC-IV: **ក្រុមប្រឹក្សា** និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិឆ្លើយថា មានយន្តការដោះស្រាយបណ្ដឹងតវ៉ារបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព។
- ACC-V៖ **ក្រុមប្រឹក្សា និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ** ឆ្លើយថា ពួកគេមានតម្រូវការក្នុងការទាក់ទាញសំឡេងឆ្នោតនៅក្នុងការបោះឆ្នោតនាពេលខាងមុខ។
- ACC-VI៖ **ក្រុមប្រឹក្សា និងមន្ត្រី** ឆ្លើយថា ពួកគេនឹងទទួលទណ្ឌកម្ម ប្រសិនបើពួកគេបំពេញការងារមិនបានល្អ ឬបំពានច្បាប់។

### ៣.៥.៦. សន្ទស្សន៍រងពាក់ព័ន្ធនឹងការចូលរួមរបស់ប្រជាពលរដ្ឋ

**និយមន័យ៖** សន្ទស្សន៍រង**ផ្នែកការចូលរួមរបស់ប្រជាពលរដ្ឋ**វាស់វែងពីវិសាលភាពដែលរដ្ឋបាលថ្នាក់ក្រោមជាតិបង្កលក្ខណៈងាយស្រួល សម្របសម្រួល និងលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមយ៉ាងសកម្មក្នុងដំណើរការអភិបាលកិច្ចមូលដ្ឋាន និងការអភិវឌ្ឍមូលដ្ឋាន តាមរយៈការផ្ដល់ឱកាសឱ្យចូលរួមដោយផ្ទាល់ក្នុងការកំណត់អាទិភាពសម្រាប់ការអភិវឌ្ឍ និងការត្រួតពិនិត្យលើលទ្ធផលនានា និងតាមរយៈការចូលរួមជាសមាជិកភាពនៃអង្គការសហគមន៍មូលដ្ឋាន ជាពិសេសអង្គការសហគមន៍មូលដ្ឋានដែលផ្ដោតលើការអភិវឌ្ឍមូលដ្ឋាន។

UN-DESA[4] កំណត់ចំណុចបីសំខាន់សម្រាប់ការចូលរួមរបស់ប្រជាពលរដ្ឋដែលរដ្ឋាភិបាលអាចផ្ដល់បាន៖ (១). ការផ្ដល់សិទ្ធិទទួលបានព័ត៌មានដល់ប្រជាពលរដ្ឋ (២). ការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ដើម្បីទទួលបានមតិកែលម្អលើបញ្ហានានា និង (៣). ការសម្របសម្រួលឱ្យមានការចូលរួមដោយផ្ទាល់ពីប្រជាពលរដ្ឋ និងដោយតំណាងប្រជាពលរដ្ឋក្នុងការធ្វើសេចក្ដីសម្រេចចិត្ត។

សូចនាករដែលបានកំណត់សម្រាប់វាស់វែងតម្លៃសន្ទស្សន៍រងផ្នែកការចូលរួមរបស់ប្រជាពលរដ្ឋរួមមានដូចខាងក្រោម៖

---

[4] UN-Department of Economic and Social Affairs (២០១៥)។ អភិបាលកិច្ចសាធារណៈប្រកបដោយការទទួលខុសត្រូវ និងគណនេយ្យភាព (របាយការណ៍វិស័យសាធារណៈពិភពលោកឆ្នាំ ២០១៥) ។

- CIV-I៖ **ប្រជាពលរដ្ឋ**ចូលរួមយ៉ាងសកម្មជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិលើការងារអភិបាលកិច្ច និងការអភិវឌ្ឍមូលដ្ឋាន
- CIV-II៖ **ប្រជាពលរដ្ឋ**ពេញចិត្តនឹងបទពិសោធន៍របស់ខ្លួនក្នុងការចូលរួមជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ
- CIV-III៖ **ប្រជាពលរដ្ឋ**ចូលរួមក្នុងអង្គការសហគមន៍មូលដ្ឋាន
- CIV-IV៖ **ប្រជាពលរដ្ឋ**ជឿថា រដ្ឋបាលថ្នាក់ក្រោមជាតិសហការប្រកបដោយប្រសិទ្ធភាពជាមួយអង្គការសហគមន៍មូលដ្ឋាន
- CIV-V៖ **ក្រុមប្រឹក្សា និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ** បានខិតខំស្វែងរកមតិយោបល់របស់ប្រជាពលរដ្ឋយ៉ាងសកម្ម តាមរយៈមធ្យោបាយផ្លូវការ និងក្រៅផ្លូវការ
- CIV-VI៖ **ក្រុមប្រឹក្សា និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ**មានទស្សនៈវិជ្ជមានចំពោះការចូលរួមរបស់ប្រជាពលរដ្ឋ
- CIV-VII៖ **ក្រុមប្រឹក្សា និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ**មានទស្សនៈវិជ្ជមានចំពោះកិច្ចសហប្រតិបត្តិការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាមួយអង្គការសង្គមស៊ីវិល និង
- CIV-VIII៖ **ក្រុមប្រឹក្សា និងមន្ត្រី**ទទួលយកបច្ចេកវិទ្យាឌីជីថល ដើម្បីសម្រួលដល់ការចូលរួមរបស់ប្រជាពលរដ្ឋ។

### ៣.៥.៧. អភិបាលកិច្ចផ្ទៃក្នុង

ការបង្កើតសូចនាករនៃអភិបាលកិច្ចផ្ទៃក្នុង រួមបញ្ចូលការសន្មត់សំខាន់ៗមួយចំនួនរួមមាន៖

- ការបង្កើនស្វ័យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាចំណុច "ល្អ" ពោលគឺ ជាវិធានការវិជ្ជមាននៃអភិបាលកិច្ចផ្ទៃក្នុង
- ជាទូទៅ សិទ្ធិអំណាចនីតិបញ្ញត្តិ និងការបង្កើតគោលនយោបាយគួរតែជាតួនាទីរបស់ក្រុមប្រឹក្សាជាជាងតួនាទីរបស់គណៈអភិបាល និងមន្ត្រីរដ្ឋបាលដែលត្រូវបានតែងតាំងឱ្យបំពេញមុខងាររបស់ជាអ្នកប្រតិបត្តិលើការសម្រេចចិត្តរបស់ក្រុមប្រឹក្សា។

ក្នុងន័យនេះ សូចនាករចំនួនបួនខាងក្រោមត្រូវបានកំណត់ដើម្បីវាស់វែងគុណភាពនៃអភិបាលកិច្ចផ្ទៃក្នុង៖

- INT-I៖ **ក្រុមប្រឹក្សា និងមន្ត្រី** វាយតម្លៃថា រដ្ឋបាលថ្នាក់ក្រោមជាតិទទួលបានការគាំទ្រសមរម្យពីរដ្ឋបាលថ្នាក់ក្រោមជាតិ
- INT-II៖ **ក្រុមប្រឹក្សា និងមន្ត្រី** វាយតម្លៃថា រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ មានស្វ័យភាពសមស្របក្នុងការគ្រប់គ្រងផែនការ ថវិកា និងការអនុវត្តការងាររបស់ខ្លួន
- INT-III៖ **ក្រុមប្រឹក្សា និងមន្ត្រី** វាយតម្លៃថា ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌមានលទ្ធភាពក្នុងការកំណត់ទិសដៅយុទ្ធសាស្ត្រ និងការត្រួតពិនិត្យលើការប្រតិបត្តិរបស់គណៈអភិបាល

- INT-IV៖ **ក្រុមប្រឹក្សា** វាយតម្លៃថា កិច្ចប្រជុំក្រុមប្រឹក្សាជួយសម្រួលដល់សមាជិកក្រុមប្រឹក្សាទាំងអស់ក្នុងការបញ្ចេញមតិ និងឈានទៅដល់ការសម្រេចចិត្តជាឯកច្ឆន្ទ។

### ៣.៦. សមាគមក្រុមប្រឹក្សាមូលដ្ឋាន

សូចនាករខាងក្រោមកំណត់សម្រាប់បង្កើតសន្ទស្សន៍ផ្នែកសមាគមក្រុមប្រឹក្សាមូលដ្ឋាន (LCA)៖

- LCA-I៖ ក្រុមប្រឹក្សា **ឃុំ សង្កាត់ និង ក្រុង ស្រុក ខណ្ឌ** ចាត់ទុកសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ មានសារៈសំខាន់ និងមានប្រសិទ្ធភាព
- LCA-II៖ **ក្រុមប្រឹក្សា និងមន្ត្រីខេត្តនានា** ចាត់ទុកសមាគមរាជធានី ខេត្ត មានសារៈសំខាន់ និងមានប្រសិទ្ធភាព។

### ៣.៧. ការបំលែង

លទ្ធផលការអង្កេតទាំងអស់ដែលប្រើក្នុងការគណនាសូចនាករ សន្ទស្សន៍រង និងសន្ទស្សន៍ ត្រូវបានបំលែងទៅជាតម្លៃចាប់ពី ១ "ល្អបំផុត" ទៅ 0 "ទាបបំផុត"។ វិធីសាស្ត្រជាច្រើនបានប្រើក្នុងបំលែងចម្លើយនានាទៅជាតម្លៃពី ១ ទៅ 0 នេះ។ ចំពោះសំណួរបិទដែលមានចម្លើយពីរ គឺ "បាទ" ឬ "ទេ" ត្រូវបានផ្តល់តម្លៃយ៉ាងសាមញ្ញ គឺ១ ឬ 0។ សំណួរដែលមានចម្លើយច្រើន (ឧទាហរណ៍ សំណួរដែលមានជម្រើសចម្លើយចំនួនប្រាំ មានដូចជា "មិនយល់ស្របសោះ" "មិនយល់ស្របខ្លះ" "មិនយល់ស្របតែមិនជំទាស់" "យល់ស្របខ្លះ" "យល់ស្របទាំងស្រុង" ត្រូវបានផ្តល់តម្លៃ "0" "0,២៥" "0,៥" "0,៧៥" និង "១"។ បញ្ជីពេញលេញនៃការបំលែងចម្លើយទៅជាតម្លៃសម្រាប់សំណួរនីមួយៗមាននៅក្នុងឧបសម្ព័ន្ធទី២។

សម្រាប់សំណួរដែលមានច្រើនផ្នែក ផ្នែកនីមួយៗត្រូវបានផ្តល់មេគុណស្មើៗគ្នាក្នុងករណីភាគច្រើន ឧទាហរណ៍ ប្រសិនបើសំណួរមានប្រាំផ្នែក ផ្នែកនីមួយៗត្រូវបានផ្តល់មេគុណ0,២ ហើយពិន្ទុនៃចម្លើយនីមួយៗត្រូវបានគណនាជាផលបូកនៃចម្លើយគុណនឹងមេគុណសម្រាប់ផ្នែកនីមួយៗ។

ស្រដៀងគ្នានេះ តម្លៃសូចនាករត្រូវបានគណនាជាផលបូកនៃពិន្ទុរបស់ចម្លើយគុណនឹងមេគុណដែលបានកំណត់ចំពោះសំណួរនីមួយៗក្នុងសមាសភាពសូចនាករ ហើយតម្លៃសន្ទស្សន៍រងត្រូវបានគណនាជាផលបូកនៃពិន្ទុសូចនាករគុណនឹងមេគុណដែលកំណត់ចំពោះសូចនាករនីមួយៗ។

### ៣.៨. ទម្ងន់នៃសូចនាករ

តម្លៃសូចនាករត្រូវបានបញ្ចូលគ្នាដើម្បីគណនាសន្ទស្សន៍រងដោយប្រើមេគុណ ដែលបានកំណត់តាមប្រធានបទនីមួយៗ (មេគុណឆ្លុះបញ្ចាំងពីការវិនិច្ឆ័យអំពីសារៈសំខាន់ពាក់ព័ន្ធនឹងសូចនាករនីមួយៗក្នុងការគណនាតម្លៃសន្ទស្សន៍រង)។ តាមរបៀបដូចគ្នានេះ ពិន្ទុនៃចម្លើយត្រូវបានបញ្ចូលគ្នាដើម្បីគណនាតម្លៃសូចនាករដោយប្រើមេគុណដែលបានកំណត់។

គោលការណ៍សំខាន់ៗដែលបានប្រើក្នុងការជ្រើសរើសមេគុណរួមមាន៖

- ក្នុងការគណនាសន្ទស្សន៍រងនីមួយៗ ពីរភាគបីនៃតម្លៃសន្ទស្សន៍រងគឺផ្អែកលើចម្លើយរបស់ប្រជាពលរដ្ឋ និងមួយភាគបីគឺផ្អែកលើចម្លើយរបស់ក្រុមប្រឹក្សា និងមន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- ចំពោះសូចនាករផ្អែកលើចម្លើយរបស់ក្រុមប្រឹក្សា និងមន្ត្រី ចម្លើយនីមួយៗត្រូវបានកំណត់មេគុណស្មើគ្នាក្នុងការគណនាសូចនាករ
- ផ្អែកលើសារៈសំខាន់នៃប្រធានបទជាក់លាក់ណាមួយ ក្នុងការគណនាតម្លៃសន្ទស្សន៍ គឺមិនឱ្យជះឥទ្ធិពលដោយចំនួនសំណួរដែលប្រើដើម្បីវាយតម្លៃប្រធានបទនោះឡើយ (ឧ.ប្រសិនបើមានសំណួរពីរឬបីដែលពាក់ព័ន្ធនឹងប្រធានបទស្រដៀងគ្នា សំណួរនីមួយៗទាំងនោះត្រូវផ្តល់មេគុណតិចជាងមេគុណដែលត្រូវផ្តល់ចំពោះសំណួរដែលមានតែមួយសម្រាប់ប្រធានបទស្រដៀងគ្នានោះ)
- ក្នុងករណីខ្លះ សំណួរ ឬសូចនាករមួយចំនួនត្រូវបានវាយតម្លៃថា មានសារៈសំខាន់ជាងសំណួរ ឬសូចនាករផ្សេងទៀត ដូច្នេះត្រូវបានផ្តល់មេគុណខ្ពស់ជាង។

ការធ្វើបែបនេះ គឺជាកិច្ចការដែលជៀសមិនរួច ហើយអាចត្រូវបានពិចារណាថាមេគុណមួយចំនួនគួរតែខ្ពស់ជាង ឬទាបជាង។ ទោះយ៉ាងក្តី ចំណុចដែលគួរកត់សម្គាល់ រួមមានដូចខាងក្រោម៖

- គ្មានវិធីសាស្ត្រណាដែលធ្វើឱ្យសម្រេចបំណងពេញលេញណាមួយ ដោយការបូកបញ្ចូលគ្នានូវចម្លើយពីក្រុមសំណាកទាំងប្រាំប្រភេទផ្សេងគ្នាទៅជាតម្លៃតែមួយសម្រាប់សន្ទស្សន៍រង និងសន្ទស្សន៍នោះឡើយ។ ឧទាហរណ៍ ប្រសិនបើសន្ទស្សន៍ត្រូវបានគណនាដោយតម្លៃជាមធ្យមនៃសូចនាករទាំងអស់ នោះមានន័យថា គឺជាការសម្រេចចិត្តផ្តល់មេគុណស្មើៗគ្នាចំពោះសូចនាករទាំងអស់
- ប្រព័ន្ធផ្តល់មេគុណដែលប្រើដោយមានតម្លាភាព អាចជួយដល់ការសិក្សា និងផ្តល់ភាពងាយយល់។ ហេតុផលនៃការជ្រើសរើសទម្ងន់ផ្សេងៗ គឺមានលក្ខណៈសាមញ្ញក្នុងករណីភាគច្រើន
- ប្រព័ន្ធផ្តល់មេគុណនេះអាចកែសម្រួលចំពោះការធ្វើអង្កេតអភិបាលកិច្ចដំណាក់កាលបន្តបន្ទាប់។ **ករណីនេះ ក៏ចាំបាច់ត្រូវកែតម្រូវលទ្ធផលនៃការអង្កេតដើមគ្រានេះទៅតាមមេគុណថ្មីផងដែរ ដើម្បីធានាឱ្យមានមូលដ្ឋានត្រឹមត្រូវសម្រាប់ការប្រៀបធៀប។**

រូបភាពខាងក្រោមនេះ គឺជាឧទាហរណ៍ដែលបង្ហាញអំពីវិធីសាស្ត្រនៃការគណនាមេគុណតាមសមាសភាពនៃសន្ទស្សន៍រង ដោយផ្អែកលើពិន្ទុចម្លើយ និងដែលមានមេគុណពាក់ព័ន្ធនានា។




## ៣.៩. ការបកស្រាយពិន្ទុ

រាល់ចម្លើយដែលបានឆ្លើយតបទៅនឹងសំណួរនានានៃការអង្កេតអភិបាលកិច្ចនេះ ត្រូវបានបំលែងទៅជាពិន្ទុដែលមានតម្លៃពី ០ (សូន្យ) ទៅ ១ (មួយ) សម្រាប់ការគណនាសន្ទស្សន៍នីមួយៗ។

ជារួម តម្លៃសន្ទស្សន៍ដែលបានបង្កើតឡើងនេះ គឺជាតម្លៃសន្ទស្សន៍ដើមគ្រា ដូច្នេះតម្លៃសន្ទស្សន៍ទាំងនេះមិនមានសារៈសំខាន់ក្នុងការឆ្លុះបញ្ចាំងអំពីកម្រិតនៃការសម្រេចបានតាមគោលបំណង និងគោលដៅនៃកជទី២នាពេលនេះឡើយ ក៏ប៉ុន្តែតម្លៃសន្ទស្សន៍នេះនឹងមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ធ្វើជាមូលដ្ឋានក្នុងវាស់វែងការផ្លាស់ប្តូរ ឬការប្រែប្រួលតម្លៃសន្ទស្សន៍ទាំងនេះ នៅពេលធ្វើអង្កេតអភិបាលកិច្ចបែបនេះនាពេល៣ឆ្នាំបន្ទាប់ ឬនៅពេលបញ្ចប់ការអនុវត្តកជទី២។ ដើម្បីជួយឱ្យការវាស់វែងកម្រិតនៃការប្រែប្រួលប្រកបដោយភាពជឿទុកចិត្ត ភាពចាំបាច់នៃស្ថិតិ (statistical significance) បានប៉ាន់ប្រមាណចន្លោះទំនុកចិត្ត គឺ៩៥% (confidence intervals) សម្រាប់តម្លៃពិន្ទុនីមួយៗ (សូមមើលផ្នែក៣.១៥.)។

ជាទូទៅ សូចនាករ ឬសន្ទស្សន៍រង ឬសន្ទស្សន៍ដែលមានតម្លៃខ្ពស់ បង្ហាញពីកម្រិតនៃការសម្រេចបានឬភាពពេញចិត្តខ្ពស់។ ផ្ទុយមកវិញ សូចនាករ ឬសន្ទស្សន៍រង ឬសន្ទស្សន៍ដែលមានតម្លៃទាបអាចបង្ហាញពីទិដ្ឋភាពនៃអភិបាលកិច្ចដែលចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត។ ទោះយ៉ាងនេះក្តី ការប្រៀបធៀបបែបនេះអាចមានភាពមិនត្រឹមត្រូវទាំងស្រុងនោះឡើយ (យើងមិនអាចបញ្ជាក់

យ៉ាងពិតប្រាកដថា សន្ទស្សន៍ផ្នែកតម្លាភាពដែលមានតម្លៃ 0,63 គឺមានភាពប្រសើរជាងសន្ទស្សន៍ផ្នែកការឆ្លើយតបដែលមានតម្លៃ0,62នោះឡើយ)។

ការផ្តល់ចំណាត់ថ្នាក់អាចប្រើជារង្វាស់សម្រាប់បង្ហាញពីភាពពេញចិត្ត ឬមិនពេញចិត្ត។ ក្នុងគោលបំណងនេះ ការផ្តល់ចំណាត់ត្រូវបានបែងចែកជាប្រាំចំណាត់ថ្នាក់ ដូចបានបង្ហាញក្នុងតារាងខាងក្រោម។ ចំណាត់ថ្នាក់ទាំងប្រាំនេះរួមមាន "ខ្សោយ" "មធ្យម" "បង្គួរ" "ល្អ" និង "ល្អណាស់" ហើយចំណាត់ថ្នាក់ទាំងនេះនឹងត្រូវប្រើប្រាស់នៅក្នុងផ្នែកទី៦ដែលពាក់ព័ន្ធនឹងលទ្ធផលនៃការអង្កេតអភិបាលកិច្ចនេះ។

*តារាង៖ ពណ៌នាអំពីលំដាប់ថ្នាក់ពិន្ទុនៃចម្លើយដែលបានបំលែងជាតម្លៃ*

| ពិន្ទុ | # សំណួរ | % | ចំណាត់ថ្នាក់ |
|---|---|---|---|
| ពី0រហូតដល់ 0,៤ | ២៨ | ២១% | ខ្សោយ |
| លើសពី 0,៤ ដល់ 0,៥៨ | ២៦ | ១៩% | មធ្យម |
| លើសពី 0,៥៨ ដល់ 0,៧ | ២៧ | ២0% | បង្គួរ |
| លើសពី 0,៧ ដល់ 0,៧៨ | ២៦ | ១៩% | ល្អ |
| លើសពី 0,៧៨ | ២៨ | ២១% | ល្អណាស់ |
| **សរុប** | **១៣៥** | **១00%** | |

### ៣.១០. ការបំបែកលទ្ធផលនៅតាមកម្រិតថ្នាក់នីមួយៗ

ផ្អែកតាមតម្រូវការសម្រាប់ការវាយតម្លៃកជទី២ សន្ទស្សន៍ផ្នែកអភិបាលកិច្ច និងសន្ទស្សន៍ផ្នែកសេវាត្រូវគណនាសន្ទស្សន៍សម្រាប់កម្រិតថ្នាក់ជាតិសរុប។

ទោះយ៉ាងនេះក្តី ដោយសារសំណាកសម្រាប់ការធ្វើអង្កេតអភិបាលនេះត្រូវបានរៀបចំយ៉ាងច្បាស់លាស់ដែលធានាដល់សមភាពយេនឌ័រ និងតំណាងឱ្យតំបន់ជនបទ និងតំបន់ទីក្រុង តំបន់នានាដែលមានភូមិសាស្ត្រផ្សេងៗគ្នា ដូចជា តំបន់ទំនាប ទន្លេសាប តំបន់ឆ្នេរ និងតំបន់ខ្ពង់រាប ជាដើម។ អាស្រ័យហេតុនេះ សម្រាប់ជាព័ត៌មានបន្ថែម លទ្ធផលនៃការអង្កេតអភិបាលកិច្ចនេះក៏អាចបង្ហាញដោយបែងចែកតាមភេទ(ស្ត្រី និងបុរស) និងតាមតំបន់ភូមិសាស្ត្រនីមួយបានផងដែរ។ តម្លៃ ឬពិន្ទុសូចនាករដែលបានបំបែកតាមភេទ និងតាមតំបន់មានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី៤។ លើសពីនេះ ក្នុងឧបសម្ព័ន្ធទី៥បានបង្ហាញអំពីចម្លើយរបស់ប្រជាពលរដ្ឋដែលបែងចែកជាគ្រួសារដែលមានសមាជិកពិការ គ្រួសារដែលមានប័ណ្ណក្រីក្រ គ្រួសារដែលជាជនជាតិដើមភាគតិច និងអ្នកឆ្លើយតបដែលមានអាយុក្រោម ៣0 ឆ្នាំ។ លើសពីនេះ តារាងតម្លៃសូចនាករតាមខេត្តនីមួយៗត្រូវបានរាយការណ៍ផងដែរ។ កំណត់សម្គាល់សំខាន់ៗអំពីលទ្ធផលដែលបានបែងចែងតាមភេទ និងតាមតំបន់មានបរិយាយក្នុងផ្នែកទី៥។

ជារួម ការបំបែកលទ្ធផលតាមតំបន់នីមួយៗនឹងកាត់បន្ថយភាពត្រឹមត្រូវផ្នែកស្ថិតិសម្រាប់ការវិភាគ ដោយសារតែចំនួនសំណាកត្រូវបានកាត់បន្ថយ (សូមមើលប្រអប់ទី៣ សម្រាប់ការពន្យល់សាមញ្ញអំពីកិច្ចការនេះ)។

> កំហុសស្តង់ដារ (Standard Error-S.E.) គឺជារង្វាស់ស្តង់ដារនៃភាពខុសគ្នាដែលរំពឹងទុករវាងតម្លៃមធ្យមដែលបានវាស់សម្រាប់សំណាកមួយ និងមធ្យមភាគ "ពិត" ដែលយើងនឹងវាស់ប្រសិនបើយើងស្ទង់មតិប្រជាជនទាំងមូល។ យើងប្រើកំហុសស្តង់ដារដើម្បីប៉ាន់ប្រមាណចន្លោះទំនុកចិត្ត ៩៥% មានន័យថាយើងជឿជាក់ថាតម្លៃមធ្យម "ពិត" គឺស្ថិតនៅក្នុងជួរនោះ។
>
> – ព្រំដែនទាបនៃជួរភាពជឿជាក់ ៩៥% = តម្លៃវាស់– ១,៩៦ x S.E
> – ព្រំដែនខាងលើនៃជួរទំនុកចិត្ត ៩៥% = [តម្លៃដែលបានវាស់វែង] + ១,៩៦ x S.E
>
> កំហុសស្តង់ដារត្រូវបានគណនាជាគម្លាតស្តង់ដារ (σ) ដកឫសការេនៃទំហំសំណាក (n)
>
> $$SE = \frac{\sigma}{\sqrt{n}}$$
>
> ដូច្នេះ ទំហំសំណាកធំនាំឱ្យមានការវាស់វែងត្រឹមត្រូវជាង (ភាពត្រឹមត្រូវស្ថិតិកើនឡើង)។ ចំណាំថា **ទំហំដាច់ខាត**នៃសំណាកគឺជាកត្តាសំខាន់ វាមិនទាក់ទងទៅនឹង % នៃចំនួនប្រជាជនដែលបានយកជាសំណាកនោះទេ។

គួរកត់សំគាល់ថា ទំហំសំណាកតាមខេត្ត និងចម្លើយដែលទទួលបានសម្រាប់សំណួរនីមួយៗនៅតាមខេត្តនីមួយៗមានចំនួនតិច។ ដូច្នេះ អាចមានភាពខុសគ្នាខ្លាំងរវាងលទ្ធផលតាមខេត្តនីមួយៗ។

### ៣.១១. សំណាក

សំណាកត្រូវបានជ្រើសរើសនៅទូទាំង២៥ រាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន៩២ ក្នុងចំណោម២១០ក្រុង ស្រុក ខណ្ឌ។ ក្នុងក្រុង ស្រុក ខណ្ឌនីមួយៗ បានជ្រើសរើសយកឃុំ សង្កាត់ចំនួនពីរ និងក្នុងឃុំ សង្កាត់នីមួយៗបានជ្រើសរើសភូមិចំនួន២ និងប្រជាពលរដ្ឋចំនួន៥នាក់ពីភូមិនីមួយៗ។ ចំនួនអ្នកផ្តល់ព័ត៌មានតាមរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅនីមួយៗត្រូវបានបង្ហាញក្នុងតារាងខាងក្រោម៖

| ប្រភេទសំណាក | ឯកតា | # ឯកតា | សំណាក/ ឯកតា | សរុប | ចំនួនសំណាកកំណត់ក្នុង TOR |
|---|---|---|---|---|---|
| ក្រុមប្រឹក្សារាជធានី ខេត្ត | រាជធានី ខេត្ត | ២៥ | ២ | ៥០ | ០ |
| គណៈអភិបាល រាជធានី ខេត្ត | រាជធានី ខេត្ត | ២៥ | ១ | ២៥ | ០ |
| ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ | ក្រុង ស្រុក ខណ្ឌ | ៩៦ | ៤ | ៣៨៤ | ៨៥៦ |
| គណៈអភិបាលក្រុង ស្រុក ខណ្ឌ | ក្រុង ស្រុក ខណ្ឌ | ៩៦ | ១ | ៩៦ | ០ |
| មន្ត្រីក្រុង ស្រុក ខណ្ឌ | ក្រុង ស្រុក ខណ្ឌ | ៩៦ | ៣ | ២៨៨ | ៨០០ |
| ក្រុមប្រឹក្សា ឃុំ សង្កាត់ | ឃុំ សង្កាត់ | ១៩២ | ៤ | ៧៦៨ | ១ ០៤១ |
| មេភូមិ | ភូមិ | ៣៨៤ | ១ | ៣៨៤ | ០ |
| ប្រជាពលរដ្ឋ | ភូមិ | ៣៨៤ | ៥ | ១ ៩២០ | ១ ១៨៩ |
| | | | | **៣ ៩១៥** | **៣ ៨៨៦** |

សំណាករដ្ឋបាលថ្នាក់ក្រោមជាតិ រួមមាន រាជធានីភ្នំពេញ និងខេត្តទាំង២៤ រដ្ឋបាលក្រុង (តំណាងតំបន់ទីប្រជុំជន) និងស្រុក (តំណាងតំបន់ជនបទ)ចម្រុះគ្រប់ខេត្ត លើកលែងតែខេត្តប៉ៃលិននិងខេត្តកែបដែលបានជ្រើសរើសយកតែក្រុង ឬស្រុកចំនួន១ពីខេត្តនីមួយៗ។ ខេត្តភាគច្រើនមានក្រុងតែមួយ ដូច្នេះត្រូវជ្រើសរើសក្រុងនោះដោយស្វ័យប្រវត្តិ។ ជាមួយគ្នានេះ ក្រុងចំនួនពីរដែលមិនមែនជាទីរួមខេត្ត គឺក្រុងបាវិត និងក្រុងប៉ោយប៉ែតត្រូវបានជ្រើសរើសជាសំណាកផងដែរ។ ដូច្នេះរដ្ឋបាលក្រុង ស្រុក ខណ្ឌគោលដៅដែលបានជ្រើសរើស គឺមានចំនួន៩៦ ក្នុងនោះ ខណ្ឌមានចំនួន៦ ក្រុងមានចំនួន ២៤ និងស្រុកមានចំនួន៦៦ ដែលត្រូវបានជ្រើសរើសដោយចៃដន្យ។ សំណាករដ្ឋបាលថ្នាក់ក្រោមជាតិមានបង្ហាញក្នុងតារាងខាងក្រោម៖

| ប្រភេទសំណាក | ចំនួនសំណាក | ការបែងចែកតាមរាជធានី ខេត្ត | # |
|---|---|---|---|
| ខណ្ឌ | ៦ | ភ្នំពេញ | ៦ |
| ក្រុង | ទាំងអស់ | ២២ ខេត្ត រួមទាំងក្រុងបាវិត និងក្រុងប៉ោយប៉ែត | ២៤ |
| ស្រុកជនបទ | ៤ | ក្នុងខេត្តបាត់ដំបង កណ្តាល ព្រៃវែង និង សៀមរាប | ១៦ |
| ស្រុកជនបទ | ៣ | ក្នុងខេត្តបន្ទាយមានជ័យ កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កំពត ក្រចេះ ព្រះវិហារ ពោធិ៍សាត់ រតនគិរី តាកែវ និងត្បូងឃ្មុំ | ៣៦ |
| ស្រុកជនបទ | ២ | ក្នុងខេត្តកោះកុង មណ្ឌលគិរី ឧត្តរមានជ័យ ព្រះសីហនុ ស្ទឹងត្រែង និងស្វាយរៀង | ១២ |
| ឯកតាពិសេស | ១ | ក្នុងខេត្តកែប និងប៉ៃលិន | ២ |
| **សរុប** | | | **៩៦** |

វិធីសាស្ត្រនៃការជ្រើសរើសសំណាកនេះបានធ្វើឱ្យមានសមាមាត្រសំណាកក្រុង ស្រុក ខណ្ឌមានលក្ខណៈប្រហែលគ្នានៅទូទាំងខេត្ត និងទូទាំងតំបន់ភូមិសាស្ត្រដូចមានក្នុងតារាងខាងក្រោម៖

| GIS | ខេត្ត | ចំនួនក្រុង ស្រុក ខណ្ឌ | តំបន់ | ឯកតាសំណាក | | | % ក្រុង ស្រុក ខណ្ឌ |
|---|---|---|---|---|---|---|---|
| | | | | ទីក្រុង | ជនបទ | សរុប | |
| ១ | បន្ទាយមានជ័យ | ៩ | ទន្លេសាប | ២ | ៣ | ៥ | ៥៦% |
| ២ | បាត់ដំបង | ១៤ | ទន្លេសាប | ១ | ៤ | ៥ | ៣៦% |
| ៣ | កំពង់ចាម | ១០ | ដីទំនាប | ១ | ៣ | ៤ | ៤0% |
| ៤ | កំពង់ឆ្នាំង | ៨ | ទន្លេសាប | ១ | ៣ | ៤ | ៥0% |
| ៥ | កំពង់ស្ពឺ | ៩ | ខ្ពង់រាប | ១ | ៣ | ៤ | ៥0% |
| ៦ | កំពង់ធំ | ៩ | ខ្ពង់រាប | ១ | ៣ | ៤ | ៤៤% |
| ៧ | កំពត | ៩ | ឆ្នេរសមុទ្រ | ១ | ៣ | ៤ | ៥0% |
| ៨ | កណ្តាល | ១៣ | ដីទំនាប | ១ | ៤ | ៥ | ៤៥% |
| ៩ | កោះកុង | ៧ | ឆ្នេរសមុទ្រ | ១ | ២ | ៣ | ៥៧% |
| ១០ | ក្រចេះ | ៧ | ខ្ពង់រាប | ១ | ៣ | ៤ | ៥0% |
| ១១ | មណ្ឌលគិរី | ៥ | ខ្ពង់រាប | ១ | ២ | ៣ | ៦0% |
| ១២ | ភ្នំពេញ | ១៤ | ដីទំនាប | ៦ | 0 | ៦ | ៥0% |
| ១៣ | ព្រះវិហារ | ៨ | ខ្ពង់រាប | ១ | ៣ | ៤ | ៥0% |
| ១៤ | ព្រៃវែង | ១៣ | ដីទំនាប | ១ | ៤ | ៥ | ៣៨% |

| GIS | ខេត្ត | ចំនួនក្រុង ស្រុក ខណ្ឌ | តំបន់ | ឯកតាសំណាក | | | % ក្រុង ស្រុក ខណ្ឌ |
|---|---|---|---|---|---|---|---|
| | | | | ទីក្រុង | ជនបទ | សរុប | |
| ១៥ | ពោធិសាត់ | ៧ | ទន្លេសាប | ១ | ៣ | ៤ | ៥០% |
| ១៦ | រតនគិរី | ៩ | ខ្ពង់រាប | ១ | ៣ | ៤ | ៤៤% |
| ១៧ | សៀមរាប | ១២ | ទន្លេសាប | ១ | ៤ | ៥ | ៤២% |
| ១៨ | ព្រះសីហនុ | ៥ | ឆ្នេរសមុទ្រ | ១ | ២ | ៣ | ៧៥% |
| ១៩ | ស្ទឹងត្រែង | ៦ | ខ្ពង់រាប | ១ | ២ | ៣ | ៥០% |
| ២០ | ស្វាយរៀង | ៨ | ដីទំនាប | ២ | ២ | ៤ | ៦៣% |
| ២១ | តាកែវ | ១០ | ដីទំនាប | ១ | ៣ | ៤ | ៤០% |
| ២២ | ឧត្តរមានជ័យ | ៥ | ខ្ពង់រាប | ១ | ២ | ៣ | ៦០% |
| ២៣ | កែប | ២ | ឆ្នេរសមុទ្រ | ១ | ០ | ១ | ៥០% |
| ២៤ | ប៉ៃលិន | ២ | ខ្ពង់រាប | ១ | ០ | ១ | ៥០% |
| ២៥ | ត្បូងឃ្មុំ | ៧ | ដីទំនាប | ១ | ៣ | ៤ | ៥៧% |
| | **សរុប** | **២០៨** | | **៣២** | **៦៤** | **៩៦** | **៤៦%** |

| តំបន់ | ចំនួននៃក្រុង ស្រុក ខណ្ឌ | ឯកតាសំណាក | | | ភាគរយនៃក្រុង ស្រុក ខណ្ឌ |
|---|---|---|---|---|---|
| | | ទីក្រុង | ជនបទ | សរុប | |
| តំបន់ទំនាប | ៧៥ | ១៣ | ១៩ | ៣២ | ៤៣% |
| ទន្លេសាប | ៥៩ | ៧ | ២០ | ២៧ | ៤៦% |
| ខ្ពង់រាប | ៥១ | ៨ | ១៨ | ២៦ | ៥១% |
| ឆ្នេរសមុទ្រ | ២៣ | ៤ | ៧ | ១១ | ៤៨% |

ការជ្រើសរើសសំណាកបានធ្វើឡើងផ្អែកលើបញ្ជីឈ្មោះរដ្ឋបាលថ្នាក់ក្រោមជាតិតាមកម្រិតនីមួយៗ (រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ភូមិ)។ ការជ្រើសរើសសំណាកនេះបានធ្វើឡើងក្នុងកម្មវិធី Excel ដោយកំណត់លេខសម្រាប់ជ្រើសរើសដោយចៃដន្យតាមលេខរៀងនៃបញ្ជីឈ្មោះរដ្ឋបាលថ្នាក់ក្រោមជាតិតាមកម្រិតនីមួយៗ។ ឧទាហរណ៍ ខេត្តបន្ទាយមានជ័យ មានស្រុកចំនួន៧ ក្នុងនោះស្រុកចំនួន៣ត្រូវជ្រើសរើសធ្វើជាសំណាក។ ដូច្នេះ ស្រុកទាំង៧ត្រូវបានកំណត់លេខសម្រាប់ការជ្រើសរើសដោយចៃដន្យ ហើយស្រុកណាដែលលេចចេញឡើងនូវលេខសម្គាល់ចៃដន្យទី១ ទី២ និងទី៣ នៅក្នុងបញ្ជីឈ្មោះស្រុកទាំង៧នេះ គឺជាស្រុកដែលត្រូវជ្រើសរើសជាសំណាក។

- **ការជ្រើសរើសសំណាកដំណាក់កាលទី១៖** គឺការជ្រើសរើសដោយចៃដន្យនូវសំណាកស្រុកនៅក្នុងខេត្តនីមួយៗ និងការជ្រើសរើសដោយចៃដន្យនូវសំណាកខណ្ឌទាំង៦ក្នុងរាជធានីភ្នំពេញ។ ក្រុងទាំង២៤ ត្រូវបានរួមបញ្ចូលដោយស្វ័យប្រវត្តិនៅក្នុងការជ្រើសរើសសំណាក់ដំណាក់កាលដំបូងនេះ។

- **ការជ្រើសរើសសំណាកដំណាក់កាលទីពីរ៖** ការជ្រើសរើសដោយចៃដន្យនូវសំណាកឃុំ សង្កាត់ចំនួនពីរសំណាកក្រុង ស្រុក ខណ្ឌដែលបានជ្រើសរើសក្នុងដំណាក់កាលទី១។
- **ការជ្រើសរើសសំណាកដំណាក់កាលទីបី៖** ការជ្រើសរើសដោយចៃដន្យនូវសំណាកភូមិចំនួនពីរចេញពីឃុំ សង្កាត់នីមួយៗដែលបានជ្រើសរើសក្នុងដំណាក់កាលទី២។

ចំពោះសំណាកប្រជាពលរដ្ឋ គ្រួសារចំនួនប្រាំត្រូវបានជ្រើសរើសដោយចៃដន្យនៅក្នុងភូមិគោលដៅនីមួយៗ ដោយមានអ្នកឆ្លើយសំណួរម្នាក់ត្រូវបានសម្ភាសន៍ក្នុងសំណាកគ្រួសារនីមួយៗ។ ការសម្ភាសន៍ត្រូវបានធ្វើឡើងជាមួយសមាជិកគ្រួសារមានវ័យចំណាស់ដែលជាអ្នកមានការប្រាស្រ័យទាក់ទងជាមួយអាជ្ញាធរមូលដ្ឋានក្នុងនាមគ្រួសារ។ ដើម្បីសម្រេចបាននូវសមភាពយេនឌ័រ ក្នុងឃុំ សង្កាត់នីមួយៗ បុរស៣នាក់ និងស្ត្រី២នាក់ត្រូវបានសម្ភាសន៍នៅក្នុងភូមិមួយ និងបុរស២នាក់ និងស្ត្រី ៣នាក់ត្រូវបានសម្ភាសន៍នៅក្នុងភូមិមួយផ្សេងទៀត។

សំណាក់ក្រុមប្រឹក្សា និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវបានជ្រើសរើសដោយចៃដន្យដែរ ហើយលទ្ធផលដែលសម្រេចបានគឺមានចំនួនបុរស និងស្ត្រីប្រហាក់ប្រហែលគ្នា លើកលែងសំណាកសមាជិកក្រុមប្រឹក្សាដែលមានចំនួនសំណាកជាបុរសច្រើនជាងសំណាកជាស្ត្រី។ វិធីសាស្ត្រដែលប្រើប្រាស់នេះ គឺការរៀបចំបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្តសម្រាប់ការជ្រើសរើសដោយចៃដន្យ។ ចំពោះឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សាជាស្ត្រីពីរនាក់ដំបូង និងសមាជិកក្រុមប្រឹក្សាជាបុរសពីរនាក់ដំបូងដែលលេចឡើងក្នុងបញ្ជីត្រូវជ្រើសរើស។ ប្រសិនបើក្រុមប្រឹក្សា មានសមាជិកស្ត្រីតិចជាងពីររូប ក្រុមប្រឹក្សាបុរសបី ឬបួននាក់ត្រូវបានជ្រើសរើស។ សម្រាប់រាជធានី ខេត្ត ក្រុមប្រឹក្សាស្ត្រីដំបូង និងបុរសដំបូងដែលមានឈ្មោះក្នុងបញ្ជីត្រូវបានជ្រើសរើស លុះត្រាតែមិនមានសមាជិកក្រុមប្រឹក្សាជាស្ត្រី ដែលក្នុងករណីនេះ សមាជិកក្រុមប្រឹក្សាជាបុរសពីរនាក់ត្រូវបានជ្រើសរើស។

សមាជិកក្រុមប្រឹក្សាត្រូវបានជ្រើសរើសមុនពេលនៃការសម្ភាសន៍ ដូច្នេះពួកគេអាចត្រូវបានអញ្ជើញឱ្យចូលរួមក្នុងការិយាល័យក្រុមប្រឹក្សាដើម្បីសម្ភាសន៍។ គ្មានការបែងចែករវាងប្រធានក្រុមប្រឹក្សា និងសមាជិកក្រុមប្រឹក្សាក្នុងការជ្រើសរើសសំណាកឡើយ។ វិធីសាស្ត្រស្រដៀងគ្នានេះ ត្រូវបានអនុវត្តសម្រាប់ជ្រើសរើសសំណាកមន្ត្រីក្រុង ស្រុក ខណ្ឌ។

វិធីសាស្ត្រជ្រើសរើសសំណាកដោយចៃដន្យនេះពុំត្រូវបានអនុវត្តចំពោះការជ្រើសរើសសំណាកសមាជិកគណៈអភិបាល (រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ) និងថ្នាក់ដឹកនាំភូមិឡើយ។ មូលហេតុទីមួយ គឺអភិបាលអាចនឹងមានការអាក់អន់ស្រពន់ចិត្ត ប្រសិនបើមិនជ្រើសរើស ហើយមូលហេតុទីពីរ ប្រសិនបើជ្រើសរើសអភិបាលទំនងជានឹងផ្ទេរភារកិច្ចឱ្យអភិបាលរងមួយរូប។ អាស្រ័យហេតុនេះ គណៈអភិបាលនីមួយៗត្រូវបានស្នើសុំឱ្យចាត់តាំងសមាជិកណា១រូបដើម្បីសម្ភាសន៍។ ដំណើរការស្រដៀងគ្នានេះ ត្រូវបានប្រើដើម្បីជ្រើសរើសថ្នាក់ដឹកនាំភូមិសម្រាប់សម្ភាសន៍។

ដោយសារចំនួនគ្រួសារក្នុងភូមិនីមួយៗ ចំនួនភូមិក្នុងឃុំ សង្កាត់នីមួយៗ ចំនួនឃុំ សង្កាត់ក្នុងក្រុង ស្រុកនីមួយៗ និងចំនួនស្រុកក្នុងខេត្តនីមួយៗមានចំនួនមិនស្មើៗគ្នា ដូច្នេះ ឱកាសសម្រាប់ការជ្រើសរើសសំណាកនីមួយៗ (probability) ត្រូវបានពិចារណាថាមានភាពខុសៗគ្នា។ ប្រការនេះ ត្រូវបានកែតម្រូវដោយការផ្តល់មេគុណសម្រាប់សំណាកនៅដំណាក់កាលវិភាគ ដែលក្នុងការអនុវត្តជាក់ស្តែងការប្រើប្រាស់មេគុណនេះបានធ្វើឱ្យមានភាពខុសគ្នាតិចតួចបំផុតចំពោះលទ្ធផលដែលទទួលបាន (សូមមើលផ្នែកទី៦)។

## ៣.១២. ការរៀបចំបញ្ជីសំណួរ

បញ្ជីសំណួរបានរៀបចំតាមដំណើរការដែលមានការចូលរួមយ៉ាងពេញលេញរវាងមន្ត្រីសំខាន់ៗនៃលេខាធិការដ្ឋាន គ.ជ.អ.ប. និងទីប្រឹក្សាអ្នកជំនាញនៃក្រុមហ៊ុន ASKL នៅក្នុងកិច្ចប្រជុំដែលបានធ្វើឡើងក្នុងខែតុលា ដល់ខែវិច្ឆិកា ឆ្នាំ២០២៤។ បញ្ជីសំណួរមួយត្រូវបានរៀបចំឡើងសម្រាប់កម្រិតថ្នាក់នៃក្រុមអ្នកផ្តល់ព័ត៌មាននីមួយៗ (ប្រជាពលរដ្ឋ ថ្នាក់ដឹកនាំភូមិ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត)។ ក្នុងន័យនេះ បញ្ជីសំណួរដូចគ្នានេះត្រូវបានប្រើប្រាស់សម្រាប់សម្ភាសន៍សមាជិកក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រីរដ្ឋបាលនៅក្រុង ស្រុក ខណ្ឌ។

បញ្ជីសំណួរបានរៀបចំឡើងដោយមានគោលបំណងសម្រាប់ការសម្ភាសន៍រយៈពេល ៤៥នាទី ដើម្បីជួយសម្រួលដល់ការបញ្ចប់ការអង្កេតប្រកបដោយប្រសិទ្ធភាពផង និងគិតគូរអំពីពេលវេលាដ៏មានតម្លៃរបស់ប្រជាពលរដ្ឋផងដែរ។ ដូច្នេះ បញ្ជីសំណួរបានរៀបចំឡើងដោយផ្តោតលើការទទួលបានព័ត៌មានសំខាន់ៗប៉ុណ្ណោះ។

បញ្ជីសំណួរនីមួយៗបានធ្វើតាមទម្រង់ស្តង់ដា និងត្រូវបានចែកជាផ្នែកដែលត្រូវនឹងសន្ទស្សន៍រងដូចខាងក្រោម៖

១. ព័ត៌មានប្រជាសាស្ត្រ (មានលក្ខណៈសង្ខេបគ្រប់គ្រាន់ ដើម្បីផ្តល់ទិន្នន័យសាមញ្ញបំផុតអំពីអ្នកផ្តល់ព័ត៌មាន)
២. សំណួរអំពីតម្លាភាព បានដាក់មុនគេព្រោះសម្រាប់ប្រជាពលរដ្ឋ ផ្នែកនេះចាប់ផ្តើមដោយការស្វែងយល់ពីការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីប្រព័ន្ធអភិបាលកិច្ចថ្នាក់ក្រោមជាតិ
៣. សំណួរពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ ឬបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
៤. សំណួរពាក់ព័ន្ធនឹងការឆ្លើយតប
៥. សំណួរពាក់ព័ន្ធនឹងគណនេយ្យភាព
៦. សំណួរអំពីការចូលរួមរបស់ប្រជាពលរដ្ឋ
៧. សំណួរអំពីអភិបាលកិច្ចផ្ទៃក្នុង (កម្រិតឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត)
៨. សំណួរអំពីសមាគមក្រុមប្រឹក្សាមូលដ្ឋាន (ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត)។

សំណួរទាំងអស់គឺជាសំណួរ "បិទ"។ ក្នុងករណីភាគច្រើន អ្នកឆ្លើយត្រូវបានផ្តល់នូវបញ្ជីចម្លើយដែលត្រូវជ្រើសរើស។ ក្នុងករណីមួយចំនួន អ្នកឆ្លើយមានសិទ្ធិឆ្លើយនូវចម្លើយណាមួយ ហើយអ្នកសួរ ឬអ្នកប្រមូលព័ត៌មាន (Enumerator) ត្រូវជ្រើសរើសយកចម្លើយដែលសមស្របបំផុតពីក្នុងបញ្ជីចម្លើយ។

សំណួរត្រូវបានបង្កើតឡើងជាភាសាខ្មែរ និងអង់គ្លេស ហើយត្រូវបានពិនិត្យយ៉ាងហ្មត់ចត់។

បញ្ជីសំណួរត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធឌីជីថលដោយប្រើកម្មវិធី Kobo Toolbox ហើយទិន្នន័យត្រូវបានផ្ទុក និងបញ្ចូលក្នុងក្នុងកម្មវិធី Excel ជារៀងរាល់ថ្ងៃ។ បន្ទាប់មកទិន្នន័យ Excel ត្រូវបានចម្លងចូលទៅក្នុងកម្មវិធីទិន្នន័យ SPSS សម្រាប់ការវិភាគ។ បញ្ជីសំណួរត្រូវបានសាកល្បងយ៉ាងម៉ត់ចត់ តាមរយៈដំណើរការជាពីរដំណាក់កាល។ នៅក្នុងដំណាក់កាលដំបូង ការធ្វើតេស្តត្រូវបានអនុវត្តក្នុងអំឡុងពេលបណ្តុះបណ្តាលនៅថ្ងៃទី២៨ ដល់ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៤។ ការកែសម្រួលបញ្ជីសំណួរឱ្យមានភាពច្បាស់លាស់បានធ្វើឡើងបន្ទាប់ពីការអនុវត្តសាកល្បងនេះ។ នៅដំណាក់កាលទីពីរ ការធ្វើតេស្តបានធ្វើឡើងក្នុងសប្តាហ៍ដំបូងនៃការចុះប្រមូលទិន្នន័យក្នុងខេត្តចំនួន៦ ដែលបានចាប់ផ្តើមដាក់ពង្រាយអ្នកប្រមូលព័ត៌មានក្នុងសប្តាហ៍ទី២នៃខែធ្នូ ឆ្នាំ២០២៤។ យោបល់ត្រឡប់សម្រាប់កែតម្រូវលើបញ្ជីសំណួរត្រូវបានប្រមូលពីអ្នកប្រមូលព័ត៌មាន និងអ្នកត្រួតពិនិត្យគុណភាពទិន្នន័យទាំង៦ក្រុម ដើម្បីធ្វើការកែតម្រូវនានានៅក្នុង Kobo Toolbox។ បញ្ជីសំណួរមាននៅឧបសម្ព័ន្ធទី៧។

### ៣.១៣. ការប្រមូលទិន្នន័យ

ក្រុមអ្នកធ្វើអង្កេត ឬក្រុមអ្នកប្រមូលទិន្នន័យ (Enumerator) មាន៦ក្រុម ដែលក្រុមនីមួយៗមានប្រធានក្រុម១រូប និងអ្នកធ្វើអង្កេតចំនួន៥រូប។ វគ្គបណ្តុះបណ្តាលក្រុមអ្នកធ្វើអង្កេតបានធ្វើឡើងនៅថ្ងៃទី២៨ និងថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៤។

ក្រុមអង្កេតនីមួយៗត្រូវបានចាត់តាំងឱ្យចុះធ្វើការអង្កេតនៅតាមរាជធានី ខេត្តចំនួន៥ ដែលមានចំនួនក្រុង ស្រុក ខណ្ឌ ចន្លោះ១៥ ទៅ១៨ អាស្រ័យលើចំនួនដែលបានយកតាមខេត្តនីមួយៗ។ ដូចដែលបានពន្យល់ខាងលើ រដ្ឋបាលឃុំ សង្កាត់ចំនួនពីរត្រូវជ្រើសរើសជាសំណាកនៅតាមក្រុង ស្រុក ខណ្ឌនីមួយៗ និងភូមិចំនួន២បានជ្រើសរើសជាសំណាក់ក្នុងឃុំ សង្កាត់នីមួយៗ ហើយប្រជាពលរដ្ឋចំនួន៥នាក់ត្រូវបានជ្រើសរើសសម្រាប់ការសម្ភាសន៍ក្នុងមួយភូមិនីមួយៗ។

ទោះយ៉ាងនេះក្តី ក៏នៅមានការប្រែប្រួលបន្តិចបន្តួចនូវចំនួនសំណាកដែលបានសម្ភាសន៍ចុងក្រោយដូចដែលបានរាយការណ៍ក្នុងតារាងស្តីពីចំនួនសំណាកខាងលើ។ ការប្រែប្រួលនេះ បណ្តាលមកពីមិនអាចធ្វើដំណើរទៅដល់ភូមិគោលដៅដោយសារមានខ្យល់ព្យុះ។ ក្នុងករណីមួយចំនួន ភូមិគោលដៅមិនទាន់មានមេភូមិ។ តារាងខាងក្រោមនេះ បង្ហាញអំពីចំនួនសំណាកដែលបានសម្ភាសន៍៖

| ប្រភេទ | គោលដៅ | | | ជាក់ស្តែង |
|---|---|---|---|---|
| | ឯកតា | សំណាក /ឯកតា | សំណាកសរុប | |
| រាជធានី ខេត្ត | ២៥ | ២ | ៥០ | ៥០ |
| គណៈអភិបាលរាជធានី ខេត្ត | ២៥ | ១ | ២៥ | ២៥ |
| ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ | ៩៦ | ៤ | ៣៨៤ | ៣៨៥ |
| គណៈអភិបាលកក្រុង ស្រុក ខណ្ឌ | ៩៦ | ១ | ៩៦ | ៩៧ |
| មន្ត្រីក្រុង ស្រុក ខណ្ឌ | ៩៦ | ៣ | ២៨៨ | ២៨៥ |
| ក្រុមប្រឹក្សាឃុំ សង្កាត់ | ១៩២ | ៤ | ៧៦៨ | ៧៦៤ |
| មេភូមិ | ៣៨៤ | ១ | ៣៨៤ | ៣៨៤ |
| ប្រជាពលរដ្ឋ | ៣៨៤ | ៥ | ១.៩២០ | ១.៩១៨ |
| **សរុប** | | | **៣.៩១៥** | **៣.៩០៨** |

ការជ្រើសរើសអ្នកផ្តល់ព័ត៌មានដែលជាក្រុមប្រឹក្សា និងមន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានជូនដំណឹង ដោយមានការពិគ្រោះជាមួយមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិសាមីនីមួយៗ។ ការអនុវត្តតាមវិធីសាស្ត្រនេះ នាំឱ្យមានសមាមាត្រអ្នកផ្តល់ព័ត៌មាននៅក្នុងមុខតំណែងជាន់ខ្ពស់ (ឧ. ប្រធានក្រុមប្រឹក្សា នាយករដ្ឋបាល) ច្រើនជាងការរំពឹងទុកពីការជ្រើសរើសដោយចៃដន្យ។

ការប្រមូលទិន្នន័យ គឺត្រូវបានអនុវត្តតាមឧបករណ៍Tablets ដោយប្រើកម្មវិធី Kobo Toolbox។ ទិន្នន័យត្រូវបានបញ្ចូលភ្លាមៗនៅពេលសម្ភាសន៍តែម្តង ហើយត្រូវបានពិនិត្យ សម្អាត និងបូកសរុបជារៀងរាល់ថ្ងៃ។

**ការធានាគុណភាពទិន្នន័យ** ដើម្បីធានាគុណភាពទិន្នន័យ ក្នុងអំឡុងពេលនៃការចុះធ្វើអង្កេតនេះ រួមមានយន្តការមួយចំនួនដូចខាងក្រោម៖

- ក្រុម Telegram មួយដែលមានឈ្មោះថា "NP-GOV Survey-២០២៤_Enumerators" រួមទាំងក្រុមរងចំនួន៦នៃអ្នកធ្វើអង្កេតត្រូវបានបង្កើតឡើងសម្រាប់ការទំនាក់ទំនង ការត្រួតពិនិត្យ និងការគាំទ្រផ្នែកបច្ចេកទេសលើការប្រមូលទិន្នន័យជាប្រចាំ
- ក្រុម Telegram មួយដែលមានឈ្មោះថា "NP-GOV Survey Team Leader" ត្រូវបានបង្កើតឡើង ដើម្បីទំនាក់ទំនងរវាងប្រធានក្រុមអ្នកធ្វើអង្កេតទាំង៦រូបជាមួយទីប្រឹក្សាជំនាញសំខាន់ៗរបស់ក្រុមហ៊ុន ASKL។ ការប្រាស្រ័យទាក់ទងគ្នានេះ មានសារៈប្រយោជន៍ខ្លាំងណាស់ក្នុងការដោះស្រាយរាល់បញ្ហាប្រឈមនានាក្នុងការចុះធ្វើអង្កេត និងដោះស្រាយបញ្ហាប្រឈមនានាឱ្យបានទាន់ពេលវេលា
- ក្រុមអ្នកធ្វើអង្កេតនីមួយៗបានរាយការណ៍ពីលទ្ធផលនៃការងាររបស់ខ្លួននៅក្នុងក្រុម Telegram ជារៀងរាល់ថ្ងៃ ដើម្បីពិនិត្យ និងផ្តល់យោបល់

- ប្រធានក្រុមអ្នកអង្កេតបានត្រួតពិនិត្យ និងគាំទ្រផ្នែកបច្ចេកទេសជាប្រចាំក្នុងអំឡុងពេលនៃការចុះអង្កេត
- ទីប្រឹក្សារបស់ក្រុមហ៊ុន ASKL និងទីប្រឹក្សានៃលេខាធិការដ្ឋាន គ.ជ.អ.ប. បានផ្តល់ការគាំទ្រ និងផ្តល់ដំណោះស្រាយជាប្រចាំលើបញ្ហានានាពាក់ព័ន្ធនឹងផ្លាស់ប្តូរពេលវេលា ការផ្លាស់ប្តូរទីតាំងសម្ភាសន៍ដោយសារឧបសគ្គដែលមិនអាចចូលទៅដល់ ការផ្លាស់ប្តូរអ្នកផ្តល់ព័ត៌មាន និងរកអ្នកផ្តល់ព័ត៌មានជំនួស ដោយសារហេតុផលចាំបាច់មួយចំនួនដូចជាអ្នកផ្តល់ព័ត៌មានមានជំងឺមិនអាចជួបសម្ភាសន៍បាន និងការបកស្រាយបំភ្លឺភ្លាមៗចំពោះតម្រូវការនានាដែលបានលើកឡើងដោយក្រុមអ្នកអង្កេត
- ការចុះពិនិត្យដោយទីប្រឹក្សា ឬក្រុមត្រួតពិនិត្យគុណភាពទិន្នន័យ ដើម្បីពិនិត្យស្ថានភាពវឌ្ឍនភាព និងតាមដានគុណភាពនៃដំណើរការចុះអង្កេត។

ការប្រមូលទិន្នន័យបានចាប់ផ្តើមនៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៤ ហើយត្រូវបានបញ្ចប់ត្រឹមថ្ងៃទី៣ ខែមករា ឆ្នាំ២០២៥ ដោយប្រើប្រាស់រយៈពេល២៧ថ្ងៃ។ ក្នុងអំឡុងពេលចុះសម្ភាសន៍ប្រមូលទិន្នន័យ មន្ត្រី និងទីប្រឹក្សាសំខាន់ៗរបស់លេខាធិការដ្ឋាននៃ គ.ជ.អ.ប. ក៏បានជួយសម្របសម្រួលជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅ ដូចជាការរៀបចំកាលវិភាគសម្រាប់ការចុះធ្វើអង្កេត លិខិតជូនដំណឹងអំពីការធ្វើអង្កេត និងការសម្របសម្រួលដោះស្រាយបញ្ហាបន្ទាន់នានា។

### ៣.១៤. ការសម្អាត និងការវិភាគទិន្នន័យ

ទិន្នន័យដែលប្រមូលបានពីការចុះអង្កេតត្រូវបានផ្ទេរទៅក្នុងកម្មវិធី SPSS ដើម្បីសម្អាតទិន្នន័យ លុបបំបាត់នូវភាពមិនប្រក្រតី (error) និងសម្រាប់ការវិភាគ។

ការវិភាគរួមបញ្ចូលទាំងការគណនា និងការកំណត់ចន្លោះទំនុកចិត្ត (Confidence intervals) សម្រាប់ពិន្ទុនៃទិន្នន័យទាំងអស់និងសូចនាករដែលបានគណនាដោយផ្អែកលើវិធីសាស្ត្រស្ថិតិស្តង់ដា។

ជាលទ្ធផលនៃការវិភាគ គឺការគណនាបាននូវតម្លៃនៃសូចនាករ និងតម្លៃនៃសន្ទស្សន៍ផ្នែកអភិបាលកិច្ច និងសន្ទស្សន៍ផ្នែកសេវា ដែលត្រូវបានបែងចែកតាមតំបន់ភូមិសាស្ត្រ តាមប្រភេទអ្នកឆ្លើយតប និងតាមភេទ។

ការវិភាគទិន្នន័យត្រូវបានធ្វើឡើងតាមជំហានបន្តបន្ទាប់ ដូចខាងក្រោម៖

១. ការដោះស្រាយលេខកូដដែលមិនឆ្លើយតប។ សម្រាប់សំណួរភាគច្រើន គ្មានការឆ្លើយតបណាត្រូវបានកត់ត្រាទុកថាគ្មានតម្លៃទេ មានន័យថា វាមិនត្រូវបានគិតគូរក្នុងការគណនាតម្លៃមធ្យម។ សម្រាប់សំណួរមួយចំនួន ការគ្មានការឆ្លើយតបត្រូវបានចាត់ទុកថាស្មើនឹងការឆ្លើយតបជាអវិជ្ជមាន។ បញ្ហានេះត្រូវបានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធទី២។

២. ការបំលែងចម្លើយទាំងអស់ឱ្យមានតម្លៃចន្លោះពី 0 ដល់ ១។

៣. ការផ្តល់មេគុណដើម្បីគណនាពិន្ទុ ឬតម្លៃនៃចម្លើយតាមសំណួរនីមួយៗ។

៤. ការប្រើមេគុណ/ទម្ងន់សម្រាប់សំណួរ និងសម្រាប់សំណាក ដើម្បីគណនាតម្លៃ/ពិន្ទុជាមធ្យម (តម្លៃ/ពិន្ទុជាមធ្យម គឺជាផលបូកនៃ (ទម្ងន់សំណាក x តម្លៃដែលបានបំលែង x ទម្ងន់សំណួរ) ចែកនឹងផលបូកនៃ (ទម្ងន់សំណាក x ទម្ងន់សំណួរ) របស់ចម្លើយអ្នកឆ្លើយសំណួរទាំងអស់ ឬរបស់ក្រុមអ្នកឆ្លើយតបតាមប្រភេទផ្សេងៗគ្នាទាំងអស់)។

បន្ទាប់មកគឺការគណនាពិន្ទុ ឬតម្លៃនៃសូចនាករ តម្លៃសន្ទស្សន៍រង និងតម្លៃសន្ទស្សន៍ដោយប្រើមេគុណ ដូចខាងក្រោម៖

៥. ការប្រើមេគុណ ដើម្បីគណនាតម្លៃសូចនាករ

៦. ការប្រើតម្លៃសូចនាករ និងមេគុណ ដើម្បីគណនាតម្លៃសន្ទស្សន៍រង

៧. ការប្រើតម្លៃសន្ទស្សន៍រង និងមេគុណដើម្បីគណនាតម្លៃសន្ទស្សន៍។

### ៣.១៥. ការគណនាកំហុសស្តង់ដា និងចន្លោះទំនុកចិត្ត

ចន្លោះទំនុកចិត្តសម្រាប់ពិន្ទុសំណួរ ត្រូវបានកំណត់ដោយការគណនាតម្លៃកំហុសស្តង់ដាសម្រាប់ការឆ្លើយតបត្រឹមត្រូវទាំងអស់នៃសំណួរនីមួយៗ ដោយប្រើការសន្មត់ស្តង់ដានៃរបាយធម្មតា (របាយ ប្រូបាប៊ីលីតេ)។ បន្ទាប់មក ចន្លោះទំនុកចិត្ត ៩៥% ត្រូវបានគណនាជាកំហុសស្តង់ដានៅតម្លៃ ១.៩៦ខាងលើ ឬខាងក្រោមតម្លៃដែលត្រូវវាស់វែង។ វិធីសាស្រ្តនេះ ត្រូវបានប្រើប្រាស់ដើម្បីគណនា និងរាយការណ៍កំហុសស្តង់ដាសម្រាប់ពិន្ទុនៃសំណួរទាំងអស់ និងសម្រាប់ពិន្ទុសូចនាករ (ឧទាហរណ៍ តម្លៃសូចនាករមួយត្រូវបានគណនាសម្រាប់អ្នកឆ្លើយសំណួរនីមួយៗ ហើយតម្លៃដែលបានរាយការណ៍ គឺជាកំហុសស្តង់ដានៃតម្លៃទាំងនេះ)។ សម្រាប់សូចនាករត្រូវបានគណនាដោយការបូកបញ្ចូលទិន្នន័យពីក្រុមសំណាកនៃរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន៤ក្រុម (ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត) តម្លៃមធ្យមជាតម្លៃដែលត្រូវបានរាយការណ៍។

ការគណនាចន្លោះទំនុកចិត្តសម្រាប់សន្ទស្សន៍រង និងតម្លៃសន្ទស្សន៍ គឺមានការលំបាកជាងដោយសារសន្ទស្សន៍ត្រូវបានគណនាដោយការបូកបញ្ចូលទិន្នន័យពីក្រុមសំណាកជាច្រើន។ ដើម្បីដោះស្រាយបញ្ហានេះ និងដើម្បីផ្តល់នូវតម្លៃប្រហាក់ប្រហែលនៃចន្លោះទំនុកចិត្តសម្រាប់សន្ទស្សន៍រង និងសន្ទស្សន៍ នីតិវិធីធ្វើសំណាករបស់ Monte Carlo ត្រូវបានប្រើប្រាស់។ ក្នុងសំណុំសំណាករងចំនួន ១០០ ដែលសំណាកនីមួយៗមាន ៤០ ក្រុង ស្រុក ខណ្ឌ (រួមបញ្ចូលក្រុមប្រឹក្សាឃុំ សង្កាត់ ភូមិ និងប្រជាពលរដ្ឋនៅក្នុងក្រុង ស្រុក ខណ្ឌទាំងនោះ) និង រាជធានី ខេត្តចំនួន ១០ ត្រូវបានកំណត់ចេញពីសំណាកទាំងមូល។ សំណាករងនានាត្រូវបានកំណត់តាមរយៈការជំនួស ដូច្នេះ ក្រុង ស្រុក ខណ្ឌ ឬរាជធានី ខេត្តមួយ អាចត្រូវបានបញ្ចូលក្នុងសំណាកចំនួនមួយម្តង ឬច្រើនដង។ សន្ទស្សន៍រង និងតម្លៃសន្ទស្សន៍ត្រូវបានគណនាសម្រាប់សំណាករងនីមួយៗ។ នីតិវិធីនេះ ត្រូវបានធ្វើម្តងទៀតជាមួយនឹងសំណាករងចំនួន

១០០ ដែលត្រូវបានកំណត់ចេញពីសំណាកចម្បងតាមមធ្យោបាយដូចគ្នា។ បន្ទាប់មក គម្លាតស្តង់ដានៃសំណុំតម្លៃសន្ទស្សន៍ ត្រូវបានយកជាកំហុសស្តង់ដាប៉ាន់ស្មានសម្រាប់សំណាកទាំងមូល។ ការប៉ាន់ស្មាននេះ ជាតម្លៃប្រហាក់ប្រហែល ប៉ុន្តែជាការប៉ាន់ស្មានមានលក្ខណៈសមហេតុផលនៃបំរែបំរួលដែលបានរំពឹងទុកនៃសន្ទស្សន៍ និងតម្លៃសន្ទស្សន៍រង ដែលកើតឡើងដោយសារកំហុសក្នុងការកំណត់សំណាក។ វិធីសាស្ត្រនេះ គឺមានលក្ខណៈអភិរក្សបន្តិច ដោយសារផ្អែកលើសំណាករងចំនួន ៥០% ដែលមានទំហំធំដូចសំណាកពិត។ ទោះជាយ៉ាងណាក៏ដោយ ពុំមានភាពចាំបាច់ក្នុងការអនុវត្តនីតិវិធីនេះម្តងទៀតទេ នៅពេលអនុវត្តការអង្កេតដំណាក់កាលបន្ទាប់ ពោលគឺតម្លៃដែលបានរាយការណ៍គួរប្រើប្រាស់ ដើម្បីវាយតម្លៃអំពីការប្រែប្រួលតាមលក្ខណៈស្ថិតិ ធៀបនឹងទិន្នន័យដើមគ្រា។

## ៤. លក្ខណៈនៃសំណាក

### ៤.១. សំណាកប្រជាពលរដ្ឋ

អ្នកផ្តល់ព័ត៌មានជាប្រជាពលរដ្ឋត្រូវបានសួរសំណួរមួយចំនួនទាក់ទងនឹងព័ត៌មានផ្ទាល់ខ្លួន និងស្ថានភាពគ្រួសារ ដោយផ្តោតលើព័ត៌មានដែលពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងការអង្កេត។ ទិន្នន័យប្រជាសាស្ត្រសង្ខេបរបស់អ្នកផ្តល់ព័ត៌មានជាប្រជាពលរដ្ឋចំនួន **១.៩១៨នាក់**មានបង្ហាញក្នុងតារាងខាងក្រោម៖

| ក្រុមសំណាកគំរូ | សរុប | ភេទ | | អាយុជាមធ្យម | អត្តសញ្ញាណក្រីក្រ | ជនជាតិដើមភាគតិច | សមាជិកដែលមានពិការភាព |
|---|---|---|---|---|---|---|---|
| | | ស្ត្រី | ប្រុស | | | | |
| សំណាកទាំងមូល | ១.៩១៨ | ៥២% | ៤៨% | ៤៨ | ១៩% | ៨% | ១១% |
| តំបន់ទីប្រជុំជន | ៦៤៦ | ៥២% | ៤៨% | ៥១ | ១៩% | ៤% | ១២% |
| តំបន់ជនបទ | ១.២៧២ | ៥២% | ៤៨% | ៤៦ | ១៩% | ១០% | ១១% |
| រាជធានីភ្នំពេញ | ១២០ | ៥៥% | ៤៥% | ៥៥ | ២៣% | ១% | ៧% |
| ខេត្តនៅតំបន់ទំនាប | ៥២២ | ៥៤% | ៤៦% | ៥១ | ១៥% | ១% | ១៤% |
| ខេត្តនៅតំបន់ទន្លេសាប | ៤៦១ | ៤៩% | ៥១% | ៤៤ | ២៣% | ១% | ១០% |
| ខេត្តនៅតំបន់ខ្ពង់រាប | ៦០០ | ៥៤% | ៤៦% | ៤៦ | ១៨% | ២១% | ១២% |
| ខេត្តនៅតំបន់មាត់សមុទ្រ | ២១៥ | ៥០% | ៥០% | ៥០ | ២២% | ៨% | ៧% |

អ្នកផ្តល់ព័ត៌មានដែលត្រូវបានសម្ភាសន៍ភាគច្រើន គឺអ្នកដែលមានអាយុច្រើនក្នុងគ្រួសារ និងមានចំនួនស្ត្រីច្រើនជាងចំនួនបុរសបន្តិច។ ជារួម ១៩% នៃគ្រួសារដែលបានសម្ភាសន៍ គឺជាគ្រួសារកាន់ប័ណ្ណក្រីក្រ។ គ្រួសារទាំងនោះក៏ត្រូវបានសួរពីទ្រព្យសម្បត្តិរបស់ពួកគាត់ធៀបទៅនឹងអ្នកផ្សេងទៀតនៅក្នុងសហគមន៍ផងដែរ។ ផ្អែកលើការអង្កេតនេះ ២៥% នៃគ្រួសារបានចាត់ទុកគ្រួសាររបស់ខ្លួនជាគ្រួសារដែលមានភាពក្រីក្រជាងគ្រួសារភាគច្រើននៅក្នុងសហគមន៍ (ទោះបីជាមិនមែនគ្រួសារដែលមានប័ណ្ណក្រីក្រទាំងអស់ចាត់ទុកខ្លួនឯងនៅក្នុងប្រភេទនេះក៏ដោយ)។ ៨% នៃអ្នកផ្តល់ព័ត៌មានបានបង្ហាញថាពួកគាត់ជាសមាជិកនៃក្រុមជនជាតិដើមភាគតិច ដែលតួលេខនេះខ្ពស់ជាងភាគរយជនជាតិដើមភាគតិច

នៅក្នុងចំនួនប្រជាជនសរុប ហើយចំណុចនេះប្រហែលជាឆ្លុះបញ្ចាំងពីប្រូបាប៊ីលីតេនៃសំណាកខ្ពស់នៅក្នុងតំបន់ដែលមានដង់ស៊ីតេប្រជាជនទាប។ ១១% នៃគ្រួសារមានសមាជិកដែលមានពិការភាព។

អ្នកផ្តល់ព័ត៌មានត្រូវបានស្នើសុំឱ្យកំណត់អំពីប្រភពចំណូលសំខាន់បំផុតសម្រាប់គ្រួសាររបស់ពួកគាត់។ សេចក្តីសង្ខេបនៃចម្លើយ មានបង្ហាញក្នុងតារាងតាមក្រោម៖

*តារាង៖ ប្រាក់ចំណូលគ្រួសារសំខាន់បំផុតរបស់សំណាកគំរូប្រជាពលរដ្ឋ*

| ក្រុមសំណាកគំរូ | ប្រភពចំណូលគ្រួសារសំខាន់បំផុត | | | | |
|---|---|---|---|---|---|
| | កសិកម្ម នេសាទ | អាជីវកម្មឯកជន | វិស័យឯកជន | ប្រាក់ខែរដ្ឋ | ផ្សេងៗ |
| សំណាកទាំងមូល | ៤៨% | ២៥% | ១២% | ៧% | ៨% |
| តំបន់ទីប្រជុំជន | ២២% | ៤០% | ១៧% | ១១% | ១០% |
| តំបន់ជនបទ | ៦១% | ១៧% | ១០% | ៥% | ៧% |
| រាជធានីភ្នំពេញ | ០% | ៥៣% | ២៣% | ១១% | ១៣% |
| ខេត្តនៅតំបន់ទំនាប | ៤៩% | ២៤% | ១១% | ៧% | ៩% |
| ខេត្តនៅតំបន់ទន្លេសាប | ៤៩% | ២៥% | ១៥% | ៥% | ៦% |
| ខេត្តនៅតំបន់ខ្ពង់រាប | ៦០% | ១៧% | ១០% | ៧% | ៦% |
| ខេត្តនៅតំបន់មាត់សមុទ្រ | ៣៨% | ៣៤% | ១១% | ៤% | ១៣% |

ជារួម ៤៨%នៃអ្នកផ្តល់ព័ត៌មានបានបញ្ជាក់ថា ប្រាក់ចំណូលគ្រួសារសំខាន់បំផុតរបស់ពួកគាត់បានមកពីការធ្វើកសិកម្ម ឬសកម្មភាពទាក់ទងនឹងធនធានធម្មជាតិ ដូចជាការនេសាទជាដើម។ ពាក់ព័ន្ធនឹងចំណុចនេះ ត្រូវមានការប្រុងប្រយ័ត្នក្នុងការបកស្រាយនូវរបកគំហើញទាំងនេះ ដោយសារការអង្កេតលម្អិតនៃគ្រួសារជាកសិករខ្នាតតូចមានទំនោរបង្ហាញថា គ្រួសារទាំងនេះពិតជាទទួលបានប្រាក់ចំណូលច្រើនជាងពីសកម្មភាពក្រៅពីការធ្វើកសិកម្ម។ ប្រភពចំណូលសំខាន់ទីពីរ គឺសកម្មភាពអាជីវកម្មឯកជនដែលមាន២៥% នៃសំណាក និង៥៣%នៃសំណាកនៅភ្នំពេញ បានឆ្លើយថាសកម្មភាពអាជីវកម្មឯកជននេះជាប្រភពចំណូលសំខាន់បំផុត។ មានតែ១២%នៃសំណាកប៉ុណ្ណោះដែលបានចាត់ទុកថា ការងារក្នុងវិស័យឯកជនជាប្រភពចំណូលសំខាន់បំផុត ទោះបីជាការប្រៀបធៀបជាមួយនឹងការអង្កេតផ្សេងទៀត និងជាមួយនឹងស្ថិតិសេដ្ឋកិច្ចកម្ពុជាបង្ហាញថា ភាគរយនេះអាចជាការប៉ាន់ស្មានទាបក៏ដោយ។

## ៤.២. ថ្នាក់ដឹកនាំភូមិ

*តារាងទី១០៖ សំណាកថ្នាក់ដឹកនាំភូមិផ្លូវការ*

| ក្រុមសំណាក | សរុប | ស្ត្រី | បុរស | អាយុជាមធ្យម | តួនាទីជាថ្នាក់ដឹកនាំ | | | សមាជិក ឃ.ក.ន.ក. |
|---|---|---|---|---|---|---|---|---|
| | | | | | មេភូមិ | អនុភូមិ | មន្ត្រីភូមិ | |
| សំណាកទាំងមូល | ៣៨៤ | ២០% | ៨០% | ៥៩ | ៧៨% | ១៦% | ៥% | ៣២% |
| តំបន់ទីប្រជុំជន | ១៣០ | ២៦% | ៧៤% | ៦១ | ៨១% | ១៤% | ៥% | ៣៩% |
| តំបន់ជនបទ | ២៥៤ | ១៧% | ៨៣% | ៥៩ | ៧៧% | ១៧% | ៦% | ២៩% |
| រាជធានីភ្នំពេញ | ២៤ | ២១% | ៧៩% | ៦០ | ៩២% | ៤% | ៤% | ៤២% |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ខេត្តនៅតំបន់ទំនាប | ១០៤ | ១៣% | ៨៧% | ៦៣ | ៨៦% | ១៣% | ២% | ២០% |
| ខេត្តនៅតំបន់ទន្លេសាប | ៩២ | ១៧% | ៨៣% | ៥៩ | ៧៦% | ២០% | ៤% | ៣៥% |
| ខេត្តនៅតំបន់ខ្ពង់រាប | ១២០ | ៣០% | ៧០% | ៥៦ | ៧១% | ១៨% | ១១% | ៣៣% |
| ខេត្តនៅតំបន់មាត់សមុទ្រ | ៤៤ | ១១% | ៨៩% | ៦១ | ៨០% | ១៨% | ២% | ៤៨% |

ក្នុងចំណោមថ្នាក់ដឹកនាំភូមិចំនួន ៣៨៤ នាក់ដែលបានសម្ភាសន៍ មាន ៧៨% ជាមេភូមិ ១៦% ជាអនុប្រធានភូមិ និង ៥% ជាមន្ត្រីភូមិ។ ២០% ជាស្ត្រី។ ៣២% នៃអ្នកផ្តល់ព័ត៌មានជាសមាជិកនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ។ អាយុជាមធ្យមរបស់ថ្នាក់ដឹកនាំភូមិ គឺប្រហាក់ប្រហែលនឹងអ្នកផ្តល់ព័ត៌មានជាប្រជាពលរដ្ឋ។ ៥%នៃគ្រួសារថ្នាក់ដឹកនាំភូមិបានចុះបញ្ជីជាអ្នកក្រីក្រ។ ៩% គឺជាជនជាតិដើមភាគតិច ដែលភាគរយនេះកើនឡើងដល់ ២៥% នៅក្នុងខេត្តតំបន់ខ្ពង់រាប ដែលជាសមាមាត្រខ្ពស់ជាងនៅក្នុងសំណាកប្រជាពលរដ្ឋ។ ១១% នៃថ្នាក់ដឹកនាំភូមិមានសមាជិកគ្រួសារដែលមានពិការភាព។

*តារាង៖ ប្រាក់ចំណូលគ្រួសារសំខាន់បំផុតនៃសំណាកថ្នាក់ដឹកនាំភូមិ*

| ក្រុមសំណាក | ប្រភពចំណូលគ្រួសារសំខាន់បំផុត។ | | | | |
|---|---|---|---|---|---|
| | កសិកម្ម នេសាទ | អាជីវកម្មឯកជន | វិស័យឯកជន | ប្រាក់ខែរដ្ឋ | ផ្សេងៗ |
| សំណាកទាំងមូល | ៥៣% | ១១% | ៤% | ៣០% | ២% |
| តំបន់ទីប្រជុំជន | ២៩% | ២២% | ៦% | ៤០% | ២% |
| តំបន់ជនបទ | ៦៥% | ៦% | ៣% | ២៦% | ១% |
| រាជធានីភ្នំពេញ | 0% | ២៥% | ១៣% | ៥៨% | ៤% |
| ខេត្តនៅតំបន់ទំនាប | ២៩% | ៥% | ៣% | ៦២% | ២% |
| ខេត្តនៅតំបន់ទន្លេសាប | ៦៤% | ១៥% | ៥% | ១៤% | ១% |
| ខេត្តនៅតំបន់ខ្ពង់រាប | ៧៨% | ៨% | ២% | ១២% | ២% |
| ខេត្តនៅតំបន់មាត់សមុទ្រ | ៤៥% | ២៣% | ៥% | ២៧% | 0% |

ចំនួននៃថ្នាក់ដឹកនាំភូមិដែលបានកំណត់ថា ការធ្វើកសិកម្ម ឬធនធានធម្មជាតិជាប្រាក់ចំណូលគ្រួសារចម្បងរបស់ពួកគាត់ គឺមានលក្ខណៈស្រដៀងគ្នាទៅនឹងចំនួននៅក្នុងសំណាកប្រជាពលរដ្ឋ។ អាជីវកម្មឯកជន និងការងារវិស័យឯកជនមិនសូវសំខាន់ទេ ខណៈដែល ៣០% និងប្រហែល ៦០% នៅភ្នំពេញ និងខេត្តតំបន់ទំនាបបានចាត់ទុកប្រាក់ខែរបស់រាជរដ្ឋាភិបាលជាប្រភពចំណូលគ្រួសារសំខាន់បំផុតរបស់ពួកគាត់។

## ៤.៣. សមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់

អ្នកផ្តល់ព័ត៌មានជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មានចំនួន ៧៦៤ នាក់ និងត្រូវបានសង្ខេបនៅក្នុងតារាងខាងក្រោម។ តិចជាងមួយភាគបីនៃអ្នកផ្តល់ព័ត៌មានជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាស្ត្រី (នៅក្នុងរាជធានីភ្នំពេញ ចំនួននេះខ្ពស់គួរឱ្យកត់សម្គាល់) ជាមួយនឹងអាយុជាមធ្យមគឺ ៥៤ ឆ្នាំ។ ២១% នៃសំណាកមានតំណែងជាមេឃុំ ចៅសង្កាត់ ឬប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ និង ២៦% ទៀតជាជំទប់

ឬចៅរងឃុំ សង្កាត់។ ២០% នៃអ្នកផ្តល់ព័ត៌មានមានតំណែងជាប្រធាន គ.ក.ន.ក. ហើយ ៣២% ទៀតជាសមាជិក គ.ក.ន.ក.។

*តារាង៖ លក្ខណៈសំណាក់គំរូជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់*

| ក្រុមសំណាកគំរូ | សរុប | ស្ត្រី | ប្រុស | អាយុជាមធ្យម | តំណែងនៅក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ | | | គ.ក.ន.ក | |
|---|---|---|---|---|---|---|---|---|---|
| | | | | | ប្រធាន | អនុប្រធាន | សមាជិក | ប្រធាន | សមាជិក |
| សំណាកទាំងមូល | ៧៦៤ | ៣២% | ៦៨% | ៥៤,២៣ | ២១% | ២៦% | ៥៣% | ២០% | ៣២% |
| តំបន់ទីប្រជុំជន | ២៦២ | ៣៤% | ៦៦% | ៥៤,៦៦ | ២០% | ២៣% | ៥៦% | ១៩% | ៣៣% |
| តំបន់ជនបទ | ៥០២ | ៣១% | ៦៩% | ៥៤,០១ | ២២% | ២៧% | ៥១% | ២០% | ៣២% |
| រាជធានីភ្នំពេញ | ៤៨ | ៤០% | ៦០% | ៥៦,១៩ | ២១% | ១៩% | ៦០% | ២៣% | ៣៣% |
| ខេត្តនៅតំបន់ទំនាប | ២០៨ | ៣១% | ៦៩% | ៥៦,១៤ | ២៤% | ២០% | ៥៧% | ២១% | ៣៣% |
| ខេត្តនៅតំបន់ទន្លេសាប | ១៨២ | ២៦% | ៧៤% | ៥៣,៨១ | ១៧% | ២៦% | ៥៧% | ១៦% | ៣២% |
| ខេត្តនៅតំបន់ខ្ពង់រាប | ២៤០ | ៣០% | ៧០% | ៥២,០២ | ២៣% | ៣០% | ៤៧% | ២១% | ៣១% |
| ខេត្តនៅតំបន់មាត់សមុទ្រ | ៨៦ | ៣៥% | ៦៥% | ៥៥,៦០ | ១៩% | ៣១% | ៥០% | ១៩% | ៣៦% |

## ៤.៤. សំណាកស្រុក ក្រុង ខណ្ឌ

សំណាកក្រុង ស្រុក ខណ្ឌ មានបីប្រភេទគឺ សំណាកដែលជាគណៈអភិបាលក្រុង ស្រុក ខណ្ឌ ចំនួន ៩៧នាក់ សំណាកដែលសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មានចំនួន ៣៨៥នាក់ និងមន្ត្រីផ្តល់សេវានៅក្នុងរដ្ឋបាលក្រុង ស្រុក ខណ្ឌ មានចំនួន ២៨៥នាក់។

ក្នុងចំណោមសំណាកគណៈអភិបាលក្រុង ស្រុក ខណ្ឌ មាន ២០% ជាស្ត្រី ដែលអាយុជាមធ្យមគឺ៤៦ឆ្នាំ។ ២៥% នៃអ្នកផ្តល់ព័ត៌មានកាន់តំណែងអភិបាល និង៧៥%ជាអភិបាលរង។ អ្នកផ្តល់ព័ត៌មានចំនួន៣នាក់ (៣%) ក៏បានកាន់តំណែងជាប្រធាន គ.ក.ស.ក. ផងដែរ ចំណែក ១១% គឺជាសមាជិក គ.ក.ស.ក.។

*តារាង៖សំណាកគណៈអភិបាលរបស់ក្រុង ស្រុក ខណ្ឌ*

| ក្រុមសំណាក | សរុប | ភេទ | | អាយុ | មុខតំណែង | | សមាជិក គ.ក.ស.ក. | |
|---|---|---|---|---|---|---|---|---|
| | | ស្ត្រី | ប្រុស | ជាមធ្យម | អភិបាល | អភិបាលរង | ប្រធាន | សមាជិក |
| សំណាកទាំងមូល | ៣២៦ | ២០% | ៨០% | ៤៦ | ២៥% | ៧៥% | ៣% | ១១% |
| តំបន់ទីប្រជុំជន | ១០៩ | ២៥% | ៧៥% | ៤៤ | ២៥% | ៧៥% | ៣% | ១៦% |
| តំបន់ជនបទ | ២១៧ | ១៧% | ៨៣% | ៤៧ | ២៥% | ៧៥% | ៣% | ៩% |
| រាជធានីភ្នំពេញ | ២០ | ៣៣% | ៦៧% | ៤៩ | 0% | ១០០% | 0% | ៣៣% |
| ខេត្តនៅតំបន់ទំនាប | ៩២ | ៣៥% | ៦៥% | ៤៥ | ១៥% | ៨៥% | ១២% | ១៥% |
| ខេត្តនៅតំបន់ទន្លេសាប | ៧៤ | ៨% | ៩២% | ៤៦ | ២៩% | ៧១% | 0% | ៨% |
| ខេត្តនៅតំបន់ខ្ពង់រាប | ១០៤ | ១៧% | ៨៣% | ៤៦ | ៣០% | ៧០% | 0% | ១០% |
| ខេត្តនៅតំបន់មាត់សមុទ្រ | ៣៦ | ៩% | ៩១% | ៤៦ | ៣៦% | ៦៤% | 0% | 0% |

តារាងខាងក្រោមបង្ហាញអំពីទិន្នន័យអ្នកផ្តល់ព័ត៌មានជាសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ។ ក្នុងចំណោមអ្នកផ្តល់ព័ត៌មានចំនួន៣៨៥នាក់ មាន៤៤%ជាស្ត្រី ហើយអាយុជាមធ្យមគឺ៥២ឆ្នាំ។ ១៥% អ្នកផ្តល់ព័ត៌មានមានតំណែងជាប្រធានក្រុមប្រឹក្សា និង១៥% មានតំណែងជាប្រធាន គ.ក.ស.ក. ហើយ ១៦% ទៀតជាសមាជិក គ.ក.ស.ក.។

*តារាង៖ សំណាកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ*

| ក្រុមសំណាកគំរូ | សរុប | ភេទ | | អាយុ | តំណែងក្នុងក្រុមប្រឹក្សា | | សមាជិកគ.ក.ស.ក. | |
|---|---|---|---|---|---|---|---|---|
| | | ស្ត្រី | ប្រុស | ជាមធ្យម | ប្រធាន | សមាជិក | ប្រធាន | សមាជិក |
| សំណាកទាំងមូល | ៣៨៥ | ៤៤% | ៥៦% | ៥២ | ១៥% | ៨៥% | ១៥% | ១៦% |
| តំបន់ទីប្រជុំជន | ១៣១ | ៤០% | ៦០% | ៥៣ | ១៧% | ៨៣% | ១៥% | ១១% |
| តំបន់ជនបទ | ២៥៤ | ៤៦% | ៥៤% | ៥២ | ១៥% | ៨៥% | ១៥% | ១៨% |
| រាជធានីភ្នំពេញ | ២៤ | ៤៦% | ៥៤% | ៥២ | ១៧% | ៨៣% | ២១% | ១៧% |
| ខេត្តនៅតំបន់ទំនាប | ១០៥ | ៤៦% | ៥៤% | ៥១ | ១២% | ៨៨% | ១០% | ២០% |
| ខេត្តនៅតំបន់ទន្លេសាប | ៩៣ | ៤៥% | ៥៥% | ៥៣ | ២០% | ៨០% | ១៧% | ១៣% |
| ខេត្តនៅតំបន់ខ្ពង់រាប | ១២០ | ៤៤% | ៥៦% | ៥១ | ១៣% | ៨៧% | ១៦% | ១៥% |
| ខេត្តនៅតំបន់មាត់សមុទ្រ | ៤៣ | ៤០% | ៦០% | ៥៤ | ១៦% | ៨៤% | ១៦% | ១៤% |

ក្នុងសំណាកមន្ត្រីរដ្ឋបាលក្រុង ស្រុក ខណ្ឌ ចំនួន២៨៥ នាក់ មាន៤៣% ជាស្ត្រី ដែលមានអាយុជាមធ្យម៣៩ឆ្នាំ គឺទាបជាងក្រុមសំណាកដទៃទៀត។ ជាងពាក់កណ្តាលនៃសំណាក (៥៦%) មានឋានៈជាប្រធានការិយាល័យ ១៣% ជានាយក ឬនាយយករងរដ្ឋបាល និង៣១% មានឋានៈជាអនុប្រធានការិយាល័យ ឬទាបជាងនេះ។ ភាគរយនៃមន្ត្រីដែលមានឋានៈទាបជាងអនុប្រធានការិយាល័យ ដែលបានយកជាសំណាកមានចំនួនច្រើននៅភ្នំពេញជាងនៅកន្លែងផ្សេងទៀត។ ប្រហែលជាពាក់កណ្តាលនៃសំណាកបានប្រាប់ថាថាពួកគាត់ជាសមាជិក គ.ក.ស.ក.។

*តារាង៖ សំណាកមន្ត្រីរដ្ឋបាលក្រុង ស្រុក ខណ្ឌ*

| ក្រុមសំណាកគំរូ | សរុប | ភេទ | | អាយុ | ចំណាត់ថ្នាក់ក្នុងការគ្រប់គ្រង | | | | | សមាជិក គ.ក.ស.ក. |
|---|---|---|---|---|---|---|---|---|---|---|
| | | ស្ត្រី | ប្រុស | ជាមធ្យម | នាយក រដ្ឋបាល | នាយករង រដ្ឋបាល | ប្រធាន ការិយាល័យ | អនុប្រធាន ការិយាល័យ | មន្ត្រី | |
| សំណាកទាំងមូល | ២៨៥ | ៤៣% | ៥៧% | ៣៩ | ៥% | ៨% | ៥៦% | ២១% | ១០% | ៥១% |
| តំបន់ទីប្រជុំជន | ១០០ | ៥១% | ៤៩% | ៣៩ | ៥% | ៦% | ៤៩% | ២៤% | ១៦% | ៥០% |
| តំបន់ជនបទ | ១៨៥ | ៣៩% | ៦១% | ៣៩ | ៤% | ១០% | ៥៩% | ២០% | ៦% | ៥១% |
| រាជធានីភ្នំពេញ | ១៨ | ៤៤% | ៥៦% | ៣៩ | 0% | ៦% | ៣៣% | ៣៣% | ២៨% | ៣៣% |
| ខេត្តតំបន់ទំនាប | ៧៦ | ៣៩% | ៦១% | ៣៩ | ៣% | ៧% | ៦១% | ២១% | ៩% | ៥៣% |
| ខេត្តតំបន់ខ្ពង់រាប | ៦៧ | ៥១% | ៤៩% | ៣៩ | ៦% | ៧% | ៤៦% | ២៥% | ១៥% | ៥៥% |
| ខេត្តតំបន់ទន្លេសាប | ៩០ | ៤៣% | ៥៧% | ៣៨ | ៨% | ១០% | ៦០% | ១៨% | ៤% | ៥៣% |
| ខេត្តតំបន់មាត់សមុទ្រ | ៣៤ | ៣៥% | ៦៥% | ៣៩ | 0% | ១២% | ៦៥% | ១៨% | ៦% | ៣៨% |

## ៤.៩. សំណាករាជធានី ខេត្ត

សំណាករាជធានី ខេត្ត មានពីរប្រភេទគឺ សំណាកជាគណៈអភិបាលរាជធានី ខេត្ត (អ្នកផ្តល់ព័ត៌មានចំនួន២៥ នាក់ និងសំណាកជាសមាជិកក្រុមប្រឹក្សារាជធានី ខេត្តចំនួន៤៩នាក់។

ក្នុងចំណោមសំណាកគណៈអភិបាលមានអ្នកផ្តល់ព័ត៌មានចំនួនតែពីរនាក់ (៨%) ជាស្ត្រី។ អាយុជាមធ្យមនៃសំណាកគណៈអភិបាលរាជធានី ខេត្ត គឺ ៤៨ឆ្នាំ ដោយអ្នកផ្តល់ព័ត៌មាននៅក្នុងរាជធានីភ្នំពេញ និងខេត្តតំបន់ទំនាបមានវ័យក្មេងគួរឱ្យកត់សម្គាល់។ មានតែអ្នកផ្តល់ព័ត៌មានម្នាក់គត់គឺអភិបាលរាជធានី ខេត្ត និងអ្នកផ្តល់ព័ត៌មានផ្សេងទៀតកាន់តំណែងជាអភិបាលរង លើកលែងខេត្តស្វាយរៀងមិនមានអ្នកផ្តល់ព័ត៌មានជាសមាជិកគណៈអភិបាលទេ ហើយត្រូវបានជំនួសដោយមន្ត្រីរដ្ឋបាល។ មិនមានសមាជិកនៃគណៈអភិបាលរាជធានី ខេត្ត ដែលបានសម្ភាសន៍ជា សមាជិក គ.ក.ន.ក.។

*តារាងសំណាកគណៈអភិបាលរាជធានី ខេត្ត*

| ក្រុមសំណាកគំរូ | សរុប | ភេទ | | អាយុជាមធ្យម | តំណែងក្នុងគណៈអភិបាល | |
|---|---|---|---|---|---|---|
| | | ស្ត្រី | ប្រុស | | អភិបាល | អភិបាលរង |
| សំណាកទាំងមូល | ២៥ | ៨% | ៨៨% | ៤៨ | ៤% | ៩២% |
| តំបន់ទីប្រជុំជន | ១ | 0% | ១00% | ៤២ | 0% | ១00% |
| តំបន់ជនបទ | ៦ | ១៧% | ៦៧% | ៤១ | 0% | ៨៣% |
| រាជធានីភ្នំពេញ | ៥ | 0% | ១00% | ៥១ | 0% | ១00% |
| ខេត្តតំបនើទំនាប | ៩ | ១១% | ៨៩% | ៤៨ | ១១% | ៨៩% |
| ខេត្តតំបន់ខ្ពង់រាប | ៤ | 0% | ១00% | ៥៤ | 0% | ១00% |

តារាងខាងក្រោមបង្ហាញអំពីទិន្នន័យអ្នកផ្តល់ព័ត៌មានជាសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ចំនួន ៤៩នាក់ ដែលក្នុងនោះ៤១%ជាស្ត្រី ហើយអាយុជាមធ្យមគឺ៥៩ឆ្នាំ។ អ្នកផ្តល់ព័ត៌មានចំនួន៤នាក់ (៨%) មានមុខតំណែងជាប្រធានក្រុមប្រឹក្សា១៤% មានមុខតំណែងជាប្រធាន គ.ក.ន.ក និង ១៦% ទៀតជាសមាជិក គ.ក.ន.ក។

*តារាង៖ សំណាកសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត*

| ក្រុមសំណាក | សរុប | ភេទ | | អាយុជាមធ្យម | តំណែងក្នុងក្រុមប្រឹក្សា | | សមាជិក គ.ក.ន.ក. | |
|---|---|---|---|---|---|---|---|---|
| | | ស្ត្រី | ប្រុស | | ប្រធាន | សមាជិក | ប្រធាន | សមាជិក |
| សំណាកទាំងមូល | ៤៩ | ៤១% | ៥៩% | ៥៩ | ៨% | ៩២% | ១៤% | ១៦% |
| តំបន់ទីប្រជុំជន | ២ | ៥0% | ៥0% | ៥៩ | ៥0% | ៥0% | ៥0% | 0% |
| តំបន់ជនបទ | ១២ | ៤២% | ៥៨% | ៥៣ | 0% | ១00% | ១៧% | ១៧% |
| រាជធានីភ្នំពេញ | ១0 | ៣0% | ៧0% | ៥៨ | 0% | ១00% | 0% | ២0% |
| ខេត្តតំបន់ទំនាប | ១៧ | ៤៧% | ៥៣% | ៦៣ | ១៨% | ៨២% | ១៨% | ១៨% |
| ខេត្តតំបន់ខ្ពង់រាប | ៨ | ៣៨% | ៦៣% | ៥៩ | 0% | ១00% | ១៣% | ១៣% |

## ៥. របកគំហើញនៃការអង្កេត

### ៥.១. តម្លៃនៃសន្ទស្សន៍

ដោយប្រើវិធីសាស្ត្រដែលបានពិពណ៌នានៅក្នុងផ្នែកទី៣ ការអង្កេតនេះបានគណនាឃើញតម្លៃសន្ទស្សន៍អភិបាលកិច្ចគឺ0,៦៤ និងសន្ទស្សន៍ផ្នែកសេវាគឺ0,៦៩ ដែលតម្លៃទាំងពីរនេះស្ថិតក្នុងចំណាត់ថ្នាក់ "បង្គួរ"។




**ពិន្ទុ (ចន្លោះពី0ទៅ១)**




ក្នុងចំណោមតម្លៃសន្ទស្សន៍រងដែលបានគណនា សន្ទស្សន៍រងផ្នែកការឆ្លើយតបមានតម្លៃ0,៧៤ ស្ថិតក្នុងចំណាត់ថ្នាក់ "ល្អ" ការបំពេញការងារមានតម្លៃ0,៦៧ ក្នុងចំណាត់ថ្នាក់ "បង្គួរ" តម្លាភាពមានតម្លៃ 0,៦២ក្នុងចំណាត់ថ្នាក់ "បង្គួរ" និងការចូលរួមរបស់ពលរដ្ឋមានតម្លៃ 0,៥៨ មានចំណាត់ថ្នាក់ "មធ្យម" និងតម្លៃសម្រាប់គណនេយ្យភាព (0,៥៤) ស្ថិតនៅក្នុងចំណាត់ថ្នាក់ "មធ្យម" ដែលអាចត្រូវបានចាត់ទុកថា

ជាផ្នែកដែលគួរយកចិត្តទុកដាក់ក្នុងការពង្រឹងបន្ថែម។ ចំណុចខ្លាំង និងចំណុចខ្សោយនៃសន្ទស្សន៍ និងសន្ទស្សន៍រងមានសង្ខេបក្នុងប្រអប់ខាងក្រោម៖

| ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|
| **ការឆ្លើយតប (ខ្លាំង)**<br>• ប្រជាពលរដ្ឋ និងរដ្ឋបាលថ្នាក់ក្រោមជាតិបានលើកឡើងនូវតម្រូវការជាអាទិភាពដូចគ្នា។ មានន័យថា ប្រជាពលរដ្ឋមានភាពជឿជាក់លើរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តសកម្មភាពជាអាទិភាពនានា ដើម្បីបម្រើផលប្រយោជន៍ប្រជាពលរដ្ឋ ហើយក្រុមប្រឹក្សា និងមន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិបានផ្ដល់អាទិភាពលើការអនុវត្តសកម្មភាពនានា ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ | **គណនេយ្យភាព (ខ្សោយបន្តិច)**<br>• មានទំនុកចិត្តទាបចំពោះប្រសិទ្ធភាពនៃធ្វើគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ<br>• ចំណេះដឹងរបស់ប្រជាពលរដ្ឋនៅមានកម្រិត និងបទពិសោធន៍មិនសូវល្អរដ្ឋបាលថ្នាក់ក្រោមជាតិអំពីការដោះស្រាយបណ្ដឹងតវ៉ានានារបស់ប្រជាពលរដ្ឋ។ |

វិធីសាស្ត្រដែលបានពិពណ៌នានៅក្នុងផ្នែកទី៣ខាងលើត្រូវបានប្រើប្រាស់ ដើម្បីប៉ាន់ប្រមាណកំហុសស្តង់ដា និងចន្លោះទំនុកចិត្តចំនួន ៩៥% សម្រាប់សន្ទស្សន៍ និងតម្លៃសន្ទស្សន៍រង។ ការប៉ាន់ស្មានទាំងនេះត្រូវមានបង្ហាញ នៅក្នុងតារាងខាងក្រោម៖

*តារាងសេចក្ដីសង្ខេបអំពីតម្លៃមធ្យម កំហុសស្តង់ដា និងចន្លោះទំនុកចិត្ត ៩៥% នៃសន្ទស្សន៍ និងសន្ទស្សន៍រង*

| សន្ទស្សន៍ | តម្លៃមធ្យម | ការប៉ាន់ស្មាន កំហុសស្តង់ដា | ៩៥% ចន្លោះទំនុកចិត្ត | |
|---|---|---|---|---|
| | | | តម្លៃទាបបំផុត | តម្លៃខ្ពស់បំផុត |
| **អភិបាលកិច្ច** | **០,៦៣៧** | *០,០០៣៦* | ០,៦៣០ | ០,៦៤៤ |
| **ការផ្ដល់សេវា** | **០,៦៨៥** | *០,០០៥១* | ០,៦៧៥ | ០,៦៩៥ |
| ការបំពេញការងារ | **០,៦៦៦** | *០,០០៦១* | ០,៦៥៤ | ០,៦៧៨ |
| ការឆ្លើយតប | **០,៧៤៣** | *០,០០៥៩* | ០,៧៣២ | ០,៧៥៥ |
| តម្លាភាព | **០,៦២២** | *០,០០៧៦* | ០,៦០៧ | ០,៦៣៧ |
| គណនេយ្យភាព | **០,៥៤០** | *០,០១០២* | ០,៥២០ | ០,៥៦០ |
| ការចូលរួមរបស់ប្រជាពលរដ្ឋ | **០,៥៧៥** | *០,០០៦៧* | ០,៥៦១ | ០,៥៨៨ |

ការបែងចែកលទ្ធផលតាមភេទ តំបន់ជនបទ តំបន់ទីប្រជុំជន និងតាមតំបន់ភូមិសាស្ត្រនានាបង្ហាញឱ្យឃើញពីភាពខុសគ្នាតិចតួចប៉ុណ្ណោះ។ ភាពខុសគ្នាទាំងនេះមានរៀបរាប់នៅក្នុងតារាងខាងក្រោម។ ភាពខុសគ្នាសំខាន់ជាងគេ ត្រូវបានសង្កេតឃើញថាមានតម្លៃខ្ពស់ជាងគេចំពោះសន្ទស្សន៍រងទាំងអស់នៅក្នុងរាជធានីភ្នំពេញ លើកលែងតែសន្ទស្សន៍រងនៃការចូលរួមរបស់ប្រជាពលរដ្ឋ។ តំបន់ទីប្រជុំជនទទួលបានតម្លៃខ្ពស់ជាងតំបន់ជនបទចំពោះការផ្ដល់សេវា។ តម្លៃដែលត្រូវបានវាយតម្លៃដោយស្ត្រីនិងបុរស គឺស្រដៀងគ្នា ទោះបីស្ត្រីហាក់ដូចជាបានវាយតម្លៃខ្ពស់ជាងបុរសក៏ដោយ ហើយចំពោះសន្ទស្សន៍តម្លាភាព និងគណនេយ្យភាពមានតម្លៃទាបជាងគ្នាបន្តិចបន្តួច។

*តារាងតម្លៃសន្ទស្សន៍ និងសន្ទស្សន៍រង បែងចែកតាមទីប្រជុំជនតំបន់ជនបទ ភេទ និងតាមតំបន់ភូមិសាស្ត្រនានា*

| សន្ទស្សន៍ | រដ្ឋបាលថ្នាក់ក្រោមជាតិ | ប្រភេទ ក្រុង ស្រុក ខណ្ឌ* | | អ្នកផ្តល់ព័ត៌មាន | | តំបន់ភូមិសាស្ត្រ | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | ទីប្រជុំជន | ជនបទ | ស្រី | ប្រុស | ភ្នំពេញ | ទំនាប | ទន្លេសាប | ខ្ពង់រាប | ឆ្នេរ |
| **អភិបាលកិច្ច** | **០,៦៣៧** | **០,៦៥៤** | **០,៦៣០** | **០,៦៣៨** | **០,៦៣៨** | **០,៦៧៤** | **០,៦២៧** | **០,៦៣៤** | **០,៦៣២** | **០,៦៣៥** |
| **ការផ្តល់សេវា** | **០,៦៨៥** | **០,៧១៣** | **០,៦៧៩** | **០,៦៩៥** | **០,៦៨០** | **០,៧៤០** | **០,៦៧០** | **០,៦៨៤** | **០,៦៨១** | **០,៦៦៥** |
| ការបំពេញការងារ | **០,៦៦៦** | ០,៦៩១ | ០,៦៤៨ | ០,៦៧១ | ០,៦៥៩ | ០,៧២៩ | ០,៦៥២ | ០,៦៥៩ | ០,៦៦៣ | ០,៦៤៩ |
| ការឆ្លើយតប | **០,៧៤៣** | ០,៧៧៩ | ០,៧៧១ | ០,៧៦៨ | ០,៧៤៤ | ០,៧៧០ | ០,៧២៤ | ០,៧៥៧ | ០,៧៣៤ | ០,៧១១ |
| តម្លាភាព | **០,៦២២** | ០,៦៤៥ | ០,៦០៥ | ០,៦០៧ | ០,៦៣៤ | ០,៦៨១ | ០,៦២៣ | ០,៥៨៨ | ០,៦២៤ | ០,៦៧៤ |
| គណនេយ្យភាព | **០,៥៤០** | ០,៥៤៦ | ០,៥៣៤ | ០,៥២០ | ០,៥៥៥ | ០,៥៥៦ | ០,៥២២ | ០,៥៥៧ | ០,៥២៦ | ០,៥៣៣ |
| ការចូលរួមរបស់ប្រជាជន | **០,៥៧៥** | ០,៥៥៣ | ០,៥៧៣ | ០,៥៧៥៥ | ០,៥៧២ | ០,៥៤៧ | ០,៥៨១ | ០,៥៧៨ | ០,៥៧១ | ០,៥៩០ |

** លទ្ធផលពីអ្នកផ្តល់ព័ត៌មានរាជធានី ខេត្ត បានលុបចោលពីលទ្ធផលជនបទ/ទីប្រជុំជន*

លទ្ធផលនៃការអង្កេតក៏ត្រូវបានបែងចែកតាមខេត្តដែរ ដោយមានកម្រិតនៃទំនុកចិត្តទាបដោយសារសំណាកមានទំហំតូច។ លទ្ធផលទាំងនេះត្រូវបានរៀបចំក្នុងតារាងខាងក្រោម។ ដូចគ្នានេះដែរ ជាលទ្ធផលគឺមានភាពស៊ីសង្វាក់គ្នាជារួម ដោយមិនមានខេត្តណាមួយមានពិន្ទុ ឬតម្លៃលើសពី "ល្អ" ឬនៅក្រោម "មធ្យម" នោះឡើយសម្រាប់សន្ទស្សន៍សំខាន់ៗ។

សន្ទស្សន៍រងបង្ហាញពីការប្រែប្រួលខ្លាំងបន្តិច។ តម្លៃសន្ទស្សន៍ការបំពេញការងារសម្រាប់ថ្នាក់ខេត្ត គឺស្ថិតនៅក្នុងចន្លោះពី "មធ្យម" ទៅ "ល្អ" តម្លៃសន្ទស្សន៍ការឆ្លើយតបគឺ "ល្អ" តម្លៃសន្ទស្សន៍តម្លាភាពមានចាប់ពី "មធ្យម" ទៅ "បង្គួរ" តម្លៃសន្ទស្សន៍គណនេយ្យភាពមានតម្លៃចាប់ពី "ខ្សោយ" ទៅ "មធ្យម" និងតម្លៃសន្ទស្សន៍នៃការចូលរួមរបស់ប្រជាពលរដ្ឋ គឺមានចំណាត់ថ្នាក់ "មធ្យម" ។

*តារាងលទ្ធផលនៃការអង្កេតបែងចែកតាមខេត្ត*

| ល.រ | ខេត្ត | តំបន់ | តម្លៃសន្ទស្សន៍ និងសន្ទស្សន៍រង | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | អភិបាលកិច្ច | សេវា | ការបំពេញការងារ | ការឆ្លើយតប | តម្លាភាព | គណនេយ្យភាព | ការចូលរួម |
| ១ | បន្ទាយមានជ័យ | ទន្លេសាប | ០,៦៣ | ០,៦៨ | ០,៦៦ | ០,៧៤ | ០,៥៧ | ០,៥៦ | ០,៥៦ |
| ២ | បាត់ដំបង | ទន្លេសាប | ០,៦៤ | ០,៦៩ | ០,៦៦ | ០,៧៦ | ០,៥៩ | ០,៥៩ | ០,៥៩ |
| ៣ | កំពង់ចាម | ដីទំនាប | ០,៦១ | ០,៦៦ | ០,៦៤ | ០,៧៤ | ០,៦០ | ០,៤៦ | ០,៥៧ |
| ៤ | កំពង់ឆ្នាំង | ទន្លេសាប | ០,៦៥ | ០,៧០ | ០,៦៨ | ០,៧៦ | ០,៦៤ | ០,៥៦ | ០,៦០ |
| ៥ | កំពង់ស្ពឺ | ខ្ពង់រាប | ០,៦៦ | ០,៧០ | ០,៦៨ | ០,៧៥ | ០,៦៧ | ០,៦២ | ០,៥៨ |
| ៦ | កំពង់ធំ | ខ្ពង់រាប | ០,៦១ | ០,៦៩ | ០,៦៧ | ០,៧៥ | ០,៥៦ | ០,៤៥ | ០,៥៦ |
| ៧ | កំពត | ឆ្នេរសមុទ្រ | ០,៦៣ | ០,៦៦ | ០,៦៤ | ០,៧៤ | ០,៦៧ | ០,៥៤ | ០,៦០ |
| ៨ | កណ្តាល | ដីទំនាប | ០,៦៧ | ០,៧៤ | ០,៧២ | ០,៧៨ | ០,៦៦ | ០,៨៤ | ០,៦២ |
| ៩ | កោះកុង | ឆ្នេរសមុទ្រ | ០,៦៥ | ០,៦៩ | ០,៦៧ | ០,៧៥ | ០,៦៩ | ០,៥០ | ០,៦០ |
| ១០ | ក្រចេះ | ខ្ពង់រាប | ០,៦២ | ០,៦៧ | ០,៦៥ | ០,៧៤ | ០,៥៩ | ០,៥២ | ០,៥៨ |
| ១១ | មណ្ឌលគិរី | ខ្ពង់រាប | ០,៦៣ | ០,៦៦ | ០,៦៤ | ០,៧១ | ០,៦៣ | ០,៥៧ | ០,៦០ |
| ១២ | ភ្នំពេញ | ដីទំនាប | ០,៦៧ | ០,៧៤ | ០,៧៣ | ០,៧៧ | ០,៦៨ | ០,៥៦ | ០,៥៥ |
| ១៣ | ព្រះ វិហារ | ខ្ពង់រាប | ០,៦០ | ០,៦៧ | ០,៦៥ | ០,៧៣ | ០,៦០ | ០,៣៨ | ០,៥៥ |
| ១៤ | ព្រៃវែង | ដីទំនាប | ០,៦២ | ០,៦៦ | ០,៦៣ | ០,៧៤ | ០,៦២ | ០,៥៤ | ០,៥៨ |

| ល.រ | ខេត្ត | តំបន់ | តម្លៃសន្ទស្សន៍ និងសន្ទស្សន៍រង | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | អភិបាលកិច្ច | សេវា | ការបំពេញការងារ | ការឆ្លើយតប | តម្លាភាព | គណនេយ្យភាព | ការចូលរួម |
| ១៥ | ពោធិ៍សាត់ | ទន្លេសាប | ០,៦១ | ០,៦៧ | ០,៦៦ | ០,៧១ | ០,៥៣ | ០,៥០ | ០,៥៧ |
| ១៦ | រតនគិរី | ខ្ពង់រាប | ០,៦៤ | ០,៦៧ | ០,៦៥ | ០,៧៣ | ០,៦៣ | ០,៥៧ | ០,៥៨ |
| ១៧ | សៀមរាប | ទន្លេសាប | ០,៦៣ | ០,៦៧ | ០,៦៥ | ០,៧៤ | ០,៦១ | ០,៥៥ | ០,៥៨ |
| ១៨ | ព្រះសីហនុ | ឆ្នេរសមុទ្រ | ០,៦៦ | ០,៧០ | ០,៦៧ | ០,៨០ | ០,៧១ | ០,៥៧ | ០,៥៦ |
| ១៩ | ស្ទឹងត្រែង | ខ្ពង់រាប | ០,៦៤ | ០,៦៩ | ០,៦៧ | ០,៧៥ | ០,៦២ | ០,៥២ | ០,៥៩ |
| ២០ | ស្វាយរៀង | ដីទំនាប | ០,៦២ | ០,៦៧ | ០,៦៤ | ០,៧៣ | ០,៦៣ | ០,៤៨ | ០,៥៨ |
| ២១ | តាកែវ | ដីទំនាប | ០,៦២ | ០,៦៦ | ០,៦៣ | ០,៧៣ | ០,៦២ | ០,៥៣ | ០,៥៩ |
| ២២ | ឧត្តរមានជ័យ | ខ្ពង់រាប | ០,៦២ | ០,៦៧ | ០,៦៤ | ០,៧៤ | ០,៥៩ | ០,៥៤ | ០,៥៩ |
| ២៣ | កែប | ឆ្នេរសមុទ្រ | ០,៦២ | ០,៦៧ | ០,៦៣ | ០,៧៨ | ០,៦៤ | ០,៥៩ | ០,៤២ |
| ២៤ | ប៉ៃលិន | ខ្ពង់រាប | ០,៥៧ | ០,៧១ | ០,៧០ | ០,៧៥ | ០,៦២ | | ០,៥៥ |
| ២៥ | ត្បូងឃ្មុំ | ដីទំនាប | ០,៦១ | ០,៦៥ | ០,៦៣ | ០,៧៣ | ០,៦០ | ០,៥២ | ០,៥៦ |
| | *ពិន្ទុអតិបរមា* | | *០,៦៧* | *០,៧៤* | *០,៧៣* | *០,៨០* | *០,៧១* | *០,៦២* | *០,៦២* |
| | *ពិន្ទុអប្បបរមា* | | *០,៥៧* | *០,៦៥* | *០,៦៣* | *០,៧១* | *០,៥៣* | *០,៣៨* | *០,៤២* |

*ការសង្ខេបការប្រៀបធៀបតម្លៃសន្ទស្សន៍តាមខេត្ត*

**ការឆ្លុះបញ្ចាំង ៖ តើយើងគួរព្រួយបារម្ភអំពីពិន្ទុទាបខុសពីធម្មតាសម្រាប់តម្លៃសន្ទស្សន៍រងមួយចំនួននៅថ្នាក់ខេត្តដែរឬទេ?**

តម្លៃវាស់វែងមួយចំនួននៃសន្ទស្សន៍រងសម្រាប់ខេត្តមួយចំនួនហាក់ដូចជាទាបជាងតម្លៃថ្នាក់ជាតិ។ ឧទាហរណ៍ គណនេយ្យភាពត្រូវបានវាស់វែងនៅកម្រិត ០,៣៨ (ខ្សោយ) សម្រាប់ខេត្តកោះកុង ហើយការចូលរួមរបស់ពលរដ្ឋត្រូវបានវាស់វែងនៅកម្រិត ០,៤២ សម្រាប់ខេត្តកែប (ខ្សោយបន្តិច)។ តើនេះជាការប្រែប្រួលស្ថិតិ ឬជាមូលហេតុសម្រាប់ការព្រួយបារម្ភឬទេ?

ការពិនិត្យមើលទិន្នន័យឱ្យបានដិតដល់ បង្ហាញថា ពិន្ទុគណនេយ្យភាពទាបសម្រាប់ខេត្តព្រះវិហារ ភាគច្រើនដោយសារតែគ្មានពិន្ទុត្រូវបានកត់ត្រាសម្រាប់សំណួរអំពីបណ្តឹងរបស់ប្រជាពលរដ្ឋទៅកាន់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ទោះយ៉ាងណាក៏ដោយ ទំហំសំណាកនៅខេត្តព្រះវិហារមានចំនួនតិចតួច ដូច្នេះគ្មានប្រជាពលរដ្ឋណាដែលមានបទពិសោធន៍ក្នុងដាក់បណ្តឹងត្រូវបានសម្ភាសន៍ក្នុងការធ្វើអង្កេតនេះឡើយ។ នៅខេត្តកែប ពិន្ទុទាបសម្រាប់ការចូលរួមរបស់ពលរដ្ឋក៏កើតឡើងពីសំណួរតែមួយដែរ។ ចំណុចនេះ ហាក់ដូចជាគ្មាននរណាម្នាក់ក្នុងចំណោមអ្នកឆ្លើយសំណួរទាំង២០នាក់នៅខេត្តកែបបានផ្តល់ចម្លើយត្រឹមត្រូវចំពោះសំណួរ CIV.៦ អំពីទំនាក់ទំនងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសហគមន៍មូលដ្ឋាននោះទេ។

ប្រសិនបើពិន្ទុមធ្យមថ្នាក់ជាតិសម្រាប់សំណួរទាំងនេះ ត្រូវបានជំនួសនៅក្នុងទិន្នន័យសម្រាប់ខេត្តកោះកុង និងកែប ព្រះវិហារ នោះពិន្ទុសន្ទស្សន៍រងគណនេយ្យភាព គឺស្ថិតនៅជិតនឹងតម្លៃមធ្យមរបស់ថ្នាក់ជាតិ។ ដូច្នេះ យើងអាចនិយាយបានថា ពិន្ទុទាបគឺជាផ្នែកមួយនៃភាពប្រែប្រួលនៃស្ថិតិ ដោយសារសំណាកមានទំហំតូច និងការកើតឡើងនៃឱកាសដែលអាចជះឥទ្ធិពលយ៉ាងខ្លាំងលើពិន្ទុខេត្ត។ ទោះជាយ៉ាងណាក៏ដោយ ទោះបីមានភាពជឿជាក់ទាបនៃទិន្នន័យនៅថ្នាក់ខេត្តក៏ដោយ ក៏ខេត្តអាចនៅតែយល់ថា មានតម្លៃក្នុងការពិនិត្យមើលពិន្ទុទាំងនេះ ដើម្បីកំណត់ពីផ្នែកណាមួយដែលត្រូវការយកចិត្តទុកដាក់ឱ្យបានខ្លាំងជាងនេះបន្ថែមទៀត។

ផ្នែកនានាខាងក្រោមនៃរបាយការណ៍អង្កេតនេះ បង្ហាញ និងវិភាគតម្លៃសម្រាប់សន្ទស្សន៍រង នីមួយៗជាមួយនឹងសូចនាករ និងសំណួរដែលពាក់ព័ន្ធ។ ប្រអប់ "**ការឆ្លុះបញ្ចាំង**" បង្ហាញការវិភាគបន្ថែម លើទិដ្ឋភាពជាក់លាក់មួយចំនួនសម្រាប់ជាឧទាហរណ៍ ដែលជាចម្លើយចំពោះសំណួរជាក់លាក់ណាមួយ ឬសំណួរមួយផ្នែកដែលមានការចាប់អារម្មណ៍។

## ៥.២. សន្ទស្សន៍រងពាក់ព័ន្ធនឹងការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

### ៥.២.១. តម្លៃសូចនាករ

**ពិន្ទុ (ចន្លោះពី0ទៅ១)**




*រូបភាពខាងលើបង្ហាញអំពីសន្ទស្សន៍ការបំពេញការងារជាមួយនឹងតម្លៃសូចនាករ និងមេគុណ*

ប្រជាពលរដ្ឋពេញចិត្តក្នុងកម្រិតពី "មធ្យម" ទៅ "បង្គួរ" ចំពោះគុណភាពសេវាសំខាន់ៗមួយចំនួន។ ការពេញចិត្តចំពោះសេវារដ្ឋបាលដែលផ្តល់តាមរយៈយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោម ជាតិ គឺមានពិន្ទុខ្ពស់ជាងសេវាសាធារណៈ។ ក្រុមប្រឹក្សា និងមន្ត្រីមានការពេញចិត្តក្នុងកម្រិត "បង្គួរ" ចំពោះការផ្តល់សេវានានា ហើយជឿជាក់ថា រដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថភាព និងធនធានដែល ចាំបាច់សម្រាប់បំពេញតាមគោលដៅនៃការផ្តល់សេវា។

ចំណុចខ្លាំង និងចំណុចខ្សោយនៃការបំពេញការងារ

| **ចំណុចខ្លាំង** | **ចំណុចខ្សោយ** |
|---|---|
| **សូចនាករពីរត្រូវបានវាស់វែងដោយមានពិន្ទុស្ថិតនៅក្រោមកម្រិត "ល្អ" បន្តិចបន្តួច គឺ៖**<br>• បទពិសោធន៍របស់ប្រជាពលរដ្ឋក្នុងការទទួលបានសេវារដ្ឋបាលតាមរយៈយន្តការច្រកចេញចូលតែមួយ<br>• ការវាយតម្លៃរបស់ក្រុមប្រឹក្សា និងមន្ត្រីអំពីសមត្ថភាព និងធនធានដែលខ្លួនមាន។ | • គុណភាពនៃសេវាសាធារណៈត្រូវបានវាយតម្លៃទាបជាងគុណភាពនៃសេវារដ្ឋបាល ទោះបីជាស្ថិតក្នុងកម្រិត "មធ្យម" ទៅ "បង្គួរ" ក៏ដោយ។ |

សន្ទស្សន៍រងផ្នែកការបំពេញការងារ ត្រូវបានគណនាដោយផ្អែកលើសូចនាករចំនួនពីរ គឺទីមួយ ការពេញចិត្តរបស់ប្រជាពលរដ្ឋលើការផ្តល់សេវា និងសូចនាកររួមមួយដែលបានពីការបូកចម្លើយពីមន្ត្រីថ្នាក់ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត។ តម្លៃសូចនាកររួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (PER-III) នៅតាមកម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវបានបញ្ចូលគ្នាជាតម្លៃតែមួយ ដើម្បីធ្វើឱ្យមានភាពងាយស្រួលក្នុងការរៀបចំភាពជាតំណាង។ តម្លៃសូចនាករលម្អិតមានបង្ហាញនៅក្នុងតារាងខាងក្រោម រួមជាមួយនឹងកំហុសស្តង់ដាដែលមានកម្រិតទំនុកចិត្ត៩៥%។

*តារាងតម្លៃសូចនាករនៃសន្ទស្សន៍រងការបំពេញការងារ*

| សូចនាករ | ពិពណ៌នា | សំណាក | ពិន្ទុ | មេគុណ | តម្លៃ | កំហុសស្តង់ដា | ៩៥% ចន្លោះទំនុកចិត្ត | |
|---|---|---|---|---|---|---|---|---|
| | | | | | | | ទាបបំផុត | ខ្ពស់បំផុត |
| PER-I | ប្រជាពលរដ្ឋពេញចិត្តនឹងគុណភាពសេវាសាធារណៈសំខាន់ៗដែលមានសម្រាប់សហគមន៍ | CIT | **០,៦១** | ០,៣៣ | ០,២០ | *០,០០៣* | ០,៦១ | ០,៦២ |
| PER-II | ប្រជាពលរដ្ឋពេញចិត្តនឹងបទពិសោធន៍ក្នុងការទទួលបានសេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយ | CIT | **០,៦៩** | ០,៣៣ | ០,២៣ | *០,០០៣* | ០,៦៨ | ០,៦៩ |
| PER-III | ក្រុមប្រឹក្សា និងមន្ត្រីមានទំនុកចិត្តថា ពួកគាត់មានសមត្ថភាព និងធនធានដែលត្រូវការ ដើម្បីសម្រេចបាននូវគោលដៅ នៃការផ្តល់សេវា។ | VIL | **០,៦៦** | *០,០៨* | ០,០៥ | *០,០០៥* | ០,៦៥ | ០,៦៧ |
| | | CS | **០,៦៧** | *០,០៨* | ០,០៦ | *០,០០៤* | ០,៦៦ | ០,៦៨ |
| | | DMK | **០,៧១** | *០,០៨* | ០,០៦ | *០,០០៤* | ០,៧០ | ០,៧១ |
| | | CP | **០,៧៥** | *០,០៨* | ០,០៦ | *០,០១៦* | ០,៧២ | ០,៧៨ |
| **តម្លៃសន្ទស្សន៍រង** | | | | | **០,៦៦** | | | |

តម្លៃសូចនាករសម្រាប់ការពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះសេវាសាធារណៈ និងសេវារដ្ឋបាលគឺមានកម្រិតបង្គួរ។ អ្នកផ្តល់ព័ត៌មានជាមន្ត្រីថ្នាក់ភូមិ ឃុំ សង្កាត់ ក៏បានផ្តល់ការវាយតម្លៃកម្រិតបង្គួរ អំពីសមត្ថភាព និងធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវា។ ទោះជាយ៉ាងណាក៏ដោយ ការវាយតម្លៃដោយអ្នកផ្តល់ព័ត៌មានដែលជាមន្ត្រីនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត ស្ថិតនៅក្នុងរង្វង់នៃកម្រិត "ល្អ" ។ តម្លៃរបស់សូចនាករទាំងនេះមានបង្ហាញនៅក្នុងតារាងខាងក្រោម៖

*តារាងតម្លៃសូចនាករនៃការបំពេញការងារបែងចែកតាមទីប្រជុំជនតំបន់ជនបទ ភេទ និងតាមតំបន់ភូមិសាស្ត្រនានា*

| **សូចនាករ** | **ពិពណ៌នា** | **សំណាក** | **សរុប** | **ក្រុង ស្រុក ខណ្ឌ** | | **ភេទ** | | **តំបន់ភូមិសាស្ត្រ** | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ទីក្រុង | ជនបទ | ស្រី | ប្រុស | ភ្នំពេញ | ទំនាប | ទន្លេសាប | ខ្ពង់រាប | សមុទ្រ |
| PER-I | ប្រជាពលរដ្ឋពេញចិត្តនឹងគុណភាពនៃសេវាសាធារណៈសំខាន់ៗ | CIT | ០,៦១ | ០,៦៧ | ០,៦០ | ០,៦២ | ០,៦១ | ០,៧១ | ០,៦០ | ០,៦២ | ០,៦០ | ០,៦០ |
| PER-II | ពលរដ្ឋពេញចិត្តនឹងបទពិសោធន៍ក្នុងការទទួលបានសេវាតាមយន្តការច្រកចេញចូលតែមួយ | CIT | ០,៦៩ | ០,៧០ | ០,៦៨ | ០,៦៩ | ០,៦៨ | ០,៧១ | ០,៦៨ | ០,៦៩ | ០,៧០ | ០,៦៤ |
| PER-III | ក្រុមប្រឹក្សា និងមន្ត្រីមានទំនុកចិត្តថា រដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថភាព និងធនធានដើម្បីសម្រេចបានគោលដៅនៃការផ្តល់សេវា | VIL | ០,៦៦ | ០,៦៦ | ០,៦៦ | ០,៦៧ | ០,៦៦ | ០,៧៤ | ០,៦៦ | ០,៦៦ | ០,៦៥ | ០,៦៦ |
| | | CS | ០,៦៧ | ០,៦៩ | ០,៦៦ | ០,៦៧ | ០,៦៧ | ០,៧១ | ០,៦៧ | ០,៦៥ | ០,៦៧ | ០,៦៧ |
| | | DMK | ០,៧១ | ០,៧៤ | ០,៦៩ | ០,៧១ | ០,៧០ | ០,៧៧ | ០,៧០ | ០,៦៩ | ០,៧២ | ០,៧០ |
| | | CP | ០,៧៥ | - | - | ០,៧៩ | ០,៧៣ | ០,៩០ | ០,៧២ | ០,៦៩ | ០,៧៥ | ០,៨២ |
| **តម្លៃសរុប** | | | **០,៦៧** | **០,៦២** | **០,៥៨** | **០,៦៩** | **០,៦៥** | **០,៦៧** | **០,៦៦** | **០,៧៣** | **០,៦៥** | **០,៦៦** |

## ៥.២.២. ចម្លើយរបស់ប្រជាពលរដ្ឋ

សូចនាករ PER-I និង PER-II ត្រូវបានវាយតម្លៃតាមសំណួរសម្រាប់សូចនាករនីមួយៗ ដែលក្នុងនោះអ្នកផ្តល់ព័ត៌មានត្រូវបានសួរឱ្យវាយតម្លៃអំពីកម្រិតនៃការពេញចិត្តរៀងៗខ្លួនចំពោះសេវាសាធារណៈ (PER-I) ឬសេវារដ្ឋបាល PER-II។ ដូច្នេះ ពិន្ទុចំពោះសំណួរនីមួយៗ គឺមានលក្ខណៈដូចគ្នាទៅនឹងពិន្ទុសូចនាករ។ ពិន្ទុសម្រាប់សំណួរទាំងនេះមានបង្ហាញក្នុងតារាងខាងក្រោម៖

*តារាងការឆ្លើយតបរបស់ប្រជាពលរដ្ឋចំពោះសំណួរអំពីការបំពេញការងារ*

| លេខសម្គាល់ | ការពិពណ៌នា | ពិន្ទុ | ទម្ងន់ | តម្លៃ | កំហុសស្តង់ដា | ៩៥% ចន្លោះទំនុកចិត្ត | |
|---|---|---|---|---|---|---|---|
| | | | | | | ទាបបំផុត | ខ្ពស់បំផុត |
| បជ.PER.១ | ការវាយតម្លៃគុណភាពនៃសេវាសាធារណៈ | ០,៦១ | *១,០០* | ០,៦១ | *០,០០៣* | ០,៦១ | ០,៦២ |
| បជ.PER-I | ពលរដ្ឋពេញចិត្តគុណភាពសេវាសាធារណៈសំខាន់ៗ។ | | | ០,៦១ | *០,០០៣* | ០,៦១ | ០,៦២ |
| បជ.PER.២ | ការវាយតម្លៃគុណភាពនៃសេវារដ្ឋបាល | ០,៦៩ | *១,០០* | ០,៦៩ | *០,០០២* | ០,៦៨ | ០,៦៩ |
| បជ.PER-II | ប្រជាពលរដ្ឋពេញចិត្តនឹងបទពិសោធន៍ក្នុងការទទួលបានសេវាតាមយន្តការច្រកចេញចូលតែមួយ | | | ០,៦៩ | *០,០០២* | ០,៦៨ | ០,៦៩ |

*ការវាយតម្លៃរបស់ប្រជាពលរដ្ឋអំពីគុណភាពនៃការផ្តល់សេវា*

**ការឆ្លុះបញ្ចាំង ៖ តើប្រជាពលរដ្ឋវាយតម្លៃអំពីសេវាផ្សេងៗដូចម្តេច?**




ការពេញចិត្តលើគុណភាពសេវាសាធារណៈនៅក្នុងទីប្រជុំជនខ្ពស់ជាងនៅតំបន់ជនបទ។ ប្រជាពលរដ្ឋក្នុងទីប្រជុំជនមានការពេញចិត្តខ្លាំងចំពោះគុណភាពនៃការផ្គត់ផ្គង់ទឹកស្អាត និងអគ្គិសនី ហើយពេញចិត្តតិចតួចចំពោះគុណភាពផ្លូវ និងការប្រមូលសំរាម។ អ្នករស់នៅតាមជនបទបានឱ្យតម្លៃខ្ពស់នៃការពេញចិត្តចំពោះសេវាសុខភាព និងសេវាសម្រាប់ស្ត្រី និងកុមារ ហើយមិនសូវពេញចិត្តចំពោះគុណភាពផ្លូវ និងស្ពាន និងការប្រមូលសំណល់រឹង។ មានភាពខុសគ្នាតិចតួចរវាងការវាយតម្លៃរបស់ប្រជាពលរដ្ឋជាបុរស និងស្ត្រីអំពីគុណភាពសេវា។

ការវាយតម្លៃរបស់ប្រជាពលរដ្ឋអំពីគុណភាពសេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយ មានភាពខុសគ្នាតិចតួចរវាងទីប្រជុំជន និងជនបទ។
សេវាពាក់ព័ន្ធនឹងការអនុញ្ញាតសាងសង់ និងការបញ្ជាក់ឯកសារផ្ទាល់ខ្លួនត្រូវបានវាយតម្លៃថាពេញចិត្តបំផុត ប៉ុន្តែភាពខុសគ្នារវាងប្រភេទនៃសេវាមានតិចតួច លើកលែងតែសេវានៃការចុះបញ្ជីអាជីវកម្មដែលត្រូវបានវាយតម្លៃថាមានកម្រិតខ្សោយទាំងនៅក្នុងទីប្រជុំជន និងជនបទ។




## ៥.២.៣. ចម្លើយរបស់ក្រុមប្រឹក្សា និងមន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិ

ការវាយតម្លៃរបស់ថ្នាក់ដឹកនាំភូមិអំពីគុណភាពសេវា គឺមានលក្ខណៈស្រដៀងគ្នាទៅនឹងការវាយតម្លៃរបស់ប្រជាពលរដ្ឋ ប៉ុន្តែការវាយតម្លៃរបស់ក្រុមប្រឹក្សា និងមន្ត្រីនៅថ្នាក់ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្តបានវាយតម្លៃខ្ពស់ជាងបន្តិច។ រដ្ឋបាលរាជធានី ខេត្តបានវាយតម្លៃអំពីសមត្ថភាព

របស់រដ្ឋបាលខ្លួនក្នុងការផ្តល់សេវាសាធារណៈខ្ពស់ជាងការវាយតម្លៃរបស់ឃុំ សង្កាត់ ឬក្រុង ស្រុក ខណ្ឌ ប៉ុន្តែរដ្ឋបាលទាំងនេះមានភាពជឿជាក់ស្រដៀងគ្នា (ខ្ពស់គួរសម) លើសមត្ថភាពក្នុងការផ្តល់សេវារដ្ឋបាលនៅគ្រប់កម្រិត។

ចម្លើយអំពីការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមថ្នាក់រដ្ឋបាលនីមួយៗមានបង្ហាញក្នុងតារាងខាងក្រោម៖

*តារាងរដ្ឋបាលថ្នាក់ក្រោមជាតិឆ្លើយតបទៅនឹងសំណួរអំពីការបំពេញការងារ*

| លេខសម្គាល់ | កាពិពណ៌នា | ពិន្ទុ | មេគុណ | តម្លៃ | កំហុសស្តង់ដា | ៩៥% ចន្លោះទំនុកចិត្ត | |
|---|---|---|---|---|---|---|---|
| | | | | | | ទាបបំផុត | ខ្ពស់បំផុត |
| VIL.PER.I | ការវាយតម្លៃគុណភាពសេវាសាធារណៈ | **០,៦៣** | *០,៥០* | ០,៣១ | *០,០០៦* | ០,៦១ | ០,៦៤ |
| VIL.PER.2 | ការវាយតម្លៃគុណភាពនៃសេវារដ្ឋបាល | **០,៦៩** | *០,៥០* | ០,៣៥ | *០,០០៥* | ០,៦៨ | ០,៧០ |
| VIL.PER-III | **ក្រុមប្រឹក្សា និងមន្ត្រីមានទំនុកចិត្តថាមានសមត្ថភាព និងធនធានសម្រាប់ការសម្រេចបានគោលដៅនៃការផ្តល់សេវា** | | | **០,៦៦** | ***០,០០៥*** | **០,៦៥** | **០,៦៧** |
| CS.PER.1 | ការវាយតម្លៃសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈ | **០,៥៩** | *០,៣០* | ០,១៨ | *០,០០៨* | ០,៥៨ | ០,៦១ |
| CS.PER.2 | ការវាយតម្លៃសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការផ្តល់សេវារដ្ឋបាល | **០,៧២** | *០,៣០* | ០,២២ | *០,០០៦* | ០,៧១ | ០,៧៣ |
| CS.PER.3 | ការវាយតម្លៃគុណភាពនៃសេវាសាធារណៈ | **០,៦៦** | *០,២០* | ០,១៣ | *០,០០៤* | ០,៦៦ | ០,៦៧ |
| CS.PER.4 | ការវាយតម្លៃគុណភាពនៃសេវារដ្ឋបាល | **០,៧១** | *០,២០* | ០,១៤ | *០,០០៣* | ០,៧០ | ០,៧១ |
| CS.PER-III | **ក្រុមប្រឹក្សា និងមន្ត្រីមានទំនុកចិត្តថាមានសមត្ថភាព និងធនធានដែលត្រូវការ ដើម្បីសម្រេចបាននូវគោលដៅនៃការផ្តល់សេវា** | | | **០,៦៧** | ***០,០០៤*** | **០,៦៦** | **០,៦៨** |
| DMK.PER.1 | ការវាយតម្លៃសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈ | ០,៦២ | *០,៣០* | ០,១៩ | *០,០០៧* | ០,៦០ | ០,៦៣ |
| DMK.PER.2 | ការវាយតម្លៃសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការផ្តល់សេវារដ្ឋបាល | ០,៨០ | *០,៣០* | ០,២៤ | *០,០០៨* | ០,៧៩ | ០,៨២ |
| DMK.PER.3 | ការវាយតម្លៃគុណភាពនៃសេវាសាធារណៈ | **០,៦៨** | *០,២០* | ០,១៤ | *០,០០៤* | ០,៦៧ | ០,៦៨ |
| DMK.PER.4 | ការវាយតម្លៃគុណភាពនៃសេវារដ្ឋបាល | **០,៧១** | *០,២០* | ០,១៤ | *០,០០៣* | ០,៧១ | ០,៧២ |
| DMK.PER-III | **ក្រុមប្រឹក្សា និងមន្ត្រីមានទំនុកចិត្តថាមានសមត្ថភាព និងធនធានសម្រាប់សម្រេចបានគោលដៅនៃការផ្តល់សេវា។** | | | **០,៧១** | ***០,០០៤*** | **០,៧០** | **០,៧១** |
| CP.PER.1 | ការវាយតម្លៃសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈ | **០,៧០** | *០,៣០* | ០,២១ | *០,០៥៧* | ០,៥៩ | ០,៨១ |
| CP.PER.2 | ការវាយតម្លៃសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការផ្តល់សេវារដ្ឋបាល | **០,៨២** | *០,៣០* | ០,២៥ | *០,០១៩* | ០,៧៨ | ០,៨៦ |
| CP.PER.3 | ការវាយតម្លៃគុណភាពនៃសេវាសាធារណៈ | **០,៧១** | *០,២០* | ០,១៤ | *០,០២១* | ០,៦៧ | ០,៧៥ |
| CP.PER.4 | ការវាយតម្លៃគុណភាពនៃសេវារដ្ឋបាល | **០,៧៥** | *០,២០* | ០,១៥ | *០,០០៩* | ០,៧៤ | ០,៧៧ |
| CP.PER-III | **ក្រុមប្រឹក្សា និងមន្ត្រីមានទំនុកចិត្តថា មានសមត្ថភាព និងធនធានសម្រាប់សម្រេចបាននូវគោលដៅនៃការផ្តល់សេវា** | | | **០,៧៥** | ***០,០១៦*** | **០,៧២** | **០,៧៨** |

**ការឆ្លុះបញ្ចាំង៖ តើសេវារដ្ឋបាលមួយណាដែលរដ្ឋបាលថ្នាក់ក្រោមជាតិមានទំនុកចិត្តជាងគេ**




**យើងបានសួរអំពីសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវារដ្ឋបាល។**

តារាងនេះបង្ហាញពីភាគរយនៃអ្នកផ្តល់ព័ត៌មានដែលជាមន្ត្រីឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌដែលបានឆ្លើយថារដ្ឋបាលថ្នាក់ក្រោមជាតិអាច "ផ្តល់សេវាប្រកបដោយសមត្ថភាពគ្រប់គ្រាន់"។

ឃុំ សង្កាត់ មានទំនុកចិត្តថា មានសមត្ថភាពក្នុងការចុះបញ្ជីអត្រានុកូលដ្ឋាន ការបញ្ជាក់លើឯកសារ និងការដោះស្រាយវិវាទនៅក្នុងឃុំ សង្កាត់។

ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មានទំនុកចិត្តច្រើនជាងឃុំ សង្កាត់ អំពីសមត្ថភាពក្នុងការផ្ទេរកម្មសិទ្ធិដីធ្លី ការចុះបញ្ជីអាជីវកម្ម និងការអនុញ្ញាតសាងសង់។

## ៥.៣. សន្ទស្សន៍រងពាក់ព័ន្ធនឹងការឆ្លើយតប

### ៥.៣.១. តម្លៃសូចនាករ

**ពិន្ទុ (ចន្លោះពី០ទី១)**




ការឆ្លើយតប គឺជាសន្ទស្សន៍រងដែលទទួលបានពិន្ទុខ្ពស់ជាងគេ គឺមានតម្លៃ ០,៧៥ ដោយផ្អែកលើការផ្ទៀងផ្ទាត់រវាងអាទិភាពរបស់ប្រជាពលរដ្ឋ និងអាទិភាពរបស់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយទំនុកចិត្តក៏មានកម្រិតខ្ពស់សម្រាប់ប្រជាពលរដ្ឋដែលបានឆ្លើយថា រដ្ឋបាលថ្នាក់ក្រោមជាតិយល់ដឹងអំពីតម្រូវការរបស់ប្រជាពលរដ្ឋ និងខិតខំព្យាយាមបំពេញតម្រូវការរបស់ប្រជាពលរដ្ឋទាំងនោះ។

*ចំណុចខ្លាំង និងចំណុចខ្សោយអំពីការឆ្លើយតប*

| ចំណុចខ្លាំង | ចំណុចខ្សោយ |
| --- | --- |
| **ខ្លាំងណាស់៖**<br>• នៅពេលដែលប្រជាពលរដ្ឋ ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ត្រីត្រូវបានសួរអំពីអាទិភាពរបស់ខ្លួនសម្រាប់ការកែលម្អសេវានានា ពួកគេបានផ្តល់ចម្លើយស្រដៀងគ្នាខ្លាំងណាស់។<br>• ប្រជាពលរដ្ឋមានទំនុកចិត្តយ៉ាងមុតមាំថា រដ្ឋបាលថ្នាក់ក្រោមជាតិយល់អំពីតម្រូវការរបស់ប្រជាពលរដ្ឋ និងព្យាយាមបំពេញតាមតម្រូវការរបស់ប្រជាពលរដ្ឋ។ | **មិនមែនជាចំណុចខ្សោយខ្លាំងនោះទេ ប៉ុន្តែ ៖**<br>• នៅពេលដែលក្រុមប្រឹក្សា និងមន្ត្រីក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ត្រូវបានសួរអំពីសារៈសំខាន់នៃតម្រូវការ និងអាទិភាពរបស់ប្រជាពលរដ្ឋក្នុងការកសាងផែនការ ការឆ្លើយតបរបស់ពួកគេគឺស្ថិតនៅក្នុងរង្វង់កម្រិត "មធ្យម"។ |

ការឆ្លើយតបរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ គឺជាសូចនាករសំខាន់នៃអភិបាលកិច្ច ដែលត្រូវបានវាយតម្លៃផ្តល់ពិន្ទុខ្ពស់បំផុតដោយប្រជាពលរដ្ឋ និងអ្នកផ្តល់ចម្លើយដែលជាមន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ សន្ទស្សន៍រងនៃការឆ្លើយតប ត្រូវបានវាយតម្លៃដោយផ្អែកលើសូចនាករចំនួនបី។

**សូចនាករ** *RES-I អាទិភាពរបស់ប្រជាពលរដ្ឋសម្រាប់ការលើកកម្ពស់សេវា គឺមានលក្ខណៈស្រដៀងគ្នាទៅនឹងអាទិភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ* ដែលត្រូវបានវាយតម្លៃតាមរយៈការកំណត់ចំណាត់ថ្នាក់នៃអាទិភាពរបស់ប្រជាពលរដ្ឋសម្រាប់ការកែលម្អការផ្តល់សេវា និងការផ្សារភ្ជាប់ចំណាត់ថ្នាក់នេះជាមួយនឹងចំណាត់ថ្នាក់ដែលផ្អែកលើចម្លើយរបស់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដូច្នេះ សូចនាករនេះគឺជាសូចនាករតែមួយគត់ដែលរួមបញ្ចូលទិន្នន័យពីប្រជាពលរដ្ឋ និងទិន្នន័យពីក្រុមប្រឹក្សា និងមន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ តម្លៃសូចនាករដែលបានរាយការណ៍ គឺជាមេគុណនៃទំនាក់ទំនងរវាងចំណាត់ទាំងពីរ ហើយជាលទ្ធផលទទួលបានតម្លៃដែលមានកម្រិត "ល្អ" គឺ០,៨៣ ដោយមានការបកស្រាយបន្ថែមនៅផ្នែកខាងក្រោម។

**សូចនាករ** *RES-II ប្រជាពលរដ្ឋយល់ថា រដ្ឋបាលថ្នាក់ក្រោមជាតិដឹងពីតម្រូវការ និងអាទិភាពរបស់ខ្លួន ហើយព្យាយាមបំពេញតាមតម្រូវការទាំងនោះ* គឺជាសំណួរដែលវាយតម្លៃអំពីទំនុកចិត្តរបស់ប្រជាពលរដ្ឋដែលបានឆ្លើយថា តម្រូវការរបស់ខ្លួន ត្រូវបានយល់ដឹងដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

**សូចនាករ** *RES-III* រួមបញ្ចូលគ្នានូវការវាយតម្លៃរបស់ថ្នាក់ដឹកនាំភូមិអំពីការឆ្លើយតបរបស់រដ្ឋបាលថ្នាក់ក្រោមជាតិជាមួយនឹងចម្លើយរបស់អ្នកផ្តល់ព័ត៌មានដែលជាមន្ត្រីឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត ចំពោះសំណួរពាក់ព័ន្ធនឹងឥទ្ធិពលលើការសម្រេចចិត្តក្នុងការកសាងផែនការ និងការរៀបចំថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

តម្លៃសូចនាករការឆ្លើយតបសម្រាប់ក្រុមសំណាកនីមួយៗ តាមភេទ និងតាមតំបន់ភូមិសាស្ត្រមានបង្ហាញនៅក្នុងតារាងខាងក្រោម៖

*តារាងតម្លៃសូចនាករនៃការឆ្លើយតបតាមក្រុមសំណាកនីមួយៗ*

| សូចនាករ | ការពិពណ៌នា | សំណាក | ពិន្ទុ | មេគុណ | តម្លៃ | កំហុសស្តង់ដា | ៩៥% ចន្លោះទំនុកចិត្ត | |
|---|---|---|---|---|---|---|---|---|
| | | | | | | | ទាបបំផុត | ខ្ពស់បំផុត |
| RES-I | អាទិភាពរបស់ប្រជាពលរដ្ឋសម្រាប់លើកកម្ពស់សេវា គឺមានលក្ខណៈស្រដៀងគ្នានឹងអាទិភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | បជ | **០,៨៣** | *០,៣៣* | ០,២៨ | *មិនមាន* | *មិនមាន* | *មិនមាន* |
| RES-II | ប្រជាពលរដ្ឋយល់ថា រដ្ឋបាលថ្នាក់ក្រោមជាតិដឹងពីតម្រូវការ និងអាទិភាពរបស់ខ្លួន ហើយព្យាយាមបំពេញតាមតម្រូវការនេះ | បជ | **០,៧២** | *០,៣៣* | ០,២៤ | *០,០០៤* | ០,៧១ | ០,៧៣ |
| RES-III | ក្រុមប្រឹក្សា និងមន្ត្រីជឿថា អាទិភាពរបស់ប្រជាពលរដ្ឋមានសារៈសំខាន់បំផុតលើការសម្រេចចិត្តក្នុងការកសាងផែនការ និងការរៀបចំថវិកា | ភ | **០,៧៨** | *០,០៨* | ០,០៦ | *០,០០៨* | ០,៧៧ | ០,៨០ |
| | | គ.ស | **០,៧១** | *០,០៨* | ០,០៦ | *០,០០៩* | ០,៦៩ | ០,៧៣ |
| | | កសខ | **០,៦៥** | *០,០៨* | ០,០៥ | *០,០០៩* | ០,៦៣ | ០,៦៧ |
| | | រខ | **០,៥៨** | *០,០៨* | ០,០៥ | *០,០២៨* | ០,៥៣ | ០,៦៤ |
| **តម្លៃសន្ទស្សន៍រង** | | | | | **០,៧៤** | | | |

*តារាងតម្លៃសូចនាករនៃការឆ្លើយតបតាមតំបន់ទីប្រជុំជន តំបន់ជនបទ ភេទ និងតំបន់ភូមិសាស្ត្រ*

| សូចនាករ | ការពិពណ៌នា | សំណាក | សរុប | ប្រភេទក្រុង ស្រុក ខណ្ឌ | | ភេទ | | តំបន់ភូមិសាស្ត្រ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ទីប្រជុំជន | ជនបទ | ស្រី | ប្រុស | ភ្នំពេញ | ទំនាប | ទន្លេសាប | ខ្ពង់រាប | សមុទ្រ |
| RES-I | អាទិភាពរបស់ប្រជាពលរដ្ឋក្នុងការលើកកម្ពស់សេវា គឺមានលក្ខណៈស្រដៀងគ្នានឹងអាទិភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | CIT | **០,៨៣** | ០,៨៧ | ០,៨៧ | ០,៩២ | ០,៨៣ | ០,៨៣ | ០,៧៨ | ០,៨៨ | ០,៨២ | ០,៧២ |
| RES-II | ប្រជាពលរដ្ឋយល់ថា រដ្ឋបាលថ្នាក់ក្រោមជាតិដឹងពីតម្រូវការ និងអាទិភាពរបស់ខ្លួន ហើយព្យាយាមបំពេញតាមតម្រូវការនេះ | CIT | **០,៧២** | ០,៧៤ | ០,៧២ | ០,៧៣ | ០,៧២ | ០,៧៧ | ០,៧៥ | ០,៦៨ | ០,៧២ | ០,៧២ |
| RES-III | ក្រុមប្រឹក្សា និងមន្ត្រីជឿថា អាទិភាពរបស់ប្រជាពលរដ្ឋមានសារៈលើការសម្រេចចិត្តក្នុងការរៀបចំផែនការ និងថវិកា | VIL | **០,៧៨** | ០,៧៨ | ០,៧៨ | ០,៧៩ | ០,៧៨ | ០,៨៣ | ០,៧៩ | ០,៧៤ | ០,៨០ | ០,៨០ |
| | | CS | **០,៧១** | ០,៦៩ | ០,៧១ | ០,៧១ | ០,៧០ | ០,៦៨ | ០,៦៨ | ០,៧៨ | ០,៦៧ | ០,៧១ |
| | | DMK | **០,៦៥** | ០,៦៦ | ០,៦៥ | ០,៦៣ | ០,៦៦ | ០,៦៧ | ០,៦១ | ០,៦៧ | ០,៦៦ | ០,៦៨ |
| | | CP | **០,៥៨** | - | - | ០,៥៤ | ០,៦០ | ០,៦៩ | ០,៥២ | ០,៦៦ | ០,៥៤ | ០,៦៥ |
| **តម្លៃរងសន្ទស្សន៍** | | | **០,៧៤** | **០,៧៨** | **០,៧៧** | **០,៧៧** | **០,៧៤** | **០,៧៧** | **០,៧២** | **០,៧៦** | **០,៧៣** | **០,៧១** |

## ៥.៣.២. តម្លៃសន្ទស្សការឆ្លើយតប ដែលបានពីចម្លើយរបស់សំណាកប្រជាពលរដ្ឋ

អាទិភាពសម្រាប់លើកកម្ពស់ការផ្តល់សេវាដែលកំណត់ដោយប្រជាពលរដ្ឋ និងអាទិភាពដែលកំណត់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ គឺមានលក្ខណៈសឹងតែដូចគ្នា។ ចំណុចនេះ បង្ហាញឱ្យឃើញច្បាស់នៅពេលសំណាកត្រូវបានបែងចែកតាមភេទ តាមតំបន់ទីប្រជុំជន/ជនបទ ឬតាមភូមិសាស្ត្រ ។

ដូចដែលបានពិពណ៌នាខាងលើ សូចនាករ RES-I ត្រូវបានវាយតម្លៃដោយការប៉ាន់ប្រមាណមេគុណនៃការជាប់ទាក់ទងគ្នារវាងចំណាត់ថ្នាក់អាទិភាពនៃការកែលម្អសេវារបស់ប្រជាពលរដ្ឋ និងរបស់អ្នកផ្តល់ព័ត៌មានជាមន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ចំណាត់ថ្នាក់ជាក់ស្តែងដែលទទួលបានពីចម្លើយនានា និងវិធីសាស្ត្រនៃការទទួលបានមេគុណនៃការជាប់ពាក់ព័ន្ធគ្នាមានបង្ហាញក្នុងរូបភាពខាងក្រោម។ អាទិភាពដែលបង្ហាញដោយប្រជាពលរដ្ឋ ត្រូវបានរៀបចំតាមលំដាប់ថ្នាក់នៅលើអ័ក្សផ្តេក ដូច្នេះអាទិភាពទីមួយ គឺការកែលម្អផ្លូវថ្នល់ និងស្ពាន និងអាទិភាពទីពីរ គឺការលើកកម្ពស់សេវាជូនប្រជាពលរដ្ឋដែលងាយរងគ្រោះ។ អ្នកផ្តល់ព័ត៌មានដែលជាមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិក៏បានចាត់ចំណាត់ថ្នាក់ផ្លូវ និងស្ពានជាអាទិភាព

ខ្ពស់បំផុត ប៉ុន្តែបានចាត់ចំណាត់ថ្នាក់សេវាជូនប្រជាពលរដ្ឋដែលងាយរងគ្រោះជាអាទិភាពលំដាប់ទីប្រាំ។ មេគុណទំនាក់ទំនងរួម R ត្រូវបានគណនា និងមានតម្លៃ ០,៨៣ ដែលត្រូវបានប្រើប្រាស់ជាពិន្ទុសំណួរ និងតម្លៃសូចនាករ ($R^{២}$ = ០,៦៩) ។




*រូបភាពទំនាក់ទំនងរវាងអាទិភាពរបស់ប្រជាពលរដ្ឋ និងរដ្ឋបាលថ្នាក់ក្រោមជាតិ (សំណាកទាំងមូល)*

ពិន្ទុនានានៃសំណួរសម្រាប់ប្រជាពលរដ្ឋក្នុងសំណាកទាំងមូលអំពីសន្ទស្សន៍រងនៃការឆ្លើយតប ត្រូវបានសង្ខេបនៅក្នុងតារាងខាងក្រោម។ តម្លៃដែលបានគណនាសម្រាប់ RES-I ស្ថិតនៅក្នុងចំណាត់ថ្នាក់ "ល្អ" ចំណែកតម្លៃដែលបានគណនាសម្រាប់ RES-II និងសំណួរដែលពាក់ព័ន្ធស្ថិតនៅក្នុងផ្នែកខាងលើនៃអ័ក្សក្នុងចំណាត់ថ្នាក់ "បង្គួរ" ។

*តារាងចម្លើយរបស់ប្រជាពលរដ្ឋចំពោះសំណួរពាក់ព័ន្ធនឹងសន្ទស្សន៍រងនៃការឆ្លើយតប*

| លេខសម្គាល់ | ការពិពណ៌នា | ពិន្ទុ | មេគុណ | តម្លៃ | កំហុសស្តង់ដា | ៩៥% ចន្លោះទំនុកចិត្ត | |
|---|---|---|---|---|---|---|---|
| | | | | | | ទាបបំផុត | ខ្ពស់បំផុត |
| CIT.RES.1 | ទំនាក់ទំនងរវាងអាទិភាពរបស់ប្រជាពលរដ្ឋសម្រាប់ការកែលម្អសេវា និងអាទិភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | **០,៨៣** | *១.០០* | ០,៨៣ | | | |
| **CIT.RES-I** | **អាទិភាពរបស់ប្រជាពលរដ្ឋសម្រាប់កែលម្អសេវា គឺមានលក្ខណៈស្រដៀងគ្នានឹងអាទិភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** | | | **០,៨៤** | | | |
| CIT.RES.2 | ការវាយតម្លៃរបស់ឃុំ សង្កាត់ចំពោះការយល់ដឹងអំពីតម្រូវការរបស់ប្រជាពលរដ្ឋ | **០,៧៣** | *០,៤០* | ០,២៩ | *០,០០៥* | ០,៧២ | ០,៧៤ |
| CIT.RES.3 | ការវាយតម្លៃរបស់ក្រុង ស្រុក ខណ្ឌចំពោះការយល់ដឹងអំពីតម្រូវការរបស់ប្រជាពលរដ្ឋ | **០,៧២** | *០,៤០* | ០,២៩ | *០,០០៧* | ០,៧០ | ០,៧៣ |
| CIT.RES.4 | ការវាយតម្លៃរបស់រាជធានី ខេត្តចំពោះការយល់ដឹងអំពីតម្រូវការរបស់ប្រជាពលរដ្ឋ | **០,៧២** | *០,២០* | ០,១៤ | *០,០០៨* | ០,៧១ | ០,៧៤ |
| **CIT.RES-II** | **ប្រជាពលរដ្ឋយល់ថា រដ្ឋបាលថ្នាក់ក្រោមជាតិដឹងពីតម្រូវការ និងអាទិភាពរបស់ខ្លួន ហើយព្យាយាមបំពេញតាមតម្រូវការទាំងនេះ** | | | **០,៧២** | *០,០០៤* | **០,៧១** | **០,៧៣** |

### ការឆ្លុះបញ្ចាំង ៖ តើយើងអាចរៀនសូត្រអ្វីខ្លះពីចំណាត់ថ្នាក់របស់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងអាទិភាពសម្រាប់ការកែលម្អសេវា?

ពេលដែលប្រជាពលរដ្ឋត្រូវបានស្នើសុំឱ្យកំណត់សេវាដែលរដ្ឋបាលថ្នាក់ក្រោមជាតិគួរផ្តល់អាទិភាពខ្ពស់បំផុតសម្រាប់កែលម្អ ចំណាត់ថ្នាក់លទ្ធផលនៃអាទិភាព គឺមានភាពស៊ីសង្វាក់គ្នាយ៉ាងខ្លាំង សូម្បីតែរវាងតំបន់ដែលមានលក្ខណៈខុសគ្នា និងរវាងបុរស និងស្ត្រី។

ចំណាត់ថ្នាក់ជារួមដោយប្រជាពលរដ្ឋទូទាំងប្រទេស ( ប្រជាពលរដ្ឋត្រូវបានស្នើសុំឱ្យដាក់ចំណាត់ថ្នាក់សេវាចំនួន ៩ សេវាដែលបានជ្រើសរើសព្រោះសេវាទាំងនោះពាក់ព័ន្ធទាំងនៅតំបន់ទីប្រជុំជន និងតំបន់ជនបទ) បញ្ជីចំណាត់ថ្នាក់លទ្ធផលដែលទទួលបានគឺ (១). ផ្លូវថ្នល់ និងស្ពាន (២). ការគាំទ្រជនងាយរងគ្រោះ (៣). សេវាសុខភាព (៤). សេវាអប់រំ (៥). សុវត្ថិភាព និងសន្តិសុខសាធារណៈ (៦). ការផ្គត់ផ្គង់ទឹក (៧). សេវាសម្រាប់ស្ត្រី និងកុមារ (៨). ការគ្រប់គ្រងសំណល់រឹង (៩). អគ្គិសនី។

សេវាដែលអាចមានអាទិភាពទាប ព្រោះប្រជាពលរដ្ឋមិនមើលឃើញថា សេវានោះមានសារសំខាន់ឡើយ ហើយក៏អាចជាអាទិភាពទាប ព្រោះសេវាត្រូវបានគេមើលឃើញថាមានគុណភាពខ្ពស់រួចហើយ ឬដោយសារប្រជាពលរដ្ឋមិនយល់ឃើញថា ជាសេវាដែលរដ្ឋបាលថ្នាក់ក្រោមជាតិអាចកែលម្អបាននោះឡើយ។

តារាងខាងស្តាំគឺការប្រៀបធៀបការផ្តល់អាទិភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិជាមួយនឹងការវាយតម្លៃដោយប្រជាពលរដ្ឋអំពីគុណភាពសេវា (សំណួរ CIT.PER.១)។

| ចំណាត់ថ្នាក់ | សេវា | ការវាយតម្លៃគុណភាព |
|---|---|---|
| ១ | ផ្លូវ និងស្ពាន | ទាប |
| ២ | គាំទ្រប្រជាជនងាយរងគ្រោះ | មធ្យម |
| ៣ | សុខភាព | ខ្ពស់ |
| ៤ | ការអប់រំ | មធ្យម |
| ៥ | សន្តិសុខ និងសុវត្ថិភាព | មធ្យម |
| ៦ | ទឹកស្អាត | ទាប |
| ៧ | ស្ត្រី និងកុមារ | ខ្ពស់ |
| ៨ | សំណល់រឹង | ទាប |
| ៩ | អគ្គិសនី | ខ្ពស់ |

សេវាដែលត្រូវបានកំណត់ថាជាអាទិភាពខ្ពស់បំផុតសម្រាប់អនុវត្ត គឺ ផ្លូវថ្នល់ និងស្ពាន ប៉ុន្តែត្រូវបានវាយតម្លៃថាមានគុណភាពទាប ខណៈពេលដែលអគ្គិសនីត្រូវបានវាយតម្លៃថាមានគុណភាពខ្ពស់ និងជាអាទិភាពទាបបំផុតសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីកែលម្អ។ ទោះជាយ៉ាងណាក៏ដោយ សុខភាពគឺស្ថិតក្នុងចំណោមអាទិភាពខ្ពស់បំផុតសម្រាប់ការកែលម្អ ទោះបីជាត្រូវបានវាយតម្លៃគុណភាពខ្ពស់រួចហើយក៏ដោយ ដោយផ្អែកលើសារៈសំខាន់នៃសេវានេះសម្រាប់ជីវិតរបស់មនុស្ស។ ជាងនេះទៅទៀត អ្វីដែលគួរឱ្យភ្ញាក់ផ្អើល គឺការគ្រប់គ្រងសំរាមសំណល់រឹងត្រូវបានវាយតម្លៃថាមានគុណភាពទាប និងមានអាទិភាពទាបផងដែរ។ ដោយសារផលប៉ះពាល់ជាអវិជ្ជមាននៃការគ្រប់គ្រងសំណល់រឹងត្រូវបានមើលជាទូទៅថាអនុវត្តមិនសូវបានល្អ ជាពិសេសនៅតំបន់ជនបទ ដែលបញ្ហានេះអាចបង្ហាញពីតម្រូវការនៃការខិតខំប្រឹងប្រែងកាន់តែខ្លាំងឡើងក្នុងការលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីបញ្ហានេះ។

**ការឆ្លុះបញ្ចាំង៖ តើយើងអាចរៀនសូត្រអ្វីខ្លះពីការបែងចែកអាទិភាពសម្រាប់កែលម្អសេវា?**







ដូចដែលបានបង្ហាញនៅក្នុងក្រាហ្វិកខាងលើ វាមានភាពខុសប្លែកគ្នាតិចតួចរវាងចំណាត់ថ្នាក់ប្រជាពលរដ្ឋលើអាទិភាពសម្រាប់កែលម្អការផ្តល់សេវា រវាងបុរសធៀបនឹងស្ត្រី ឬរវាងតំបន់ជនបទ និងទីប្រជុំជន។

ទោះយ៉ាងណាក្តី ភាពខុសគ្នាខ្លះអាចត្រូវបានសង្កេតឃើញនៅពេលដែលយើងពិនិត្យលើចំណាត់ថ្នាក់នៃសេវាដែលបានជ្រើសរើស។ ក្នុងក្រាហ្វិកខាងក្រោម ចំណាត់ថ្នាក់ត្រូវបានដាក់បញ្រ្ចាស ដូច្នេះ ៩ គឺជាអាទិភាពខ្ពស់បំផុត និង ១ ជាអាទិភាពទាបបំផុត ដើម្បីងាយស្រួលក្នុងការអានក្រាហ្វិក។







នៅក្នុងក្រាហ្វិកនេះ យើងអាចមើលឃើញថា ការកែលម្អការអប់រំ និងការផ្គត់ផ្គង់ទឹកស្អាត ត្រូវបានគេមើលឃើញថាជាអាទិភាពទាបនៅក្នុងរាជធានីភ្នំពេញជាងតំបន់ផ្សេងទៀត។ ចំណុចនេះ អាចដោយសារសេវាមានគុណភាពល្អរួចទៅហើយ។ ផ្ទុយទៅវិញ សុវត្ថិភាពនិងសន្តិសុខ មានអាទិភាពខ្ពស់នៅក្នុងរាជធានីភ្នំពេញជាងនៅតំបន់ឆ្នេរ និងខេត្តទំនាប។ ផ្ទុយទៅវិញ សុវត្ថិភាពសាធារណៈនិងសន្តិសុខ និងការគ្រប់គ្រងសំណល់រឹង មានចំណាត់ថ្នាក់ខ្ពស់ជាងនៅក្នុងរាជធានីភ្នំពេញ។ ស្ត្រីបានវាយតម្លៃសេវាសម្រាប់ស្ត្រីនិងកុមារ និងសុវត្ថិភាពនិងសន្តិសុខ ខ្ពស់ជាងការវាយតម្លៃដោយបុរស ខណៈសាលារៀន ការប្រមូលសំរាម និងការផ្គត់ផ្គង់ទឹកស្អាតដែលវាយតម្លៃដោយស្ត្រីមានចំណាត់ថ្នាក់ខ្ពស់ជាងបុរសបន្តិច។

## ៥.៣.៣. តម្លៃសន្ទស្សន៍នៃការឆ្លើយតបដែលបានមកពីសំណាករដ្ឋបាលថ្នាក់ក្រោមជាតិ

ក្រុមប្រឹក្សាឃុំ សង្កាត់បានផ្តល់សារៈសំខាន់ខ្ពស់ចំពោះទស្សនៈរបស់ប្រជាពលរដ្ឋក្នុងការកំណត់អាទិភាពនៃការកសាងផែនការ និងការរៀបចំថវិកា។ ដោយឡែក អ្នកផ្តល់ព័ត៌មានដែលជាក្រុមប្រឹក្សា និងមន្ត្រីរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត បានយល់ថា មានកត្តាផ្សេងទៀតដែលមានសារៈសំខាន់ក្នុងការសម្រេចចិត្តនៃការកសាងផែនការ។ ថ្នាក់ដឹកនាំភូមិមានទំនុកចិត្តខ្ពស់ជាងប្រជាពលរដ្ឋអំពីការយល់ដឹងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទៅលើតម្រូវការរបស់ប្រជាពលរដ្ឋ និងព្យាយាមបំពេញតម្រូវការទាំងនោះ។

ពិន្ទុដែលបានវាយតម្លៃសម្រាប់សន្ទស្សន៍នៃការឆ្លើយតបពីក្រុមសំណាករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានសង្ខេបនៅក្នុងតារាងខាងក្រោម។ តម្លៃដែលបានវាយតម្លៃដោយថ្នាកដឹកនាំភូមិ និងឃុំ សង្កាត់

សម្រាប់ RES-III គឺស្ថិតក្នុងកម្រិត "ល្អ" ប៉ុន្តែតម្លៃផ្អែកលើចម្លើយរបស់អ្នកផ្តល់ព័ត៌មានជាមន្ត្រីក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត ស្ថិតក្នុងកម្រិតពី "មធ្យម" ទៅ "បង្គួរ"។

*តារាងរដ្ឋបាលថ្នាក់ក្រោមជាតិឆ្លើយតបទៅនឹងសំណួរពាក់ព័ន្ធនឹងសន្ទស្សន៍ការឆ្លើយតប*

| លេខសម្គាល់ | ការពិពណ៌នា | ពិន្ទុ | មេគុណ | តម្លៃ | កំហុសស្តង់ដា | ៩៥% ចន្លោះទំនុកចិត្ត | |
|---|---|---|---|---|---|---|---|
| | | | | | | ទាបបំផុត | ខ្ពស់បំផុត |
| ក.RES.២ | ការវាយតម្លៃរបស់ឃុំ សង្កាត់ស្តីពីការយល់ដឹងអំពីតម្រូវការរបស់ប្រជាពលរដ្ឋ | **០,៨២** | *០,៣៣* | ០,២៧ | *០,០០៨* | ០,៨១ | ០,៨៤ |
| ក.RES.៣ | ការវាយតម្លៃរបស់ក្រុង ស្រុកពីការយល់ដឹងអំពីតម្រូវការរបស់ប្រជាពលរដ្ឋ | **០,៧៧** | *០,៣៣* | ០,២៦ | *០,០០៩* | ០,៧៥ | ០,៧៩ |
| ក.RES.៤ | ការវាយតម្លៃរបស់រាជធានី ខេត្ត ស្តីពីការយល់ដឹងអំពីតម្រូវការរបស់ប្រជាពលរដ្ឋ | **០,៧៥** | *០,៣៣* | ០,២៥ | *០,០១០* | ០,៧៣ | ០,៧៧ |
| ក.RES-III | **ក្រុមប្រឹក្សា និងមន្ត្រីជឿថា អាទិភាពរបស់ប្រជាពលរដ្ឋមានសារៈសំខាន់បំផុតក្នុងការរៀបចំផែនការ និងថវិកា** | | | **០,៧៨** | ***០,០០៨*** | **០,៧៧** | **០,៨០** |
| ឃស.RES.២ | តើអ្វីជាឥទ្ធិពលសំខាន់បំផុតលើការរៀបចំផែនការរដ្ឋបាលថ្នាក់ក្រោមជាតិ | **០,៧១** | *១.០០* | ០,៧១ | *០,០០៣* | ០,៧០ | ០,៧១ |
| ឃស.RES-III | **ក្រុមប្រឹក្សា និងមន្ត្រីជឿថា អាទិភាពរបស់ប្រជាពលរដ្ឋមានសារៈសំខាន់បំផុតក្នុងការរៀបចំផែនការ និងថវិកា** | | | **០,៧១** | ***០,០០៩*** | **០,៦៩** | **០,៧៣** |
| កស៩.RES.២ | តើអ្វីជាឥទ្ធិពលសំខាន់បំផុតលើការរៀបចំផែនការរដ្ឋបាលថ្នាក់ក្រោមជាតិ | **០,៦៥** | *១.០០* | ០,៦៥ | *០,០០៨* | ០,៦៤ | ០,៦៧ |
| កស៩.RES-III | **ក្រុមប្រឹក្សា និងមន្ត្រីជឿថា អាទិភាពរបស់ប្រជាពលរដ្ឋមានសារៈសំខាន់បំផុតក្នុងការរៀបចំផែនការ និងថវិកា** | | | **០,៦៥** | ***០,០០៩*** | **០,៦៣** | **០,៦៧** |
| ៤៩.RES.២ | តើអ្វីជាឥទ្ធិពលសំខាន់បំផុតលើការរៀបចំផែនការរដ្ឋបាលថ្នាក់ក្រោមជាតិ | **០,៥៨** | *១.០០* | ០,៥៨ | - | ០,៥៨ | ០,៥៨ |
| ៤៩.RES-III | **ក្រុមប្រឹក្សា និងមន្ត្រីជឿថា អាទិភាពរបស់ប្រជាពលរដ្ឋមានសារៈសំខាន់បំផុតក្នុងការសម្រេចចិត្តរៀបចំផែនការ និងថវិកា** | | | **០,៥៨** | ***០,០២៨*** | **០,៥៣** | **០,៦៤** |

**ការឆ្លុះបញ្ចាំង ៖ តើអ្វីជាឥទ្ធិពលដ៏សំខាន់បំផុតលើការកសាងផែនការអភិវឌ្ឍន៍នៅថ្នាក់ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត?**

| ឥទ្ធិពលសំខាន់បំផុតលើការសម្រេចចិត្តអំពីការជ្រើសរើសគម្រោងមូលនិធិឃុំ សង្កាត់ | **% ជ្រើសរើសចម្លើយនេះ** | | |
|---|---|---|---|
| | **ទី១** | **ទី២** | **ទី៣** |
| អនុវត្តតាមការណែនាំពីថ្នាក់ជាតិ | ២៤% | ១០% | ១៥% |
| អនុវត្តតាមការណែនាំរបស់រដ្ឋបាលខេត្ត/រាជធានី | ៥% | ១០% | ៨% |
| អនុវត្តតាមការណែនាំរបស់រដ្ឋបាលក្រុង/ស្រុក/ខណ្ឌ | ២% | ១០% | ១៤% |
| មេឃុំ ចៅសង្កាត់ជាអ្នកដឹកនាំ ដូច្នេះគាត់ប្រើចំណេះដឹងខ្លួន ដើម្បីជ្រើសរើសគម្រោងសម្រាប់ប្រជាពលរដ្ឋ | ១៦% | ២២% | ២៤% |
| ក្រុមប្រឹក្សាឃុំ សង្កាត់ ប្រើប្រាស់ចំណេះដឹងរបស់ខ្លួន ដើម្បីជ្រើសរើសគម្រោងសម្រាប់ប្រជាពលរដ្ឋ | ១២% | ៣៣% | ១៦% |
| ក្រុមប្រឹក្សាឃុំសង្កាត់ជ្រើសរើសគម្រោងដែលមានការគាំទ្រច្រើនបំផុតពីប្រជាពលរដ្ឋ | ៤០% | ១៦% | ២២% |

- "ជ្រើសរើសគម្រោងដែលមានការគាំទ្រច្រើនបំផុតពីប្រជាពលរដ្ឋ" ត្រូវបានជ្រើសរើសនៅលំដាប់ទី១ ដោយ ៤០% នៃអ្នកឆ្លើយតបឃុំ សង្កាត់
- ជម្រើសបន្ទាប់គឺ "ធ្វើតាមការណែនាំពីថ្នាក់ជាតិ"។

| ឥទ្ធិពលដ៏សំខាន់បំផុតលើការសម្រេចចិត្តអំពីការជ្រើសរើសគម្រោងអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ | **% ជ្រើសរើសចម្លើយនេះ** | | |
|---|---|---|---|
| | **ទី១** | **ទី២** | **ទី៣** |
| គោលនយោបាយ និងការណែនាំពីថ្នាក់ជាតិ | ២៦% | ១០% | ៩% |
| គោលនយោបាយ និងការណែនាំពីរាជធានី/ខេត្ត | ៥% | ១១% | ១០% |
| ចំណេះដឹងរបស់គណៈភិបាល | ៦% | ១០% | ១២% |
| ការផ្តល់យោបល់ពីមន្ត្រីក្រុង/ខណ្ឌ ដែលមានជំនាញឯកទេស ឬអ្នកដែលប្រើប្រាស់ទិន្នន័យ ដើម្បីកំណត់គម្រោងសំខាន់ៗ | ៨% | ២២% | ២០% |
| ចំណេះដឹងរបស់ក្រុមប្រឹក្សាស្រុក/ក្រុង/ខណ្ឌ | ៣% | ១៣% | ១៥% |
| ស្នើសុំពីក្រុមប្រឹក្សាឃុំ សង្កាត់ | ៤% | ១៦% | ១៦% |
| អាទិភាពពីប្រជាពលរដ្ឋ (គម្រោងដែលទទួលបានការគាំទ្រច្រើនបំផុតពីប្រជាពលរដ្ឋក្នុងការប្រជុំផែនការជាដើម គឺជាគម្រោងដែលទទួលបានហិរញ្ញប្បទាន) | ៤៧% | ១៧% | ១៧% |

- ការឆ្លើយតបរបស់ក្រុង ស្រុក ខណ្ឌ គឺស្រដៀងទៅនឹងការឆ្លើយតបរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ការណែនាំអំពីគោលនយោបាយជាតិមានសារៈសំខាន់ ប៉ុន្តែការណែនាំពីថ្នាក់ខេត្តមានសារសំខាន់ផងដែរ។

| ឥទ្ធិពលដ៏សំខាន់បំផុតលើការសម្រេចចិត្តអំពីការជ្រើសរើសគម្រោងអភិវឌ្ឍន៍រាជធានី ខេត្ត | **% ជ្រើសរើសចម្លើយនេះ** | | |
|---|---|---|---|
| | **ទី១** | **ទី២** | **ទី៣** |
| គោលនយោបាយ និងការណែនាំពីថ្នាក់ជាតិ | ២៤% | ៩% | ១២% |
| ចំណេះដឹងរបស់ក្រុមប្រឹក្សាភិបាល | ១២% | ១៧% | ៨% |
| ចំណេះដឹងរបស់ក្រុមប្រឹក្សារាជធានី ខេត្ត | ៤% | ១១% | ១៩% |
| ការផ្តល់យោបល់របស់មន្ត្រីរដ្ឋបាលរាជធានី/ខេត្ត (សាលាខេត្ត) ដែលមានជំនាញឯកទេស ឬអ្នកដែលប្រើប្រាស់ទិន្នន័យដើម្បីកំណត់អត្តសញ្ញាណគម្រោងសំខាន់ៗ | ៨% | ២៤% | ១៧% |
| ការណែនាំពីមន្ទីរជំនាញខេត្ត ក្រសួងបច្ចេកទេស | ១% | ៨% | ៨% |
| សំណូមពរពីអាជ្ញាធរក្រុង ស្រុក ខណ្ឌ | ៣% | ៩% | ៥% |
| សំណើរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ | ០% | ១១% | ១១% |
| អាទិភាពពីប្រជាពលរដ្ឋ (គម្រោងដែលទទួលបានការគាំទ្រច្រើនបំផុតពីប្រជាពលរដ្ឋក្នុងការប្រជុំផែនការជាដើម គឺជាគម្រោងដែលទទួលបានហិរញ្ញប្បទាន) | ៤៧% | ១១% | ១៩% |

## ៥.៤. សន្ទស្សន៍វង់ពាក់ព័ន្ធនឹងតម្លាភាព

### ៥.៤.១. តម្លៃសូចនាករ




*រូបភាពសន្ទស្សន៍វង់នៃតម្លាភាព រួមទាំងពិន្ទុ និងមេគុណសូចនាករ*

ប្រជាពលរដ្ឋមានចំណេះដឹងតិចតួចអំពីរចនាសម្ព័ន្ធ និងតួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ចំណុចនេះបង្ហាញថា ការផ្សព្វផ្សាយព័ត៌មានមិនមានប្រសិទ្ធភាពពេញលេញនៅឡើយ។ ទោះជាយ៉ាងណាក៏ដោយ ក៏ប្រជាពលរដ្ឋមានជំនឿយ៉ាងមុតមាំថា ពួកគាត់មានសិទ្ធិទទួលបានព័ត៌មាន ក៏ប៉ុន្តែប្រជាពលរដ្ឋមានទំនុកចិត្តតិចតួចថា សេវារដ្ឋបាលថ្នាក់ក្រោមជាតិបានកំណត់តម្លៃដោយតម្លាភាព។ ក្រុមប្រឹក្សា និងមន្ត្រីបង្ហាញអាកប្បកិរិយាវិជ្ជមានយ៉ាងខ្លាំងចំពោះតម្លាភាព និងមានវិធីសាស្ត្រសម្រាប់ការផ្សព្វផ្សាយព័ត៌មានក្នុងកម្រិតមធ្យម។

*ចំណុចខ្លាំង និងចំណុចខ្សោយនៃតម្លាភាព*

| ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|
| • ប្រជាពលរដ្ឋមានជំនឿយ៉ាងថា ពួកគាត់មានសិទ្ធិដឹងអំពីការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ក្រុមប្រឹក្សា និងមន្ត្រីបានបង្ហាញអាកប្បកិរិយាជាវិជ្ជមានយ៉ាងខ្លាំងចំពោះតម្លាភាព។ | • ចំណេះដឹងរបស់ប្រជាពលរដ្ឋអំពីរចនាសម្ព័ន្ធ និងតួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានកម្រិត (ខ្សោយបន្តិច)<br>• ទំនុកចិត្តរបស់ប្រជាពលរដ្ឋដែលថាសេវារដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានដាក់តម្លៃប្រកបដោយតម្លាភាព គឺមានកម្រិតមធ្យម។ |

តម្លៃនៃសូចនាករតម្លាភាពចំនួនពីរផ្អែកលើចម្លើយរបស់ប្រជាពលរដ្ឋ និងសូចនាករចំនួនពីរផ្អែកលើចម្លើយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានបង្ហាញនៅក្នុងតារាងខាងក្រោម៖

*តារាងតម្លៃសូចនាករតម្លាភាព*

| សូចនាករ | ការពិពណ៌នា | សំណាក | ពិន្ទុ | មេគុណ | តម្លៃ | កំហុសស្តង់ដា | ៩៥% ចន្លោះទំនុកចិត្ត | |
|---|---|---|---|---|---|---|---|---|
| | | | | | | | ទាបបំផុត | ទាបបំផុត |
| TRA-I | ប្រជាពលរដ្ឋមានចំណេះដឹងអំពីរចនាសម្ព័ន្ធ និងតួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | បជ | **០,៤០** | *០,២៧* | ០,១១ | *០,០០៣* | ០,៣៩ | ០,៤១ |
| TRA-II | ប្រជាពលរដ្ឋជឿថា ពួកគាត់មានសិទ្ធិទទួលបានព័ត៌មានអំពីការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | បជ | **០,៧៦** | *០,២៧* | ០,២០ | *០,០០៥* | ០,៧៥ | ០,៧៧ |
| TRA-III | ប្រជាពលរដ្ឋជឿថា សេវារដ្ឋបាលថ្នាក់ក្រោមជាតិមានតម្លៃតម្លាភាព ហើយប្រជាពលរដ្ឋបង់ថ្លៃសេវាត្រឹមត្រូវ។ | បជ | **០,៥៧** | *០,១៣* | ០,០៨ | *០,០០៩* | ០,៥៥ | ០,៥៨ |
| TRA-IV | ក្រុមប្រឹក្សា និងមន្ត្រីមានអាកប្បកិរិយាវិជ្ជមានចំពោះតម្លាភាព | ភ | **០,៧៤** | *០,០៤* | ០,០៣ | *០,០០៧* | ០,៧៣ | ០,៧៥ |
| | | គ.ស | **០,៧៨** | *០,០៤* | ០,០៣ | *០,០០៤* | ០,៧៧ | ០,៧៩ |
| | | កសខ | **០,៧៥** | *០,០៤* | ០,០៣ | *០,០០៤* | ០,៧៥ | ០,៧៦ |
| | | រខ | **០,៧៦** | *០,០៤* | ០,០៣ | *០,០១៤* | ០,៧៣ | ០,៧៨ |
| TRA-V | ក្រុមប្រឹក្សា និងមន្ត្រីរាយការណ៍អំពីវិធីសាស្ត្រសកម្មក្នុងការផ្សព្វផ្សាយព័ត៌មាន | ភ | **០,៧៧** | *០,០៤* | ០,០៣ | *០,០០៧* | ០,៧៦ | ០,៧៩ |
| | | គ.ស | **០,៦៤** | *០,០៤* | ០,០៣ | *០,០០៤* | ០,៦៣ | ០,៦៥ |
| | | កសខ | **០,៦៤** | *០,០៤* | ០,០៣ | *០,០០៥* | ០,៦៣ | ០,៦៥ |
| | | រខ | **០,៦៩** | *០,០៤* | ០,០៣ | *០,០១៩* | ០,៦៦ | ០,៧៣ |
| **តម្លៃសន្ទស្សន៍រង** | | | | | **០,៦៣** | | | |

តម្លៃសូចនាករតម្លាភាពបែងចែងតាមតំបន់ទីប្រជុំជន តំបន់ជនបទ តាមភេទ និងតាមតំបន់ភូមិសាស្ត្រនានាមានបង្ហាញក្នុងតារាងខាងក្រោម។ តម្លៃសូចនាករតម្លាភាពនៅក្នុងរាជធានីភ្នំពេញ គឺខ្ពស់ជាងកន្លែងផ្សេងទៀត ទោះបីស្ថិតក្នុងកម្រិត "មធ្យម" ជារួមក៏ដោយ។

*តារាងតម្លៃសម្រាប់សូចនាករតម្លាភាពតាមតំបន់ទីប្រជុំជន តំបន់ជនបទ ភេទ និងតំបន់ភូមិសាស្ត្រ*

| សូចនាករ | អ្នកពិពណ៌នា | សំណាក | សរុប | ក្រុង ស្រុក ខណ្ឌ | | ភេទ | | តំបន់ភូមិសាស្ត្រ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ប្រជុំជន | ជនបទ | ស្រី | ប្រុស | ភ្នំពេញ | ទំនាប | ទន្លេសាប | ខ្ពង់រាប | សមុទ្រ |
| TRA-I | ប្រជាពលរដ្ឋមានចំណេះដឹងអំពីរចនាសម្ព័ន្ធ និងតួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | CIT | ០,៤០ | ០,៤៣ | ០,៣៩ | ០,៣៨ | ០,៤២ | ០,៤៥ | ០,៤៣ | ០,៣៦ | ០,៣៧ | ០,៤៥ |
| TRA-II | ប្រជាពលរដ្ឋជឿថា ពួកគាត់មានសិទ្ធិទទួលបានព័ត៌មានអំពីការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | CIT | ០,៧៦ | ០,៧៨ | ០,៧៥ | ០,៧៥ | ០,៧៧ | ០,៨២ | ០,៧៦ | ០,៦៩ | ០,៨០ | ០,៧៩ |
| TRA-III | ប្រជាពលរដ្ឋជឿថា សេវារដ្ឋបាលថ្នាក់ក្រោមជាតិមានតម្លៃតម្លាភាព ហើយប្រជាពលរដ្ឋបង់ថ្លៃសេវាត្រឹមត្រូវ | CIT | ០,៥៧ | ០,៦៤ | ០,៥៤ | ០,៥៤ | ០,៥៩ | ០,៦៨ | ០,៤៦ | ០,៥៨ | ០,៥៨ | ០,៧៤ |
| TRA-IV | ក្រុមប្រឹក្សា និងមន្ត្រីមានអាកប្បកិរិយាវិជ្ជមានចំពោះតម្លាភាព | VIL | ០,៧៤ | ០,៧៤ | ០,៧៤ | ០,៦៩ | ០,៧៥ | ០,៧៤ | ០,៧៥ | ០,៧៣ | ០,៧៣ | ០,៧៩ |
| | | CS | ០,៧៨ | ០,៧៩ | ០,៧៧ | ០,៧៨ | ០,៧៨ | ០,៨០ | ០,៨០ | ០,៧៦ | ០,៧៧ | ០,៧៤ |
| | | DMK | ០,៧៥ | ០,៧៨ | ០,៧៥ | ០,៧៤ | ០,៧៦ | ០,៧៨ | ០,៧៦ | ០,៧៣ | ០,៧៦ | ០,៧៥ |
| | | CP | ០,៧៦ | - | - | ០,៧៧ | ០,៧៥ | ០,៨២ | ០,៧៨ | ០,៧៣ | ០,៧៣ | ០,៨០ |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| TRA-V | ក្រុមប្រឹក្សា និងមន្ត្រីរាយការណ៍អំពីវិធីសាស្ត្រសកម្មក្នុងការផ្សព្វផ្សាយព័ត៌មាន | VIL | ០,៧៧ | ០,៧៧ | ០,៧៧ | ០,៧៦ | ០,៧៨ | ០,៨២ | ០,៨២ | ០,៧៥ | ០,៧៣ | ០,៨១ |
| | | CS | ០,៦៤ | ០,៦៥ | ០,៦៤ | ០,៦៣ | ០,៦៤ | ០,៦៦ | ០,៦៥ | ០,៦៤ | ០,៦២ | ០,៦៥ |
| | | DMK | ០,៦៤ | ០,៦៨ | ០,៦២ | ០,៥៧ | ០,៦៤ | ០,៦៤ | ០,៦១ | ០,៦២ | ០,៦៣ | ០,៦៩ |
| | | CP | ០,៦៩ | - | - | ០,៧១ | ០,៦៩ | ០,៨០ | ០,៧២ | ០,៦៤ | ០,៦៨ | ០,៧៣ |
| **តម្លៃរងសន្ទស្សន៍** | | | **០,៦២** | **០,៦៥** | **០,៦១** | **០,៦១** | **០,៦៣** | **០,៦៨** | **០,៦២** | **០,៥៩** | **០,៦២** | **០,៦៧** |

## ៥.៤.២. តម្លៃតម្លាភាពដែលបានពីចម្លើយសំណាកប្រជាពលរដ្ឋ

ប្រជាពលរដ្ឋយល់ដឹងអំពីដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ច្រើនជាងការយល់ដឹងអំពីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត និងអំពីការតែងតាំងគណៈអភិបាល។ ប្រជាពលរដ្ឋមិនមានការយល់ដឹងច្រើនអំពី កជទី២ ឬមិនមានការយល់ដឹងច្រើនអំពីកិច្ចការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ក៏ប៉ុន្តែប្រជាពលរដ្ឋមានទំនុកចិត្តថាអាចស្វែងរកព័ត៌មានបានប្រសិនបើពួកគាត់ត្រូវការ។

*តារាងការឆ្លើយតបរបស់ប្រជាពលរដ្ឋចំពោះសំណួរតម្លាភាព*

| លេខសម្គាល់ | អ្នកពិពណ៌នា | ពិន្ទុ | ទម្ងន់ | តម្លៃ | កំហុសស្តង់ដា | ៩៥% ចន្លោះទំនុកចិត្ត | |
|---|---|---|---|---|---|---|---|
| | | | | | | ទាបបំផុត | ខ្ពស់បំផុត |
| បជ.TRA.១ | ចំណេះដឹងអំពីការជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ | **០,៨២** | *០,១០* | ០,០៨ | *០,០០៩* | ០,៨១ | ០,៨៤ |
| បជ.TRA.២ | ចំណេះដឹងអំពីការជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ | **០,២៤** | *០,១០* | ០,០២ | *០,០១០* | ០,២៣ | ០,២៦ |
| បជ.TRA.៣ | ចំណេះដឹងអំពីការតែងតាំងគណៈអភិបាលក្រុង ស្រុក ខណ្ឌ | **០,២១** | *០,១០* | ០,០២ | *០,០០៩* | ០,១៩ | ០,២៣ |
| បជ.TRA.៤ | ការយល់ដឹងអំពីកម្មវិធីជាតិ | **០,៣៥** | *០,១០* | ០,០៤ | *០,០០៧* | ០,៣៤ | ០,៣៧ |
| បជ.TRA.៥ | ចំណេះដឹងអំពីតួនាទី ផែនការ ថវិកា និងសកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ | **០,២៧** | *០,៣០* | ០,០៨ | *០,០០៥* | ០,២៦ | ០,២៧ |
| បជ.TRA.៦ | តើអ្នកផ្តល់ព័ត៌មានដឹងពីរបៀបទទួលបានព័ត៌មានអំពីកិច្ចការរដ្ឋបាលថ្នាក់ក្រោមជាតិទេ? | **០,៥២** | *០,៣០* | ០,១៦ | *០,០០៧* | ០,៥១ | ០,៥៤ |
| **បជ.TRA-I** | ប្រជាពលរដ្ឋមានចំណេះដឹងអំពីរចនាសម្ព័ន្ធ និងតួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | | | **០,៤០** | ***០,០០៣*** | **០,៣៩** | **០,៤១** |
| បជ.TRA.៧ | ទស្សនៈអំពីសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មានអំពីតួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | **០,៧៦** | *១.០០* | ០,៧៦ | *០,០០៦* | ០,៧៤ | ០,៧៧ |
| **បជ.TRA-II** | ប្រជាពលរដ្ឋជឿថា ពួកគាត់មានសិទ្ធិទទួលបានព័ត៌មានពីការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | | | **០,៧៦** | ***០,០០៥*** | **០,៧៥** | **០,៧៧** |
| បជ.TRA.៩ | តើអ្នកទទួលសេវារដ្ឋបាលត្រូវបានជូនដំណឹងអំពីតម្លៃត្រឹមត្រូវយ៉ាងដូចម្តេច? | **០,៤៨** | *០,៥០* | ០,២៤ | *០,០២៨* | ០,៤២ | ០,៥៣ |
| បជ.TRA.១០ | តើអ្នកទទួលសេវាបង់ថ្លៃត្រឹមត្រូវសម្រាប់សេវារដ្ឋបាលឬទេ? | **០,៦៦** | *០,៥០* | ០,៣៣ | *០,០៣២* | ០,៥៩ | ០,៧២ |
| បជ.TRA-III | ប្រជាពលរដ្ឋជឿថា សេវារដ្ឋបាលថ្នាក់ក្រោមជាតិមានតម្លៃប្រកបដោយតម្លាភាព ហើយប្រជាពលរដ្ឋបង់ថ្លៃសេវាត្រឹមត្រូវ | | | **០,៥៧** | ***០,០០៩*** | **០,៥៥** | **០,៥៨** |

### ការឆ្លុះបញ្ចាំង ៖ តើប្រជាពលរដ្ឋដឹងអ្វីខ្លះអំពីរដ្ឋបាលថ្នាក់ក្រោមជាតិ?

តារាងខាងក្រោមបង្ហាញអំពីភាគរយនៃប្រជាពលរដ្ឋដែលអាចជ្រើសរើសចម្លើយត្រឹមត្រូវចំពោះសំណួរអំពី៖

| តើប្រជាពលរដ្ឋដឹងឬទេអំពី? | **ទាំងអស់** | **ទីប្រជុំជន** | **ជនបទ** | **ស្រី** | **ប្រុស** | **យុវជន** | **ប័ណ្ណក្រីក្រ** | **ពិការភាព** |
|---|---|---|---|---|---|---|---|---|
| ការជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ | **៨២%** | ៨៦% | ៨២% | ៨២% | ៨៤% | ៧៩% | ៧៩% | ៧៥% |
| ការជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ | **២៤%** | ២៤% | ២៥% | ២០% | 30% | ២៥% | ២១% | ២២% |
| ការតែងតាំងគណៈអភិបាលក្រុង ស្រុក ខណ្ឌ | **២១%** | ២៦% | ២០% | ១៧% | ២៦% | ១៧% | ១៧% | ៣៦% |
| ដឹងច្បាស់អំពីកជទី២ | **៩%** | ១០% | ៩% | ៧% | ១១% | ៧% | ៨% | ៤% |

តារាងខាងក្រោមបង្ហាញ % នៃប្រជាពលរដ្ឋដែលឆ្លើយថាពួកគាត់យល់ "មួយចំនួន" ឬ "ច្រើន" អំពី

| តើប្រជាពលរដ្ឋដឹងទេ? | **ទាំងអស់** | **ទីក្រុង** | **ជនបទ** | **ស្រី** | **ប្រុស** | **យុវជន** | **ប័ណ្ណក្រីក្រ** | **ពិការភាព** |
|---|---|---|---|---|---|---|---|---|
| តួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សារាជធានី ខេត្ត | **៩%** | ១១% | ៨% | ៧% | ១២% | 3% | ១២% | ៩% |
| អាទិភាពនៃការធ្វើផែនការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ | **៧%** | ១០% | ៦% | ៦% | ៩% | 3% | ៨% | ៤% |
| ថវិការបស់ក្រុមប្រឹក្សាឃុំ សង្កាត់ | **៥%** | ៥% | ៤% | ៤% | ៦% | ១% | ៤% | ៥% |
| គម្រោងអ្វីដែលក្រុមប្រឹក្សាឃុំសង្កាត់បានអនុវត្ត | **១៩%** | ២3% | ១៧% | ១៥% | ២២% | ១២% | ២១% | ១៥% |




**ថ្វីត្បិតតែចំណេះដឹងរបស់ប្រជាពលរដ្ឋមានកម្រិតក៏ដោយ ប៉ុន្តែពួកគាត់ជឿថា ពួកគាត់ត្រូវទទួលបានព័ត៌មាន។**

- ប្រជាពលរដ្ឋមានភាពងាយស្រួលក្នុងការទទួលបានព័ត៌មានអំពីឃុំ សង្កាត់ និងកាន់តែងាយស្រួលក្នុងការទទួលបានព័ត៌មានពីថ្នាក់ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត
- អ្នករស់នៅក្នុងទីប្រជុំជនកាន់តែមានទំនុកចិត្តថាពួកគាត់អាចទទួលបានព័ត៌មាន
- ស្ត្រីមានចំនួនតិចជាងបុរសបន្តិច ប៉ុន្តែភាពខុសគ្នាគឺតូច (៥៨% / ៦0% សម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់)
- យុវជន (អ្នកផ្តល់ព័ត៌មានដែលមានអាយុរហូតដល់៣0ឆ្នាំ) ហាក់ដូចជាមិនសូវប្រាកដថាពួកគេអាចទទួលបានព័ត៌មាននោះទេ។

*របៀបដែលប្រជាពលរដ្ឋដឹងពីតម្លៃសេវារដ្ឋបាលថ្នាក់ក្រោមជាតិ*

**ការឆ្លុះបញ្ចាំង៖ តើប្រជាពលរដ្ឋដឹងពីតម្លៃត្រឹមត្រូវនៃការផ្តល់សេវារដ្ឋបាលថ្នាក់ក្រោមជាតិដោយរបៀបណា?**




**ក្នុងចំណោមអ្នកផ្តល់ព័ត៌មានជាប្រជាពលរដ្ឋដែលបានរាយការណ៍ថាខ្លួនបានទៅការិយាល័យរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីទទួលសេវា គឺមានតែ ២៥% ប៉ុណ្ណោះដែលចងចាំថាបានឃើញបញ្ជីតម្លៃដែលបង្ហាញយ៉ាងច្បាស់។**

- ប្រាកដណាស់ ប្រជាពលរដ្ឋមួយចំនួនប្រហែលជាបានសួរអំពីតម្លៃសេវាជាមុន ដោយមិនបានរកមើលតារាងតម្លៃដែលបានបង្ហាញ។ ទន្ទឹមនេះ មិនមែនប្រជាពលរដ្ឋទាំងអស់ចេះអាននោះទេ។
- ទោះជាយ៉ាងណាក៏ដោយ ស្ទើរតែមួយភាគបីនៃប្រជាពលរដ្ឋនិយាយថា ពួកគាត់មិនបានរកឃើញតម្លៃសម្រាប់ការផ្តល់សេវាសេវានោះឡើយ។

## ៥.៤.៣. តម្លៃតម្លាភាពដែលបានពីចម្លើយសំណាកមន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិ

ថ្នាក់ដឹកនាំភូមិមានចំណេះដឹងច្រើនជាងប្រជាពលរដ្ឋអំពីតួនាទីរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និង អំពី កជទី២។ ទោះជាយ៉ាងណាក៏ដោយ ក៏ក្រុមប្រឹក្សាឃុំ សង្កាត់មិនសូវមានចំណេះដឹងអំពីដំណើរការជ្រើសរើសគណៈអភិបាលក្រុង ស្រុក ខណ្ឌឡើយ។ អ្នកផ្តល់ព័ត៌មានជាមន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិមានទំនោរប៉ាន់ស្មានចំណេះដឹងរបស់ប្រជាពលរដ្ឋខ្ពស់អំពីការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រុមសំណាកទាំងអស់បានអះអាងថា ប្រជាពលរដ្ឋមានសិទ្ធិទទួលបានព័ត៌មាន។

តារាងខាងក្រោមសង្ខេបអំពីពិន្ទុរបស់អ្នកផ្តល់ព័ត៌មានជាមន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់សំណួរតម្លាភាព និងតម្លៃសូចនាករ ដែលបានបែងចែកតាមថ្នាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

*រដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្លើយតបទៅនឹងសំណួរអំពីតម្លាភាព*

| លេខសម្គាល់ | ការពិពណ៌នា | ពិន្ទុ | ទម្ងន់ | តម្លៃ | កំហុសស្តង់ដា | ៩៥% ចន្លោះទំនុកចិត្ត | |
|---|---|---|---|---|---|---|---|
| | | | | | | ទាបបំផុត | ធំបំផុត |
| ភ.TRA.១ | ចំណេះដឹងអំពីការជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ | **០,៩៤** | *០,១០* | ០,០៩ | *០,០១០* | ០,៩២ | ០,៩៦ |
| ភ.TRA.២ | ចំណេះដឹងអំពីការជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ | **០,៧៦** | *០,១០* | ០,០៨ | *០,០២០* | ០,៧២ | ០,៨០ |
| ភ.TRA.៣ | ចំណេះដឹងអំពីការជ្រើសរើសគណៈអភិបាលក្រុង ស្រុក | **០,៤២** | *០,១០* | ០,០៤ | *០,០២៥* | ០,៣៧ | ០,៤៧ |
| ភ.TRA.៤ | ការយល់ដឹងអំពីកម្មវិធីជាតិស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ | **០,៧៥** | *០,១០* | ០,០៧ | *០,០១៥* | ០,៧២ | ០,៧៨ |
| ភ.TRA.៥ | ចំណេះដឹងអំពីតួនាទី ផែនការ ថវិកា និងសកម្មភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ | **០,៥០** | *០,១០* | ០,០៥ | *០,០០៨* | ០,៤៨ | ០,៥១ |
| ភ.TRA.៧ | ទស្សនៈយល់ដឹងអំពីសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មានអំពីការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | **០,៨១** | *០,៥០* | ០,៤០ | *០,០១០* | ០,៧៩ | ០,៨៣ |
| **ភ.TRA-IV** | **ក្រុមប្រឹក្សា មន្ត្រីមានអាកប្បកិរិយាវិជ្ជមានចំពោះតម្លាភាព** | | | **០,៧៤** | ***០,០០៧*** | **០,៧៣** | **០,៧៥** |
| ឃស.TRA.១ | ការវាយតម្លៃអំពីចំណេះដឹងរបស់ប្រជាពលរដ្ឋអំពីការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | **០,៦២** | *០,៤០* | ០,២៥ | *០,០០៥* | ០,៦១ | ០,៦២ |

| លេខសម្គាល់ | ការពិពណ៌នា | ពិន្ទុ | ទម្ងន់ | តម្លៃ | កំហុសស្តង់ដា | ៩៥% ចន្លោះទំនុកចិត្ត | |
|---|---|---|---|---|---|---|---|
| | | | | | | ទាបបំផុត | ធំបំផុត |
| យស.TRA.២ | ទស្សនៈយល់ដឹងអំពីសិទ្ធិប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មានអំពីការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | **០,៨៩** | *០,៦០* | ០,៥៣ | *០,០០៥* | ០,៨៨ | ០,៩០ |
| **យស.TRA-IV** | **ក្រុមប្រឹក្សា មន្ត្រីមានអាកប្បកិរិយាវិជ្ជមានចំពោះតម្លាភាព** | | | **០,៧៨** | ***០,០០៤*** | **០,៧៧** | **០,៧៩** |
| កសខ.TRA.១ | ការវាយតម្លៃអំពីចំណេះដឹងរបស់ប្រជាពលរដ្ឋអំពីការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | **០,៥៥** | *០,៤០* | ០,២២ | *០,០០៥* | ០,៥៣ | ០,៥៦ |
| កសខ.TRA.២ | ទស្សនៈយល់ដឹងអំពីសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មានអំពីការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | **០,៨៩** | *០,៦០* | ០,៥៤ | *០,០០៥* | ០,៨៨ | ០,៩០ |
| **កសខ.TRA-IV** | **ក្រុមប្រឹក្សា/មន្ត្រីមានអាកប្បកិរិយាវិជ្ជមានចំពោះតម្លាភាព** | | | **០,៧៥** | ***០,០០៤*** | **០,៧៥** | **០,៧៦** |
| រខ.TRA.១ | ការវាយតម្លៃអំពីចំណេះដឹងរបស់ប្រជាពលរដ្ឋអំពីការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | **០,៥៦** | *០,៤០* | ០,២២ | *០,០១៨* | ០,៥២ | ០,៥៩ |
| រខ.TRA.២ | ទស្សនៈអំពីសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មានអំពីការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | **០,៨៩** | *០,៦០* | ០,៥៣ | *០,០៤៣* | ០,៨០ | ០,៩៧ |
| **រខ.TRA-IV** | **ក្រុមប្រឹក្សា/មន្ត្រីមានអាកប្បកិរិយាវិជ្ជមានចំពោះតម្លាភាព** | | | **០,៧៦** | ***០,០១៤*** | **០,៧៣** | **០,៧៨** |
| ភ.TRA.៦ | តើអ្នកផ្តល់ព័ត៌មានដឹងពីរបៀបទទួលបានព័ត៌មានអំពីការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិឬទេ? | **០,៦៣** | *០,៤០* | ០,២៥ | *០,០១០* | ០,៦១ | ០,៦៥ |
| ភ.TRA.៨ | តើអ្នកប្រើប្រាស់សេវារដ្ឋបាលត្រូវបានជូនដំណឹងអំពីតម្លៃត្រឹមត្រូវសម្រាប់សេវាយ៉ាងដូចម្តេច? | **០,៨២** | *០,៤០* | ០,៣៣ | *០,០១២* | ០,៨០ | ០,៨៤ |
| ភ.TRA.៩ | តើអ្នកប្រើប្រាស់សេវារដ្ឋបាលឬទេ បានបង់ថ្លៃត្រឹមត្រូវឬទេ? | **០,៩៧** | *០,២០* | ០,១៩ | *០,០០៧* | ០,៩៦ | ០,៩៨ |
| **ភ.TRA-V** | **ក្រុមប្រឹក្សា និងមន្ត្រីរាយការណ៍អំពីវិធីសាស្ត្រក្នុងការផ្សព្វផ្សាយព័ត៌មាន** | | | **០,៧៧** | ***០,០០៧*** | **០,៧៦** | **០,៧៩** |
| យស.TRA.៣ | តើរដ្ឋបាលថ្នាក់ក្រោមជាតិ ចែករំលែកព័ត៌មានប្រភេទណាដល់ប្រជាពលរដ្ឋ? | **០,៧៦** | *០,៤០* | ០,៣០ | *០,០០៦* | ០,៧៤ | ០,៧៧ |
| យស.TRA.៤ | រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រើប្រាស់មធ្យោបាយអ្វី ដើម្បីចែករំលែកព័ត៌មាន? | **០,៣៨** | *០,៤០* | ០,១៥ | *០,០០៥* | ០,៣៧ | ០,៣៩ |
| យស.TRA.៥ | តើអ្នកប្រើប្រាស់សេវារដ្ឋបាលត្រូវបានជូនដំណឹងអំពីតម្លៃត្រឹមត្រូវសម្រាប់សេវាយ៉ាងដូចម្តេច? | **០,៩០** | *០,១០* | ០,០៩ | *០,០០៧* | ០,៨៩ | ០,៩១ |
| យស.TRA.៦ | តើអ្នកប្រើប្រាស់បង់ថ្លៃត្រឹមត្រូវសម្រាប់សេវារដ្ឋបាលទេ? | **០,៩៧** | *០,១០* | ០,១០ | *០,០០៤* | ០,៩៦ | ០,៩៨ |
| **យស.TRA-V** | **ក្រុមប្រឹក្សា និងមន្ត្រីរាយការណ៍អំពីវិធីសាស្ត្រសកម្មក្នុងការផ្សព្វផ្សាយព័ត៌មាន** | | | **០,៦៤** | ***០,០០៤*** | **០,៦៣** | **០,៦៥** |
| កសខ.TRA.៣ | តើរដ្ឋបាលថ្នាក់ក្រោមជាតិ ចែករំលែកព័ត៌មានប្រភេទណាខ្លះដល់ប្រជាពលរដ្ឋ? | **០,៧១** | *០,៤០* | ០,២៨ | *០,០០៨* | ០,៦៩ | ០,៧៣ |
| កសខ.TRA.៤ | រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រើប្រាស់មធ្យោបាយអ្វី ដើម្បីចែករំលែកព័ត៌មាន? | **០,៤១** | *០,៤០* | ០,១៧ | *០,០០៧* | ០,៤០ | ០,៤៣ |
| កសខ.TRA.៥ | តើអ្នកប្រើប្រាស់សេវារដ្ឋបាលត្រូវបានជូនដំណឹងអំពីតម្លៃត្រឹមត្រូវសម្រាប់សេវាយ៉ាងដូចម្តេច? | **០,៩០** | *០,១០* | ០,០៩ | *០,០០៧* | ០,៨៩ | ០,៩១ |
| កសខ.TRA.៦ | តើអ្នកប្រើប្រាស់សេវារដ្ឋបាលបានបង់ថ្លៃសេវាត្រឹមត្រូវទេ? | **០,៩៨** | *០,១០* | ០,១០ | *០,០០៤* | ០,៩៨ | ០,៩៩ |
| **កសខ.TRA-V** | **ក្រុមប្រឹក្សា និងមន្ត្រីរាយការណ៍អំពីវិធីសាស្ត្រសកម្មក្នុងការផ្សព្វផ្សាយព័ត៌មាន** | | | **០,៦៤** | ***០,០០៥*** | **០,៦៣** | **០,៦៥** |
| រខ.TRA.៣ | តើរដ្ឋបាលថ្នាក់ក្រោមជាតិ ចែករំលែកព័ត៌មានប្រភេទណាដល់ប្រជាពលរដ្ឋ? | **០,៧១** | *០,៤០* | ០,២៨ | *០,០៣៤* | ០,៦៤ | ០,៧៨ |
| រខ.TRA.៤ | រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រើប្រាស់មធ្យោបាយអ្វី ដើម្បីចែករំលែកព័ត៌មាន? | **០,៥៦** | *០,៤០* | ០,២២ | *០,០៣០* | ០,៥០ | ០,៦២ |

| លេខសម្គាល់ | ការពិពណ៌នា | ពិន្ទុ | ទម្ងន់ | តម្លៃ | កំហុសស្តង់ដា | ៩៥% ចន្លោះទំនុកចិត្ត | |
|---|---|---|---|---|---|---|---|
| | | | | | | ទាបបំផុត | ធំបំផុត |
| ៗខ.TRA.៥ | តើអ្នកប្រើប្រាស់សេវារដ្ឋបាលត្រូវបានជូនដំណឹងអំពីតម្លៃត្រឹមត្រូវសម្រាប់សេវាយ៉ាងដូចម្តេច? | **0,៩១** | *0,១0* | 0,0៩ | *0,0៤៧* | 0,៨២ | ១.00 |
| ៗខ.TRA.៦ | តើអ្នកប្រើប្រាស់សេវារដ្ឋបាលបានបង់ថ្លៃសេវាត្រឹមត្រូវឬទេ? | **0,៩៥** | *0,១0* | 0,១0 | *0,0២៥* | 0,៩0 | ១.00 |
| ៗខ.TRA-V | **តើអ្នកប្រើប្រាស់សេវារដ្ឋបាលត្រូវបានជូនដំណឹងអំពីតម្លៃត្រឹមត្រូវសម្រាប់សេវាកម្មយ៉ាងដូចម្តេច?** | | | **0,៦៩** | ***0,0១៩*** | **0,៦៦** | **0,៧៣** |

## ៥.៥. សន្ទស្សន៍រងពាក់ព័ន្ធនឹងគណនេយ្យភាព

### ៥.៥.១. តម្លៃសូចនាករ

**ពិន្ទុ (ចន្លោះពី0ទៅ១)**




ប្រជាពលរដ្ឋមានចំណេះដឹងតិចតួចអំពីនីតិវិធីដាក់បណ្ដឹងតវ៉ា ទោះបីមន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិបានឆ្លើយថា មានយន្តការទទួលបណ្ដឹងតវ៉ាដែលមានចំណាត់ថ្នាក់បង្គួរ ឬមានប្រសិទ្ធភាពល្អក៏ដោយ។ ចំនួនពិតប្រាកដនៃបណ្ដឹងតវ៉ាដែលបានដោះស្រាយ គឺមានតិចតួច។ ប្រជាពលរដ្ឋ និងមន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិមិនជឿជាក់ខ្លាំងទេថា សំឡេងឆ្នោតគាំទ្រពីប្រជាពលរដ្ឋ គឺជាការដាក់ទណ្ឌកម្មប្រកបដោយប្រសិទ្ធភាពចំពោះការអនុវត្តការងារមិនបានល្អរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ទាំងប្រជាពលរដ្ឋ និងមន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិមានទំនុកចិត្តជាបង្គួរថា សមាជិកក្រុមប្រឹក្សា និងមន្ត្រីអាចត្រូវបានដាក់ទណ្ឌកម្ម បើសិនជាអនុវត្តការងារមិនបានល្អ ឬការបំពានច្បាប់។

*ចំណុចខ្លាំង និងចំណុចខ្សោយ៖ គណនេយ្យភាព*

| **ចំណុចខ្លាំង** | **ចំណុចខ្សោយ** |
|---|---|
| ក្រុមអ្នកផ្តល់ព័ត៌មានទាំងអស់មានទំនុកចិត្តជាមធ្យមថា ក្រុមប្រឹក្សា និងមន្ត្រីអាចត្រូវបានដាក់ពិន័យ ឬមានទោសចំពោះការបំពេញការងារមិនបានល្អ ឬការបំពានច្បាប់។ | • ចំណេះដឹង និងបទពិសោធន៍របស់ប្រជាពលរដ្ឋក្នុងការដោះស្រាយបណ្តឹងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅមានកម្រិតទាប។ មានប្រជាពលរដ្ឋចំនួនតិចតួចណាស់ដែលដឹងអំពីការិយាល័យប្រជាពលរដ្ឋ។<br>• ប្រជាពលរដ្ឋ និងអ្នកផ្តល់ព័ត៌មានជាមន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិមានជំនឿតិចតួចថា សំឡេងឆ្នោតរបស់ប្រជាពលរដ្ឋជះឥទ្ធិពលដល់ការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ |

វិធានការវាស់វែងសន្ទស្សន៍ផ្នែកគណនេយ្យភាពចំនួនបីត្រូវបានអនុវត្តនៅក្នុងការអង្កេតនេះ។ វិធានការ**ទី១** គឺការវាស់វែងលើយល់ដឹងរបស់ប្រជាពលរដ្ឋអំពីយន្តការដាក់បណ្តឹងតវ៉ាចំពោះការអនុវត្តមិនបានល្អរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងឆន្ទៈក្នុងការដាក់បណ្តឹងតវ៉ា និងការវាយតម្លៃលើនីតិវិធីនៃការដោះស្រាយបណ្តឹងជាក់ស្តែងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ **ទី២** គឺការពិនិត្យ វាយតម្លៃលើទំនុកចិត្តរបស់ក្រុមសំណាកទាំងអស់ទៅលើប្រសិទ្ធភាពនៃគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ពោលគឺទំនាក់ទំនងរវាងការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការសម្រេចចិត្តបោះឆ្នោតរបស់ប្រជាពលរដ្ឋ។ **ទី៣** គឺទាំងប្រជាពលរដ្ឋ និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានសួរឱ្យវាយតម្លៃអំពីលទ្ធភាពដែលសមាជិកក្រុមប្រឹក្សា ឬមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិប្រព្រឹត្តខុស ឬបំពានច្បាប់អាចនឹងត្រូវទទួលរងការដាក់វិន័យ និងទណ្ឌកម្មផ្លូវច្បាប់។

*តារាងតម្លៃសូចនាករគណនេយ្យភាព*

| **សូចនាករ** | **ការពិពណ៌នា** | **សំណាក** | **ពិន្ទុ** | **ទម្ងន់** | **តម្លៃ** | **កំហុសស្តង់ដា** | **៩៥% ចន្លោះទំនុកចិត្ត** | |
|---|---|---|---|---|---|---|---|---|
| | | | | | | | **តម្លៃទាបបំផុត** | **តម្លៃខ្ពស់បំផុត** |
| ACC-I | ប្រជាពលរដ្ឋជឿថាគាត់មានលទ្ធភាពប្តឹងតវ៉ា បើគាត់មិនពេញចិត្តនឹងការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយបណ្តឹងទាំងនេះត្រូវបានទទួល និងដោះស្រាយយ៉ាងត្រឹមត្រូវ | បជ | **0,៥0** | *0,២២* | 0,១១ | *0,00៧* | 0,៤៨ | 0,៥១ |
| ACC-II | ប្រជាពលរដ្ឋជឿថា ការបោះឆ្នោតរបស់ខ្លួនអាចដាក់ទណ្ឌកម្មយ៉ាងមានប្រសិទ្ធភាពចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិដែលបំពេញការងារមិនបានល្អ | បជ | **0,៤៧** | *0,២២* | 0,១0 | *0,00៥* | 0,៤៦ | 0,៤៨ |
| ACC-III | ប្រជាពលរដ្ឋជឿថា មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សានឹងត្រូវទទួលទោស ប្រសិនបើប្រព្រឹត្តខុស ឬប្រព្រឹត្តល្មើសច្បាប់ | បជ | **0,៦៤** | *0,២២* | 0,១៤ | *0,00៦* | 0,៦៣ | 0,៦៥ |
| ACC-IV | ក្រុមប្រឹក្សា និងមន្ត្រីរាយការណ៍ថា មានយន្តការដោះស្រាយបណ្តឹងដ៏មានប្រសិទ្ធភាព | ភ | **0,៤៦** | *0,0៣* | 0,0១ | *0,0២៥* | 0,៤១ | 0,៥១ |
| | | ឃុំ សង្កាត់ | **0,៦២** | *0,0៣* | 0,0២ | *0,00៥* | 0,៦១ | 0,៦៣ |
| | | DMK | **0,៦៣** | *0,0៣* | 0,0២ | *0,00៨* | 0,៦១ | 0,៦៤ |
| | | រខ | **0,៧0** | *0,0៣* | 0,0២ | *0,0១៨* | 0,៦៦ | 0,៧៣ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ACC-V | ក្រុមប្រឹក្សានិងមន្ត្រីនិយាយថា ពួកគេមានតម្រូវការទាក់ទាញសំឡេងឆ្នោតក្នុងការបោះឆ្នោតនាពេលអនាគត | ភ | **០,៤៤** | *០,០៣* | ០,០១ | *០,០១៣* | ០,៤១ | ០,៤៦ |
| | | ឃុំ សង្កាត់ | **០,៤១** | *០,០៣* | ០,០១ | *០,០០៩* | ០,៣៩ | ០,៤២ |
| | | DMK | **០,៤២** | *០,០៣* | ០,០១ | *០,០០៩* | ០,៤១ | ០,៤៤ |
| | | រខ | **០,៤១** | *០,០៣* | ០,០១ | *០,០៣២* | ០,៣៥ | ០,៤៧ |
| ACC-VI | ក្រុមប្រឹក្សា និងមន្ត្រីនិយាយថា ពួកគេនឹងត្រូវទទួលទោស ប្រសិនបើពួកគេបំពេញការងារមិនល្អ ឬល្មើសច្បាប់ | ភ | **០,៧១** | *០,០៣* | ០,០២ | *០,០១១* | ០,៦៩ | ០,៧៣ |
| | | ឃុំ សង្កាត់ | **០,៦៣** | *០,០៣* | ០,០២ | *០,០១១* | ០,៦១ | ០,៦៥ |
| | | DMK | **០,៥៨** | *០,០៣* | ០,០២ | *០,០១០* | ០,៥៦ | ០,៦០ |
| | | រខ | **០,៦២** | *០,០៣* | ០,០២ | *០,០៣១* | ០,៥៦ | ០,៦៨ |
| **តម្លៃសន្ទស្សន៍រង** | | | | | **០,៥៤** | | | |

គួរឱ្យកត់សម្គាល់ថាអ្នកផ្តល់ព័ត៌មាននៅរាជធានី ខេត្តរាយការណ៍អំពីការដោះស្រាយបណ្តឹង គឺមានប្រសិទ្ធភាព (ពិន្ទុ០,៧០) ជាងនៅតំបន់ផ្សេងទៀត។ ដោយឡែក ថ្នាក់ដឹកនាំភូមិមានជំនឿខ្លាំងលើប្រសិទ្ធភាពនៃការដាក់ទណ្ឌកម្មផ្នែករដ្ឋបាល ឬផ្លូវច្បាប់ជាងរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត។

សូចនាករគណនេយ្យភាពតាមទីប្រជុំជន តំបន់ជនបទ តាមភេទ និងតំបន់ភូមិសាស្ត្រនានាមានរៀបរាប់នៅក្នុងតារាងខាងក្រោម។ ដូចគ្នានឹងសន្ទស្សន៍រងដែលបានរៀបរាប់ខាងលើដែរ ភាពខុសគ្នារវាងក្រុមសំណាក គឺមានតិចតួចសម្រាប់សូចនាករទាំងនេះ។ តម្លៃគណនេយ្យភាពដែលវាយតម្លៃដោយស្ត្រីខ្ពស់ជាងបុរស និងនៅរាជធានីភ្នំពេញក៏មានពិន្ទុខ្ពស់ជាងនៅតំបន់ផ្សេងទៀតដែរ។

*តារាងតម្លៃសូចនាករគណនេយ្យភាពតាមតំបន់ទីប្រជុំជន តំបន់ជនបទ ភេទ និងតំបន់ភូមិសាស្ត្រ*

| សូចនាករ | ការពិពណ៌នា | សំណាក | សរុប | ប្រភេទក្រុង ស្រុក ខណ្ឌ | | ភេទ | | តំបន់ភូមិសាស្ត្រ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ប្រជុំជន | ជនបទ | ស្រី | ប្រុស | ភ្នំពេញ | ទំនាប | ទន្លេសាប | ខ្ពង់ រាប | សមុទ្រ |
| ACC-I | ប្រជាពលរដ្ឋជឿថាគាត់មានលទ្ធភាពប្តឹងតវ៉ា បើគាត់មិនពេញចិត្តនឹងការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយបណ្តឹងទាំងនេះត្រូវបានទទួល និងដោះស្រាយយ៉ាងត្រឹមត្រូវ | បជ | **០,៥០** | ០,៥១ | ០,៥០ | ០,៤៧ | ០,៥២ | ០,៥០ | ០,៥២ | ០,៤២ | ០,៥៤ | ០,៤៩ |
| ACC-II | ប្រជាពលរដ្ឋជឿថា ការបោះឆ្នោតរបស់ខ្លួនអាចដាក់ទណ្ឌកម្មយ៉ាងមានប្រសិទ្ធភាពចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិដែលបំពេញការងារមិនបានល្អ | បជ | **០,៤៧** | ០,៤៧ | ០,៤៧ | ០,៤៦ | ០,៤៩ | ០,៥២ | ០,៤៥ | ០,៤៩ | ០,៤៦ | ០,៤៤ |
| ACC-III | ប្រជាពលរដ្ឋជឿថា មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សានឹងត្រូវទទួលទោស ប្រសិនបើប្រព្រឹត្តខុស ឬប្រព្រឹត្តល្មើសច្បាប់ | បជ | **០,៦៤** | ០,៦៦ | ០,៦៣ | ០,៦១ | ០,៦៧ | ០,៦៦ | ០,៦៣ | ០,៧០ | ០,៥៧ | ០,៥៩ |
| ACC-IV | ក្រុមប្រឹក្សា និងមន្ត្រីរាយការណ៍ថាមានយន្តការដោះស្រាយបណ្តឹងដ៏មានប្រសិទ្ធភាព | ភ | **០,៤៦** | ០,៤៦ | ០,៤៦ | ០,៤២ | ០,៤៧ | ០,៤១ | ០,៤៥ | ០,៥៨ | ០,៣៥ | ០,៦២ |
| | | ឃុំ សង្កាត់ | **០,៦២** | ០,៥៨ | ០,៥៧ | ០,៦២ | ០,៥៣ | ០,៥៥ | ០,៥៦ | ០,៦៦ | ០,៦៤ | ០,៦២ |
| | | DMK | **០,៦៣** | ០,៦៦ | ០,៦២ | ០,៦២ | ០,៦៣ | ០,៦៦ | ០,៦២ | ០,៦៥ | ០,៥៨ | ០,៦៩ |
| | | រខ | **០,៧០** | - | - | ០,៧១ | ០,៧០ | ០,៧១ | ០,៦៧ | ០,៧២ | ០,៦៨ | ០,៧៥ |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ACC-V | ក្រុមប្រឹក្សានិងមន្ត្រីនិយាយថា ពួកគេមានតម្រូវការទាក់ទាញសំឡេងឆ្នោតក្នុងការបោះឆ្នោតនាពេលអនាគត | ភ | **០,៤៤** | ០,៤៤ | ០,៤៤ | ០,៤៦ | ០,៤៣ | ០,៤០ | ០,៣២ | ០,៥១ | ០,៥១ | ០,៤៥ |
| | | ឃុំសង្កាត់ | **០,៤១** | ០,៣៩ | ០,៤១ | ០,៤១ | ០,៤១ | ០,៤១ | ០,៣៨ | ០,៤៣ | ០,៤១ | ០,៤០ |
| | | DMK | **០,៤២** | ០,៤៥ | ០,៤២ | ០,៤១ | ០,៤៣ | ០,៥០ | ០,៣៦ | ០,៤៧ | ០,៤៣ | ០,៤២ |
| | | រខ | **០,៤១** | - | - | ០,៣២ | ០,៤៥ | ០,២៨ | ០,៣៨ | ០,៣៧ | ០,៤០ | ០,៥៦ |
| ACC-VI | ក្រុមប្រឹក្សានិងមន្ត្រីនិយាយថា ពួកគេនឹងត្រូវទទួលទោស ប្រសិនបើពួកគេបំពេញការងារមិនល្អ ឬល្មើសច្បាប់ | ភ | **០,៧១** | ០,៧១ | ០,៧១ | ០,៦៩ | ០,៧២ | ០,៦៦ | ០,៦៩ | ០,៧៥ | ០,៧១ | ០,៧០ |
| | | CS | **០,៦៣** | ០,៦២ | ០,៦៣ | ០,៦១ | ០,៦៤ | ០,៦៥ | ០,៦០ | ០,៧៣ | ០,៥៨ | ០,៥៧ |
| | | DMK | **០,៥៨** | ០,៦២ | ០,៥៧ | ០,៥៦ | ០,៦០ | ០,៦៨ | ០,៥៣ | ០,៦៩ | ០,៥៤ | ០,៥៦ |
| | | CP | **០,៦២** | - | - | ០,៦៤ | ០,៦២ | ០,៧២ | ០,៥៤ | ០,៦៣ | ០,៦០ | ០,៧៥ |
| **តម្លៃរងសន្ទស្សន៍** | | | **០,៥៤** | **០,៥៥** | **០,៥៣** | **០,៥២** | **០,៥៥** | **០,៥៦** | **០,៥២** | **០,៥៦** | **០,៥៣** | **០,៥៣** |

## ៥.៥.២. តម្លៃគណនេយ្យភាពដែលបានពីសំណាករបស់ប្រជាពលរដ្ឋ

អ្នកផ្តល់ព័ត៌មានភាគច្រើនអាចលើកឡើងអំពីយន្តការដែលមានសក្តានុពលសម្រាប់ដាក់បណ្តឹងតវ៉ាពាក់ព័ន្ធនឹងការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ប៉ុន្តែមានប្រជាពលរដ្ឋតិចតួច ដែលបានដាក់បណ្តឹងតវ៉ាពិតប្រាកដ។ អ្នកដែលបានឆ្លើយពីបណ្តឹងតវ៉ា បាននិយាយថា ពួកគាត់ជាទូទៅមិនពេញចិត្តនឹងលទ្ធផលនៃការដោះស្រាយបណ្តឹងតវ៉ានោះទេ។

គួរកត់សម្គាល់ថា បណ្តឹងពិតប្រាកដមានតិចតួចធៀបនឹងចំនួនប្រជាពលរដ្ឋដែលបានលើកឡើងចង់ប្តឹងតវ៉ា ត្រូវបានសន្មត់ថាជាសូចនាករអវិជ្ជមាន (មានជំនឿតិចតួចលើប្រសិទ្ធភាព)។

*តារាងការឆ្លើយតបរបស់ប្រជាពលរដ្ឋចំពោះសំណួរគណនេយ្យភាព*

| **លេខសម្គាល់** | **ការពិពណ៌នា** | **ពិន្ទុ** | **ទម្ងន់** | **តម្លៃ** | **កំហុសស្តង់ដា** | **៩៥% ចន្លោះទំនុកចិត្ត** | |
|---|---|---|---|---|---|---|---|
| | | | | | | តម្លៃទាបបំផុត | តម្លៃខ្ពស់បំផុត |
| បជ.ACC.១ | ចំណេះដឹងរបស់ប្រជាពលរដ្ឋអំពីមធ្យោបាយដាក់បណ្តឹងតវ៉ាអំពីសេវាសាធារណៈ | **០,៦៤** | *០,២៥* | ០,១៦ | *០,០០៧* | ០,៦៣ | ០,៦៦ |
| បជ.ACC.២ | តើអ្នកផ្តល់ព័ត៌មានចង់ប្តឹងតវ៉ាទេ (កាលពីឆ្នាំមុន) | | | | | | |
| បជ.ACC.៣ | តើអ្នកផ្តល់ព័ត៌មានបានប្តឹងពិតមែនទេ? | **០,១៨** | *០,២៥* | ០,០៤ | *០,០១៧* | ០,១៤ | ០,២១ |
| បជ.ACC.៤ | តើអ្នកផ្តល់ព័ត៌មានបានប្តឹងតវ៉ាទៅអ្នកណា? | | | | | | |
| បជ.ACC-I | **ប្រជាពលរដ្ឋជឿជាក់ថា ពួកគាត់មានលទ្ធភាពប្តឹងតវ៉ា ប្រសិនបើពួកគាត់មិនពេញចិត្តនឹងការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយបណ្តឹងពួកគាត់នឹងត្រូវបានទទួល និងដោះស្រាយយ៉ាងត្រឹមត្រូវ។** | **០,៥៩** | ***០,៥០*** | **០,២៩** | ***០,០៣៤*** | **០,៥២** | **០,៦៦** |
| បជ.ACC.៦ | តើគុណភាពនៃសេវាមានឥទ្ធិពលលើការបោះឆ្នោតរបស់ប្រជាពលរដ្ឋដែរឬទេ? | | | ០,៥០ | *០,០០៧* | ០,៤៨ | ០,៥១ |
| បជ.ACC-II | **ប្រជាពលរដ្ឋជឿថា ការបោះឆ្នោតរបស់គាត់អាចដាក់ទណ្ឌកម្មយ៉ាងមានប្រសិទ្ធភាពលើរដ្ឋបាលថ្នាក់ក្រោមជាតិដែលបំពេញការងារមិនបានល្អ** | **០,៤៧** | ***១.០០*** | **០,៤៧** | ***០,០០៥*** | **០,៤៦** | **០,៤៨** |
| បជ.ACC.៧ | តើគិតថាក្រុមប្រឹក្សានិងមន្ត្រីនឹងត្រូវទទួលទោសចំពោះការបំពេញការងារមិនល្អឬអំពើខុសច្បាប់? | | | ០,៤៧ | *០,០០៥* | ០,៤៦ | ០,៤៨ |
| បជ.ACC-III | **ប្រជាពលរដ្ឋជឿថា មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សានឹងត្រូវទទួលទោស ប្រសិនបើប្រព្រឹត្តខុស ឬប្រព្រឹត្តល្មើសច្បាប់** | **០,៦៤** | ***១.០០*** | **០,៦៤** | ***០,០០៦*** | **០,៦៣** | **០,៦៥** |

**ការឆ្លុះបញ្ចាំង ៖ តើប្រជាពលរដ្ឋពេញចិត្តនឹងលទ្ធផលនៃពាក្យបណ្តឹងរបស់ពួកគេយ៉ាងដូចម្តេច?**

អ្នកផ្តល់ព័ត៌មានស្ទើរតែទាំងអស់ដែលជាប្រជាពលរដ្ឋអាចកំណត់យ៉ាងហោចណាស់វិធីសាស្ត្រចំនួនមួយដែលពួកគេអាចប្តឹង ប្រសិនបើពួកគេមិនពេញចិត្តនឹងសេវារដ្ឋបាលថ្នាក់ក្រោមជាតិ និងជាងពាក់កណ្តាលនៃប្រជាពលរដ្ឋអាចផ្តល់យោបល់យ៉ាងហោចណាស់វិធីសាស្ត្រចំនួន ២ដែលពួកគាត់ប្រើប្រាស់។ ការដាក់បណ្តឹងទៅកាន់អាជ្ញាធរភូមិ គឺជាវិធីសាស្ត្រដែលត្រូវបានអនុវត្តញឹកញាប់បំផុត បន្ទាប់មកគឺការប្តឹងទៅការិយាល័យក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ ឬរាជធានី ខេត្ត។ ការដាក់បណ្តឹងដោយផ្ទាល់ទៅកាន់សមាជិកប្រឹក្សា ឬមន្រ្តីក៏ត្រូវបានលើកឡើងជាច្រើនដងផងដែរ។ ទោះជាយ៉ាងនេះក្តី មានអ្នកផ្តល់ព័ត៌មានតិចតួចណាស់ដែលបានលើកឡើងពីការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ ក្រុង ស្រុក ខណ្ឌ និង រាជធានី ខេត្ត។

| របៀបដាក់បណ្តឹង | ការលើកឡើង | % |
|---|---|---|
| អាជ្ញាធរភូមិ | ១ ៥២៨ | ៣៦% |
| អាជ្ញាធរឃុំ សង្កាត់ | ១ ៣៨៩ | ៣៣% |
| អាជ្ញាធររាជធានី ខេត្ត | ១៦៧ | ៤% |
| តាមរយៈអ្នកស្គាល់គ្នា | ១៨១ | ៤% |
| ការិយាល័យប្រជាពលរដ្ឋ | ១៥ | 0,៤% |
| ផ្សេងៗ | ៣៤0 | ៨% |

ប្រជាពលរដ្ឋត្រូវបានសួរថា តើពួកគាត់ចង់ប្តឹងតវ៉ាអំពីសេវារដ្ឋបាលថ្នាក់ក្រោមជាតិកាលពីឆ្នាំមុនដែរឬទេ? ប្រជាពលរដ្ឋចំនួន ៤៧៩នាក់បាននិយាយថា គេចង់ប្តឹងតវ៉ាអំពីសេវាសាធារណៈ ប៉ុន្តែមានតែប្រជាពលរដ្ឋចំនួន ៨៩នាក់ប៉ុណ្ណោះ (១៩%) ដែលបានដាក់បណ្តឹងតវ៉ា។ ប្រជាពលរដ្ឋចំនួន ១៧១នាក់ចង់ប្តឹងតវ៉ាអំពីសេវារដ្ឋបាលដែលគេបានទទួលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលក្នុងនោះមានប្រជាពលរដ្ឋចំនួន ៤៩នាក់ (២៩%) បានរាយការណ៍ថាបានដាក់បណ្តឹងតវ៉ា។

| វិធីសាស្ត្របណ្តឹង | បណ្តឹងត្រូវបានរាយការណ៍ | % ពេញចិត្ត |
|---|---|---|
| អាជ្ញាធរភូមិ | ៣៤ | ៥៣% |
| អាជ្ញាធរឃុំ សង្កាត់ | ៤៤ | ៤៨% |
| ផ្សេងៗ | ១១ | ៥៥% |
| វិធីសាស្ត្រផ្សេងទៀត | **៩៨** | **៥១%** |

ប្រជាពលរដ្ឋដែលបានដាក់បណ្តឹងតវ៉ាភាគច្រើន គឺបានដាក់បណ្តឹងទៅកាន់មេភូមិ ឬទៅសាលាឃុំ សង្កាត់ និងមានចំនួនតិចតួចប៉ុណ្ណោះដែលរាយការណ៍ថាបានដាក់បណ្តឹងតាមវិធីសាស្ត្រផ្សេងពីនេះ។

ជាងពាក់កណ្តាលនៃអ្នកដែលបានដាក់បណ្តឹងបាននិយាយថា ពួកគាត់ "ពេញចិត្តខ្លះ" ឬ "ពេញចិត្តខ្លាំង" ចំពោះលទ្ធផលនៃបណ្តឹងរបស់ពួកគាត់។

## ៥.៥.៣. តម្លៃគណនេយ្យភាពដែលបានពីចម្លើយរបស់មន្រ្តីរដ្ឋបាលថ្នាក់ក្រោមជាតិ

*តារាងរដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្លើយតបទៅនឹងសំណួរគណនេយ្យភាព*

| លេខសម្គាល់ | ការពិពណ៌នា | ពិន្ទុ | ទម្ងន់ | តម្លៃ | កំហុសស្តង់ដា | ៩៥% ចន្លោះទំនុកចិត្ត | |
|---|---|---|---|---|---|---|---|
| | | | | | | *ទាបបំផុត* | *ខ្ពស់បំផុត* |
| VIL.ACC.1 | ចម្លើយថ្នាក់ដឹកនាំភូមិចំពោះប្រជាពលរដ្ឋដែលចង់ប្តឹងអំពីសេវា | **0,៤៦** | ១.00 | 0,៤៦ | 0,0២៤ | 0,៤១ | 0,៥១ |
| VIL.ACC.2 | ការវាយតម្លៃរបស់ថ្នាក់ដឹកនាំភូមិលើអាជ្ញាធរដែលមានសមត្ថកិច្ចក្នុងការដោះស្រាយបណ្តឹងតវ៉ា | - | - | - | - | - | - |
| VIL.ACC-IV | **ក្រុមប្រឹក្សា និងមន្រ្តីរាយការណ៍ថា មានយន្តការដោះស្រាយបណ្តឹងដ៏មានប្រសិទ្ធភាព** | | | **0,៤៦** | **0,0២៥** | **0,៤១** | **0,៥១** |
| CS.ACC.1 | ភាពញឹកញាប់នៃការប្តឹងទៅរដ្ឋបាលថ្នាក់ក្រោមជាតិអំពីគុណភាពសេវាសាធារណៈ | **0,១៦** | 0,១0 | 0,0២ | 0,00៦ | 0,១៥ | 0,១៧ |
| CS.ACC.2 | ភាពញឹកញាប់នៃបណ្តឹងទៅរដ្ឋបាលថ្នាក់ក្រោមជាតិអំពីគុណភាពសេវារដ្ឋបាល | **0,១0** | 0,១0 | 0,0១ | 0,00៦ | 0,0៩ | 0,១១ |
| CS.ACC.3 | តើរដ្ឋបាលថ្នាក់ក្រោមជាតិ រក្សាកំណត់ហេតុនៃបណ្តឹងឬទេ? | **0,៧៩** | 0,៤0 | 0,៣២ | 0,0១៦ | 0,៧៦ | 0,៨៣ |
| CS.ACC.4 | តើរដ្ឋបាលថ្នាក់ក្រោមជាតិរាយការណ៍អំពីបណ្តឹងដែលបានទទួល និងដោះស្រាយឬទេ? | **0,៧0** | 0,២0 | 0,១៤ | 0,0១៦ | 0,៦៧ | 0,៧៣ |
| CS.ACC.5 | រដ្ឋបាលថ្នាក់ក្រោមជាតិវាយតម្លៃលើភាគរយនៃអ្នកតវ៉ាដែលពេញចិត្តនឹងការឆ្លើយតប | **0,៦៩** | 0,២0 | 0,១៤ | 0,0១៣ | 0,៦៧ | 0,៧២ |

| លេខសម្គាល់ | ការពិពណ៌នា | ពិន្ទុ | ទម្ងន់ | តម្លៃ | កំហុសស្តង់ដា | ៩៥% ចន្លោះទំនុកចិត្ត | |
|---|---|---|---|---|---|---|---|
| | | | | | | *ទាបបំផុត* | *ខ្ពស់បំផុត* |
| CS.ACC-IV | **ក្រុមប្រឹក្សា និងមន្ត្រីរាយការណ៍ថា មានយន្តការដោះស្រាយបណ្តឹងដ៏មានប្រសិទ្ធភាព** | | | **០,៦២** | **០,០០៥** | **០,៦១** | **០,៦៣** |
| DMK.ACC.1 | ភាពញឹកញាប់នៃការប្តឹងទៅរដ្ឋបាលថ្នាក់ក្រោមជាតិអំពីគុណភាពនៃសេវាសាធារណៈ | **០,១៧** | ០,១០ | ០,០២ | ០,០០៦ | ០,១៦ | ០,១៨ |
| DMK.ACC.2 | ភាពញឹកញាប់នៃបណ្តឹងទៅរដ្ឋបាលថ្នាក់ក្រោមជាតិអំពីគុណភាពនៃសេវារដ្ឋបាល | **០,១៣** | ០,១០ | ០,០១ | ០,០០៦ | ០,១២ | ០,១៤ |
| DMK.ACC.3 | តើរដ្ឋបាលថ្នាក់ក្រោមជាតិ រក្សាកំណត់ហេតុនៃបណ្តឹងឬទេ? | **០,៨៣** | ០,៤០ | ០,៣៣ | ០,០១១ | ០,៨១ | ០,៨៥ |
| DMK.ACC.4 | តើរដ្ឋបាលថ្នាក់ក្រោមជាតិរាយការណ៍អំពីបណ្តឹងដែលបានទទួលនិងដោះស្រាយឬទេ? | **០,៧០** | ០,២០ | ០,១៤ | ០,០១៣ | ០,៦៧ | ០,៧២ |
| DMK.ACC.5 | រដ្ឋបាលថ្នាក់ក្រោមជាតិវាយតម្លៃអំពី% នៃអ្នកតវ៉ាដែលពេញចិត្តនឹងការឆ្លើយតប | **០,៦៣** | ០,២០ | ០,១៣ | ០,០១៣ | ០,៦១ | ០,៦៦ |
| DMK.ACC-IV | **ក្រុមប្រឹក្សា និងមន្ត្រីរាយការណ៍ថា មានយន្តការដោះស្រាយបណ្តឹងដ៏មានប្រសិទ្ធភាព** | | | **០,៦៣** | **០,០០៨** | **០,៦១** | **០,៦៤** |
| CP.ACC.1 | ភាពញឹកញាប់នៃការប្តឹងទៅរដ្ឋបាលថ្នាក់ក្រោមជាតិអំពីគុណភាពនៃសេវាសាធារណៈ | **០,២១** | ០,១០ | ០,០២ | ០,០៤៣ | ០,១៣ | ០,៣០ |
| CP.ACC.2 | ភាពញឹកញាប់នៃបណ្តឹងទៅរដ្ឋបាលថ្នាក់ក្រោមជាតិអំពីគុណភាពនៃសេវារដ្ឋបាល | **០,១៨** | ០,១០ | ០,០២ | ០,០២៣ | ០,១៤ | ០,២២ |
| CP.ACC.3 | តើរដ្ឋបាលថ្នាក់ក្រោមជាតិ រក្សាកំណត់ហេតុនៃបណ្តឹងឬទេ? | **០,៩២** | ០,៤០ | ០,៣៧ | ០,០៨៩ | ០,៧៥ | ១.១០ |
| CP.ACC.4 | តើរដ្ឋបាលថ្នាក់ក្រោមជាតិរាយការណ៍អំពីបណ្តឹងដែលបានទទួលនិងដោះស្រាយឬទេ? | **០,៧០** | ០,២០ | ០,១៤ | ០,០៣៧ | ០,៦៣ | ០,៧៧ |
| CP.ACC.5 | រដ្ឋបាលថ្នាក់ក្រោមជាតិវាយតម្លៃអំពីភាគរយនៃអ្នកតវ៉ាដែលពេញចិត្តនឹងការឆ្លើយតប | **០,៧៥** | ០,២០ | ០,១៥ | ០,០២៥ | ០,៧០ | ០,៨០ |
| CP.ACC-IV | **ក្រុមប្រឹក្សា និងមន្ត្រីរាយការណ៍ថា មានយន្តការដោះស្រាយបណ្តឹងដ៏មានប្រសិទ្ធភាព** | | | **០,៧០** | **០,០១៨** | **០,៦៦** | **០,៧៣** |
| VIL.ACC.3 | តើគុណភាពនៃសេវាមានឥទ្ធិពលលើការបោះឆ្នោតរបស់ប្រជាពលរដ្ឋដែរឬទេ? | **០,៤៤** | ១.០០ | ០,៤៤ | ០,០១៣ | ០,៤១ | ០,៤៦ |
| VIL.ACC-V | **ក្រុមប្រឹក្សានិងមន្ត្រីនិយាយថា ពួកគេមានតម្រូវការទាក់ទាញសំឡេងឆ្នោតក្នុងការបោះឆ្នោតនាពេលអនាគត** | | | **០,៤៤** | **០,០១៣** | **០,៤១** | **០,៤៦** |
| VIL.ACC.6 | តើគុណភាពនៃសេវាមានឥទ្ធិពលលើការបោះឆ្នោតរបស់ប្រជាពលរដ្ឋដែរឬទេ? | **០,៤១** | ១.០០ | ០,៤១ | ០,០០៩ | ០,៣៩ | ០,៤២ |
| CS.ACC-V | **ក្រុមប្រឹក្សានិងមន្ត្រីនិយាយថា ពួកគេមានតម្រូវការទាក់ទាញសំឡេងឆ្នោតក្នុងការបោះឆ្នោតនាពេលអនាគត** | | | **០,៤១** | **០,០០៩** | **០,៣៩** | **០,៤២** |
| DMK.ACC.6 | តើគុណភាពនៃសេវាមានឥទ្ធិពលលើការបោះឆ្នោតរបស់ប្រជាពលរដ្ឋដែរឬទេ? | **០,៤២** | ១.០០ | ០,៤២ | ០,០០៩ | ០,៤១ | ០,៤៤ |
| DMK.ACC-V | **ក្រុមប្រឹក្សានិងមន្ត្រីនិយាយថា ពួកគេមានតម្រូវការទាក់ទាញសំឡេងឆ្នោតក្នុងការបោះឆ្នោតនាពេលអនាគត** | | | **០,៤២** | **០,០០៩** | **០,៤១** | **០,៤៤** |
| CP.ACC.6 | តើគុណភាពនៃសេវាមានឥទ្ធិពលលើការបោះឆ្នោតរបស់ប្រជាពលរដ្ឋដែរឬទេ? | **០,៤១** | ១.០០ | ០,៤១ | ០,០៥០ | ០,៣១ | ០,៥១ |
| CP.ACC-V | **ក្រុមប្រឹក្សានិងមន្ត្រីនិយាយថា ពួកគេមានតម្រូវការទាក់ទាញសំឡេងឆ្នោតក្នុងការបោះឆ្នោតនាពេលអនាគត** | | | **០,៤១** | **០,០៣២** | **០,៣៥** | **០,៤៧** |
| VIL.ACC.4 | តើអ្នកគិតថាក្រុមប្រឹក្សា និងមន្ត្រីនឹងត្រូវទទួលទោសចំពោះការបំពេញការងារមិនល្អឬអំពើខុសច្បាប់ដែរឬទេ? | **០,៧១** | ១.០០ | ០,៧១ | ០,០១០ | ០,៦៩ | ០,៧៣ |

| លេខសម្គាល់ | ការពិពណ៌នា | ពិន្ទុ | ទម្ងន់ | តម្លៃ | កំហុសស្តង់ដា | ៩៥% ចន្លោះទំនុកចិត្ត | |
|---|---|---|---|---|---|---|---|
| | | | | | | *ទាបបំផុត* | *ខ្ពស់បំផុត* |
| VIL.ACC-VI | **ក្រុមប្រឹក្សា និងមន្ត្រីនិយាយថា ពួកគេនឹងត្រូវទទួលទោស ប្រសិនបើពួកគេបំពេញការងារមិនល្អ ឬល្មើសច្បាប់** | | | **០,៧១** | **០,០១១** | **០,៦៩** | **០,៧៣** |
| VIL.ACC.7 | តើអ្នកគិតថាក្រុមប្រឹក្សា និងមន្ត្រីនឹងត្រូវទទួលទោសចំពោះការបំពេញការងារមិនល្អឬអំពើខុសច្បាប់ឬទេ? | **០,៦៣** | ១.00 | ០,៦៣ | ០,០១១ | ០,៦១ | ០,៦៥ |
| CS.ACC-VI | **ក្រុមប្រឹក្សា និងមន្ត្រីនិយាយថា ពួកគេនឹងត្រូវទទួលទោស ប្រសិនបើពួកគេបំពេញការងារមិនល្អ ឬល្មើសច្បាប់** | | | **០,៦៣** | **០,០១១** | **០,៦១** | **០,៦៥** |
| DMK.ACC.7 | តើអ្នកគិតថាក្រុមប្រឹក្សា និងមន្ត្រីនឹងត្រូវទទួលទោសចំពោះការបំពេញការងារមិនល្អឬអំពើខុសច្បាប់ឬទេ? | **០,៥៨** | ១.00 | ០,៥៨ | ០,00៩ | ០,៥៦ | ០,៦០ |
| DMK.ACC-VI | **ក្រុមប្រឹក្សា និងមន្ត្រីនិយាយថា ពួកគេនឹងត្រូវទទួលទោស ប្រសិនបើពួកគេបំពេញការងារមិនល្អ ឬល្មើសច្បាប់** | | | **០,៥៨** | **០,០១០** | **០,៥៦** | **០,៦០** |
| CP.ACC.7 | តើអ្នកគិតថាក្រុមប្រឹក្សា និងមន្ត្រីនឹងត្រូវទទួលទោសចំពោះការបំពេញការងារមិនល្អឬអំពើខុសច្បាប់ឬទេ? | **០,៦២** | ១.00 | ០,៦២ | ០,០៣៧ | ០,៥៥ | ០,៧០ |
| CP.ACC-VI | **ក្រុមប្រឹក្សា និងមន្ត្រីនិយាយថា ពួកគេនឹងត្រូវទទួលទោស ប្រសិនបើពួកគេបំពេញការងារមិនល្អ ឬល្មើសច្បាប់** | | | **០,៦២** | **០,០៣១** | **០,៥៦** | **០,៦៨** |

ជាទូទៅ ថ្នាក់ដឹកនាំភូមិមិនសូវមានភាពសកម្មខ្លាំងក្នុងការជួយប្រជាពលរដ្ឋក្នុងការដាក់បណ្តឹងតវ៉ាទេ (VIL.ACC.1) លើកលែងថ្នាក់ដឹកនាំភូមិនៅតំបន់ឆ្នេរដែលមានភាពសកម្មជាងគេ។ ភាពញឹកញាប់នៃពាក្យបណ្តឹងដែលទទួលបាននៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិ ហាក់ដូចជាមានភាពស្រដៀងគ្នា (CS.ACC.2, DMK.ACC.2, CP.ACC.2)។

*ទំនុកចិត្តរបស់ប្រជាពលរដ្ឋចំពោះគណនេយ្យភាពផ្នែករដ្ឋបាល និងផ្នែកច្បាប់*

**ការឆ្លុះបញ្ចាំង៖ តើប្រជាពលរដ្ឋជឿលើគណនេយ្យភាពរដ្ឋបាល ឬផ្នែកច្បាប់ដែរឬទេ?**

- យើងបានសួរប្រជាពលរដ្ឋថា តើគាត់គិតថាក្រុមប្រឹក្សា ឬមន្ត្រីអាចប្រឈមនឹងការដាក់ទណ្ឌកម្មចំពោះការអនុវត្តការងារមិនបានល្អ ឬអំពើខុសច្បាប់ឬទេ។
- តារាងខាងក្រោមសង្ខេបអំពីភាគរយនៃប្រជាពលរដ្ឋដែលគិតថា ក្រុមប្រឹក្សា ឬមន្ត្រីនឹងត្រូវទទួលទណ្ឌកម្ម "ជាញឹកញាប់" ឬ "តែងតែ" សម្រាប់ប្រភេទផ្សេងគ្នានៃការអនុវត្តការងារមិនបានល្អ។

| ប្រភេទនៃការអនុវត្តការងារមិនបានល្អ | ជារួម | ទីប្រជុំជន | ជនបទ |
|---|---|---|---|
| បើពួកគាត់មិនធ្វើការងារឱ្យមានស្តង់ដាខ្ពស់ | ២៨% | ២៧% | ២៩% |
| ប្រសិនបើពួកគាត់ជារឿយៗអវត្តមានពីការងារ | ៣៤% | ៣៧% | ៣៣% |
| បើពួកគាត់មិនគោរពប្រជាពលរដ្ឋ | ៤១% | ៤០% | ៤២% |
| បើពួកគាត់មិនមានការប្រយ័ត្ននឹងការចាយវាយថវិកាសាធារណៈ | ៥១% | ៥៩% | ៤៨% |
| បើពួកគាត់គិតបន្លំលុយ | ៨២% | ៨៦% | ៨១% |
| បើពួកគាត់ស្នើសុំ និងទទួលសំណូកពីប្រជាពលរដ្ឋ | ៧៦% | ៨០% | ៧៥% |

- ប្រជាពលរដ្ឋភាគច្រើនមិនបានគិតថា ក្រុមប្រឹក្សា ឬមន្ត្រីនឹងត្រូវទទួលទោសចំពោះតែការបំពេញការងារមិនល្អនោះទេ
- ប្រជាពលរដ្ឋភាគច្រើនគិតថា ក្រុមប្រឹក្សា និងមន្ត្រីនឹងត្រូវទទួលទោសចំពោះទង្វើខុសច្បាប់។

**ការឆ្លុះបញ្ចាំង ៖ តើការបោះឆ្នោតនៅមូលដ្ឋានមានប្រសិទ្ធភាពសម្រាប់គណនេយ្យភាពឬទេ?**

| ស្ថានភាពដែលអាចប៉ះពាលការបោះឆ្នោតរបស់ប្រជាពលរដ្ឋ | ជាទូទៅ | ទីក្រុង | ជនបទ |
|---|---|---|---|
| ផ្លូវចូលភូមិមិនមានស្ថានភាពល្អ | **៣០%** | ៣០% | ៣០% |
| សុវត្ថិភាពសាធារណៈ និងសន្តិសុខក្នុងភូមិមិនល្អគ្រប់គ្រាន់ | **៣២%** | ៣១% | ៣២% |
| សេវាសម្រាប់ស្ត្រី និងកុមារ និងសម្រាប់ប្រជាជនក្រីក្រ និងងាយរងគ្រោះមិនល្អគ្រប់គ្រាន់ | **៣១%** | ៣០% | ៣១% |
| មិនមានការគាំទ្រគ្រប់គ្រាន់ចំពោះប្រជាពលរដ្ឋដែលធ្វើការងារតាមបែបដែលអ្នកភូមិធ្វើ | **៣០%** | ៣១% | ៣០% |
| ប្រជាពលរដ្ឋជឿថា ក្រុមប្រឹក្សាឃុំ សង្កាត់ មិនយល់ពីតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋ | **៣២%** | ៣១% | ៣២% |
| នៅពេលប្រជាពលរដ្ឋទៅការិយាល័យឃុំ សង្កាត់ដើម្បីទទួលសេវាណាមួយ ពួកគាត់ពិតជាមានការលំបាកណាស់ក្នុងការទទួលបានជំនួយដែលពួកគាត់ត្រូវការ | **៣១%** | ៣៣% | ៣១% |
| ប្រជាពលរដ្ឋជឿថា ក្រុមប្រឹក្សាឃុំ សង្កាត់ ខ្ជិលច្រអូស ហើយមិនប្រឹងប្រែងគ្រប់គ្រាន់សម្រាប់ប្រជាពលរដ្ឋ | **៣៥%** | ៤០% | ៣៤% |
| ប្រជាពលរដ្ឋជឿថា ក្រុមប្រឹក្សាឃុំ សង្កាត់ជាប់ពាក់ព័ន្ធនឹងអំពើពុករលួយ | **៤៧%** | ៥១% | ៤៦% |

**យើងបានសួរប្រជាពលរដ្ឋអំពីស្ថានភាពផ្សេងៗគ្នាមួយចំនួនដែលអាចប៉ះពាល់ដល់ការសម្រេចចិត្តរបស់ប្រជាជនក្នុងការបោះឆ្នោតឃុំសង្កាត់។**

**តារាងបានសង្ខេប % នៃប្រជាពលរដ្ឋដែលគិតថា "ភាគច្រើន" ឬ "ស្ទើរតែទាំងអស់" ប្រជាជនអាចផ្លាស់ប្តូរការសម្រេចចិត្តលើការបោះឆ្នោតរបស់ពួកគាត់ដោយសារតែស្ថានភាពផ្សេងៗ។**

- សរុបមក មានប្រហែលជា ៣០% នៃការឆ្លើយតបដែលប្រជាជនអាចផ្លាស់ប្តូរការបោះឆ្នោតរបស់ពួកគាត់។
- ទោះជាយ៉ាងណាក៏ដោយ ចំនួនអ្នកដែលគិតថានឹងផ្លាស់ប្តូរសន្លឹកឆ្នោតរបស់ពួកគេដោយសារតែអំពើពុករលួយមានច្រើនជាងជាពិសេសនៅតាមទីប្រជុំជន។

## ៥.៦. សន្ទស្សន៍រងពាក់ព័ន្ធនឹងការចូលរួមរបស់ប្រជាពលរដ្ឋ

### ៥.៦.១. តម្លៃសូចនាករ




សន្ទស្សន៍រងនៃការចូលរួមរបស់ពលរដ្ឋជាមួយពិន្ទុសូចនាករ និងទម្ងន់

ផ្អែកតាមរូបភាពខាងលើ យើងអាចសន្និដ្ឋានបានថាកម្រិតនៃការចូលរួមរបស់ប្រជាពលរដ្ឋជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិមានកម្រិតមធ្យម។ ជាមួយគ្នានេះ ប្រជាពលរដ្ឋក៏មានការជឿជាក់ថារដ្ឋបាលថ្នាក់ក្រោមជាតិបានសហការល្អជាមួយអង្គការសហគមន៍មូលដ្ឋាន ក៏ប៉ុន្តែមានចំនួនប្រជាពលរដ្ឋតិចតួចដែលជាសមាជិកនៃអង្គការសហគមន៍មូលដ្ឋានទាំងនោះ។ រដ្ឋបាលថ្នាក់ក្រោមជាតិបានខិតខំប្រឹងប្រែងដើម្បីឱ្យប្រជាពលរដ្ឋបានចូលរួមតាមមធ្យោបាយផ្សេងៗ។ ទោះយ៉ាងនេះក្តី បច្ចេកវិទ្យាឌីជីថលគួរត្រូវបានជំរុញការប្រើប្រាស់ដើម្បីបង្កភាពងាយស្រួលដល់ប្រជាពលរដ្ឋ។ មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិយល់ឃើញថា ការចូលរួមរបស់ប្រជាពលរដ្ឋគ្រាន់តែជាមធ្យោបាយផ្តល់ព័ត៌មាន និងការប្រមូលទិន្នន័យផ្សេងៗប៉ុណ្ណោះ ជាជាងមធ្យោបាយសម្រាប់ការសិក្សាអំពីទស្សនៈរបស់ប្រជាពលរដ្ឋ។ មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិមានទស្សនៈវិជ្ជមានក្នុងកម្រិតមធ្យមចំពោះកិច្ចសហប្រតិបត្តិការជាមួយអង្គការសហគមន៍មូលដ្ឋាន។

*ចំណុចខ្លាំង និងចំណុចខ្សោយ៖ ការចូលរួមរបស់ប្រជាពលរដ្ឋ*

| នាពខ្លាំង | ចំណុចខ្សោយ |
|---|---|
| • ការចូលរួមរបស់ប្រជាពលរដ្ឋជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងបទពិសោធន៍របស់ពួកគេអំពីការចូលរួមនេះមានក្នុងកម្រិតបង្គួរ<br>• ប្រជាពលរដ្ឋមានទំនុកចិត្តកម្រិតមធ្យមថា រដ្ឋបាលថ្នាក់ក្រោមជាតិបានសហការល្អជាមួយអង្គការសហគមន៍មូលដ្ឋាន ហើយថ្នាក់ដឹកនាំរដ្ឋបាលថ្នាក់ក្រោមជាតិបង្ហាញការគាំទ្រយ៉ាងខ្លាំងចំពោះសកម្មភាពរបស់អង្គការសហគមន៍មូលដ្ឋាន។ | • ការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងអង្គការសហគមន៍មូលដ្ឋានគឺនៅមានកម្រិតទាប គឺត្រឹម២៣% ប៉ុណ្ណោះ<br>• រដ្ឋបាលថ្នាក់ក្រោមជាតិបានប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងកម្រិតទាបនៅឡើយក្នុងការបង្កភាពងាយស្រួលដល់ប្រជាពលរដ្ឋចូលរួមជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ក្រុមប្រឹក្សា និងមន្ត្រីយល់ដឹងតិចតួចអំពីអត្ថប្រយោជន៍នៃការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការធ្វើផែនការ។ |

ការចូលរួមរបស់ប្រជាពលរដ្ឋត្រូវបានវាយតម្លៃ តាមរយៈការវាស់វែងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងអភិបាលកិច្ចមូលដ្ឋាន និងកម្រិតនៃការពេញចិត្តរបស់ប្រជាពលរដ្ឋតាមរយៈបទពិសោធន៍ជាសមាជិកភាពរបស់អង្គការសហគមន៍មូលដ្ឋាន និងទំនាក់ទំនងជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការខិតខំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីស្វែងរកទស្សនៈរបស់ប្រជាពលរដ្ឋ។ តម្លៃសូចនាករដែលបានវាស់វែងត្រូវបានសង្ខេបនៅក្នុងតារាងខាងក្រោម៖

*តារាងតម្លៃសូចនាករការចូលរួមរបស់ពលរដ្ឋ*

| សូចនាករ | ការពិពណ៌នា | សំណាក | ពិន្ទុ | មេគុណ | តម្លៃ | កំហុសស្តង់ដា | ៩៥% ចន្លោះទំនុកចិត្ត | |
|---|---|---|---|---|---|---|---|---|
| | | | | | | | ទាបបំផុត | ខ្ពស់បំផុត |
| CIV-I | ប្រជាពលរដ្ឋចូលរួមជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ លើបញ្ហាអភិបាលកិច្ច និងការអភិវឌ្ឍមូលដ្ឋាន | បជ | **0,៦៦** | *0,១៧* | 0,១១ | *0,00៩* | 0,៦៤ | 0,៦៧ |
| CIV-II | ប្រជាពលរដ្ឋពេញចិត្តនឹងបទពិសោធន៍ចូលរួមជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ | បជ | **0,៦៨** | *0,១៧* | 0,១១ | *0,00៥* | 0,៦៧ | 0,៦៩ |
| CIV-III | ប្រជាពលរដ្ឋចូលរួមក្នុងអង្គការសហគមន៍ | បជ | **0,២៣** | *0,១៧* | 0,0៤ | *0,0១0* | 0,២១ | 0,២៤ |
| CIV-IV | ប្រជាពលរដ្ឋជឿថា រដ្ឋបាលថ្នាក់ក្រោមជាតិសហការយ៉ាងមានប្រសិទ្ធភាពជាមួយអង្គការសហគមន៍ | បជ | **0,៦៨** | *0,១៧* | 0,១១ | *0,00៧* | 0,៦៧ | 0,៧0 |
| CIV-V | ក្រុមប្រឹក្សា និងមន្ត្រីស្វែងរកមតិប្រជាពលរដ្ឋយ៉ាងសកម្មតាមរយៈមធ្យោបាយផ្លូវការ និងក្រៅផ្លូវការ | ភ | **0,៨២** | *0,0២* | 0,0១ | *0,00៥* | 0,៨១ | 0,៨៣ |
| | | គស | **0,៦0** | *0,0២* | 0,0១ | *0,00៥* | 0,៥៩ | 0,៦១ |
| | | កសខ | **0,៥៣** | *0,0២* | 0,0១ | *0,00៦* | 0,៥១ | 0,៥៤ |
| | | រខ | **0,៧២** | *0,0២* | 0,0១ | *0,0២៤* | 0,៦៨ | 0,៧៧ |
| CIV-VI | ក្រុមប្រឹក្សា និងមន្ត្រីទទួលយកបច្ចេកវិទ្យាឌីជីថល ដើម្បីសម្រួលដល់ការចូលរួមរបស់ប្រជាពលរដ្ឋ | គស | **0,៥៣** | *0,0២* | 0,0១ | *0,0១១* | 0,៥១ | 0,៥៥ |
| | | កសខ | **0,៣៥** | *0,0២* | 0,0១ | *0,0១0* | 0,៣៣ | 0,៣៧ |
| | | រខ | **0,៧១** | *0,0២* | 0,0២ | *0,0៣៥* | 0,៦៤ | 0,៧៨ |
| CIV-VII | ក្រុមប្រឹក្សា និងមន្ត្រីមានទស្សនៈវិជ្ជមានចំពោះការចូលរួមរបស់ប្រជាពលរដ្ឋ | គស | **0,៥0** | *0,0៣* | 0,0២ | *0,00៧* | 0,៤៨ | 0,៥១ |
| | | កសខ | **0,៥0** | *0,0៣* | 0,0២ | *0,00៧* | 0,៤៩ | 0,៥១ |
| | | រខ | **0,៥១** | *0,0៣* | 0,0២ | *0,0២១* | 0,៤៧ | 0,៥៦ |
| CIV-VIII | ក្រុមប្រឹក្សា និងមន្ត្រីមានទស្សនៈវិជ្ជមានចំពោះកិច្ចសហប្រតិបត្តិការរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយអង្គការសហគមន៍មូលដ្ឋាន | ភ | **0,៧១** | *0,0២* | 0,0២ | *0,00៩* | 0,៧0 | 0,៧៣ |
| | | គស | **0,៦៣** | *0,0២* | 0,0២ | *0,00៥* | 0,៦២ | 0,៦៤ |
| | | កសខ | **0,៧៤** | *0,0២* | 0,0២ | *0,00៣* | 0,៧៣ | 0,៧៤ |
| | | រខ | **0,៧៦** | *0,0២* | 0,0២ | *0,0១២* | 0,៧៤ | 0,៧៨ |
| **តម្លៃសន្ទស្សន៍រង** | | | | | **0,៥៨** | | | |

សូចនាករទាំងនេះត្រូវបានលម្អិតនៅក្នុងតារាងខាងក្រោម។ ដូចទៅនឹងទិដ្ឋភាពផ្សេងទៀតនៃអភិបាលកិច្ចដែរ កម្រិតលម្អៀងរវាងក្រុមសំណាកផ្សេងៗគ្នាគឺមានកម្រិតតូចតាច។ ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនៅរដ្ឋបាលរាជធានី ខេត្ត គឺខ្ពស់ជាងឃុំ សង្កាត់ ហើយការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនៅសង្កាត់ទីប្រជុំជនគឺខ្ពស់ជាងឃុំនៅជនបទ ប៉ុន្តែការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ហាក់ទាបជាងឃុំ សង្កាត់។

*តារាងតម្លៃសូចនាករការចូលរួមរបស់ប្រជាពលរដ្ឋតាមតំបន់ទីប្រជុំជន តំបន់ជនបទ ភេទ និងតំបន់ភូមិសាស្ត្រ*

| សូចនាករ | ការពិពណ៌នា | សំណាក | សរុប | ប្រភេទក្រុង ស្រុក ខណ្ឌ | | ភេទ | | តំបន់ភូមិសាស្ត្រ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ទីក្រុង | ជនបទ | ស្រី | ប្រុស | ភ្នំពេញ | ទំនាប | ទន្លេសាប | ខ្ពង់រាប | សមុទ្រ |
| CIV-I | ប្រជាពលរដ្ឋចូលរួមជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ លើបញ្ហាអភិបាលកិច្ច និងការអភិវឌ្ឍមូលដ្ឋាន | បជ | **០,៦៦** | ០,៦៣ | ០,៦៧ | ០,៦៩ | ០,៦២ | ០,៥៦ | ០,៦៧ | ០,៧២ | ០,៦៤ | ០,៥៤ |
| CIV-II | ប្រជាពលរដ្ឋពេញចិត្តនឹងបទពិសោធន៍ចូលរួមជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ | បជ | **០,៦៨** | ០,៧១ | ០,៦៨ | ០,៦៧ | ០,៦៩ | ០,៧៣ | ០,៦៩ | ០,៦៧ | ០,៦៧ | ០,៧២ |
| CIV-III | ប្រជាពលរដ្ឋចូលរួមក្នុងអង្គការសហគមន៍ | បជ | **០,២៣** | ០,១២ | ០,២៦ | ០,២២ | ០,២៣ | ០,០៨ | ០,៣០ | ០,១៧ | ០,២០ | ០,៣៦ |
| CIV-IV | ប្រជាពលរដ្ឋជឿថា រដ្ឋបាលថ្នាក់ក្រោមជាតិសហការមានប្រសិទ្ធភាពជាមួយអង្គការសហគមន៍ | បជ | **០,៦៨** | ០,៧៣ | ០,៦៨ | ០,៦៨ | ០,៦៩ | ០,៧៨ | ០,៦៤ | ០,៧២ | ០,៦៩ | ០,៧២ |
| CIV-V | ក្រុមប្រឹក្សា និងមន្ត្រី ស្វែងរកមតិប្រជាពលរដ្ឋយ៉ាងសកម្ម តាមរយៈមធ្យោបាយផ្លូវការ និងក្រៅផ្លូវការ | ភ | **០,៨២** | ០,៨៣ | ០,៨១ | ០,៨២ | ០,៨១ | ០,៨៥ | ០,៨៥ | ០,៧៦ | ០,៨២ | ០,៨៤ |
| | | គ.ស | **០,៦០** | ០,៦០ | ០,៦១ | ០,៦១ | ០,៦០ | ០,៥៧ | ០,៦៣ | ០,៥៧ | ០,៦៤ | ០,៥៧ |
| | | កសខ | **០,៥៣** | ០,៥៤ | ០,៥២ | ០,៥៣ | ០,៥២ | ០,៥២ | ០,៥៥ | ០,៤៨ | ០,៥២ | ០,៥៥ |
| | | រខ | **០,៧២** | - | - | ០,៦៧ | ០,៧៥ | ០,៧០ | ០,៧៦ | ០,៦៦ | ០,៧៥ | ០,៧០ |
| CIV-VI | ក្រុមប្រឹក្សា និងមន្ត្រីទទួលយកបច្ចេកវិទ្យាឌីជីថល ដើម្បីសម្រួលដល់ការចូលរួមរបស់ប្រជាពលរដ្ឋ | គ.ស | **០,៥៣** | ០,៤៦ | ០,៥២ | ០,៥៤ | ០,៥៣ | ០,៣៤ | ០,៥៣ | ០,៥៣ | ០,៦១ | ០,៤៧ |
| | | កសខ | **០,៣៥** | ០,២៦ | ០,៣៨ | ០,៣៦ | ០,៣៥ | ០,២០ | ០,៣៣ | ០,៤៤ | ០,៣៨ | ០,២៨ |
| | | រខ | **០,៧១** | - | - | ០,៥៩ | ០,៧៦ | ០,៦៧ | ០,៦៧ | ០,៥៨ | ០,៧៤ | ០,៨៨ |
| CIV-VII | ក្រុមប្រឹក្សា និងមន្ត្រីមានទស្សនៈវិជ្ជមានចំពោះការចូលរួមរបស់ប្រជាពលរដ្ឋ | គ.ស | **០,៥០** | ០,៥៣ | ០,៤៨ | ០,៥២ | ០,៤៩ | ០,៥៤ | ០,៤៧ | ០,៥១ | ០,៥០ | ០,៥០ |
| | | កសខ | **០,៥០** | ០,៥២ | ០,៥០ | ០,៤៩ | ០,៥១ | ០,៥២ | ០,៤៧ | ០,៥៣ | ០,៥០ | ០,៤៨ |
| | | រខ | **០,៥១** | - | - | ០,៥០ | ០,៥២ | ០,៤៦ | ០,៥៤ | ០,៥៥ | ០,៥០ | ០,៤៩ |
| CIV-VIII | ក្រុមប្រឹក្សា និងមន្ត្រីមានទស្សនៈវិជ្ជមានចំពោះកិច្ចសហប្រតិបត្តិការរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយអង្គការសហគមន៍មូលដ្ឋាន | ភ | **០,៧១** | ០,៧០ | ០,៧២ | ០,៧៣ | ០,៧១ | ០,៦៨ | ០,៧១ | ០,៧១ | ០,៧២ | ០,៧៥ |
| | | គ.ស | **០,៦៣** | ០,៦២ | ០,៦៤ | ០,៦២ | ០,៦៤ | ០,៥៨ | ០,៦០ | ០,៦៤ | ០,៦៦ | ០,៦៥ |
| | | កសខ | **០,៧៤** | ០,៧៤ | ០,៧៤ | ០,៧៣ | ០,៧៤ | ០,៧៦ | ០,៧៣ | ០,៧៣ | ០,៧៥ | ០,៧៤ |
| | | រខ | **០,៧៦** | - | - | ០,៨០ | ០,៧៤ | ០,៧៩ | ០,៨០ | ០,៧៧ | ០,៧២ | ០,៧៦ |
| **តម្លៃរងសន្ទស្សន៍** | | | **០,៥៧** | **០,៥៥** | **០,៥៧** | **០,៥៨** | **០,៥៧** | **០,៥៥** | **០,៥៨** | **០,៥៨** | **០,៥៧** | **០,៥៩** |

## ៥.៦.២. តម្លៃនៃការចូលរួមរបស់ប្រជាពលរដ្ឋដែលវាយតម្លៃដោយប្រជាពលរដ្ឋ

ប្រជាពលរដ្ឋភាគច្រើនបានផ្តល់ចម្លើយថា បានចូលរួមក្នុងកិច្ចប្រជុំដែលរៀបចំដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយអ្នកចូលរួមទាំងនោះបានវាយតម្លៃជាវិជ្ជមានអំពីបទពិសោធន៍នៃការចូលរួមរបស់ពួកគេ ប៉ុន្តែឱកាសក្នុងការចែករំលែកគំនិតជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិនៅក្រៅកិច្ចប្រជុំផ្សេងៗនៅមានកម្រិតនៅឡើយ។ អង្គការសហគមន៍មូលដ្ឋានមានសកម្មភាពនៅស្ទើរគ្រប់ទីកន្លែងនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ប៉ុន្តែមានតែប្រជាពលរដ្ឋប្រហែល ២៣%ប៉ុណ្ណោះដែលជាសមាជិកនៃអង្គការសហគមន៍មូលដ្ឋាន

ទាំងនោះ។ ការឆ្លើយតបរបស់ប្រជាពលរដ្ឋចំពោះសំណួរអំពីការចូលរួមរបស់ប្រជាពលរដ្ឋត្រូវបានសង្ខេប នៅក្នុងតារាងខាងក្រោម៖

*តារាងតម្លៃនៃចម្លើយរបស់ប្រជាពលរដ្ឋចំពោះសំណួរពាក់ព័ន្ធការចូលរួមរបស់ប្រជាពលរដ្ឋ*

| លេខសម្គាល់ | អ្នកពិពណ៌នា | ពិន្ទុ | មេគុណ | តម្លៃ | កំហុសស្តង់ដា | ៩៥% ចន្លោះទំនុកចិត្ត | |
|---|---|---|---|---|---|---|---|
| | | | | | | ទាបបំផុត | ខ្ពស់ |
| បជ.CIV.១ | តើអ្នកបានចូលរួមកិច្ចប្រជុំដែលរៀបចំដោយរដ្ឋបាលថ្នាក់ក្រោមជាតិឬទេ? | ០,៦៦ | ១.00 | ០,៦៦ | ០,00៩ | ០,៦៤ | ០,៦៧ |
| **បជ.CIV-I** | **ប្រជាពលរដ្ឋចូលរួមជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិលើបញ្ហាអភិបាលកិច្ច និងការអភិវឌ្ឍមូលដ្ឋាន** | | | **០,៦៦** | **០,00៩** | **០,៦៤** | **០,៦៧** |
| បជ.CIV.៣ | ការវាយតម្លៃអំពីភាពងាយស្រួលពាក់ព័ន្ធនឹងការបើកចំហសិទ្ធិនៃការចូលរួម | ០,៨៥ | ០,៥0 | ០,៤៣ | ០,00៤ | ០,៨៤ | ០,៨៦ |
| បជ.CIV.៤ | តើពលរដ្ឋមានឱកាសចែករំលែកគំនិតជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិក្រៅកិច្ចប្រជុំដែរឬទេ? | ០,៥២ | ០,៥0 | ០,២៦ | ០,0១0 | ០,៥0 | ០,៥៤ |
| **បជ.CIV-II** | **ប្រជាពលរដ្ឋពេញចិត្តនឹងបទពិសោធន៍ចូលរួមជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ** | | | **០,៦៨** | **០,00៥** | **០,៦៧** | **០,៦៩** |
| បជ.CIV.៥ | សមាជិកភាពនៃអង្គការសហគមន៍មូលដ្ឋាន | ០,២៣ | ១.00 | ០,២៣ | ០,0១0 | ០,២១ | ០,២៤ |
| **បជ.CIV-III** | **ប្រជាពលរដ្ឋចូលរួមក្នុងអង្គការសហគមន៍** | | | **០,២៣** | **០,0១0** | **០,២១** | **០,២៤** |
| បជ.CIV.៦ | ទំនាក់ទំនងរវាងអង្គការសហគមន៍មូលដ្ឋាន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | ០,៦៨ | ១.00 | ០,៦៨ | ០,0១២ | ០,៦៦ | ០,៧១ |
| **បជ.CIV-IV** | **ប្រជាពលរដ្ឋជឿថា រដ្ឋបាលថ្នាក់ក្រោមជាតិសហការយ៉ាងមានប្រសិទ្ធភាពជាមួយអង្គការសហគមន៍មូលដ្ឋាន** | | | **០,៦៨** | **០,00៧** | **០,៦៧** | **០,៧0** |

គួរកត់សម្គាល់ថា ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចប្រជុំនៅរាជធានីភ្នំពេញមានកម្រិតទាបជាងតំបន់ផ្សេងទៀត ប៉ុន្តែប្រជាពលរដ្ឋនៅរាជធានីភ្នំពេញបញ្ជាក់ថា មានឱកាសខ្ពស់ក្នុងការចែករំលែកគំនិតជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិនៅខាងក្រៅកិច្ចប្រជុំ។ ប្រជាពលរដ្ឋជាបុរសបានចូលរួមក្នុងកិច្ចប្រជុំនានាខ្ពស់ជាងប្រជាពលរដ្ឋជាស្ត្រី ទោះបីជាពិន្ទុនៃការចូលរួមដែលវាយតម្លៃដោយប្រជាជនទាំងពីរភេទស្ថិតនៅក្នុងកម្រិត "មធ្យម"ក៏ដោយ។

**ការឆ្លុះបញ្ចាំង ៖ របៀបដែលប្រជាពលរដ្ឋចែករំលែកទស្សនៈរបស់ខ្លួនជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ**

ក្នុងចំណោមប្រជាពលរដ្ឋចំនួន ១.៩១៨នាក់ មាន១.០៥៧នាក់ (៥៥%) បានរាយការណ៍ថា បានចូលរួមកិច្ចប្រជុំដែលរៀបចំដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងរយៈពេល២ឆ្នាំកន្លងមក ហើយប្រជាពលរដ្ឋ ១៩% បាននិយាយថាពួកគេបាននិយាយដោយផ្ទាល់នៅក្នុងកិច្ចប្រជុំទាំងនេះ។ នៅក្នុង ៨៤% បានចូលរួមកិច្ចប្រជុំធ្វើឡើងនៅក្នុងភូមិរបស់ពួកគេ ខណៈដែល ១៦% បានចូលរួមកិច្ចប្រជុំដែលធ្វើឡើងនៅទីតាំងផ្សេងទៀត។

ប្រជាពលរដ្ឋបានផ្តល់តម្លៃវិជ្ជមានខ្ពស់អំពីបទពិសោធន៍របស់ពួកគេនៃការចូលរួមក្នុងកិច្ចប្រជុំទាំងនេះ ដោយជាង ៩០% បញ្ជាក់ថា ពួកគេពេញចិត្ត ឬពេញចិត្តយ៉ាងខ្លាំងចំពោះទិដ្ឋភាពទាំងប្រាំមួយដែលត្រូវបានសួរ។

| សូចនាករគុណភាពនៃការប្រជុំ | % ពេញចិត្ត |
|---|---|
| ពេលវេលា និងទីតាំងងាយស្រួល | ៩៦% |
| បញ្ហាទាក់ទងនឹងអ្នក | ៩២% |
| ងាយស្រួលសម្រាប់ពលរដ្ឋធម្មតាក្នុងការនិយាយ | ៩៣% |
| អ្នកចូលរួមស្តាប់ប្រជាពលរដ្ឋ | ៩២% |
| មេដឹកនាំបានស្តាប់ប្រជាពលរដ្ឋ | ៩៣% |
| យល់ស្របនឹងការសម្រេចចិត្តដែលបានធ្វើឡើង | ៩៣% |

| វិធីសាស្ត្រចែករំលែកអំពីទស្សនៈ | % ដែលឆ្លើយថាងាយស្រួល |
|---|---|
| ពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ឬមន្ត្រី | ៤០% |
| ពិភាក្សាជាមួយក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឬមន្ត្រី | ២៣% |
| និយាយជាមួយក្រុមប្រឹក្សារាជធានី ខេត្ត ឬមន្ត្រី | ១៦% |
| ផ្ញើលិខិត | ២២% |
| ទូរស័ព្ទ Facebook ជាដើម | ១៩% |
| ជួបជាមួយអង្គការនានាដែលអាចពាំនាំទស្សនៈរបស់ពួកគេទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ | ២៣% |

ឱកាសប្រជាពលរដ្ឋក្នុងការចែករំលែកទស្សនៈជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិនៅក្រៅកិច្ចប្រជុំមានកម្រិតនៅឡើយ។

ប្រជាពលរដ្ឋត្រូវបានគេសួរថា តើពួកគេងាយស្រួលក្នុងការចែករំលែកទស្សនៈតាមមធ្យោបាយណា? អ្នកឆ្លើយតបបាននិយាយថាមធ្យោបាយនីមួយៗ "ងាយស្រួលណាស់" ឬ"ងាយស្រួល" ដែលត្រូវបានសង្ខេបនៅក្នុងតារាង។

## ៥.៦.៣. តម្លៃនៃការចូលរួមរបស់ប្រជាពលរដ្ឋដែលបានវាយតម្លៃដោយរដ្ឋបាលថ្នាក់ក្រោមជាតិ

ពិន្ទុរបស់អ្នកឆ្លើយដែលជាមន្ត្រី និងក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងការចូលរួមរបស់ប្រជាពលរដ្ឋត្រូវបានសង្ខេបនៅក្នុងតារាងខាងក្រោម។ ថ្នាក់ដឹកនាំភូមិយល់ឃើញថា កិច្ចប្រជុំរដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងភូមិរបស់ខ្លួនកាលពីឆ្នាំមុនមាន៩០%ករណី ហើយពួកគេវាយតម្លៃថាគុណភាពនៃកិច្ចប្រជុំទាំងនេះ គឺខ្ពស់ (០,៨៩) តែបានវាយតម្លៃកម្រិតមធ្យមសម្រាប់ការផ្តល់ឱកាសឱ្យប្រជាពលរដ្ឋចែករំលែកអំពីទស្សនៈផ្សេងៗក្នុងកិច្ចប្រជុំទាំងនោះគឺ (០,៦៦) ប៉ុណ្ណោះ។ ឃុំ សង្កាត់យល់ឃើញថាមានសារៈសំខាន់ខ្លាំងក្នុងការរៀបចំកិច្ចប្រជុំដែលមានការចូលរួមពីប្រជាពលរដ្ឋ ហើយការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ បានត្រឹមកម្រិតមធ្យមប៉ុណ្ណោះ។

ការប្រើប្រាស់មធ្យោបាយផ្សេងៗទៀតដើម្បីទទួលបានទស្សនៈរបស់ប្រជាពលរដ្ឋ ត្រូវបានបង្ហាញថា មានកម្រិតទាបនៅថ្នាក់ឃុំ សង្កាត់ និងក្រុង ស្រុក ប៉ុន្តែមានកម្រិតខ្ពស់នៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត។ ទោះយ៉ាងនេះក្តី អ្នកឆ្លើយសំណួរជាមន្ត្រី និងក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិបានផ្តល់ពិន្ទុកម្រិតខ្សោយទៅលើអត្ថប្រយោជន៍នៃការចូលរួមរបស់ពលរដ្ឋ។ ប្រការនេះ អាចដោយសារតែការយល់ឃើញថា ការចូលរួមរបស់ប្រជាពលរដ្ឋ គឺជាការផ្សព្វផ្សាយព័ត៌មាន និងការប្រមូលទិន្នន័យតែប៉ុណ្ណោះជាជាងការស្តាប់មតិយោបល់របស់ប្រជាពលរដ្ឋ។

រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌបានផ្តល់ពិន្ទុខ្ពស់ចំពោះសកម្មភាពរបស់អង្គការសហគមន៍មូលដ្ឋាន បើប្រៀបធៀបទៅនឹងឃុំ សង្កាត់។ ប្រការនេះ អាចបណ្តាលមកពីមានចំនួនអង្គការសហគមន៍មូលដ្ឋានច្រើននៅក្នុងខេត្តទាំងមូល បើប្រៀបធៀបទៅនឹងចំនួនអង្គការសហគមន៍មូលដ្ឋាននៅតាមឃុំ សង្កាត់នីមួយៗ។ ជាទូទៅ ទស្សនៈរបស់មន្ត្រី និងក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិអំពីអង្គការសហគមន៍មូលដ្ឋានមានភាពវិជ្ជមាន ប៉ុន្តែក្រុមប្រឹក្សាឃុំ សង្កាត់ ហាក់មានមន្ទិលសង្ស័យអំពីតម្លៃនៃអង្គការសហគមន៍មូលដ្ឋាន ជាងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌនិងរាជធានី ខេត្ត។

*ប្រភេទនៃអង្គការសហគមន៍មូលដ្ឋាន*

**ការវិភាគ/ពិនិត្យ: ការឆ្លុះបញ្ចាំង ៖ តើអង្គការសហគមន៍មូលដ្ឋានប្រភេទណាដែលប្រជាពលរដ្ឋចូលរួម?**

ប្រជាពលរដ្ឋត្រូវបានសួរថា តើពួកគេជាសមាជិកនៃអង្គការសហគមន៍មូលដ្ឋាននានាដែរឬទេ។ សរុបមក ២៤% នៃអ្នកឆ្លើយតបបាននិយាយថា ពួកគេជាសមាជិកអង្គការសហគមន៍មូលដ្ឋាន រួមមានដូចជា ក្រុមសន្សំប្រាក់ អង្គការសហគមន៍សេដ្ឋកិច្ច សហករណ៍កសិកម្ម និងក្រុមថែទាំហេដ្ឋារចនាសម្ព័ន្ធ និងការការពារធនធានធម្មជាតិ។

៨០% នៃថ្នាក់ដឹកនាំភូមិ និង ៩៤% នៃក្រុមប្រឹក្សាឃុំ សង្កាត់ បានរាយការណ៍អំពីសកម្មភាពរបស់អង្គការសហគមន៍មូលដ្ឋាន យ៉ាងហោចណាស់ក៏មានមួយដែរនៅក្នុងឃុំ សង្កាត់របស់គេ។ ៧៣% នៃអ្នកដឹកនាំភូមិ និង ៨៧% នៃក្រុមប្រឹក្សាឃុំ សង្កាត់ បានរាយការណ៍ថា មានអង្គការសហគមន៍មូលដ្ឋានយ៉ាងហោចណាស់មួយប្រភេទដែលមានភាពសកម្មនៅក្នុងតំបន់របស់ពួកគេ។

| ប្រភេទនៃអង្គការសហគមន៍មូលដ្ឋាន | % ប្រជាពលរដ្ឋជាសមាជិក | % នៅតាមតំបន់ | | %នៃភាពសកម្មតាមតំបន់ | |
|---|---|---|---|---|---|
| | | ភូមិ | ឃុំ សង្កាត់ | ភូមិ | ឃុំ សង្កាត់ |
| អង្គការសហគមន៍សេដ្ឋកិច្ច ឧទាហរណ៍ សហករណ៍កសិកម្ម ឬ ក្រុមអាជីវកម្ម | ៧% | ៣១% | ៤៦% | ២៣% | ៣៧% |
| ក្រុមសន្សំប្រាក់ | ៩% | ៣៨% | ៤៩% | ២៩% | ៣៩% |
| អង្គការសហគមន៍គ្រប់គ្រង និងការពារធនធានធម្មជាតិ (សហគមន៍ព្រៃឈើ សហគមន៍នេសាទ។ល។) | ៥% | ៣១% | ៤៣% | ២៤% | ៣៨% |
| ក្រុមថែរក្សាហេដ្ឋារចនាសម្ព័ន្ធ (ប្រឡាយ អណ្តូងទឹក ។ល។) | ៥% | ៣៣% | ៤៣% | ២៨% | ៣៥% |
| សហជីព | 0% | ៤% | ៩% | ៤% | ៧% |
| អង្គការសាសនា | ៤% | ២៣% | ៥២% | ១៦% | ៣៨% |
| អង្គការជួយជនក្រីក្រ និងជនងាយរងគ្រោះ | ៧% | ៣២% | ៤៤% | ២៨% | ៣៧% |
| ក្លឹបកីឡា និងសមាគមសកម្មភាពកម្សាន្តផ្សេងៗ | ២% | ៩% | ១៥% | ៧% | ១១% |
| ប្រភេទផ្សេងទៀតនៃអង្គការសហគមន៍ | ៣% | ១២% | ២៤% | ១0% | ២១% |
| អង្គការសហគមន៍មូលដ្ឋានផ្សេងទៀត | ២៤% | ៨0% | ៩៤% | ៧៣% | ៨៧% |

*តារាងតម្លៃនៃការឆ្លើយតបរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះសំណួរពាក់ព័ន្ធនឹងការចូលរួមរបស់ប្រជាពលរដ្ឋ*

| លេខសម្គាល់ | អ្នកពិពណ៌នា | ពិន្ទុ | មេគុណ | តម្លៃ | កំហុសស្តង់ដា | ៩៥% ចន្លោះទំនុកចិត្ត | |
|---|---|---|---|---|---|---|---|
| | | | | | | ទាបបំផុត | ខ្ពស់បំផុត |
| ភ.CIV.១ | តើរដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំកិច្ចប្រជុំនៅក្នុងភូមិ (២ឆ្នាំចុងក្រោយ) | **0,៩0** | 0,៣៣ | 0,៣0 | 0,00៩ | 0,៨៩ | 0,៩២ |
| ភ.CIV.២ | ការវាយតម្លៃអំពីភាពងាយស្រួល និងការបើកចំហសម្រាប់ការចូលរួមកិច្ចប្រជុំ | **0,៨៨** | 0,៣៣ | 0,២៩ | 0,00៦ | 0,៨៧ | 0,៩0 |
| ភ.CIV.៣ | តើពលរដ្ឋមានឱកាសចែករំលែកគំនិតជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិក្រៅកិច្ចប្រជុំដែរឬទេ? | **0,៦៦** | 0,៣៣ | 0,២២ | 0,00៩ | 0,៦៤ | 0,៦៨ |

| លេខសម្គាល់ | អ្នកពិពណ៌នា | ពិន្ទុ | មេគុណ | តម្លៃ | កំហុសស្តង់ដា | ៩៥% ចន្លោះទំនុកចិត្ត | |
|---|---|---|---|---|---|---|---|
| | | | | | | ទាបបំផុត | ខ្ពស់បំផុត |
| **ភ.CIV-V** | **ក្រុមប្រឹក្សា និងមន្ត្រីស្វែងរកមតិយោបល់របស់ប្រជាពលរដ្ឋយ៉ាងសកម្ម តាមរយៈមធ្យោបាយផ្លូវការ និងក្រៅផ្លូវការ** | | | **0,៨២** | **0,00៥** | **0,៨១** | **0,៨៣** |
| យស.CIV.១ | តើរដ្ឋបាលថ្នាក់ក្រោមជាតិរៀបចំកិច្ចប្រជុំដោយមានការចូលរួមញឹកញាប់? | **0,៨៤** | 0,៣0 | 0,២៥ | 0,0១0 | 0,៨២ | 0,៨៦ |
| យស.CIV.២ | តើការប្រជុំដែលមានការចូលរួមត្រូវធ្វើនៅឯណា? | **0,៨៤** | 0,១0 | 0,0៨ | 0,00៨ | 0,៨២ | 0,៨៦ |
| យស.CIV.៣ | តើប្រជាពលរដ្ឋចូលរួមប្រជុំក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិដែរឬទេ? | **0,៦៥** | 0,៣0 | 0,២0 | 0,0១២ | 0,៦៣ | 0,៦៨ |
| យស.CIV.៤ | តើរដ្ឋបាលថ្នាក់ក្រោមជាតិប្រើមធ្យោបាយអ្វី ដើម្បីស្វែងរកទស្សនៈប្រជាជន? | **0,២៤** | 0,៣0 | 0,0៧ | 0,00៩ | 0,២២ | 0,២៦ |
| **យស.CIV-V** | **ក្រុមប្រឹក្សា និងមន្ត្រីស្វែងរកមតិយោបល់របស់ប្រជាពលរដ្ឋយ៉ាងសកម្ម តាមរយៈមធ្យោបាយផ្លូវការ និងក្រៅផ្លូវការ** | | | **0,៦0** | **0,00៥** | **0,៥៩** | **0,៦១** |
| កសខ.CIV.១ | តើរដ្ឋបាលថ្នាក់ក្រោមជាតិរៀបចំកិច្ចប្រជុំដោយមានការចូលរួមញឹកញាប់? | **0,៧៩** | 0,៣0 | 0,២៤ | 0,0១១ | 0,៧៦ | 0,៨១ |
| កសខ.CIV.២ | តើការប្រជុំដែលមានការចូលរួមត្រូវធ្វើនៅឯណា? | **0,៨៨** | 0,១0 | 0,0៩ | 0,00៨ | 0,៨៦ | 0,៨៩ |
| កសខ.CIV.៣ | តើប្រជាពលរដ្ឋចូលរួមប្រជុំក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិដែរឬទេ? | **0,៥៤** | 0,៣0 | 0,១៦ | 0,0១៣ | 0,៥១ | 0,៥៦ |
| កសខ.CIV.៤ | តើរដ្ឋបាលថ្នាក់ក្រោមជាតិប្រើមធ្យោបាយអ្វី ដើម្បីស្វែងរកទស្សនៈប្រជាជន? | **0,១៤** | 0,៣0 | 0,0៤ | 0,00៨ | 0,១២ | 0,១៥ |
| **កសខ.CIV-V** | **ក្រុមប្រឹក្សា និងមន្ត្រីស្វែងរកមតិយោបល់របស់ប្រជាពលរដ្ឋយ៉ាងសកម្ម តាមរយៈមធ្យោបាយផ្លូវការ និងក្រៅផ្លូវការ** | | | **0,៥៣** | **0,00៦** | **0,៥១** | **0,៥៤** |
| រខ.CIV.១ | តើរដ្ឋបាលថ្នាក់ក្រោមជាតិរៀបចំកិច្ចប្រជុំដោយមានការចូលរួមញឹកញាប់? | **0,៨0** | 0,៣0 | 0,២៤ | 0,0៣៦ | 0,៧៣ | 0,៨៧ |
| រខ.CIV.២ | តើការប្រជុំដែលមានការចូលរួមត្រូវធ្វើនៅឯណា? | **0,៨៦** | 0,១0 | 0,0៩ | 0,0២៧ | 0,៨១ | 0,៩១ |
| រខ.CIV.៣ | តើប្រជាពលរដ្ឋចូលរួមប្រជុំក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិដែរឬទេ? | **0,៥២** | 0,៣0 | 0,១៥ | 0,0៥៩ | 0,៤0 | 0,៦៣ |
| រខ.CIV.៤ | តើរដ្ឋបាលថ្នាក់ក្រោមជាតិប្រើមធ្យោបាយអ្វី ដើម្បីស្វែងរកទស្សនៈប្រជាជន? | **0,៨១** | 0,៣0 | 0,២៤ | 0,0៤៨ | 0,៧២ | 0,៩១ |
| **រខ.CIV-V** | **ក្រុមប្រឹក្សា និងមន្ត្រីស្វែងរកមតិយោបល់របស់ប្រជាពលរដ្ឋយ៉ាងសកម្ម តាមរយៈមធ្យោបាយផ្លូវការ និងក្រៅផ្លូវការ** | | | **0,៧២** | **0,0២៤** | **0,៦៨** | **0,៧៧** |
| យស.CIV.៥ | តើប្រព័ន្ធផ្សព្វផ្សាយឌីជីថលប្រភេទណាខ្លះ ដែលរដ្ឋបាលថ្នាក់ក្រោមជាតិប្រើប្រាស់? | **0,៥៣** | ១.00 | 0,៥៣ | 0,0១១ | 0,៥១ | 0,៥៥ |
| **យស.CIV-VI** | **ក្រុមប្រឹក្សា និងមន្ត្រីទទួលយកបច្ចេកវិទ្យាឌីជីថល ដើម្បីសម្រួលដល់ការចូលរួមរបស់ប្រជាពលរដ្ឋ** | | | 0,៥៣ | 0,0១១ | 0,៥១ | 0,៥៥ |
| កសខ.CIV.៥ | តើប្រព័ន្ធផ្សព្វផ្សាយឌីជីថលប្រភេទណាខ្លះ ដែលរដ្ឋបាលថ្នាក់ក្រោមជាតិប្រើប្រាស់? | **0,៣៥** | ១.00 | 0,៣៥ | 0,0១0 | 0,៣៣ | 0,៣៧ |
| **កសខ.CIV-VI** | **ក្រុមប្រឹក្សា និងមន្ត្រីទទួលយកបច្ចេកវិទ្យាឌីជីថល ដើម្បីសម្រួលដល់ការចូលរួមរបស់ប្រជាពលរដ្ឋ** | | | **0,៣៥** | **0,0១0** | **0,៣៣** | **0,៣៧** |
| រខ.CIV.៥ | តើប្រព័ន្ធផ្សព្វផ្សាយឌីជីថលប្រភេទណាខ្លះ ដែលរដ្ឋបាលថ្នាក់ក្រោមជាតិប្រើប្រាស់? | **0,៧១** | ១.00 | 0,៧១ | 0,0២៨ | 0,៦៦ | 0,៧៦ |
| **រខ.CIV-VI** | **ក្រុមប្រឹក្សា និងមន្ត្រីទទួលយកបច្ចេកវិទ្យាឌីជីថល ដើម្បីសម្រួលដល់ការចូលរួមរបស់ប្រជាពលរដ្ឋ** | | | 0,៧១ | 0,0៣៥ | 0,៦៤ | 0,៧៨ |
| យស.CIV.៦ | រដ្ឋបាលថ្នាក់ក្រោមជាតិវាយតម្លៃអត្ថប្រយោជន៍នៃការចូលរួមរបស់ប្រជាជន | **0,៥0** | ១.00 | 0,៥0 | 0,00៦ | 0,៤៩ | 0,៥១ |
| **យស.CIV-VII** | **ក្រុមប្រឹក្សា និងមន្ត្រីមានទស្សនៈវិជ្ជមានចំពោះការចូលរួមរបស់ប្រជាពលរដ្ឋ** | | | 0,៥0 | 0,00៧ | 0,៤៨ | 0,៥១ |
| កសខ.CIV.៦ | រដ្ឋបាលថ្នាក់ក្រោមជាតិវាយតម្លៃអត្ថប្រយោជន៍នៃការចូលរួមរបស់ប្រជាជន | 0,៥0 | ១.00 | 0,៥0 | 0,00៥ | 0,៤៩ | 0,៥១ |
| **កសខ.CIV-VII** | **ក្រុមប្រឹក្សា និងមន្ត្រីមានទស្សនៈវិជ្ជមានចំពោះការចូលរួមរបស់ប្រជាពលរដ្ឋ** | | | 0,៥0 | 0,00៧ | 0,៤៩ | 0,៥១ |
| រខ.CIV.៦ | រដ្ឋបាលថ្នាក់ក្រោមជាតិវាយតម្លៃអត្ថប្រយោជន៍នៃការចូលរួមរបស់ប្រជាជន | 0,៥១ | ១.00 | 0,៥១ | 0,0៦0 | 0,៤0 | 0,៦៣ |
| **រខ.CIV-VII** | **ក្រុមប្រឹក្សា និងមន្ត្រីមានទស្សនៈវិជ្ជមានចំពោះការចូលរួមរបស់ប្រជាពលរដ្ឋ** | | | **0,៥១** | **0,0២១** | **0,៤៧** | **0,៥៦** |
| ភ.CIV.៤ | សមាជិកភាពនៃអង្គការសហគមន៍មូលដ្ឋាន | 0,៤៨ | 0,២0 | 0,១0 | 0,0១៩ | 0,៤៤ | 0,៥២ |
| ភ.CIV.៥ | តើរដ្ឋបាលថ្នាក់ក្រោមជាតិមានទស្សនៈវិជ្ជមានចំពោះអង្គការសហគមន៍មូលដ្ឋានដែរឬទេ? | 0,៧២ | 0,៤0 | 0,២៩ | 0,00៩ | 0,៧0 | 0,៧៤ |
| ភ.CIV.៦ | ទំនាក់ទំនងរវាងអង្គការសហគមន៍មូលដ្ឋាន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | 0,៨៣ | 0,៤0 | 0,៣៣ | 0,00៨ | 0,៨១ | 0,៨៤ |

| លេខសម្គាល់ | អ្នកពិពណ៌នា | ពិន្ទុ | មេគុណ | តម្លៃ | កំហុសស្តង់ដា | ៩៥% ចន្លោះទំនុកចិត្ត | |
|---|---|---|---|---|---|---|---|
| | | | | | | ទាបបំផុត | ខ្ពស់បំផុត |
| **ភ.CIV-VIII** | **ក្រុមប្រឹក្សា និងមន្ត្រីមានទស្សនៈវិជ្ជមានចំពោះកិច្ចសហប្រតិបត្តិការរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយអង្គការសហគមន៍មូលដ្ឋាន** | | | **០,៧១** | **០,០០៩** | **០,៧០** | **០,៧៣** |
| យស.CIV.៧ | សមាជិកភាពនៃអង្គការសហគមន៍មូលដ្ឋាន | ០,៥៦ | ០,២០ | ០,១១ | ០,០០៧ | ០,៥៤ | ០,៥៧ |
| យស.CIV.៨ | តើរដ្ឋបាលថ្នាក់ក្រោមជាតិមានទស្សនៈវិជ្ជមានចំពោះអង្គការសហគមន៍មូលដ្ឋានដែរឬទេ? | ០,៤៨ | ០,៤០ | ០,១៩ | ០,០០៤ | ០,៤៧ | ០,៤៩ |
| យស.CIV.៩ | ទំនាក់ទំនងរវាងអង្គការសហគមន៍មូលដ្ឋាន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | ០,៨២ | ០,៤០ | ០,៣៣ | ០,០០៩ | ០,៨០ | ០,៨៤ |
| **យស.CIV-VIII** | **ក្រុមប្រឹក្សា និងមន្ត្រីមានទស្សនៈវិជ្ជមានចំពោះកិច្ចសហប្រតិបត្តិការរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយអង្គការសហគមន៍មូលដ្ឋាន** | | | **០,៦៣** | **០,០០៥** | **០,៦២** | **០,៦៤** |
| កសខ.CIV.៧ | សមាជិកភាពនៃអង្គការសហគមន៍មូលដ្ឋាន | - | | | | | |
| កសខ.CIV.៨ | តើរដ្ឋបាលថ្នាក់ក្រោមជាតិមានទស្សនៈវិជ្ជមានចំពោះអង្គការសហគមន៍មូលដ្ឋានដែរឬទេ? | ០,៦២ | ០,៥០ | ០,៣១ | ០,០០៦ | ០,៦១ | ០,៦៣ |
| កសខ.CIV.៩ | ទំនាក់ទំនងរវាងអង្គការសហគមន៍មូលដ្ឋាន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | ០,៨៥ | ០,៥០ | ០,៤៣ | ០,០០៦ | ០,៨៤ | ០,៨៧ |
| **កសខ.CIV-VIII** | **ក្រុមប្រឹក្សា និងមន្ត្រីមានទស្សនៈវិជ្ជមានចំពោះកិច្ចសហប្រតិបត្តិការរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយអង្គការសហគមន៍មូលដ្ឋាន** | | | **០,៧៤** | **០,០០៣** | **០,៧៣** | **០,៧៤** |
| រខ.CIV.៧ | សមាជិកភាពនៃអង្គការសហគមន៍មូលដ្ឋាន | ០,៦៧ | ០,២០ | ០,១៣ | ០,០៤១ | ០,៥៩ | ០,៧៥ |
| រខ.CIV.៨ | តើរដ្ឋបាលថ្នាក់ក្រោមជាតិមានទស្សនៈវិជ្ជមានចំពោះអង្គការសហគមន៍មូលដ្ឋានដែរឬទេ? | ០,៧១ | ០,៤០ | ០,២៨ | ០,០២០ | ០,៦៧ | ០,៧៥ |
| រខ.CIV.៩ | ទំនាក់ទំនងរវាងអង្គការសហគមន៍មូលដ្ឋាន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | ០,៨៥ | ០,៤០ | ០,៣៤ | ០,០២៨ | ០,៨០ | ០,៩១ |
| **រខ.CIV-VIII** | **ក្រុមប្រឹក្សា និងមន្ត្រីមានទស្សនៈវិជ្ជមានចំពោះកិច្ចសហប្រតិបត្តិការរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយអង្គការសហគមន៍មូលដ្ឋាន** | | | **០,៧៦** | **០,០១២** | **០,៧៤** | **០,៧៨** |

## *ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចប្រជុំក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ*

**ការឆ្លុះបញ្ចាំង ៖ តើប្រជាពលរដ្ឋចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាដែរឬទេ?**

ក្រុមប្រឹក្សា និងមន្ត្រីនៅឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត ត្រូវបានសួរអំពីការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សា។ ចម្លើយហាក់មានភាពខុសគ្នាច្រើន ដោយភាគច្រើនអះអាងថា ប្រជាពលរដ្ឋអាចចូលរួមដោយសេរី ខណៈចម្លើយមួយចំនួនលើកឡើងថា ពលរដ្ឋមិនអនុញ្ញាតឱ្យចូលរួម។ ចម្លើយត្រូវបានសង្ខេបនៅក្នុងតារាង។

សរុបមក អ្នកឆ្លើយដែលជាក្រុមប្រឹក្សាឃុំ សង្កាត់ ៦០% បានឆ្លើយថា ប្រជាពលរដ្ឋអាចចូលរួមដោយសេរី។ ការឆ្លើយបែបនេះ សម្រាប់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មាន៤៦% និងរាជធានី ខេត្តមាន ៤០% ប៉ុណ្ណោះ។

| ការពិពណ៌នា | % នៃអ្នកឆ្លើយតប | | |
|---|---|---|---|
| | ឃុំ សង្កាត់ | ក្រុង ស្រុក ខណ្ឌ | រាជធានី ខេត្ត |
| ប្រជាពលរដ្ឋអាចចូលរួម ហើយមានប្រជាពលរដ្ឋចូលរួមច្រើនជាងសមាជិកក្រុមប្រឹក្សានៅក្នុងកិច្ចប្រជុំ | ៤៣% | ២៩% | ៣៣% |
| ប្រជាពលរដ្ឋអាចចូលរួមបាន ប៉ុន្តែមិនមានច្រើនទេ ជាធម្មតាមានក្រុមប្រឹក្សាច្រើនជាងប្រជាពលរដ្ឋ | ១៧% | ១៧% | ៧% |
| ប្រជាពលអាចចូលរួមកិច្ចប្រជុំក្រុមប្រឹក្សានៅពេលដែលមានការអញ្ជើញដោយហេតុផលជាក់លាក់មួយ | ៣៤% | ៤១% | ៤១% |
| ប្រជាពលមិនចូលរួមប្រជុំក្រុមប្រឹក្សា | ៦% | ១២% | ១៩% |

**ការឆ្លុះបញ្ចាំង៖ តើរដ្ឋបាលថ្នាក់ក្រោមជាតិប្រើវិធីសាស្ត្រអ្វីខ្លះ ដើម្បីស្វែងយល់ពីទស្សនៈរបស់ប្រជាពលរដ្ឋ?**

កិច្ចប្រជុំដែលមានការចូលរួមពីប្រជាពលរដ្ឋនៅតែជាមធ្យោបាយសំខាន់សម្រាប់ថ្នាក់ដឹកនាំ និងសមាជិកក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីចែករំលែកព័ត៌មាន និងស្វែងយល់ពីទស្សនៈ និងអាទិភាពរបស់ប្រជាពលរដ្ឋ ប៉ុន្តែនៅក្នុងសេដ្ឋកិច្ចទំនើប ប្រជាពលរដ្ឋទំនងជានឹងពិបាករកពេលវេលាសម្រាប់ចូលរួមកិច្ចប្រជុំបែបនេះ។ ដូច្នេះ គួរពិនិត្យលើការប្រើប្រាស់វិធីសាស្ត្រផ្សេងៗ រួមទាំងប្រព័ន្ធផ្សព្វផ្សាយឌីជីថល ដែលអនុញ្ញាតឱ្យប្រជាពលរដ្ឋចែករំលែកទស្សនៈរបស់ពួកគេជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។

ការអង្កេតបានសួរសមាជិកក្រុមប្រឹក្សា និងមន្ត្រីថា តើរដ្ឋបាលថ្នាក់ក្រោមជាតិបានប្រើវិធីណាមួយក្នុងចំណោមវិធីសាស្ត្រចំនួនបួន ដើម្បីស្វែងរកគំនិត ឬទស្សនៈរបស់ប្រជាពលរដ្ឋ។ ការអង្កេតក៏បានសួរអំពីប្រភេទនៃប្រព័ន្ធផ្សព្វផ្សាយឌីជីថលដែលរដ្ឋបាលថ្នាក់ក្រោមជាតិប្រើប្រាស់សម្រាប់គោលបំណងនេះ។ តារាងខាងក្រោមបង្ហាញពី % នៃអ្នកឆ្លើយតបនៅកម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដែលបានរាយការណ៍អំពីការប្រើប្រាស់វិធីសាស្ត្រនីមួយៗ។

| វិធីសាស្ត្រស្វែងរកទស្សនៈរបស់ប្រជាពលរដ្ឋ | ក្រុមប្រឹក្សាឃុំ សង្កាត់ | | | ក្រុង ស្រុក ខណ្ឌ | រាជធានី ខេត្ត |
|---|---|---|---|---|---|
| | ទាំងអស់ | ទីក្រុង | ជនបទ | | |
| ក្រុមប្រឹក្សាពិភាក្សាជាមួយប្រជាពលរដ្ឋជាលក្ខណៈបុគ្គល | ៤% | ៥% | ៣% | ១១% | ៨១% |
| ប្រជាពលរដ្ឋផ្ញើលិខិតមករដ្ឋបាលថ្នាក់ក្រោមជាតិ | ៣៩% | ៤០% | ៣៨% | ២០% | ៨៧% |
| ប្រជាពលរដ្ឋប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយឌីជីថល ដើម្បីទំនាក់ទំនងជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ | ៣៥% | ២៧% | ៣៩% | ១3% | ៧៩% |
| រដ្ឋបាលថ្នាក់ក្រោមជាតិពិភាក្សាជាមួយអង្គការដែលអាចតំណាងឱ្យទស្សនៈរបស់ប្រជាពលរដ្ឋ | ១៨% | ២១% | ១៧% | ១១% | ៧៩% |
| មធ្យោបាយណាមួយក្នុងចំណោមមធ្យោបាយទាំង៤ខាងលើ | **៥៩%** | **៦១%** | **៥៨%** | **3៨%** | **៩3%** |

ក្រុមប្រឹក្សាឃុំ សង្កាត់ហាក់មិនយល់ស្របថា ការជជែកផ្ទាល់ជាមួយប្រជាពលរដ្ឋម្នាក់ៗគឺជាវិធីសាស្ត្រសំខាន់ ដើម្បីស្វែងយល់អំពីទស្សនៈរបស់ប្រជាពលរដ្ឋឡើយ ទោះបីមធ្យោបាយនេះគឺជាមធ្យោបាយដែលត្រូវអនុវត្តក្នុងនាមជាក្រុមប្រឹក្សាដែលជាតំណាងឱ្យសហគមន៍។ ការប្រើប្រាស់លិខិតនៅតែជាវិធីសាស្ត្រសំខាន់ជាងគេ។ ការប្រើប្រាស់ប្រព័ន្ធឌីជីថលត្រូវបានកត់សម្គាល់ ហើយអាចនឹងកើនឡើង ប៉ុន្តែនៅថ្នាក់ក្រុង ស្រុក ខណ្ឌ នៅមានកម្រិតទាបនៅឡើយ។ ប្រមាណ ៤០% នៃក្រុមប្រឹក្សាឃុំ សង្កាត់ និងជាង ៦០% នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ មិនអាចកំណត់វិធីសាស្ត្រផ្សេង ដើម្បីស្វែងយល់អំពីទស្សនៈប្រជាពលរដ្ឋ ក្រៅពីការរៀបចំកិច្ចប្រជុំផ្លូវការ។

ការអង្កេតបានសួរក្រុមប្រឹក្សា និងមន្ត្រីថាតើរដ្ឋបាលថ្នាក់ក្រោមជាតិបានប្រើប្រាស់ប្រព័ន្ធឌីជីថលណាមួយ ដើម្បីស្វែងយល់អំពីទស្សនៈប្រជាពលរដ្ឋ។ ចំនួនអ្នកឆ្លើយតបបានបង្ហាញការកើនឡើងដែលប្រមាណ ៩០% អាចឱ្យឈ្មោះប្រព័ន្ធឌីជីថលយ៉ាងហោចណាស់មួយសម្រាប់ទំនាក់ទំនងជាមួយប្រជាពលរដ្ឋ។ ទោះយ៉ាងណា ការប្រើប្រាស់ប្រព័ន្ធឌីជីថលនៅថ្នាក់ក្រុង ស្រុក ខណ្ឌនៅមានកម្រិតទាបគួរឱ្យកត់សម្គាល់។ ការប្រើប្រាស់សារខ្លីៗត្រូវបានប្រើប្រាស់ញឹកញាប់ជាងបណ្តាញសង្គមផ្សេងទៀត។ អ្នកឆ្លើយតបភាគច្រើនថា បានប្រើប្រាស់គេហទំព័រ។ ក្នុងចំណោមឃុំ សង្កាត់ទាំងអស់ ការប្រើប្រាស់ប្រព័ន្ធឌីជីថលនៅតំបន់ជនបទខ្ពស់ជាងតំបន់ប្រជុំជន។

| ប្រភេទនៃប្រព័ន្ធផ្សព្វផ្សាយឌីជីថល | ក្រុមប្រឹក្សាឃុំ សង្កាត់ | | | ក្រុង ស្រុក ខណ្ឌ | រាជធានី ខេត្ត |
|---|---|---|---|---|---|
| | ទាំងអស់ | ទីក្រុង | ជនបទ | | |
| សារ SMS | ៧៣% | ៦៩% | ៧៥% | ៦០% | ៤៩% |
| ហ្វេសប៊ុក | ៣៤% | ២៣% | ៤០% | ៩% | ៨៥% |
| ការជជែកជាក្រុម (ឧ. តេឡេក្រាម) | ៣១% | ២៩% | ៣២% | ២៤% | ៨០% |
| គេហទំព័រ | ៧៤% | ៦៦% | ៧៨% | ៤៦% | ៦៩% |
| មធ្យោបាយណាមួយក្នុងចំណោមធ្យោបាយខាងលើ | **៨៩%** | **៨៦%** | **៩០%** | **៧៥%** | **៩៣%** |

## ៤.៧. ទំនាក់ទំនងផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ




*រូបភាពសន្ទស្សន៍ទំនាក់ទំនងផ្ទៃក្នុងជាមួយពិន្ទុសូចនាករ និងមេគុណ*

ជារួម ទំនាក់ទំនងផ្ទៃក្នុងត្រូវបានវាយតម្លៃថារឹងមាំ។ ក្រុមប្រឹក្សា និងមន្ត្រីជឿជាក់ថា រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានគាំទ្រយ៉ាងល្អពីថ្នាក់លើ ប៉ុន្តែមិនសូវប្រាកដថារដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ មានស្វ័យភាពគ្រប់គ្រាន់ក្នុងការធ្វើផែនការ រៀបចំថវិកា និងការអនុវត្ត។ ក្រុមប្រឹក្សា និងមន្ត្រីបានអះអាងយ៉ាងមុតមាំថា ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត មានប្រសិទ្ធភាពក្នុងការត្រួតពិនិត្យកិច្ចការរបស់គណៈអភិបាល ហើយបានផ្តល់ពិន្ទុខ្ពស់សម្រាប់ដំណើរការនៃកិច្ចប្រជុំក្រុមប្រឹក្សា។

*ចំណុចខ្លាំង និងចំណុចខ្សោយ៖ ទំនាក់ទំនងផ្ទៃក្នុង*

| ចំណុចខ្លាំង | ចំនុចខ្សោយ |
|---|---|
| **ល្អណាស់៖**<br>• ប្រសិទ្ធភាពនៃការបំពេញការងាររបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត<br>• ដំណើរការនៃកិច្ចប្រជុំក្រុមប្រឹក្សាបានល្អ<br>**ល្អ៖**<br>• ការគាំទ្រពីរដ្ឋបាលកម្រិតខ្ពស់ទៅរដ្ឋបាលកម្រិតទាបនៃរដ្ឋបាលថ្នាក់ក្រោមជាតិ | • ស្វ័យភាពផ្នែកថវិការបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវបានវាយតម្លៃថាស្ថិតក្នុងកម្រិតខ្សោយ |

ទិដ្ឋភាពបួននៃទំនាក់ទំនងផ្ទៃក្នុងត្រូវបានពិនិត្យ៖ (១). ការគាំទ្រពីស្ថាប័នថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងការគាំទ្រពីរដ្ឋបាលខេត្តទៅរដ្ឋបាលមូលដ្ឋាន (២). កម្រិតស្វ័យភាពរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ (៣). ប្រសិទ្ធភាពនៃការបំពេញការងាររបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ

និងរាជធានី ខេត្ត និង(៤). ការដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។ សំណួរទំនាក់ទំនងផ្ទៃក្នុងត្រូវបានសួរចំពោះតែអ្នកឆ្លើយតបជាមន្ត្រី ឬក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិប៉ុណ្ណោះ។

*តារាងតម្លៃសូចនាករទំនាក់ទំនងផ្ទៃក្នុង*

| សូចនាករ | ការពិពណ៌នា | សំណាក | តម្លៃ | មេគុណ | តម្លៃ | កំហុសស្តង់ដា | ៩៥% ចន្លោះទំនុកចិត្ត | |
|---|---|---|---|---|---|---|---|---|
| | | | | | | | ទាបបំផុត | ខ្ពស់បំផុត |
| INT-I | ក្រុមប្រឹក្សា និងមន្ត្រីវាយតម្លៃថា រដ្ឋបាលថ្នាក់ក្រោមជាតិទទួលបានការគាំទ្រសមរម្យពីរដ្ឋបាលថ្នាក់ក្រោមជាតិ (លើបន្ទាប់) និងស្ថាប័នថ្នាក់ជាតិ | គ.ស | **០,៧៩** | *០,១១* | ០,០៩ | *០,០០៤* | ០,៧៨ | ០,៨០ |
| INT-I | | កស ខ | **០,៧៦** | *០,០៨* | ០,០៦ | *០,០០៥* | ០,៧៥ | ០,៧៧ |
| INT-I | | រខ | **០,៧៩** | *០,០៨* | ០,០៧ | *០,០១១* | ០,៧៦ | ០,៨១ |
| INT-II | ក្រុមប្រឹក្សានិងមន្ត្រីវាយតម្លៃថា រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់មានស្វ័យភាពសមស្របក្នុងការគ្រប់គ្រងផែនការ ថវិកា និងការអនុវត្តការងារ | គស | **០,៥១** | *០,១១* | ០,០៦ | *០,០១០* | ០,៤៩ | ០,៥៣ |
| INT-II | | កសខ | **០,៥៤** | *០,០៨* | ០,០៥ | *០,០១១* | ០,៥២ | ០,៥៦ |
| INT-II | | រខ | **០,៦០** | *០,០៨* | ០,០៥ | *០,០២៩* | ០,៥៤ | ០,៦៥ |
| INT-III | ក្រុមប្រឹក្សា និងមន្ត្រីវាយតម្លៃថា ក្រុមប្រឹក្សាមានប្រសិទ្ធភាពក្នុងការកំណត់ទិសដៅយុទ្ធសាស្ត្រ និងការត្រួតពិនិត្យលើការប្រតិបត្តិរបស់គណៈអភិបាល | កសខ | **០,៩០** | *០,០៨* | ០,០៨ | *០,០០៤* | ០,៨៩ | ០,៩១ |
| INT-III | | រខ | **០,៩២** | *០,០៨* | ០,០៨ | *០,០១៣* | ០,៩០ | ០,៩៥ |
| INT-IV | ក្រុមប្រឹក្សាវាយតម្លៃថា កិច្ចប្រជុំក្រុមប្រឹក្សាជួយសម្រួលដល់សមាជិកក្រុមប្រឹក្សាក្នុងការបញ្ចេញមតិ និងឈានទៅដល់ការសម្រេចចិត្តជាឯកច្ឆ័ន្ទ | គស | **០,៩៤** | *០,១១* | ០,១០ | *០,០០៣* | ០,៩៣ | ០,៩៤ |
| INT-IV | | កស ខណ | **០,៩៤** | *០,០៨* | ០,០៨ | *០,០០៤* | ០,៩៣ | ០,៩៤ |
| INT-IV | | រខ | **០,៩៣** | *០,០៨* | ០,០៨ | *០,០១២* | ០,៩១ | ០,៩៥ |
| **តម្លៃសន្ទស្សន៍រង** | | | | | **០,៧៨** | | | |

តារាងខាងលើបង្ហាញថា ការវាយតម្លៃរបស់ក្រុមប្រឹក្សា និងមន្ត្រីរដ្ឋបាលក្រុង ស្រុក ខណ្ឌ អំពីការគាំទ្រដែលទទួលបានពីថ្នាក់លើ (INT-I) គឺតិចជាងការវាយតម្លៃរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងរាជធានី ខេត្ត។ ទាំងក្រុមប្រឹក្សា និងមន្ត្រីឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌ បានផ្តល់ពិន្ទុទាបសម្រាប់សូចនាករ INT-II។ ប្រការនេះ ប្រហែលជាក្រុមប្រឹក្សារដ្ឋបាលទាំងនេះចូលចិត្តស្វ័យភាពខ្លាំងជាង។ ពិន្ទុសម្រាប់ INT-III និង INT-IV មានកម្រិតពីមធ្យមទៅខ្លាំងនៅគ្រប់ក្រុមសំណាកទាំងអស់ ទោះបីជាការវាយតម្លៃរបស់ក្រុមប្រឹក្សា និងមន្ត្រីរដ្ឋបាលក្រុង ស្រុក ខណ្ឌ អំពីគុណភាពនៃកិច្ចប្រជុំក្រុមប្រឹក្សាមានកម្រិតទាបជាងក្រុមផ្សេងទៀតក៏ដោយ។ សូចនាករសម្រាប់ទំនាក់ទំនងផ្ទៃក្នុងត្រូវបានបង្ហាញលម្អិតនៅក្នុងតារាងខាងក្រោម៖

*តារាងតម្លៃសូចនាករទំនាក់ទំនងផ្ទៃក្នុងតាមតំបន់ទីប្រជុំជន តំបន់ជនបទ ភេទ និងតាមតំបន់ភូមិសាស្ត្រ*

| សូចនាករ | ការពិពណ៌នា | សំណាក | សរុប | ក្រុង ស្រុក ខណ្ឌ | | ភេទ | | តំបន់ភូមិសាស្ត្រ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ទីក្រុង | ជនបទ | ស្រី | ប្រុស | ភ្នំពេញ | ទំនាប | ទន្លេសាប | ខ្ពង់រាប | សមុទ្រ |
| INT-I | ក្រុមប្រឹក្សា និងមន្ត្រីវាយតម្លៃថា រដ្ឋបាលថ្នាក់ក្រោមជាតិទទួលបាន | គ.ស | **០,៧៩** | - | - | ០,៨១ | ០,៧៨ | ០,១៦ | ០,៧១ | ០,៦៨ | ០,៧២ | ០,៦២ |
| | | កសខ | **០,៧៦** | ០,៧៧ | ០,៧៦ | ០,៧៦ | ០,៧៦ | ០,៧៨ | ០,៧៥ | ០,៧៥ | ០,៧៧ | ០,៧៧ |
| | | រខ | **០,៧៩** | - | - | ០,៨០ | ០,៧៨ | ០,៨៣ | ០,៧៤ | ០,៧៨ | ០,៨០ | ០,៨៤ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | ការគាំទ្រសមរម្យពីរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថាប័នថ្នាក់ជាតិ | | | | | | | | | | |
| INT-II | ក្រុមប្រឹក្សា និងមន្ត្រីវាយតម្លៃថារដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់មានស្វ័យភាពសមស្របក្នុងការគ្រប់គ្រងផែនការ ថវិកា និងការអនុវត្តការងាររបស់ខ្លួន | គ.ស | **០,៥១** | ០,៥០ | ០,៥២ | ០,៥២ | ០,៥១ | ០,៥២ | ០,៥៤ | ០,៥៤ | ០,៥២ | ០,៣១ |
| | | កសខ | **០,៥៤** | ០,៥៤ | ០,៥៤ | ០,៥០ | ០,៥៧ | ០,៥៧ | ០,៥៤ | ០,៥៧ | ០,៥៥ | ០,៤៦ |
| | | រខ | **០,៦០** | - | - | ០,៦០ | ០,៥៩ | ០,៧៥ | ០,៦១ | ០,៥២ | ០,៥៩ | ០,៦៤ |
| INT-III | ក្រុមប្រឹក្សា និងមន្ត្រីវាយតម្លៃថាក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌមានប្រសិទ្ធភាពក្នុងការកំណត់ទិសដៅយុទ្ធសាស្ត្រ និងត្រួតពិនិត្យលើប្រតិបត្តិការរបស់គណៈអភិបាល | កសខ | **០,៩០** | ០,៩០ | ០,៩០ | ០,៨៩ | ០,៩១ | ០,៩១ | ០,៩០ | ០,៩០ | ០,៩០ | ០,៨៩ |
| | | រខ | **០,៩២** | - | - | ០,៩៣ | ០,៩២ | ០,៩២ | ០,៩៣ | ០,៨៨ | ០,៩១ | ០,៩៧ |
| INT-IV | ក្រុមប្រឹក្សាវាយតម្លៃថា កិច្ចប្រជុំក្រុមប្រឹក្សាជួយសម្រួលដល់សមាជិកក្រុមប្រឹក្សាទាំងអស់ក្នុងការបញ្ចេញមតិ និងឈានទៅដល់ការសម្រេចចិត្តជាឯកច្ឆ័ន្ទ | គ.ស | **០,៩៤** | ០,៩៤ | ០,៩៤ | ០,៩២ | ០,៩៥ | ០,៩៤ | ០,៩៥ | ០,៩៣ | ០,៩៥ | ០,៨៨ |
| | | កសខ | **០,៩៤** | ០,៩៥ | ០,៩៣ | ០,៩៤ | ០,៩៣ | ០,៩៥ | ០,៩៤ | ០,៩៣ | ០,៩៤ | ០,៩១ |
| | | រខ | **០,៩៣** | - | - | ០,៩៥ | ០,៩២ | ០,៨៤ | ០,៩៣ | ០,៩៣ | ០,៩២ | ០,៩៦ |
| **តម្លៃសន្ទស្សន៍រង** | | | **០,៧៨** | **០,៦៤** | **០,៦៣** | **០,៧៨** | **០,៧៨** | **០,៧៣** | **០,៧៧** | **០,៧៦** | **០,៧៨** | **០,៧៤** |

ពិន្ទុសូចនាករជាទូទៅមានភាពស៊ីសង្វាក់គ្នានៅទូទាំងតំបន់ទីប្រជុំជន តំបន់ជនបទ ភេទ និងតាមតំបន់ភូមិសាស្ត្រនានា។ ពិន្ទុនៅក្នុងទីក្រុងភ្នំពេញខ្ពស់ជាងតំបន់ផ្សេងទៀតស្ទើរតែគ្រប់សូចនាករទាំងអស់។

*តារាងសង្ខេបតម្លៃសន្ទស្សន៍ទំនាក់ទំនងផ្ទៃក្នុង*

| **លេខសម្គាល់** | **ពិពណ៌នា** | **ពិន្ទុ** | **មេគុណ** | **តម្លៃ** | **ស្តង់ដាកំហុស** | **៩៥% ចន្លោះទំនុកចិត្ត** | |
|---|---|---|---|---|---|---|---|
| | | | | | | **ទាបបំផុត** | **ខ្ពស់បំផុត** |
| ឃស.INT.១ | ការវាយតម្លៃរបស់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីគុណភាពនៃការគាំទ្រដែលទទួលបានពីថ្នាក់លើ | **០,៧៩** | *១.00* | ០,៧៩ | *0,00៤* | ០,៧៨ | ០,៨០ |
| **ឃស.INT-I** | **ក្រុមប្រឹក្សា និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិវាយតម្លៃថាទទួលបានការគាំទ្រសមរម្យពីរដ្ឋបាលថ្នាក់ក្រោមជាតិ (លើបន្ទាប់) និងស្ថាប័នជាតិ** | | | **០,៧៩** | ***0,00៤*** | **០,៧៨** | **០,៨០** |
| កសខ.INT.១ | ការវាយតម្លៃរបស់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីគុណភាពនៃការគាំទ្រដែលទទួលបានពីថ្នាក់លើ | **០,៧៥** | *0,៥0* | ០,៣៨ | *0,00៣* | ០,៧៥ | ០,៧៦ |
| កសខ.INT.២ | រដ្ឋបាលថ្នាក់ក្រោមជាតិ វាយតម្លៃកិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ (កម្រិតដូចគ្នា និងថ្នាក់ក្រោម) | **០,៧៧** | *0,៥0* | ០,៣៨ | *0,00២* | ០,៧៦ | ០,៧៧ |
| **កសខ.INT-I** | **ក្រុមប្រឹក្សា និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិវាយតម្លៃថាទទួលបានការគាំទ្រសមរម្យពីរដ្ឋបាលថ្នាក់ក្រោមជាតិ (លើបន្ទាប់) និងស្ថាប័នជាតិ** | | | **០,៧៦** | ***0,00៥*** | **០,៧៥** | **០,៧៧** |
| រខ.INT.១ | ការវាយតម្លៃរបស់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីគុណភាពនៃការគាំទ្រដែលទទួលបានពីថ្នាក់លើ | **០,៧៩** | *0,៥0* | ០,៣៩ | *0,00៦* | ០,៧៨ | ០,៨០ |
| រខ.INT.២ | រដ្ឋបាលថ្នាក់ក្រោមជាតិ វាយតម្លៃកិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ (កម្រិតដូចគ្នា និងថ្នាក់ក្រោម) | **០,៧៩** | *0,៥0* | ០,៣៩ | *0,0១៧* | ០,៧៥ | ០,៨២ |
| **រខ.INT-I** | **ក្រុមប្រឹក្សា និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិវាយតម្លៃថាទទួលបានការគាំទ្រសមរម្យពីរដ្ឋបាលថ្នាក់ក្រោមជាតិ (លើបន្ទាប់) និងស្ថាប័នជាតិ** | | | **០,៧៩** | ***0,0១១*** | **០,៧៦** | **០,៨១** |

| | | | | | | | |
|---|---|---|---|---|---|---|---|
| យស.INT.២ | ការវាយតម្លៃរបស់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីស្វ័យភាពរបស់ខ្លួនក្នុងការសម្រេចចិត្ត | **០,៥១** | *១.00* | ០,៥១ | *០,០១០* | ០,៤៩ | ០,៥៣ |
| **យស.INT-II** | **ក្រុមប្រឹក្សា និងមន្ត្រីរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ វាយតម្លៃថា មានស្វ័យភាពសមស្របក្នុងការគ្រប់គ្រងផែនការ ថវិកា និងការអនុវត្តការងាររបស់ខ្លួន** | | | **០,៥១** | ***០,០១០*** | **០,៤៩** | **០,៥៣** |
| កសខ.INT.៣ | ការវាយតម្លៃរបស់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីស្វ័យភាពរបស់ខ្លួនក្នុងការសម្រេចចិត្ត | **០,៥៤** | *១.00* | ០,៥៤ | *០,០១១* | ០,៥២ | ០,៥៦ |
| **កសខ.INT-II** | **ក្រុមប្រឹក្សា និងមន្ត្រីរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ វាយតម្លៃថា មានស្វ័យភាពសមស្របក្នុងការគ្រប់គ្រងផែនការ ថវិកា និងការអនុវត្តការងាររបស់ខ្លួន** | | | **០,៥៤** | ***០,០១១*** | **០,៥២** | **០,៥៦** |
| រខ.INT.៣ | ការវាយតម្លៃរបស់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីស្វ័យភាពរបស់ខ្លួនក្នុងការសម្រេចចិត្ត | **០,៦០** | *១.00* | ០,៦០ | *០,០៦៧* | ០,៤៦ | ០,៧៣ |
| **រខ.INT-II** | **ក្រុមប្រឹក្សា និងមន្ត្រីរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ វាយតម្លៃថា មានស្វ័យភាពសមស្របក្នុងការគ្រប់គ្រងផែនការ ថវិកា និងការអនុវត្តការងាររបស់ខ្លួន** | | | **០,៦០** | ***០,០២៩*** | **០,៥៤** | **០,៦៥** |
| កសខ.INT.៤ | ទស្សនៈរបស់អ្នកឆ្លើយសំណួរអំពីតួនាទីសមស្របរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | **០,៨៤** | *០,២០* | ០,១៧ | *០,០០៨* | ០,៨៣ | ០,៨៦ |
| កសខ.INT.៥ | ទស្សនៈរបស់អ្នកឆ្លើយអំពីប្រសិទ្ធភាពរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | **០,៩២** | *០,៨០* | ០,៧៣ | *០,០០៤* | ០,៩១ | ០,៩២ |
| **កសខ.INT-III** | **ក្រុមប្រឹក្សា និងមន្ត្រីវាយតម្លៃថា ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មានប្រសិទ្ធភាពក្នុងការកំណត់ទិសដៅយុទ្ធសាស្ត្រ និងការត្រួតពិនិត្យប្រតិបត្តិការរបស់គណៈអភិបាល** | | | **០,៩០** | ***០,០០៤*** | **០,៨៩** | **០,៩១** |
| រខ.INT.៤ | ទស្សនៈរបស់អ្នកឆ្លើយសំណួរអំពីតួនាទីសមស្របរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | **០,៩២** | *០,២០* | ០,១៨ | *០,០៣៩* | ០,៨៤ | ០,៩៩ |
| រខ.INT.៥ | ទស្សនៈរបស់អ្នកឆ្លើយអំពីប្រសិទ្ធភាពរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | **០,៩២** | *០,៨០* | ០,៧៤ | *០,០១២* | ០,៩០ | ០,៩៥ |
| **រខ.INT-III** | **ក្រុមប្រឹក្សា និងមន្ត្រីវាយតម្លៃថា ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មានប្រសិទ្ធភាពក្នុងការកំណត់ទិសដៅយុទ្ធសាស្ត្រ និងការត្រួតពិនិត្យប្រតិបត្តិការរបស់គណៈអភិបាល** | | | **០,៩២** | ***០,០១៣*** | **០,៩០** | **០,៩៥** |
| យស.INT.៣ | ការវាយតម្លៃរបស់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីគុណភាព និងភាពបើកចំហនៃកិច្ចប្រជុំក្រុមប្រឹក្សា | **០,៩៤** | *១.00* | ០,៩៤ | *០,០០៣* | ០,៩៣ | ០,៩៤ |
| **យស.INT-IV** | **ក្រុមប្រឹក្សាវាយតម្លៃថា កិច្ចប្រជុំក្រុមប្រឹក្សាជួយសម្រួលដល់សមាជិកក្រុមប្រឹក្សាក្នុងការបញ្ចេញមតិ និងឈានទៅដល់ការសម្រេចចិត្តជាឯកច្ឆ័ន្ទ** | | | **០,៩៤** | ***០,០០៣*** | **០,៩៣** | **០,៩៤** |
| កសខ.INT.៦ | ការវាយតម្លៃរបស់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីគុណភាព និងភាពបើកចំហនៃកិច្ចប្រជុំក្រុមប្រឹក្សា | **០,៩៤** | *១.00* | ០,៩៤ | *០,០០៣* | ០,៩៣ | ០,៩៤ |
| **កសខ.INT-IV** | **ក្រុមប្រឹក្សាវាយតម្លៃថា កិច្ចប្រជុំក្រុមប្រឹក្សាជួយសម្រួលដល់សមាជិកក្រុមប្រឹក្សាក្នុងការបញ្ចេញមតិ និងឈានទៅដល់ការសម្រេចចិត្តជាឯកច្ឆ័ន្ទ** | | | **០,៩៤** | ***០,០០៤*** | **០,៩៣** | **០,៩៤** |
| រខ.INT.៦ | ការវាយតម្លៃរបស់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីគុណភាព និងភាពបើកចំហនៃកិច្ចប្រជុំក្រុមប្រឹក្សា | **០,៩៣** | *១.00* | ០,៩៣ | *០,០១២* | ០,៩១ | ០,៩៥ |
| **រខ.INT-IV** | **ក្រុមប្រឹក្សាវាយតម្លៃថា កិច្ចប្រជុំក្រុមប្រឹក្សាជួយសម្រួលដល់សមាជិកក្រុមប្រឹក្សាក្នុងការបញ្ចេញមតិ និងឈានទៅដល់ការសម្រេចចិត្តជាឯកច្ឆ័ន្ទ** | | | **០,៩៣** | ***០,០១២*** | **០,៩១** | **០,៩៥** |

## ៤.៨. សមាគមក្រុមប្រឹក្សាមូលដ្ឋាន




*រូបភាពសន្ទស្សន៍សមាគមក្រុមប្រឹក្សាមូលដ្ឋានជាមួយពិន្ទុ និងមេគុណសូចនាករ*

មន្ត្រី និងក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិបានផ្តល់ការវាយតម្លៃខ្ពស់អំពីសារៈសំខាន់ និងប្រសិទ្ធភាពនៃសមាគមក្រុមប្រឹក្សាមូលដ្ឋាន (សមាគមក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងសមាគមក្រុមប្រឹក្សារាជធានី ខេត្ត)។

មន្ត្រី និងក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានសួរឱ្យគិតថា តើតួនាទីរបស់សមាគមក្រុមប្រឹក្សាមូលដ្ឋានមានសារៈសំខាន់ប៉ុណ្ណា ហើយតើយល់ឃើញថា ការគាំទ្រពីសមាគមក្រុមប្រឹក្សាមូលដ្ឋានដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិមានប្រសិទ្ធភាពដែរឬទេ។ ប្រជាពលរដ្ឋមិនត្រូវបានសួរអំពីសមាគមក្រុមប្រឹក្សាមូលដ្ឋានឡើយ។

*តារាងតម្លៃសូចនាករនៃសមាគមក្រុមប្រឹក្សាមូលដ្ឋាន*

| **សូចនាករ** | **ការពិពណ៌នា** | **សំណាក** | **ពិន្ទុ** | **មេគុណ** | **តម្លៃ** | **កំហុសស្តង់ដា** | **៩៥% ចន្លោះទំនុកចិត្ត** | |
|---|---|---|---|---|---|---|---|---|
| | | | | | | | **ទាបបំផុត** | **ខ្ពស់បំផុត** |
| LCA-I | ក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌ ចាត់ទុកសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ មានសារៈសំខាន់ និងមានប្រសិទ្ធភាព | ឃ.ស | ០,៧៦ | *០,៣៣* | ០,២៥ | *០,០០៥* | ០,៧៥ | ០,៧៧ |
| | | កសខ | ០,៧៧ | *០,៣៣* | ០,២៦ | *០,០០៥* | ០,៧៦ | ០,៧៨ |
| LCA-II | ក្រុមប្រឹក្សារាជធានី ខេត្ត ចាត់ទុកសមាគមក្រុមប្រឹក្សារាជធានី ខេត្ត មានសារៈសំខាន់ និងមានប្រសិទ្ធភាព | រខ | ០,៧៨ | *០,៣៣* | ០,២៦ | *០,០១៨* | ០,៧៤ | ០,៨១ |
| **តម្លៃសន្ទស្សន៍ (ផលបូកនៃតម្លៃសរុប)** | | | | | **០,៧៧** | | | |

*តារាងតម្លៃសូចនាករសមាគមក្រុមប្រឹក្សាមូលដ្ឋានតាមតំបន់ទីប្រជុំជន តំបន់ជនបទ ភេទ និងតំបន់ភូមិសាស្ត្រនានា*

| សូចនាករ | អ្នកពិពណ៌នា | សំណាក | សរុប | ក្រុង ស្រុក ខណ្ឌ | | ភេទ | | តំបន់ភូមិសាស្ត្រ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ទីក្រុង | ជនបទ | ស្រី | ប្រុស | ភ្នំពេញ | ទំនាប | ទន្លេសាប | ខ្ពង់រាប | សមុទ្រ |
| LCA-I | ក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ ចាត់ទុកសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុង និងខណ្ឌមានសារៈសំខាន់ និងមានប្រសិទ្ធភាព | ឃ.ស | ០,៧៦ | ០,៧៦ | ០,៧៥ | ០,៧៦ | ០,៧៥ | ០,៧៥ | ០,៧៤ | ០,៧៧ | ០,៧៦ | ០,៧៥ |
| | | កសខ | ០,៧៧ | ០,៧៨ | ០,៧៦ | ០,៧៧ | ០,៧៦ | ០,៧៩ | ០,៧៥ | ០,៧៩ | ០,៧៦ | ០,៧៦ |
| LCA-II | ក្រុមប្រឹក្សារាជធានី ខេត្តចាត់ទុកសមាគមក្រុមប្រឹក្សារាជធានី ខេត្តមានសារៈសំខាន់និងមានប្រសិទ្ធភាព | រខ | ០,៧៨ | - | - | ០,៨៣ | ០,៧៦ | ០,៧៩ | ០,៧៦ | ០,៧៣ | ០,៧៨ | ០,៨៦ |
| **តម្លៃរងសន្ទស្សន៍** | | | **០,៧៧** | **០,៧៧** | **០,៧៦** | **០,៧៩** | **០,៧៦** | **០,៧៨** | **០,៧៥** | **០,៧៦** | **០,៧៦** | **០,៧៩** |

ដូចដែលបានឃើញក្នុងតារាងខាងលើ ការវាយតម្លៃរបស់មន្ត្រី និងក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិបង្ហាញថា សមាគមក្រុមប្រឹក្សាថ្នាក់ក្រោមជាតិមានសារៈសំខាន់ខ្លាំង។

*តារាងសង្ខេបនៃការឆ្លើយតបទៅនឹងសំណួរពាក់ព័ន្ធនឹងសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន*

| លេខសម្គាល់ | អ្នកពិពណ៌នា | ពិន្ទុ | មេគុណ | តម្លៃ | កំហុសស្តង់ដា | ៩៥% ចន្លោះទំនុកចិត្ត | |
|---|---|---|---|---|---|---|---|
| | | | | | | ទាបបំផុត | ខ្ពស់បំផុត |
| ឃស.LCA.១ | ការវាយតម្លៃរបស់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីសារៈសំខាន់នៃតួនាទីរបស់សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន | **០,៨០** | *០,៥០* | ០,៤០ | *០,០០៦* | ០,៧៩ | ០,៨២ |
| ឃស.LCA.២ | រដ្ឋបាលថ្នាក់ក្រោមជាតិវាយតម្លៃគុណភាពនៃការគាំទ្រដែលទទួលបានពីសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន | **០,៧១** | *០,៥០* | ០,៣៥ | *០,០១៧* | ០,៦៧ | ០,៧៤ |
| ឃស.LCA-I | **ឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌ ចាត់ទុកសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ មានសារៈសំខាន់ និងមានប្រសិទ្ធភាព** | | | ០,៧៦ | *០,០០៥* | ០,៧៥ | ០,៧៧ |
| កសខ.LCA.១ | ការវាយតម្លៃរបស់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីសារៈសំខាន់នៃតួនាទីរបស់សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន | **០,៨១** | *០,៥០* | ០,៤០ | *០,០០៦* | ០,៨០ | ០,៨២ |
| កសខ.LCA.២ | រដ្ឋបាលថ្នាក់ក្រោមជាតិវាយតម្លៃគុណភាពនៃការគាំទ្រដែលទទួលបានពីសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន | **០,៧២** | *០,៥០* | ០,៣៦ | *០,០០៧* | ០,៧១ | ០,៧៤ |
| កសខ.LCA-I | **ឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌ ចាត់ទុកសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ មានសារៈសំខាន់ និងមានប្រសិទ្ធភាព** | | | ០,៧៧ | *០,០០៥* | ០,៧៦ | ០,៧៨ |
| រខ.LCA.១ | ការវាយតម្លៃរបស់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីសារៈសំខាន់នៃតួនាទីរបស់សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន | **០,៨២** | *០,៥០* | ០,៤១ | *០,០២៣* | ០,៧៧ | ០,៨៧ |
| រខ.LCA.២ | រដ្ឋបាលថ្នាក់ក្រោមជាតិវាយតម្លៃគុណភាពនៃការគាំទ្រដែលទទួលបានពីសមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន | **០,៧៤** | *០,៥០* | ០,៣៧ | *០,០២២* | ០,៦៩ | ០,៧៨ |
| រខ.LCA-II | **ក្រុមប្រឹក្សារាជធានី ខេត្ត ចាត់ទុកសមាគមក្រុមប្រឹក្សារាជធានី ខេត្ត មានសារៈសំខាន់ និងមានប្រសិទ្ធភាព** | | | ០,៧៨ | *០,០១៨* | ០,៧៤ | ០,៨១ |

## ៦. របាយការណ៍នៃសិក្ខាសាលាពិគ្រោះយោបល់

របកគំហើញចម្បងៗនៃការអង្កេតនេះ ត្រូវបានបង្ហាញ និងដាក់ឱ្យពិភាក្សា ពិគ្រោះយោបល់ក្នុងសិក្ខាសាលាពិគ្រោះយោបល់នាថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៥។

សិក្ខាសាលានេះបានរៀបចំឡើងក្រោមអធិបតីភាព **ឯកឧត្តម ចាន់ សុផា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប.** ដោយមានអ្នកចូលរួមចំនួន**៥៩នាក់** តំណាងឱ្យក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា។

នៅក្នុងសុន្ទរកថាបើក **ឯកឧត្តម ចាន់ សុផា** បានសង្កត់ធ្ងន់លើសារៈសំខាន់នៃការធ្វើអង្កេតអភិបាលកិច្ចនេះ ដើម្បីមានមូលដ្ឋានសម្រាប់វាស់វែងការប្រែប្រួលនៃសន្ទស្សន៍សេវា និងសន្ទស្សន៍អភិបាលកិច្ចដែលជាការវាយតម្លៃកម្រិតនៃការសម្រេចបាននូវគោលដៅ និងគោលបំណងនៃក.ជ.ទី២។

ឯកឧត្តមបានថ្លែងអំណរគុណចំពោះ UNDP និងរដ្ឋាភិបាលជប៉ុនដែលបានផ្តល់ការគាំទ្រដល់ការធ្វើអង្កេតដើមគ្រានេះតាមរយៈគម្រោង "**ការលើកកម្ពស់តម្លាភាព និងគណនេយ្យភាពក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ**"។

ក្នុងសិក្ខាសាលា ក្រុមទីប្រឹក្សារបស់ក្រុមហ៊ុន AKSL បានបង្ហាញការរកឃើញចម្បងនៃការអង្កេតដូចដែលបានពិពណ៌នានៅក្នុងផ្នែកខាងលើនៃរបាយការណ៍នេះ។

បន្ទាប់ពីបទបង្ហាញ ក៏មានការពិភាក្សាយ៉ាងផុលផុស រួមទាំងសំណើសុំការបំភ្លឺបន្ថែមលើចំណុចសំខាន់ៗមួយចំនួន។ ជារួម អ្នកចូលរួមសិក្ខាសាលាបានស្វាគមន៍របាយការណ៍នេះ ប៉ុន្តែបានស្នើសុំការកែប្រែចំនុចមួយចំនួន ជាពិសេស ការពន្យល់អំពីអត្ថន័យនៃតម្លៃសន្ទស្សន៍ និងសន្ទស្សន៍រង និងគួរតែដាក់ចំណាត់ថ្នាក់ឱ្យកាន់តែច្បាស់តាមមាត្រដ្ឋានពិពណ៌នាជាក់លាក់ ដូចជា ពី "ខ្សោយ" "មធ្យម" "បង្គួរ" "ល្អ" និង "ល្អណាស់" ជាដើម។ អ្នកចូលរួមជាច្រើនបានស្នើថា របាយការណ៍គួរតែមានការណែនាំលម្អិតបន្ថែមទៀតអំពីការកែលម្អអភិបាលកិច្ចដោយផ្អែកលើការរកឃើញ។ ក្រុមការងារ AKSL ក៏បានទទួលយកសំណើសំណូមពរទាំងនេះ និងបានបញ្ជាក់ថា នឹងកែលម្អរបាយការណ៍ស្តីពីលទ្ធផលនៃការធ្វើអង្កេតនេះ ប៉ុន្តែត្រូវស្ថិតនៅក្នុងក្របខ័ណ្ឌដែលរបាយការណ៍នេះ គឺជាមូលដ្ឋានសម្រាប់ការប្រៀបធៀបនៃការវាស់វែងនាពេលអនាគត។ ការវិភាគ និងការណែនាំផ្នែកគោលនយោបាយ គឺស្ថិតនៅក្រៅវិសាលភាពនៃរបាយការណ៍នេះ។

នៅពិធីបិទសិក្ខាសាលា **ឯកឧត្តម ចាន់ សុផា** បានស្នើរឱ្យការរៀបចំរបាយការណ៍គួរផ្តល់និយមន័យឱ្យកាន់តែច្បាស់អំពីសន្ទស្សន៍ និងសន្ទស្សន៍រងសំខាន់ៗ ដើម្បីជៀសវាងនូវការភ័ន្តច្រឡំជាមួយនឹងការវាយតម្លៃលើទិដ្ឋភាពផ្សេងទៀត។ ឧទាហរណ៍ កម្មវិធីគណនេយ្យភាពសង្គម ដែលមានពាក្យស្រដៀងគ្នា ក៏ប៉ុន្តែខ្លឹមសារ និងវិធីសាស្ត្រនៃការអនុវត្តគឺផ្សេងគ្នា ដែលប្រការនេះ គឺមិនអាចប្រៀបធៀបគ្នាបានឡើយ។

ជារួម អង្គសិក្ខាសាលាបានឯកភាពឱ្យទុកពេលពីរសប្ដាហ៍ដើម្បីឱ្យអ្នកចូលរួមផ្ដល់មតិជាលាយលក្ខណ៍អក្សរបន្ថែមលើសេចក្ដីព្រាងរបាយការណ៍នេះ។

## ៧. ដែនកំណត់នៃការអង្កេត

ការអង្កេតនេះ មិនមែនជាការអង្កេតពេញលេញលើគ្រប់ទិដ្ឋភាពទាំងអស់នៃអភិបាលកិច្ចនោះឡើយ វាគ្រាន់តែជាការអង្កេតលើទិដ្ឋភាពមួយចំនួនដែលអាចវាស់វែងបានតែប៉ុណ្ណោះ។ ជាឧទាហរណ៍ ការអង្កេតពឹងផ្អែកលើការវាយតម្លៃរបស់ប្រជាពលរដ្ឋអំពីសេវាជាមូលដ្ឋានដែលប្រជាពលរដ្ឋប្រើប្រាស់ប្រចាំថ្ងៃ និងបទពិសោធន៍នៃការចូលរួមរបស់ប្រជាពលរដ្ឋក្នុងសកម្មភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ វិធីសាស្ត្រទាំងនេះមិនសូវសមរម្យក្នុងការវាយតម្លៃលើគុណភាពនៃសេវាសាធារណៈមួយចំនួន ដែលមិនត្រូវបានប្រើប្រាស់ដោយប្រជាពលរដ្ឋភាគច្រើន (ឧទាហរណ៍ សេវាការពារបរិស្ថាន ឬសេវាចុះឈ្មោះអាជីវកម្មជាដើម)។ ដូច្នេះ ប្រជាពលរដ្ឋត្រូវបានសួរតែសំណួរមួយចំនួនតូចដែលពាក់ព័ន្ធនឹងគណនេយ្យភាពនៃការបោះឆ្នោត ឬការទប់ស្កាត់អំពើពុករលួយជាដើម។

**អ្នកឆ្លើយតបជាប្រជាពលរដ្ឋអាចមិនយល់ពីអត្ថន័យនៃសំណួរទាំងអស់នោះទេ៖** ប្រជាពលរដ្ឋសាមញ្ញអាចគិតអំពីអភិបាលកិច្ចតាមរបៀបផ្សេងៗគ្នាពីអ្នកជំនាញផ្នែកអភិបាលកិច្ច និងការប្រើប្រាស់វាក្យស័ព្ទខុសៗគ្នាក្នុងជីវិតប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋតាមតំបន់នីមួយៗ។ បញ្ជីសំណួរស្ទង់មតិត្រូវបានសរសេរយ៉ាងសាមញ្ញ និងច្បាស់លាស់ ដោយជៀសវាងពាក្យបច្ចេកទេសតាមដែលអាចធ្វើទៅបាន ក៏ប៉ុន្តែវានៅតែអាចមានការយល់ច្រឡំខ្លះកើតមានឡើង។

**អ្នកឆ្លើយតបអាចយល់អំពីសំណួរ ប៉ុន្តែមានចំណេះដឹងមិនគ្រប់គ្រាន់ ដើម្បីផ្ដល់ចម្លើយដែលអាចទុកចិត្តបាន៖** ការអង្កេតគឺពឹងផ្អែកលើចំណេះដឹង និងការយល់ដឹងរបស់អ្នកឆ្លើយសំណួរ និងឆន្ទៈក្នុងការចែករំលែកទស្សនៈរបស់អ្នកឆ្លើយដោយបើកចំហនៅក្នុងបរិបទដែលអ្នកឆ្លើយមិនធ្លាប់ជួបប្រទះក្នុងការឆ្លើយសំណួរបែបនេះ។ ជាពិសេស ប្រជាពលរដ្ឋដែលជ្រើសរើសដោយចៃដន្យ ទំនងជាមិនមានចំណេះដឹងលម្អិតអំពីកិច្ចការរដ្ឋបាលថ្នាក់ក្រោមជាតិនោះទេ ហើយសំណួរមួយចំនួនអាចទាក់ទងនឹងបញ្ហាដែលប្រជាពលរដ្ឋមិនដែលបានគិតដល់កាលពីមុនមក។

**ជាទូទៅ ចំនួនសំណាកជារួមមានលក្ខណៈសមស្រប ប៉ុន្តែសម្រាប់សំណួរមួយចំនួនមានចំនួនសំណាកតិច៖** កំហុសស្តង់ដាតិចតួចដែលបានប៉ាន់ប្រមាណសម្រាប់សំណួរភាគច្រើនបង្ហាញពីភាពគ្រប់គ្រាន់នៃចំនួនសំណាក យ៉ាងហោចណាស់សម្រាប់ក្រុមអ្នកឆ្លើយជាប្រជាពលរដ្ឋ។ ទោះយ៉ាងណាក៏ដោយ ចំពោះសំណួរមួយចំនួន ដោយសារសំណាកមានចំនួនតិចអាចធ្វើឱ្យប្រសិទ្ធភាពកាន់តែទាប។ ឧទាហរណ៍ នៅពេលសួរថា តើអ្នកពេញចិត្តនឹងការដោះស្រាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះពាក្យបណ្ដឹងតវ៉ាដែរឬទេ ប្រសិទ្ធភាពសំណាកនៃអ្នកឆ្លើយតប គឺបានតែពីអ្នកដែលធ្លាប់មានបទពិសោធន៍លើការដាក់ពាក្យបណ្ដឹងតវ៉ា ដែលមានចំនួនតិចតួចនៃចំនួនប្រជាជនទាំងអស់។ នៅក្នុងករណីនេះ កំហុសស្តង់ដាក្លាយជាធំ ហើយការរកឃើញត្រូវតែវិភាគដោយប្រុងប្រយ័ត្ន។

**តម្លៃសន្ទស្សន៍អភិបាលកិច្ច និងតម្លៃសន្ទស្សន៍រងអាស្រ័យតាមមេគុណៈ** មេគុណ ឬទម្ងន់ត្រូវកំណត់ទៅលើសំណួរ និងសូចនាករនីមួយៗសម្រាប់ការវាយតម្លៃលើអ្វីដែលបានរកឃើញពាក់ព័ន្ធនឹងគោលបំណងនៃការវាស់វែងគុណភាពអភិបាលកិច្ច។ ទោះយ៉ាងណាក៏ដោយ ក៏ការកំណត់មេគុណ ឬទម្ងន់គឺអាចកំណត់ផ្សេងៗគ្នា។ ដូច្នេះ ត្រូវមានការយល់ដឹងច្បាស់អំពីប្រព័ន្ធផ្តល់មេគុណ និងជម្រើសសមស្របនានាសម្រាប់ការធ្វើអង្កេតនាពេលក្រោយ។

**តម្លៃសន្ទស្សន៍ត្រូវបានគណនាដោយការបញ្ចូលគ្នានៃទិន្នន័យពីក្រុមសំណាកផ្សេងៗគ្នាៈ** ការគណនាបែបនេះ គឺពាក់ព័ន្ធទៅនឹងការដាក់មេគុណទៅតាមចម្លើយរបស់ក្រុមសំណាកនីមួយៗ។ ស្របតាមការពិពណ៌នាអំពីសន្ទស្សន៍ផ្នែកអភិបាលកិច្ចក្នុងឯកសារ ក.ជ.ទី២ ទម្ងន់ភាគច្រើន (ពីរភាគបី) ត្រូវបានផ្តល់ទៅលើការឆ្លើយតបរបស់ប្រជាពលរដ្ឋ ខណៈដែលមួយភាគបីដែលនៅសល់ត្រូវបានបែងចែកស្មើៗគ្នារវាងក្រុមអ្នកឆ្លើយតបដែលជាក្រុមប្រឹក្សា និងមន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការរួមបញ្ចូលគ្នានូវលទ្ធផលពីក្រុមសំណាកផ្សេងៗគ្នាក៏បណ្តាលឱ្យ**មានការលំបាកក្នុងការប៉ាន់ប្រមាណកំហុសស្តង់ដា និងចន្លោះនៃទំនុកចិត្តសម្រាប់សន្ទស្សន៍រង និងតម្លៃសន្ទស្សន៍**ផងដែរ។ ដូច្នេះ វិធីសាស្ត្រដែលបានប្រើអាចចាត់ទុកថា ជាការប៉ាន់ស្មានប៉ុណ្ណោះ ប៉ុន្តែវាគ្រប់គ្រាន់សម្រាប់ការវាយតម្លៃវាស់វែងលើការផ្លាស់ប្តូរនៃតម្លៃសន្ទស្សន៍ដែលត្រូវធ្វើអង្កេតនាពេលក្រោយបន្តបន្ទាប់។

**ការអង្កេតនេះ មិនអាចវាយតម្លៃពីមូលហេតុនៃនិន្នាការអភិបាលកិច្ចបានឡើយៈ** ការអង្កេតនេះគឺជាការវាស់វែងនិន្នាការអភិបាលកិច្ចក្នុងក្របខ័ណ្ឌនៃក.ជ.ទី២។ ទោះយ៉ាងណា ការផ្លាស់ប្តូរណាមួយដែលត្រូវបានរកឃើញ គឺការអង្កេតនេះមិនអាចកំណត់បានថាតើការផ្លាស់ប្តូរទាំងនោះកើតឡើងដោយសារ ក.ជ.ទី២ ឬដោយសារហេតុផ្សេងទៀតនោះឡើយ។ ប្រការនេះ ដោយសារតែ "ក្រុមអ្នកទទួលផល" នៃ ក.ជ.ទី២ គឺជាប្រជាពលរដ្ឋគ្រប់រូប ហើយការអង្កេតលើក្រុមអ្នកទទួលផលទាំងអស់នេះ គឺមិនអាចអនុវត្តបានឡើយ។

## ៨. ការរក្សាទុកដាក់ទិន្នន័យ និងសំណាក

ការអង្កេតនេះ គឺជាការអង្កេតដើមគ្រា ហើយការអង្កេតបន្ទាប់ត្រូវធ្វើពី ៣ទៅ៤ឆ្នាំទៀត។ ដូច្នេះ ការថែរក្សាទុកដាក់ឯកសារទាំងអស់នៃការអង្កេតនេះ ដើម្បីជួយសម្រួលដល់ភាពត្រឹមត្រូវក្នុងការកំណត់វិធីសាស្ត្រសម្រាប់ធ្វើអង្កេតបន្ទាប់ គឺជាកិច្ចការដ៏មានសារៈសំខាន់ ទោះបីក្រុមអ្នកធ្វើអង្កេតនាពេលបន្តបន្ទាប់មិនបានចូលរួមក្នុងដំណើរការធ្វើអង្កេតដើមគ្រានេះក៏ដោយ។

ក្នុងន័យនេះ សំណុំឯកសារដែលត្រូវរៀបចំសម្រាប់ការអង្កេតបន្ទាប់រួមមានៈ

- របាយការណ៍ ការពន្យល់លម្អិតអំពីវិធីសាស្ត្រនៃការអង្កេត សំណាក និងការវិភាគ
- បញ្ជីសំណួរស្ទង់មតិ (ជាភាសាអង់គ្លេស និងភាសាខ្មែរ);
- ឯកសារទិន្នន័យស្ថិតិសរុបជាឯកសារ SPSS ដែលរួមមានសំណុំរូបមន្តដែលបានប្រើ ដើម្បីគណនាពិន្ទុ

- ទិន្នន័យក្នុង MS Excel ប្រើសម្រាប់ការវិភាគទិន្នន័យបន្ថែម ដែលបានយកចេញពី SPSS ជាពិសេសសម្រាប់ការគណនាតម្លៃសន្ទស្សន៍រង និងសន្ទស្សន៍
- តារាងគណនាតម្លៃ និងកំហុសស្តង់ដាតាមសំណួរគ្រប់ផ្នែក និងតាមសូចនាករ។

ទិន្នន័យទាំងនេះ គួរតែត្រូវបានរក្សាទុកដោយលេខាធិការដ្ឋាន គ.ជ.អ.ប. នៅលើម៉ាស៊ីនផ្ទុកឯកសារ ដែលមានសុវត្ថិភាពជាមួយនឹងកំណត់ត្រាច្បាស់លាស់ ដើម្បីជួយសម្រួលដល់ការយកមកប្រើប្រាស់នាពេលអនាគត។

## ៩. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

### ៩.១. ការរៀបចំបង្កើត និងការគណនាតម្លៃសន្ទស្សន៍ដោយជោគជ័យ

ការអង្កេតអភិបាលកិច្ចដើមគ្រានេះ បានបង្កើតដោយជោគជ័យនូវតម្លៃសន្ទស្សន៍ផ្នែកអភិបាលកិច្ច និងការផ្តល់សេវា ដោយមានសន្ទស្សន៍រងដែលពាក់ព័ន្ធនឹងការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការឆ្លើយតប តម្លាភាព គណនេយ្យភាព និងការចូលរួមរបស់ពលរដ្ឋ និងសន្ទស្សន៍បន្ថែមនៃអភិបាលកិច្ចផ្ទៃក្នុង និងសមាគមក្រុមប្រឹក្សាមូលដ្ឋាន ដោយសង្ខេបនូវព័ត៌មានពាក់ព័ន្ធទិដ្ឋភាពសំខាន់ៗនៃអភិបាលកិច្ច។

សន្ទស្សន៍ផ្នែកអភិបាលកិច្ច និងការផ្តល់សេវា និងសន្ទស្សន៍រងគឺពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការវាយតម្លៃអំពីការសម្រេចនូវគោលដៅ និងគោលបំណងនៃការអនុវត្ត ក.ជ.ទី២។

តម្លៃសន្ទស្សន៍ និងសន្ទស្សន៍រងគឺមានភាពស៊ីសង្វាក់គ្នាយ៉ាងខ្លាំងនៅតាមតំបន់ភូមិសាស្ត្រដែលមានលក្ខណៈស្រដៀងគ្នា និងមានការប្រែប្រួលតិចតួចប៉ុណ្ណោះរវាងតំបន់ទីប្រជុំជន តំបន់ជនបទ តំបន់ភូមិសាស្ត្រផ្សេងៗ ឬតាមភេទរបស់អ្នកឆ្លើយតប។ ការប៉ាន់ស្មានកំហុសស្តង់ដាសម្រាប់សន្ទស្សន៍ និងតម្លៃសន្ទស្សន៍រងនៅកម្រិតជាតិគឺតូចណាស់។ ការអង្កេតនេះ ផ្តល់នូវទំនុកចិត្តខ្ពស់ចំពោះការផ្លាស់ប្តូរពិតប្រាកដណាមួយនៃគុណភាពអភិបាលកិច្ច ដោយការអង្កេតបន្ទាប់ដែលប្រើវិធីសាស្ត្រដូចការអង្កេតដើមគ្រា។

លទ្ធផលនៃការអង្កេតបានបង្ហាញជាតម្លៃសន្ទស្សន៍នៅចន្លោះតម្លៃពីសូន្យ (អាក្រក់បំផុត) ទៅមួយ (ល្អបំផុត)។ ការវាយតម្លៃលើភាពជោគជ័យ គឺមិនមែនជាតម្លៃនៃសន្ទស្សន៍ទាំងនេះទេ គឺការប្រែប្រួលនៃតម្លៃសន្ទស្សន៍ដែលនឹងត្រូវវាស់វែងនៅក្នុងពេលធ្វើអង្កេតបន្ទាប់។ ទោះយ៉ាងណាក៏ដោយ លទ្ធផលនៃការអង្កេតដើមគ្រានេះអាចបកស្រាយ ដើម្បីធ្វើការសន្និដ្ឋានបណ្តោះអាសន្នដូចខាងក្រោម៖

### ៩.២. គុណភាពនៃអភិបាលកិច្ច និងផ្តោតលើផ្នែកដែលត្រូវការកែលម្អ

#### ៩.២.១. សន្ទស្សន៍ជាយុទ្ធសាស្ត្រ

**សន្ទស្សន៍អភិបាលកិច្ច** = 0,៦៤ និង**សន្ទស្សន៍ការផ្តល់សេវា** = 0,៦៩ ស្ថិតនៅក្នុងចំណាត់ថ្នាក់ "**បង្គួរ**" ផ្អែកលើប្រព័ន្ធគណនាតម្លៃដែលបានប្រើប្រាស់ក្នុងការអង្កេតនេះ។

ការអង្កេតនេះ គឺជាការអង្កេតដើមគ្រា មិនមានមូលដ្ឋានសម្រាប់ការប្រៀបធៀបឡើយ ក៏ប៉ុន្តែអាចជាការវាយតម្លៃដ៏សមហេតុផលមួយ បើពិចារណាទៅលើកិច្ចខិតខំប្រឹងប្រែង និងសមិទ្ធផលនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនៅកម្ពុជា ដែលបានអនុវត្តរហូតមកដល់បច្ចុប្បន្ននេះ។

តម្លៃសន្ទស្សន៍រងដែលរួមបង្កើតបានតម្លៃសន្ទស្សន៍ជាយុទ្ធសាស្ត្រ គឺ **ការឆ្លើយតប** = ០,៧៤ "ល្អ" **ការបំពេញការងារ** =០,៦៧ "បង្គួរ" **តម្លាភាព** = ០,៦២ "បង្គួរ" **គណនេយ្យភាព** = ០,៥៤ និង**ការចូលរួមរបស់ប្រជាពលរដ្ឋ** = ០,៥៨ "មធ្យម"។

ជារួម ក.ជ.ទី២ មានបំណងពង្រឹង និងលើកកម្ពស់គ្រប់ផ្នែកទាំងអស់នៃអភិបាលកិច្ចល្អ។ ក្នុងន័យនេះ ផ្អែកតាមលទ្ធផលនៃការអង្កេតនេះ ផ្នែកគណនេយ្យភាព និងការចូលរួមរបស់ពលរដ្ឋត្រូវគណនាថា មានតម្លៃទាបជាងគេ គឺមានចំណាត់ថ្នាក់មធ្យម អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលគួរខិតខំប្រឹងប្រែងបន្ថែមទៀតក្នុងការជំរុញ និងលើកកម្ពស់ផ្នែកគណនេយ្យភាព និងការចូលរួមរបស់ប្រជាពលរដ្ឋ ដើម្បីធ្វើឱ្យមានភាពប្រសើរឡើងនូវតម្លៃសន្ទស្សន៍អភិបាលកិច្ចជារួម។

### ៩.២.២. ការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវា មានតម្លៃសន្ទស្សន៍=០,៦៧ ចំណាត់ថ្នាក់**"បង្គួរ"** ។

សូចនាករចំនួនពីរត្រូវបានវាយតម្លៃស្ថិតជិតដល់កម្រិត "ល្អ" គឺ៖

- បទពិសោធន៍របស់ប្រជាពលរដ្ឋក្នុងការទទួលសេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការវាយតម្លៃរបស់ក្រុមប្រឹក្សា និងមន្ត្រីដែលបង្ហាញថា រដ្ឋបាលថ្នាក់ក្រោមជាតិសមត្ថភាព និងធនធានសម្រាប់ការផ្តល់សេវាតាមគោលដៅកំណត់។

គុណភាពនៃសេវាសាធារណៈត្រូវបានវាយតម្លៃទាបជាងគុណភាពនៃសេវារដ្ឋបាល ទោះបីស្ថិតក្នុងកម្រិត "បង្គួរ" ក៏ដោយ។

សន្ទស្សន៍រងដែលគួរកែលម្អ រួមមានដូចខាងក្រោម៖

១. បន្តវិនិយោគលើសេវាសាធារណៈនៅតាមមូលដ្ឋាន ដោយផ្តោតការយកចិត្តទុកដាក់លើការកែលម្អបណ្តាញផ្លូវ ថ្នល់ដែលជាអាទិភាពខ្ពស់បំផុតរបស់ប្រជាពលរដ្ឋ និងការផ្តល់សេវាជួយប្រជាពលរដ្ឋដែលងាយរងគ្រោះ គឺជាអាទិភាពខ្ពស់បំផុតទីពីរ។ កម្រិតនៃការពេញចិត្តទាបបំផុត គឺចំពោះសេវាប្រមូលសំរាម សំណល់រឹងនៅតំបន់ជនបទ ដែលចំណុចនេះក៏ត្រូវការពង្រឹង និងជំរុញបន្ថែមផងដែរ។

២. ក្នុងចំណោមសេវារដ្ឋបាលដែលបានលើកឡើងនៅក្នុងការអង្កេតនេះ ប្រជាពលរដ្ឋបានចាត់ថ្នាក់គុណភាពផ្តល់សេវាស្ថិតជិតដល់កម្រិត "ល្អ" លើកលែងតែសេវាចុះបញ្ជីអាជីវកម្ម។ ដោយមើលឃើញពីសារៈសំខាន់នៃសហគ្រាសធុនតូចចំពោះជីវភាពរស់នៅរបស់ប្រជាជនដូច្នេះ ដំណើរការចុះបញ្ជីអាជីវកម្មខ្នាតតូចប្រកបដោយប្រសិទ្ធភាពតាមរយៈការិយាល័យច្រកចេញចូលតែមួយ គឺជាការងារដែលគួរផ្តល់អាទិភាពក្នុងការពង្រឹងបន្ថែម
៣. ក្រុមប្រឹក្សា និងមន្ត្រីរដ្ឋបាលឃុំ សង្កាត់បានវាយតម្លៃអំពីសមត្ថភាពរបស់ខ្លួនថា មានកម្រិតទាប។ ក្នុងន័យនេះ គួរបន្តផ្តោតលើការពង្រឹងសមត្ថភាពរបស់រដ្ឋបាលឃុំ សង្កាត់ ព្រមទាំងបែងចែកឱ្យបានច្បាស់លាស់នូវតួនាទីផ្តល់សេវារវាងរដ្ឋបាល ឃុំ សង្កាត់ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

### ៩.២.៣. ការឆ្លើយតប

ការឆ្លើយតបត្រូវបានវាយតម្លៃស្ថិតនៅកម្រិត "ល្អ" (០,៧៤) រួមទាំងសូចនាករភាគច្រើនគឺស្ថិតកម្រិតល្អ ឬល្អណាស់។ ចំណុចខ្លាំងសំខាន់ៗគឺ៖

- នៅពេលដែលប្រជាពលរដ្ឋ ក្រុមប្រឹក្សា និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានសួរអំពីអាទិភាពសម្រាប់ការកែលម្អសេវា ទាំងប្រជាពលរដ្ឋ និងក្រុមប្រឹក្សាបានផ្តល់ចម្លើយស្រដៀងគ្នាខ្លាំងណាស់
- ប្រជាពលរដ្ឋមានទំនុកចិត្តយ៉ាងខ្លាំងថា រដ្ឋបាលថ្នាក់ក្រោមជាតិយល់ពីតម្រូវការរបស់ខ្លួន ហើយព្យាយាមបំពេញតាមតម្រូវការទាំងនោះ។

ជារួម ពុំមានចំណុចខ្សោយណាមួយត្រូវបានរកឃើញនោះទេ ប៉ុន្តែនៅពេលដែលក្រុមប្រឹក្សា និងមន្ត្រីនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត ត្រូវបានសួរអំពីសារៈសំខាន់នៃការចូលរួមរបស់ប្រជាពលរដ្ឋ ដើម្បីកំណត់ពីតម្រូវការ និងអាទិភាពរបស់ប្រជាពលរដ្ឋក្នុងការធ្វើផែនការ ចម្លើយរបស់អ្នកទាំងនោះ គឺស្ថិតនៅក្នុងកម្រិត "បង្គួរ" ប៉ុណ្ណោះ។

ចំណុចដែលគួរការកែលម្អមួយចំនួនសម្រាប់ធ្វើឱ្យប្រសើរឡើងសន្ទស្សន៍រងនៃការឆ្លើយតបរួមមានដូចខាងក្រោម៖

១. ការជំរុញ លើកទឹកចិត្តឱ្យក្រុមប្រឹក្សា និងមន្ត្រីរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌស្វែងយល់អំពីទស្សនៈរបស់ប្រជាពលរដ្ឋលើការអភិវឌ្ឍន៍ និងផ្តល់អាទិភាពដល់តម្រូវការរបស់ប្រជាពលរដ្ឋក្នុងដំណើរការរៀបចំផែនការ។
២. ផ្តោតការយកចិត្តទុកដាក់លើការធានាថា សំឡេង និងតម្រូវការជាក់លាក់របស់ជនជាតិដើមភាគតិច ត្រូវបានស្តាប់ និងពិចារណាយ៉ាងយកចិត្តទុកដាក់ក្នុងដំណើរការកសាងផែនការ។

### ៩.២.៤. តម្លាភាព

តម្លៃសន្ទស្សន៍រងតម្លាភាព = ០.៦២ មានចំណាត់ថ្នាក់ "បង្គួរ"។ ក្នុងចំណោមសូចនាករតម្លាភាពទាំងប្រាំ សូចនាករមួយ "ខ្សោយ" សូចនាករមួយ "មធ្យម" សូចនាករមួយ "បង្គួរ" និងសូចនាករពីរ"ល្អ" ដែលបង្ហាញនូវស្ថានភាពចម្រុះជាក់លាក់ដែលគួរធ្វើឱ្យបានល្អប្រសើរឡើងនាពេលអនាគត។

**ចំណុចខ្លាំងរួមមាន៖**

- ប្រជាពលរដ្ឋជឿជាក់យ៉ាងខ្លាំងថា ប្រជាពលរដ្ឋមានសិទ្ធិដឹងពីការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ក្រុមប្រឹក្សា និងមន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិបង្ហាញអាកប្បកិរិយាវិជ្ជមានយ៉ាងខ្លាំងចំពោះតម្លាភាព។

**ចំណុចខ្សោយគួរឱ្យកត់សម្គាល់គឺ៖**

- ចំណេះដឹងរបស់ប្រជាពលរដ្ឋអំពីរចនាសម្ព័ន្ធ និងតួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានមានក្នុងកម្រិតខ្សោយ
- ប្រជាពលរដ្ឋយល់ថា តម្លាភាពនៃតម្លៃសេវារដ្ឋបាលរបស់ថ្នាក់ក្រោមជាតិ គឺនៅក្នុងកម្រិតខ្សោយទៅមធ្យម។

ចំណុចសំខាន់ដែលគួរកែលម្អផ្នែកតម្លាភាព រួមមានដូចខាងក្រោម៖

១. គួររៀបចំយុទ្ធនាការផ្សព្វផ្សាយព័ត៌មាន ដើម្បីលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីរចនាសម្ព័ន្ធ តួនាទី អាណត្តិការងារ និងការផ្តល់សេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ការលើកកម្ពស់ចំណេះដឹងរបស់ប្រជាពលរដ្ឋ មិនត្រឹមតែជាគោលបំណងមួយនោះទេ គឺអាចជួយឱ្យសម្រេចគោលបំណងផ្សេងទៀត ដូចជាការធ្វើឱ្យប្រសើរឡើងនៃគណនេយ្យភាពនៅពេលដែលរដ្ឋបាលថ្នាក់ក្រោមជាតិមិនបានផ្តល់សេវាប្រកបដោយគុណភាព និងប្រសិទ្ធភាព ការធ្វើឱ្យប្រសើរឡើងនូវការចូលរួមរបស់ប្រជាពលរដ្ឋ ហើយប្រជាពលរដ្ឋក៏អាចទទួលបានសេវាពីរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាពផងដែរ។

២. ទោះបីជាមានការខិតខំប្រឹងប្រែងក្នុងការផ្តល់សេវាក៏ដោយ ក៏ប្រជាពលរដ្ឋនៅតែមិនទាន់មានទំនុកចិត្តខ្លាំងលើការកំណត់តម្លៃសេវាប្រកបដោយតម្លាភាព។ ប្រការនេះ ចាំបាច់ខិតខំប្រឹងប្រែងផ្តល់ការអប់រំ ផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីសិទ្ធិដឹងពីតម្លៃជាក់លាក់សម្រាប់សេវាកម្មនីមួយៗ ការធ្វើឱ្យការទំនាក់ទំនងកាន់តែប្រសើរឡើង ការការរៀបចំដាក់បង្ហាញបញ្ជីតម្លៃច្បាស់ៗ លើផ្ទាំងធំៗនិងលេចធ្លោ ជាមួយនឹងការណែនាំថាតម្រូវឱ្យបង់ប្រាក់តាមតែតារាងតម្លៃប៉ុណ្ណោះ។

៣.ការជំរុញ និងបង្កើនការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយឌីជីថលសម្រាប់ការផ្សព្វផ្សាយព័ត៌មាន។

### ៩.២.៥. គណនេយ្យភាព

តម្លៃសន្ទស្សន៍រងនៃគណនេយ្យភាព =0,៥៤ ស្ថិតក្នុងចំណាត់ថ្នាក់ "មធ្យម ឬខ្សោយបន្តិច"។ ក្នុងចំណោមសូចនាករចំនួនប្រាំមួយ មានសូចនាករចំនួនបី "ខ្សោយ" ហើយសូចនាករចំនួនបីទៀតស្ថិតនៅក្នុងកម្រិត "មធ្យម"។ សន្ទស្សន៍រងគណនេយ្យភាពគឺទាបជាងគេបើធៀបទៅនឹងសន្ទស្សន៍រងផ្សេងទៀត។

ទោះបីយ៉ាងនេះក្តី សូចនាករមួយចំនួនត្រូវបានកត់សម្គាល់ឃើញថាជាចំណុចខ្លាំង នោះគឺក្រុមអ្នកឆ្លើយសំណួរទាំងអស់យល់ឃើញថា នៅពេលក្រុមប្រឹក្សា និងមន្ត្រីបំពេញការងារមិនល្អ ឬបំពានច្បាប់ ពួកគាត់នឹងត្រូវរងការដាក់វិន័យ និងវិធានការផ្លូវច្បាប់។

**ចំណុចខ្សោយនៃគណនេយ្យភាពគឺៈ**

- ការយល់ឃើញ និងបទពិសោធន៍របស់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងការដោះស្រាយបណ្តឹងតវ៉ានានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានកម្រិត "ខ្សោយ"។ ជាពិសេស មានប្រជាពលរដ្ឋចំនួនតិចតួចណាស់ដែលដឹងអំពីការងាររបស់ "ការិយាល័យប្រជាពលរដ្ឋ"។
- អ្នកឆ្លើយជាប្រជាពលរដ្ឋ និងជាមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិយល់ឃើញថា សំឡេងឆ្នោតរបស់ប្រជាពលរដ្ឋមានឥទ្ធិពលតិចតួចដល់ការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ចំពោះសន្ទស្សន៍រងគណនេយ្យភាព គឺចាំបាច់ត្រូវផ្តល់ការយកចិត្តទុកក្នុងការជំរុញ និងលើកកម្ពស់គ្រប់សូចនាករ។ ទោះជាយ៉ាងណាក៏ដោយ សូចនាករសំខាន់ចំនួនបី ដែលត្រូវផ្តោតការយកចិត្តឱ្យបានខ្លាំងបន្ថែមទៀតអាចជាៈ

១. កែលម្អយន្តការដោះស្រាយបណ្តឹងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការអនុវត្តជាក់ស្តែង ប្រជាពលរដ្ឋតិចតួចណាស់ដែលបានឮអំពីការិយាល័យប្រជាពលរដ្ឋ ហើយពាក្យបណ្តឹងភាគច្រើនត្រូវបានបញ្ជូនទៅមេភូមិ មេឃុំ ឬចៅសង្កាត់មុនគេ។ ថ្នាក់ដឹកនាំភូមិ និងមេឃុំ ចៅសង្កាត់គួរតែត្រូវបានបណ្តុះបណ្តាលអំពីការរៀបចំឯកសារបណ្តឹងតវ៉ា និងការឆ្លើយតបទៅនឹងពាក្យបណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋ រួមទាំងការយល់ដឹងពីប្រភេទបណ្តឹងតវ៉ាណាដែលត្រូវបញ្ជូនទៅការិយាល័យប្រជាពលរដ្ឋ។

២. លើកកម្ពស់ការយល់ដឹងអំពីតួនាទីរបស់ការិយាល័យប្រជាពលរដ្ឋ តាមរយៈការផ្សព្វផ្សាយព័ត៌មាន និងការផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញជាដើម។

៣. បង្កើនការជឿជាក់ និងប្រសិទ្ធភាពនៃគណនេយ្យភាពតាមបែបប្រជាធិបតេយ្យដោយជំរុញឱ្យប្រជាពលរដ្ឋ និងរដ្ឋបាលថ្នាក់ក្រោមជាតិមើលឃើញថា ការបោះឆ្នោតនៅថ្នាក់ក្រោមជាតិជាឱកាសសម្រាប់ប្រជាពលរដ្ឋក្នុងការផ្តល់រង្វាន់ ឬដាក់ទណ្ឌកម្មលើការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

### ៩.២.៦. ការចូលរួមរបស់ប្រជាពលរដ្ឋ

សន្ទស្សន៍រងការចូលរួមរបស់ប្រជាពលរដ្ឋ=0,៥៨ គឺស្ថិតក្នុងចំណាត់ថ្នាក់"មធ្យម" ឬ"ខ្សោយបន្តិច"។ ក្នុងចំណោមសូចនាករទាំងប្រាំបី សូចនាករចំនួនប្រាំត្រូវបានវាយតម្លៃនៅក្នុងកម្រិត "បង្គួរ" និងសូចនាករពីរនៅក្នុងកម្រិត "មធ្យម" ខណៈពេលដែលសូចនាករមួយក្នុងកម្រិត "ខ្សោយខ្លាំង"។ សូចនាករដែល "ខ្សោយខ្លាំងនេះ គឺជាសូចនាករដែលសួរពីការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងអង្គការសហគមន៍មូលដ្ឋាន។ សូចនាករមួយនេះ អាចផ្ទុយទៅនឹងសូចនាករផ្សេងទៀត ហើយមានឥទ្ធិពលជាអវិជ្ជមានលើពិន្ទុជារួម។

**ចំណុចខ្លាំងរួមមាន៖**

- ការចូលរួមរបស់ប្រជាពលរដ្ឋជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងបទពិសោធន៍នៃការចូលរួមនេះ គឺស្ថិតក្នុងកម្រិត "បង្គួរ" និងជិតទៅដល់កម្រិត "ល្អ"។
- ប្រជាពលរដ្ឋមានទំនុកចិត្តក្នុងកម្រិត "បង្គួរ" ថារដ្ឋបាលថ្នាក់ក្រោមជាតិបានសហការល្អជាមួយអង្គការសហគមន៍មូលដ្ឋាន ហើយថ្នាក់ដឹកនាំរដ្ឋបាលថ្នាក់ក្រោមជាតិបង្ហាញការគាំទ្រយ៉ាងខ្លាំងចំពោះសកម្មភាពអង្គការសហគមន៍មូលដ្ឋាន។

**ចំនុចខ្សោយបំផុតគឺ៖**

- ការចូលរួមរបស់ប្រជាពលរដ្ឋជាមួយអង្គការសហគមន៍មូលដ្ឋាន គឺទាបណាស់
- ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលសម្រាប់ផ្តល់ឱកាសដល់ការចូលរួមរបស់ប្រជាពលរដ្ឋនៅមានកម្រិតទាបបន្តិច
- ក្រុមប្រឹក្សា និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិមានការយល់ដឹងតិចតួចអំពីអត្ថប្រយោជន៍នៃការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការធ្វើផែនការ។

ចំណុចសំខាន់ដែលត្រូវកែលម្អសន្ទស្សន៍រងនៃការចូលរួមរបស់ប្រជាពលរដ្ឋ រួមមាន៖

១. លើកទឹកចិត្ត និងកសាងសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការប្រើប្រាស់វិធីសាស្ត្រ និងវិធានទំនើបជាងមុនក្នុងការជំរុញ និងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ជាពិសេសតាមរយៈការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយឌីជីថល។ ការអង្កេតបានរកឃើញថា កិច្ចប្រជុំបែបប្រពៃណី គឺនៅតែមានប្រសិទ្ធភាពល្អ ក៏ប៉ុន្តែវាមិនសូវសមស្របទៅនឹងការរស់នៅរបស់ប្រជាពលរដ្ឋក្នុងសម័យសេដ្ឋកិច្ចទំនើបទេ។

២. ក្រុមប្រឹក្សា និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិគួរយល់ថា ការស្វែងយល់ពីទស្សនៈ និងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ គឺជាគោលបំណងសំខាន់បំផុតនៃការចូលរួមរបស់ប្រជាពលរដ្ឋ។ ការផ្សព្វផ្សាយព័ត៌មាន និងការប្រមូលទិន្នន័យក៏ជាកិច្ចការដ៏មានសារៈសំខាន់ផងដែរ ហើយជាពិសេស "សំឡេង" របស់ប្រជាពលរដ្ឋ គឺសំខាន់បំផុត។

៣. តាមរយៈការពង្រឹងភាពជាដៃគូប្រកបដោយប្រសិទ្ធភាពជាមួយអង្គការសហគមន៍មូលដ្ឋាន

ជាពិសេសអង្គការដែលផ្តោតលើការអភិវឌ្ឍន៍មូលដ្ឋាន រដ្ឋបាលថ្នាក់ក្រោមជាតិអាចលើកទឹកចិត្តប្រជាពលរដ្ឋឱ្យមើលឃើញអត្ថប្រយោជន៍កាន់តែច្រើនពីការចូលរួមយ៉ាងសកម្មនៅក្នុងអង្គការសហគមន៍មូលដ្ឋានទាំងនេះ។

### ៩.២.៧. អភិបាលកិច្ចផ្ទៃក្នុង និងសមាគមក្រុមប្រឹក្សាមូលដ្ឋាន

សន្ទស្សន៍**ទំនាក់ទំនងផ្ទៃក្នុង**របស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានវាយតម្លៃថា មានកម្រិត "ល្អ" ជិតដល់កម្រិត "ល្អណាស់" ដោយផ្អែកលើសូចនាករចំនួនបួន។ សូចនាករចំនួនពីរត្រូវបានវាយតម្លៃក្នុងកម្រិត "ល្អណាស់" សូចនាករមួយ "ល្អ" និងសូចនាករមួយទៀត "មធ្យម"។

**ចំណុចខ្លាំងនៃទំនាក់ទំនងផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិគឺ៖**

- ការវាយតម្លៃលើប្រសិទ្ធភាពរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្តក្នុងការកំណត់ទិសដៅយុទ្ធសាស្ត្រ និងការត្រួតពិនិត្យលើប្រតិបត្តិការរបស់គណៈអភិបាល
- កិច្ចប្រជុំក្រុមប្រឹក្សា (ក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត) ជួយសម្រួលដល់សមាជិកក្រុមប្រឹក្សាទាំងអស់ក្នុងការបញ្ចេញទស្សនៈរបស់ខ្លួន និងឈានដល់ការសម្រេចចិត្តជាឯកច្ឆ័ន្ទ។

ចំណុចខ្សោយជាងគេ គឺពាក់ព័ន្ធនឹងការវាយតម្លៃរបស់សមាជិកក្រុមប្រឹក្សា និងមន្ត្រីទៅលើស្វ័យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការ ការគ្រប់គ្រងថវិកា និងការអនុវត្តការងារ។ សូចនាករនេះ មានភាពខុសគ្នារវាងឃុំ សង្កាត់ (មធ្យម=0,៥១) ក្រុង ស្រុក ខណ្ឌ (មធ្យម=0,៥៤) និងរាជធានី ខេត្ត (បង្គួរ=0,៦០)។

ក្នុងន័យនេះ រាជរដ្ឋាភិបាលគួរតែបន្តជំរុញ និងលើកកម្ពស់ស្វ័យភាពនៃរដ្ឋបាលមូលដ្ឋាន (ក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌ) ស្របតាមគោលបំណងនៃក.ជ.ទី២។

អ្នកឆ្លើយសំណួរបានផ្តល់ការវាយតម្លៃខ្ពស់អំពីសារៈសំខាន់ និងប្រសិទ្ធភាពនៃ**សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ** (សមាគមក្រុមប្រឹក្សាឃុំ សង្កាត់ ស្រុក ក្រុង ខណ្ឌ និងសមាគមក្រុមប្រឹក្សារាជធានី ខេត្ត) ដែលជាលទ្ធផលនៃតម្លៃសន្ទស្សន៍=0,៧៧ គឺ "ល្អ" ឬ "ល្អណាស់"។

## ៩.៣. អនុសាសន៍សម្រាប់ការអង្កេតនាពេលបន្ទាប់

### ៩.៣.១. ពេលវេលានៃការអង្កេតបន្ទាប់

វិធីសាស្ត្រ ឧបករណ៍អង្កេត ទិន្នន័យ ឧបករណ៍វិភាគ និងលទ្ធផលនៃការអង្កេតត្រូវបានចងក្រងជាឯកសារយ៉ាងម៉ត់ចត់ ដើម្បីសម្រួលដល់ការធ្វើអង្កេតនាបន្តបន្ទាប់ ហើយវិធីសាស្ត្រនៃការធ្វើអង្កេតពេលនេះគួរត្រូវបានប្រើប្រាស់សម្រាប់ការអង្កេតនាពេលបន្តបន្ទាប់ផងដែរ។

ឯកសារ ក.ជ.ទី២ បានកំណត់ឱ្យការអង្កេតអភិបាលកិច្ចត្រូវធ្វើឡើងចំនួនបីដងក្នុងអំឡុងពេលកជទី២។ បន្ទាប់ពីការអង្កេតដើមគ្រា ការអង្កេតបន្ទាប់ត្រូវធ្វើក្នុងឆ្នាំទី៥ និងការអង្កេតចុងគ្រាក្នុងឆ្នាំទី៩។

ដោយសារការអង្កេតដើមគ្រានេះបានធ្វើឡើងនៅចុងឆ្នាំទី៣នៃក.ជ.ទី២ គឺនៅឆ្នាំ២០២៤ អាស្រ័យហេតុនេះ ការអង្កេតបន្តបន្ទាប់ត្រូវពន្យារពេលទៅរហូតដល់ឆ្នាំ២០២៧ និងការអង្កេតចុងក្រោយត្រូវធ្វើឡើងនៅក្នុងឆ្នាំ២០៣០។ ដូច្នេះ យើងរំពឹងថានឹងមានរយៈពេលប្រហែល៣ឆ្នាំរវាងការអង្កេតនីមួយៗ ដែលគួរតែគ្រប់គ្រាន់សម្រាប់ការសិក្សាអំពីផលជះនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការពង្រឹងផ្នែកអភិបាលកិច្ច។

### ៩.៣.២. ការប្រើវិធីសាស្ត្រដដែលដោយប្រុងប្រយ័ត្ន

ការអង្កេតគឺដើម្បីវាស់វែងនូវការប្រែប្រួលនូវតម្លៃសន្ទស្សន៍អភិបាលកិច្ច និងសន្ទស្សន៍សេវា អាស្រ័យហេតុនេះ ការអង្កេតនាពេលបន្តបន្ទាប់ត្រូវតែប្រើវិធីសាស្ត្រដូចនឹងការធ្វើអង្កេតដើមគ្រានាពេលនេះ បើមិនដូច្នេះទេលទ្ធផលនៃការអង្កេតមិនអាចប្រៀបធៀបគ្នាបានទេ។

### ៩.៣.៣. គួរប្រើសំណួរ និងពាក្យពេជដូចគ្នា ឬត្រូវរក្សាការប្រៀបធៀបបាន ប្រសិនបើមានការផ្លាស់ប្តូរសំណួរ និងពាក្យពេចន៍

សំណួរដែលប្រើក្នុងការអង្កេតដើមគ្រា គួរតែប្រើតាមរបៀបដូចគ្នានៅពេលធ្វើអង្កេតបន្ទាប់។ ទោះបីមានកំហុសវាយអក្សរ ឬកំហុសការបកប្រែខ្លះនៅក្នុងសំណួរក៏ដោយ ការផ្លាស់ប្តូរសំណួរណាមួយគួរតែត្រូវបានពិនិត្យដោយប្រុងប្រយ័ត្ន។

សំណួរមួយចំនួនអាចដកចេញ ប៉ុន្តែលទ្ធផលនៃការអង្កេតដើមគ្រាគួរតែត្រូវគណនាឡើងវិញដោយគ្មានសំណួរទាំងនោះ។

សំណួរជាច្រើនទៀតអាចត្រូវបន្ថែម ប៉ុន្តែមិនគួរត្រូវបានបញ្ចូលនៅក្នុងការវាយតម្លៃសូចនាករសម្រាប់គោលបំណងនៃការប្រៀបធៀបជាមួយនឹងលទ្ធផលអង្កេតដើមគ្រានោះទេ។

### ៩.៣.៤. គួរប្រើវិធីសាស្ត្រវិភាគដដែល ឬការគណនាឡើងវិញនៃការអង្កេតដើមគ្រាបើសិនមានការផ្លាស់ប្តូរណាមួយ

ត្រូវប្រើវិធីសាស្ត្រវិភាគដើមគ្រាទាំងស្រុង ក្នុងការគណនាលទ្ធផលនៃការអង្កេតបន្ទាប់។ នេះរួមបញ្ចូលទាំងប្រព័ន្ធដាក់ពិន្ទុដូចគ្នាលើសំណួរ និងសូចនាករនានា។ ម៉្យាងទៀត ការផ្លាស់ប្តូរវិធីសាស្ត្រវិភាគណាមួយ គួរតែត្រូវបានធ្វើឡើងវិញចំពោះការវិភាគទិន្នន័យនៃការអង្កេតដើមគ្រាដែរ។

### ៩.៣.៥. គួរប្រើវិធីសាស្ត្រជ្រើសរើសសំណាកដូចគ្នា ក្នុងការជ្រើសរើសសំណាកថ្មី

គួរប្រើវិធីសាស្ត្រជ្រើសរើសសំណាកដូចនឹងការអង្កេតដើមគ្រាដែរ។ ការធ្វើបែបនេះ នឹងនាំឱ្យការជ្រើសរើសបានដោយចៃដន្យនូវរដ្ឋបាលថ្នាក់ក្រោមជាតិ ភូមិ និងប្រជាពលរដ្ឋ ដែលមានលក្ខណៈអាចប្រៀបធៀបទៅនឹងការអង្កេតដើមគ្រា។ ភាពស៊ីសង្វាក់គ្នាល្អនៃលទ្ធផល និងកំហុសស្តង់ដាតូច នឹងធ្វើឱ្យមានចន្លោះទំនុកចិត្តខ្ពស់ទៅលើលទ្ធផលដែលទទួលបាន ដែលបង្កើតបានជាមូលដ្ឋានដ៏ល្អសម្រាប់ការប្រៀបធៀប។ បើអាចធ្វើទៅបាន គួរប្រើវិធីសាស្ត្រ "សំណាកដដែល" សម្ភាសន៍អ្នកឆ្លើយសំណួរដដែលនៅពេលធ្វើអង្កេតដើមគ្រា ប៉ុន្តែវិធីសាស្ត្រនេះទំនងជាមានការលំបាកក្នុងការតាមរកអ្នកឆ្លើយ

សំណួរដដែល ហើយអ្នកឆ្លើយសំណួរជាមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិអាចផ្លាស់ប្តូរទៅតំណែងផ្សេងៗ នាពេលនោះ។

### ៩.៣.៦. គួរពិចារណាកាត់បន្ថយចំនួនអ្នកឆ្លើយតបជាក្រុមប្រឹក្សាឬមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ

គួរពិចារណាលើការបង្រួមចំនួនសំណាកជាក្រុមប្រឹក្សា ឬមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិបន្តិច។ ជាក់ស្តែង យើងបានសម្ភាសន៍ក្រុមប្រឹក្សា និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិចំនួនប្រាំពីរប្រភេទផ្សេងគ្នា ដូចជា ថ្នាក់ដឹកនាំភូមិ ក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈអភិបាល ក្រុមប្រឹក្សា និងមន្ត្រីក្រុង ស្រុក ខណ្ឌ ព្រមទាំងគណៈអភិបាល និងក្រុមប្រឹក្សារាជធានី ខេត្ត។ ជាពិសេស តម្លៃនៃការសម្ភាសន៍មន្ត្រីរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលបានជ្រើសរើសដោយចៃដន្យ (ភារកិច្ចរបស់មន្ត្រីទាំងនោះពាក់ព័ន្ធតិចតួចទៅនឹងប្រធានបទនៃការអង្កេត) គឺមិនសូវច្បាស់លាស់ទេ។ ជាជម្រើស គឺអាចបន្ថយចំនួនមន្ត្រី ហើយការអង្កេតគួរផ្តោតលើការសម្ភាសន៍ជាមួយប្រជាពលរដ្ឋ និងអ្នកតំណាងដែលជាប់ឆ្នោតរបស់ប្រជាពលរដ្ឋ (ឧទាហរណ៍ក្រុមប្រឹក្សានៅកម្រិតនីមួយៗ) ប៉ុណ្ណោះ។ ការកាត់បន្ថយចំនួនប្រភេទអ្នកឆ្លើយតបនឹងមានអត្ថប្រយោជន៍បន្ថែមក្នុងការបង្កើនចំនួនសំណាកប្រភេទដែលនៅសល់។

ទោះយ៉ាងណាក៏ដោយ ប្រសិនបើការផ្លាស់ប្តូរណាមួយត្រូវបានធ្វើឡើងក្នុងការជ្រើសរើសក្រុមសំណាក នោះចាំបាច់ត្រូវពិចារណាអំពីផលប៉ះពាល់លើលទ្ធផលនៃការអង្កេត។ ប្រការនេះ ត្រូវគណនាឡើងវិញនូវទិន្នន័យអង្កេតដើមគ្រា នៅពេលដកប្រភេទអ្នកឆ្លើយតបណាមួយចេញ (ឧទាហរណ៍ដកការសម្ភាសន៍ជាមួយមន្ត្រីរដ្ឋបាលក្រុង ស្រុក ខណ្ឌ)។

**លេខាធិការដ្ឋាន គ.ជ.អ.ប.** ស្ថិតក្នុងបរិវេណក្រសួងមហាផ្ទៃ

អាគារ (V) មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

អ៊ីម៉ែល: info@ncdd.gov.kh

គេហទំព័រ: www.ncdd.gov.kh

ទំព័រហ្វេសប៊ុក: www.facebook.com/ncdds

**គាំទ្រដោយៈ**

From the People of Japan